*អ្វីៗដែលនៅលើលោកនេះ សុទ្ធតែសម្រាប់បម្រើបងប្អូនទាំងអស់*
*រីឯបងប្អូនវិញ បងប្អូនបម្រើព្រះគ្រីស្ត ហើយព្រះគ្រីស្តបម្រើព្រះជាម្ចាស់ -១ករ ៣,២២-២៣-*

# អារម្ភកថា

***

សៀវភៅនេះ គឺជាឧបករណ៍មួយ ដើម្បីរៀនអធិដ្ឋាន និងរីកចម្រើនក្នុងការអធិដ្ឋាន។

**សៀវភៅនេះ ជាសៀវភៅស្រួលអាន**

យើងអាចប្រើសៀវភៅនេះជាក្រុមៗ គឺសៀវភៅនេះអាចជួយយើងដើម្បីចែករំលែកអំពីជីវិតរបស់យើង។ យើងអាចប្រើសៀវភៅនេះតែម្នាក់ឯង គឺដើម្បីជួយយើងឲ្យរីកចម្រើនជាប្រចាំថ្ងៃ ឬដើម្បីធ្វើសំណាក់ធម៌ខាងវិញ្ញាណម៉្យាងនៅផ្ទះ ឬដើម្បីកុំឲ្យខាតពេលវេលា - នៅពេលត្រូវរង់ចាំ ឬនៅពេលសម្រាក។

**សៀវភៅនេះ ជាសៀវភៅស្រួលអាន**

ក្នុងពិភពលោកយើង មានមនុស្សជាច្រើនធ្លាប់និយាយថា៖ ពិតជាពិបាកស្រឡាញ់! ប៉ុន្តែសៀវភៅនេះដូចជាសាលារៀនពិតប្រាកដ ដើម្បីបង្រៀនយើងឲ្យចេះស្រឡាញ់ជាដំបូង ដើម្បីជឿថាព្រះជាម្ចាស់ស្រឡាញ់យើងម្នាក់ៗ ហើយជឿថានៅពេលយើងបានជ្រមុជទឹក ព្រះអង្គមានព្រះបន្ទូលសន្យាថា មិនដែលបោះបង់យើងចោលឡើយ។ ដូច្នេះហើយ បានជាអ្នកណាដឹងថា ព្រះជាម្ចាស់ស្រឡាញ់គាត់ អ្នកនោះលែងខ្វះសេចក្តីស្រឡាញ់ លែងភ័យខ្លាច លែងតែលតោល ហើយក្លាយទៅជាមនុស្សម្នាក់ដែលជាប់ចិត្តនឹងព្រះជាម្ចាស់ ហើយដែលជាមិត្តភក្តិរបស់មនុស្ស។

**សៀវភៅនេះ ជាសៀវភៅស្រួលអាន**

ប៉ុន្តែសៀវភៅនេះ មិនមែនជាសៀវភៅមន្តអាគមទេ គឺបើយើងមិនចំណាយពេលវេលាអានសៀវភៅនេះបន្តិចបន្តួច សៀវភៅនេះគ្មានប្រយោជន៍សោះ។ ត្រូវតែអានសៀវភៅនេះបន្តិចម្តងៗ ក្នុងពេលស្ងៀមស្ងាត់ គឺក្នុងភាពស្ងៀមស្ងាត់នៃដួងចិត្តយើងនោះយើង ឆ្លើយតបនឹងព្រះជាម្ចាស់។

**សៀវភៅនេះ ជាសៀវភៅស្រួលអាន**

សៀវភៅនេះ ចេញមកពីការអធិដ្ឋានរបស់សន្តបុគ្គលជនជាតិបារាំងម្នាក់ គឺលោកយ៉ូហាន អើដ ដែលជាបូជាចារ្យដ៏ល្បីពូកែណែនាំខាងវិញ្ញាណ។ តាំងពីបីសតវត្សមកហើយ បុរសនិងស្ត្រីជាច្រើនបានដើរតាមលោក ហើយបានសម្រេច សម្រាប់សម័យរបស់គេ ទាំងរួមរស់ជាមួយព្រះគ្រីស្ត ដោយមានចិត្តភក្តី។ ក្នុងសៀវភៅនេះពួកគេប្រគល់បទពិសោធន៍ដ៏ល្អៗរបស់គេ។

**លោកអភិបាល ដូបូស្ត**

# មាតិកាអត្ថបទ

* * * *


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | សេចក្ដីផ្ដើមទូទៅ............ | ៣ |
| ២ | - ដំណាក់កាលទី១ ៖ ធ្វើជាសាវ័ក............ | ៩ |
| ៣ | - ដំណាក់កាលទី២ ៖ អានប្រវត្តិរបស់ខ្លួនឡើងវិញ............ | ១៤ |
| ៤ | - ដំណាក់កាលទី៣ ៖ ជួបព្រះយេស៊ូ............ | ១៩ |
| ៥ | - ដំណាក់កាលទី៤ ៖ ស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់............ | ២៣ |
| ៦ | - ដំណាក់កាលទី៥ ៖ សម្លឹងមើលព្រះនាងម៉ារី............ | ២៨ |
| ៧ | - ដំណាក់កាលទី៦ ៖ យល់ថា ព្រះជាម្ចាស់ប្រសូតជាមនុស្សដូចយើងបេះបិទ............ | ៣៤ |
| ៨ | - ដំណាក់កាលទី៧ ៖ ដឹងខ្លួនថា បានទទួលការសង្គ្រោះ............ | ៤០ |
| ៩ | - ដំណាក់កាលទី៨ ៖ ទទួលស្គាល់ថា ខ្លួនមកពីព្រះជាម្ចាស់............ | ៤៤ |
| ១០ | - ដំណាក់កាលទី៩ ៖ បណ្ដោយខ្លួនទៅតាមសេចក្ដីស្រឡាញ់............ | ៤៨ |
| ១១ | - ដំណាក់កាលទី១០៖ រៀនអធិដ្ឋាន............ | ៥៦ |
| ១២ | - ដំណាក់កាលទី១១៖ រៀនស្រឡាញ់............ | ៦០ |
| ១៣ | - ដំណាក់កាលទី១២ ៖ រួបរួមជាមួយព្រះត្រៃឯក............ | ៦៥ |
| ១៤ | - ដំណាក់កាលទី១៣៖ ប្រកាសជំនឿរបស់ខ្លួន............ | ៧២ |
| ១៥ | - ដំណាក់កាលទី១៤ ៖ ទៅជាគ្រីស្ដទូត............ | ៧៦ |
| ១៦ | - ដំណាក់កាលទី១៥ ៖ រកមុខងាររបស់ខ្លួននៅក្នុងព្រះសហគមន៍............ | ៨២ |
| ១៧ | - ដំណាក់កាលទី១៦ ៖ អធិដ្ឋានរួមជាមួយព្រះសហគមន៍............ | ៨៨ |
| ១៨ | - ដំណាក់កាលទី១៧ ៖ អនុវត្តពិធីជ្រមុជទឹក............ | ៩៤ |
| ១៩ | - ដំណាក់កាលទី១៨៖ ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលខ្លួនឯង............ | ១០១ |
| ២០ | - ដំណាក់កាលទី១៩៖ សុភមង្គលដ៏ពិតប្រាកដ............ | ១០៦ |
| ២១ | - ដំណាក់កាលទី២០៖ សម្ដែងធម៌មេត្តាករុណា............ | ១១១ |
| ២២ | - ដំណាក់កាលទី២១៖ តើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើអ្វីខ្លះ?............ | ១១៥ |
| ២៣ | - ដំណាក់កាលទី២២៖ ប្រុងប្រៀបខ្លួនឆ្លើយតបអំពីសេចក្ដីសង្ឃឹម............ | ១២៥ |

សូមឲ្យព្រះហឫទ័យព្រះជាម្ចាស់បានសម្រេចក្នុងគ្រប់កិច្ចការទាំងអស់

## សេចក្តីផ្តើមទូទៅ

### ១- សន្ត: យ៉ូហាន អើដ ជាគ្រូខាងវិញ្ញាណ

នៅសតវត្សទី ១៨ បុរសម្នាក់ គឺលោកយ៉ូហាន អើដ បាននាំគ្រីស្តបរិស័ទឲ្យដឹងប្រកពដែលផ្តល់ជីវិតឲ្យលោក។ បួនសតវត្សក្រោយមកគំនិតខាងវិញ្ញាណរបស់លោក អាចជួយផ្តល់កម្លាំងដល់អស់អ្នកដែលហ៊ានស្វែងរកអំពីលទ្ធិរបស់លោក ដូចជាក្រុមគ្រួសារបព្វជិតបព្វជិតា និងគ្រីស្តបរិស័ទជាច្រើន ដែលបានរកឃើញទ្រព្យសម្បត្តិនៃកេរមរតករបស់លោក។

### សាលារៀនខាងវិញ្ញាណ

ទោះបីជាមានដំណឹងល្អតែមួយយ៉ាងណាក៏ដោយ ក៏មានរបៀបជាច្រើនឲ្យស្តាប់ ជាពិសេសប្រព្រឹត្តតាមដំណឹងល្អនេះ តាមចរិតរបស់មនុស្សម្នាក់ៗ និងទំនាក់ទំនងដំបូងរបស់គេជាមួយព្រះជាម្ចាស់។ យើងមានដំណឹងល្អតែមួយ ប៉ុន្តែយើងប្រព្រឹត្តតាមដំណឹងល្អនេះ តាមរបៀបផ្សេងៗ គឺតាមផ្លូវណាដែលយើងប្រើ ដូចជាផ្លូវរបស់សន្ត:**បេណេឌិកតូ**សន្ត:**ហ្វ្រង់ស្វ័រ**សន្ត:**ដូមីនីកូ**សន្ត:**អ៊ីញាស**ឬសន្ត:**យ៉ូហានអើដ**។សាលារៀនខាងវិញ្ញាណជាសារព័ន្ធនៃលទ្ធិគំនិតទំនៀមទម្លាប់ និងឥរិយាបថ ដែលអ្នកបង្កើតម្នាក់បានទុកជាមរតក ហើយដែលបានក្លាយទៅជាលទ្ធិគំនិត ទំនៀមទម្លាប់ និងឥរិយាបថរបស់អស់អ្នកដែលបានរួមចិត្តគំនិតជាមួយគាត់។

សរុបសេចក្តី ផ្លូវខាងវិញ្ញាណផ្សេងៗពុំមានលក្ខណៈពិសេស ប្លែកពីរបៀបរស់នៅជាគ្រីស្តបរិស័ទឡើយ គឺព្រះយេស៊ូជាស្នូលនៃផ្លូវទាំងអស់នោះ។ មានតែរបៀបចូលក្នុងអាថ៌កំបាំងនៃគ្រីស្តសាសនាប្លែកៗតាមផ្លូវនីមួយៗ ជាពិសេសក្នុងសាលារៀនបារាំងខាងវិញ្ញាណ។

### សាលារៀនខាងវិញ្ញាណ

សម្រាប់សាលារៀនខាងវិញ្ញាណដែលមានលោក សិលា នៃបេរូល ជាអ្នកបង្កើតគ្រីស្តសាសនាមិនមែនជាប្រព័ន្ធ ឬគោលលទ្ធិនៃទស្សនវិទ្យាទេ គ្រីស្តសាសនាជាមនុស្សម្នាក់ គឺព្រះយេស៊ូគ្រីស្ត។ ដូច្នេះ យើងធ្លាប់និយាយថា ព្រះគ្រីស្ត ជាស្នូលនៃសាលារៀនខាងវិញ្ញាណ។

ប្រពៃណីដ៏រស់រវើក ដែលជាជ័រនៃក្រុមគ្រួសារបព្វជិតបព្វជិតា ឬក្រុមបូជាចារ្យ ដែលមកពីសាលារៀនបារាំងជាកម្មសិទ្ធិរបស់ព្រះសហគមន៍ទាំងមូលដែរ ដែលប្រពៃណីនេះនៅតែប្រោសឲ្យមានជីវិត។

ការកើតជាថ្មីឡើងវិញនៃគ្រីស្តសាសនាសព្វថ្ងៃរំឭកយើងថា សាលារៀនបារាំងខាងវិញ្ញាណអាចបំពេញសេចក្តីរង់ចាំ និងតម្រូវការរបស់មនុស្សយើង គឺ៖

- ការក្រាបថ្វាយបង្គំ
- ទំនាក់ទំនងជាមួយព្រះយេស៊ូ
- ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជំរុញឲ្យប្រកាសដំណឹងល្អមហាសន្និបាតវ៉ាទីកង់ទីពីរ បានលើកស្ទួយឧត្តមគតិសំខាន់ៗនៃសាលារៀនខាងវិញ្ញាណ ដូចជា៖

❍ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ គ្រីស្តបរិស័ទធម្មតា បព្វជិតបព្វជិតា បូជាចារ្យ និងឧបដ្ឋាកឲ្យទៅជាសន្តបុគ្គល ដោយរួមជាមួយព្រះយេស៊ូនៅក្នុងព្រះសហគមន៍ នឹងដោយប្រកាសដំណឹងល្អ។ ខ្ញុំបាត់អ្នករាល់គ្នាដើម្បីបន្តជីវិត និងកិច្ចការរបស់ខ្ញុំនៅលើផែនដី។

❍ ការយល់ឃើញថា ព្រះសហគមន៍ជាអាថ៌កំបាំង គឺជាព្រះកាយព្រះគ្រីស្ត ព្រះដំណាក់នៃព្រះវិញ្ញាណ និងប្រជាជនរបស់ព្រះជាម្ចាស់។

## អ្វីទៅជាព្រះសហគមន៍ ?

- ❍ គឺជាសហគមន៍របស់គ្រីស្តបរិស័ទ ដែលមានជំនឿតែមួយ និងទទួលអគ្គសញ្ញា ដោយមានព្រះយេស៊ូគ្រីស្តជួយណែនាំជីវិតខាងវិញ្ញាណដែលចាក់ឫសលើគ្រឹះនៃជំនឿ ដែលមានសន្តៈយ៉ូហាន និងសន្តៈប៉ូលបង្ហាញឲ្យយើងស្គាល់។ ត្រូវមានបំណងប្រាថ្នា និងត្រូវរើរវល់នឹងការបង្កើតព្រះយេស៊ូក្នុងខ្លួនយើង។
- ❍ ជីវិតខាងពិធីបុណ្យនៅក្នុងខ្លួនះយើងត្រូវបន្ត និងបំពេញនៅក្នុងខ្លួននៃព្រឹត្តិការណ៍ទាំងប៉ុន្មានរបស់ព្រះយេស៊ូ និងទូលអង្វរព្រះអង្គ ឲ្យទ្រង់បំពេញព្រឹត្តិការណ៍ទាំងអស់នោះនៅក្នុងខ្លួន និងនៅក្នុងព្រះសហគមន៍ផង។

លក្ខណៈផ្សេងមួយទៀតរបស់លោកបេរូល និងសាលារៀនបារាំងទាំងមូល ដែលមនុស្សយើងសព្វថ្ងៃចាប់អារម្មណ៍ គឺទុក្ខកង្វល់ឲ្យបង្រួបបង្រួមគ្រីស្តបរិស័ទទាំងខាងក្រៅផង ទាំងខាងក្នុងផង។

## សន្តៈយ៉ូហានអើដ

លោក កាឌីណាល បេរូល បានទទួលសាវ័ក និងអ្នកបន្តមុខងាររបស់លោក។ មានអ្នកខ្លះទៀត ទោះជាមិនមែនជាសាវ័កក៏ដោយ ក៏បានទទួលឥទ្ធិពលពីលោកដែរ។ ម្នាក់ៗបានណែនាំជីវិតខាងវិញ្ញាណរបស់ខ្លួនតាមរបៀបរៀងៗខ្លួន។ នៅក្នុងចំណោមសាវ័កទាំងប៉ុន្មានរបស់លោក មានសន្តៈយ៉ូហាន អើដ -១៦០១-១៦៨០-

សន្តៈយ៉ូហានកើតនៅស្រុក ណូរមង់ឌី នៅភូមិភាគសេស្ស៍នៅឆ្នាំ១៦០១។ លោកជាសាវ័កម្នាក់ក្នុងចំណោមសាវ័កដើមដំបូងរបស់លោកបេរូល។

លោកមានលក្ខណៈពិសេសប្លែកពីម្ចាស់របស់ខ្លួន គឺលោកមានចិត្តចង់ប្រកាសដំណឹងល្អលើសអ្វីៗទាំងអស់។ លោកស្វែងរកមធ្យោបាយ ដើម្បីជួយគ្រីស្តបរិស័ទម្នាក់ៗឲ្យរកឃើញទ្រព្យសម្បត្តិនៃពិធីជ្រមុជទឹក គឺឲ្យព្រះយេស៊ូកើតមក និងសោយរាជ្យនៅក្នុងខ្លួនប្រោសយើងឲ្យបានវិសុទ្ធ ហើយឲ្យយើងរួមរស់ជាមួយព្រះអង្គ។ នេះជាឧត្តមគតិ ដែលលោកស្នើសុំសម្រាប់គ្រីស្តបរិស័ទម្នាក់ៗ។

តាមគំនិតរបស់លោក យើងកែប្រែចិត្តគំនិត មិនមែនមកពីយើងខិតខំប្រព្រឹត្តអំពើល្អតែប៉ុណ្ណោះទេ គឺមកពីយើងសម្លឹងមើលព្រះយេស៊ូដោយចិត្តស្រឡាញ់៖

❍ យើងសម្លឹងមើលព្រះអង្គយ៉ាងយូរ ដោយកោតសរសើរព្រះអង្គ!

❍ យើងសូមអង្វរព្រះអង្គ ឲ្យលើកលែងទោសឲ្យយើង ចំពោះអ្វីដែលយើងបានប្រព្រឹត្តខុសនឹងព្រះហឫទ័យព្រះអង្គ!

១ យើងថ្វាយខ្លួនចំពោះព្រះវិញ្ញាណព្រះអង្គ សូមឲ្យព្រះអង្គបំផ្លាញអ្វីដែលនៅក្នុងខ្លួនយើងដែលប្រឆាំងនឹងជីវិតរបស់ព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គប្រោសយើងឲ្យមានជីវិតរួមជាមួយព្រះអង្គ។

ដូច្នេះហើយ បានជាការខិតខំទាំងប៉ុន្មានរបស់យើងមិននាំឲ្យមានអារម្មណ៍តានតឹងទេ ប៉ុន្តែនាំឲ្យយើងជឿទុកចិត្តលើព្រះជាម្ចាស់ ព្រមទាំងអធិដ្ឋាន និងអរព្រះគុណព្រះអង្គផង។ អស់មួយជីវិត ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យបន្ត និងបំពេញបេសកកម្មរបស់ព្រះយេស៊ូ។ យើងក៏ទៅជាមនុស្សម្នាក់ដែលទៅប្រកាសដំណឹងល្អ យើងមានកង្វល់តែមួយ គឺធ្វើឲ្យព្រះយេស៊ូមានព្រះជន្ម និងសោយរាជ្យនៅក្នុងចិត្តមនុស្សទាំងអស់ ដើម្បីឲ្យពួកគេអាចទទួលទ្រព្យសម្បត្តិរបស់ព្រះបេះដូងព្រះគ្រីស្ត ដែលជាប្រភពនៃជីវិត។

## ផ្លូវខាងវិញ្ញាណដ៏រស់រវើក

សន្តៈយ៉ូហាន អើដ បានបើកផ្លូវ ហើយយើងក៏ត្រូវតែចូលតាមបទពិសោធន៍ដើមដំបូងនេះដែរ។ នៅចុងសតវត្សទី២០នេះ អ្នកអានសន្តៈយ៉ូហានអើដ ទទួលរបៀបរស់នៅ និងបទពិសោធន៍មួយជាគ្រីស្តបរិស័ទ។ ត្រូវអនុវត្តមូលដ្ឋានគ្រឹះនៃរបៀបរស់នៅខាងផ្លូវវិញ្ញាណនេះ ក្នុងជីវិតប្រចាំថ្ងៃ និងទទួលបទពិសោធន៍នេះ ដើម្បីឲ្យផ្លូវខាងវិញ្ញាណនេះកើតជាថ្មី។ ហេតុនេះហើយ បានជាត្រូវតែរំឭកទាំងអតីតកាល -បទពិសោធន៍របស់លោកយ៉ូហានអើដ និងអត្ថបទផ្សេងៗដែល ផ្តល់សក្ខីភាពអំពីបទពិសោធន៍ទាំងនេះ នាពេលបច្ចុប្បន្នកាល -គឺអស់អ្នកដែលអនុវត្តតាមបទពិសោធន៍នេះ។ ហេតុនេះ ផ្លូវខាងវិញ្ញាណដ៏រស់រវើក អាចចេញមកពីបទពិសោធន៍ទាំងពីរនោះ គឺបទពិសោធន៍របស់គ្រូផង និងបទពិសោធន៍របស់សិស្សផង។ រីឯយើងនឹងអាចបង្កើតផ្លូវខាងវិញ្ញាណថ្មីដ៏រស់រវើកមួយទៀតសម្រាប់បច្ចុប្បន្នកាលដែរ។

## ២- ផ្លូវរបស់លោក យ៉ូហាន អើដ

### *ក្រុមគ្រួសារខាងវិញ្ញាណ*

យើងណែនាំផ្លូវមួយ ដែលបានកើតមកក្នុងក្រុមគ្រួសារដ៏ធំរបស់សន្តៈយ៉ូហានអើដ គឺក្រុមបព្វជិតបព្វជិតាជាច្រើន បានរួមសហការជាមួយគ្នា ដើម្បីបង្កើតផ្លូវខាងវិញ្ញាណនេះ៖ ដូនជីនៃបេះដូងដ៏វិសុទ្ធរបស់ព្រះយេស៊ូ និងព្រះនាងម៉ារី ប៉ារ៉ាមេ ដូនជី នៃឧបការគុណនៅទីក្រុងអេវ៉ីស្រ៍ ដូនជីនៃធម៌មេត្តាករុណា ដូនជីនៃគង្វាលដ៏សប្បុរស ក្រុមគ្រួសាររបស់សន្តៈយ៉ូហាន អើដ។ យើងសង្ឃឹមថា ឯកសារនេះនឹងទៅជាឧបករណ៍ ដើម្បីជួយណែនាំមនុស្សខាងផ្លូវវិញ្ញាណតាមសន្តៈយ៉ូហានអើដ។

### *ប្រពៃណីនៃសាលាខាងវិញ្ញាណរបស់សន្តៈយ៉ូហាន អើដ*

នៅសតវត្សទី ១៧ នៅសាលារៀនបារាំងខាងវិញ្ញាណ ចាប់អារម្មណ៍ខ្លាំងអំពីព្រះគ្រីស្តប្រសូតជាមនុស្ស សន្តៈយ៉ូហាន អើដ អញ្ជើញគ្រីស្តបរិស័ទឲ្យរំឭកអគ្គសញ្ញាជ្រមុជទឹកឡើងវិញ ដោយលះបង់ខ្លួនឯងចោល -បើកចិត្តឲ្យទូលាយ -ដើម្បីរួមជាមួយព្រះយេស៊ូ -ថ្វាយខ្លួនចំពោះព្រះអង្គ-។

## ផ្លូវមួយ

**ផ្លូវរបស់សន្តៈយ៉ូហាន អើដ មានបួនដំណាក់កាល៖** បើកចិត្តក្រាបថ្វាយបង្គំ សូមទោសថ្វាយខ្លួន។

ដំណាក់កាលទីមួយ ៖ បើកចិត្តឲ្យទូលាយ

**ការទទួល**

ត្រូវបើកទ្វារទទួលអស់អ្នកដែលខុសប្លែកពីយើង និងទទួលព្រះជាម្ចាស់។ ត្រូវទទួលខ្លួនឯងពីព្រះជាម្ចាស់មានជីវិតរស់នៅដោយមិនការពារខ្លួនឯងពីអ្វីមួយ ឬពីរមនុស្សម្នាក់។

**ដំណាក់កាលទីពីរ ៖** ថ្វាយបង្គំ

**ព្រះអំណោយទីមួយចេញមកពីការទទួលស្វាគមន៍**

ត្រូវសម្លឹងមើលព្រះជាម្ចាស់ពិភពលោក និងអ្នកដទៃឡើងវិញ ដើម្បីថ្វាយបង្គំព្រះអង្គ គឺនៅពេលនោះយើងបំភ្លេចខ្លួនឯង យើងអរព្រះគុណព្រះអង្គ ដើម្បីអ្វីៗដែលព្រះអង្គបានធ្វើ ជាពិសេសដើម្បីព្រះអង្គតែម្តង។ ព្រះជាម្ចាស់ប្រទានព្រះអំណោយទាននេះ ជាព្រះអំណោយទានដើមដំបូងរបស់ព្រះអង្គដល់អស់អ្នក ដែលទទួលស្វាគមន៍ព្រះអង្គ ។

**ដំណាក់កាលទីបី ៖** សូមទោស

**ការទទួលទីពីរ**

ក្រោយពីបានថ្វាយបង្គំ និងអរព្រះគុណព្រះជាម្ចាស់ យើងដឹងខ្លួនថា យើងឃ្លាតឆ្ងាយពីព្រះអង្គដែលស្រឡាញ់យើងយ៉ាងអស្ចារ្យ។ ដំណាក់កាលនេះ នាំយើងឲ្យចង់ទទួលការលើកលែងទោសបន្តិចម្តងៗ។ ឲ្យការសូមលើកលែងទោសនោះមកពីខ្ញុំប្លែកពីខ្លួនខ្ញុំចង់ឲ្យបានប្លែកពីអ្នកដទៃហើយព្រះជាម្ចាស់ក៏ប្លែកពីអ្វីដែលខ្ញុំផងដែរ។ ខ្ញុំត្រូវតែលើកលែងទោសឲ្យខ្ញុំថា ខ្ញុំមិនមែនដូចអ្វីដែលខ្ញុំចង់បានឡើយ។ ខ្ញុំត្រូវលើកលែងទោសឲ្យអ្នកដទៃ ដែលប្លែកពីខ្ញុំ ហើយខ្ញុំត្រូវលើកលែងទោសឲ្យព្រះជាម្ចាស់ ដែលទ្រង់មានព្រះហឫទ័យប្លែកពីបំណងចិត្តខ្ញុំ។

កំណត់ព្រំដែនរបស់ខ្ញុំ ឬរបស់អ្នកដទៃនាំខ្ញុំឲ្យទៅរកកម្លាំងចិត្តក្រៅពីខ្ញុំ គឺនៅក្នុងអង្គព្រះជាម្ចាស់ដែលបានប្រគល់អ្វីៗទាំងអស់មកយើង ដោយបានប្រគល់ព្រះបុត្រាព្រះអង្គ ព្រះអង្គដែលជាព្រះបិតាពោរពេញទៅដោយធម៌មេត្តាករុណា។

**ដំណាក់កាលទីបួន ៖** ថ្វាយខ្លួនចំពោះព្រះជាម្ចាស់

**ព្រះអំណោទានទីពីរ**

ត្រូវថ្វាយខ្លួនដោយដឹងខ្លួនថា យើងជាអ្នកបាប ប៉ុន្តែដោយយល់ឃើញថា ព្រះជាម្ចាស់ស្រឡាញ់យើងផងដែរ។ យើងបានទទួលព្រះយេស៊ូ ព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គ និងសេចក្តីស្រឡាញ់របស់ព្រះអង្គ ដើម្បីអាចថ្វាយខ្លួនចំពោះព្រះអង្គ។ យើងទទួលសេចក្តីស្រឡាញ់របស់ព្រះអង្គកាន់តែច្រើនយ៉ាងណា យើងក៏ថ្វាយខ្លួនក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ និងឆ្លុះបញ្ចាំងសេចក្តីស្រឡាញ់នោះ កាន់តែច្រើនយ៉ាងនោះដែរ។ ការថ្វាយខ្លួននេះ ដូចជាផ្តល់សក្ខីភាពចំពោះអ្នកដទៃ។ យើងថ្វាយខ្លួនដើម្បីទៅជាសាក្សី។

ផ្លូវរបស់សន្តៈយ៉ូហានអើដនាំយើងទៅប្រកាសដំណឹងល្អ។

## គរុកោសល្យ

ផ្លូវរបស់សន្តៈយ៉ូហានអើដមានដូចជាចលនាពីរ គឺការទទួល និងការថ្វាយខ្លួន។ ព្រះជាម្ចាស់ដែលយើងសម្លឹងមើលនៅក្នុងអង្គព្រះគ្រីស្ត នាំអ្នកឲ្យសម្លឹងមើលព្រះអង្គដោយទទួលស្គាល់ភាពវេទនារបស់ខ្លួន និងនាំគេឲ្យថ្វាយខ្លួនដើម្បីទៅជា ភ្នែក មាត់ បេះដូងរបស់ព្រះយេស៊ូ។

## មាតិកាចែកជាវគ្គផ្សេងៗដូចជា៖

- ការណែនាំប្រធានបទ និងគោលដៅនៃដំណាក់កាលនីមួយៗ
- ការទទួល និងការបើកចិត្ត
- ការសម្លឹងមើលព្រះជាម្ចាស់ និងការអរព្រះគុណព្រះអង្គ
- ការទទួលការលើកលែងទោស
- ការថ្វាយខ្លួនចំពោះព្រះជាម្ចាស់ និងការប្រកាសដំណឹងល្អ
- ការណែនាំអំពីសៀវភៅផ្សេងទៀត ដូចជាលទ្ធិនៃគ្រីស្តសាសនា ដើម្បីឲ្យផ្លូវខាងវិញ្ញាណរបស់យើងចាក់ឫសក្នុងជំនឿរបស់ព្រះសហគមន៍។

ផ្លូវខាងវិញ្ញាណរបស់សន្តៈយ៉ូហានអើដ ត្រូវនាំអ្នកចូលឲ្យរីកចម្រើន តាមពាក្យសន្យានៃពិធីបុណ្យជ្រមុជទឹក គឺរួមរស់ជាមួយព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គសោយរាជ្យ។ បន្តិចម្តងៗ យើងជាសាវ័កក្លាយទៅជាគ្រីស្តទូត។ ផ្លូវរបស់សន្តៈ យ៉ូហាន អើដ ត្រូវមានបំណងប្រាថ្នាឲ្យទៅជាគ្រីះ ហើយត្រូវឲ្យមានព្រះយេស៊ូគ្រីស្ត ដែលជាទីសង្ឃឹមរបស់យើងទៅជាគោលដៅ។ ព្រះយេស៊ូកំដរយើងនៅតាមផ្លូវ ព្រះអង្គក៏ជាទីដើម និងទីបុងក្រោយនៃអ្វីៗទាំងអស់។ ទីបញ្ចប់សេចក្តីសង្ឃឹមរបស់យើងជាគ្រីស្តបរិស័ទ គឺមនុស្សម្នាក់៖ ព្រះយេស៊ូផ្ទាល់តែម្តង។

## អនុវត្តពិធីជ្រមុជទឹក

ផ្លូវរបស់សន្តៈយ៉ូហានអើដ មិនមែនដូចជាមេរៀននៅសាលា ឬកម្មវិធីសិក្សាទេ ប៉ុន្តែជាបទពិសោធន៍មួយក្រោមការដឹកនាំរបស់គ្រូខាងវិញ្ញាណដែលមានឈ្មោះថា យ៉ូហានអើដ។ ផ្លូវនេះចង់ឲ្យយើងអនុវត្តពិធីជ្រមុជ ទឹកដែលយើងបានទទួលដើម្បីឲ្យរីកចម្រើន និងឲ្យព្រះយេស៊ូគ្រងរាជ្យនៅក្នុងខ្លួនយើង។ តាមពាក្យសម្តីរបស់សន្តៈយ៉ូហានអើដផ្ទាល់ គោលដៅនៃផ្លូវខាងវិញ្ញាណរបស់លោក គឺឲ្យយើងទៅដូចជាព្រះយេស៊ូ។

## ៣ -ឱកាសខ្លះៗដើម្បីអនុវត្តផ្លូវខាងវិញ្ញាណ

យើងអាចអនុវត្តផ្លូវខាងវិញ្ញាណរបស់ សន្តៈយ៉ូហាន អើដ តែម្នាក់ឯង ឬជាក្រុមតូចៗ នៅផ្ទះផ្ទាល់ខ្លួន ឬនៅក្នុងមណ្ឌលខាងវិញ្ញាណណាមួយ ដោយមានអ្នកណែនាំខាងវិញ្ញាណមកជួយ (បើអាចធ្វើបាន)។ ប្រសិនបើគ្មានអ្នកណែនាំអាចជួយបានទេ យើងអាច៖

***ទីមួយ ៖*** ធ្វើសំណាក់ធម៌តែម្នាក់ឯងដោយស្ងៀមស្ងាត់។ បើមានតែមួយថ្ងៃ សូមធ្វើតាមដំណាក់កាលតែមួយ។ បើមានពីរបីថ្ងៃសូមធ្វើតាមពីរបីដំណាក់កាល។

***ទីពីរ ៖*** ក្នុងការរស់នៅប្រចាំថ្ងៃ ចំណាយពេលវេលាជារៀងរាល់ថ្ងៃ ដោយគ្រោងម៉ោងវេលា និងទីកន្លែងទុកជាមុន។ បើមានអ្នកណែនាំ ឬក្រុមណាមួយអាចជួយបាន ត្រូវរៀបចំអ្វីៗទាំងអស់ទុកជាមុនដែរ។ ត្រូវតែមាន

កូនសៀវភៅដើម្បីកត់ត្រាថ្ងៃចាប់ផ្តើមដំណាក់កាលនីមួយៗ ចម្លើយនឹងសំណួរផ្សេងៗ ការរិះគិតពិចារណា និង ការអធិដ្ឋានដែលចេញមកពីការរិះគិតនេះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជាគ្រឹះនៃការរិះគិត...។

## ដើម្បីអានអត្ថបទ

ដូចសាវ័ករបស់ព្រះយេស៊ូឯទៀតៗ សន្តៈយ៉ូហាន អើដ បានដកពិសោធន៍នៃការស្តាប់ព្រះបន្ទូលព្រះជាម្ចាស់។ គួរចាប់ផ្តើមអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ស្ងប់ចិត្តឲ្យស្ងាត់ រៀបចំចិត្តគំនិតឲ្យស្តាប់ព្រះបន្ទូល អានអត្ថបទមួយៗចាប់អារម្មណ៍អំពីពាក្យទាំងប៉ុន្មានដែលខ្លួនពេញចិត្ត អានអត្ថបទឡើងវិញម្តងហើយនិងម្តងទៀត។ រួចហើយថ្វាយបង្គំ អរព្រះគុណ សូមទោសថ្វាយខ្លួន។

បើកដួងចិត្តឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ សូមព្រះអង្គមានព្រះបន្ទូលមកយើង ដោយមិនកើតទុក្ខព្រួយ បើគ្មានអ្វីកើតឡើង។ គោរពពេលវេលា ដែលយើងបានគ្រោងទុកជាមុន ទីបញ្ចប់អរព្រះគុណព្រះអង្គ សម្រាប់អារម្មណ៍នឹងចិត្ត អ្វីៗទាំងអស់ដែលយើងបានទទួលក្នុងការអធិដ្ឋាន។

## ដើម្បីអធិដ្ឋាន

***ទីកន្លែង ៖*** ត្រូវតែស្នាក់នៅក្នុងកន្លែង ដែលយើងពេញចិត្ត ហើយដែលជួយយើងឲ្យអធិដ្ឋាន។

***រាងកាយ ៖*** បន្ធូរអារម្មណ៍ ដកដង្ហើមមួយៗ ដើរមួយៗ អាចជួយឲ្យយើងចូលក្នុងការអធិដ្ឋាន។ អង្គុយឲ្យបានស្រួលបួល។

***វេលា ៖*** ត្រូវតែដឹងជាមុនថា តើយើងចំណាយពេលវេលាប៉ុន្មានដងក្នុងមួយខែ មួយអាទិត្យ ឬមួយថ្ងៃ ដើម្បីអធិដ្ឋាន ហើយអស់រយៈពេលប៉ុន្មានម៉ោងឬនាទី? តាមម្នាក់ៗអាចធ្វើបាន។

***ការចាប់ផ្តើម ៖*** ក្រោយពីបានទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធកុំឲ្យយើងវង្វេងស្មារតី ត្រូវចាប់អារម្មណ៍អំពីចំណុចណាមួយដូចជាព្រឹត្តិការណ៍មួយ ដែលបានកើតឡើងក្នុងជីវិត ព្រះបន្ទូលណាមួយដោយដឹងថា ព្រះវិញ្ញាណអាចណែនាំយើងតាមផ្លូវផ្សេងទៀត។

***ដំណើរការ ៖*** យើងអធិដ្ឋានដើម្បីស្រឡាញ់ មិនមែនដើម្បីរិះគិតពិចារណាតែប៉ុណ្ណោះ។ ព្រះវិញ្ញាណណែនាំយើងឲ្យយើងអាចយកគម្រប់តាមព្រះយេស៊ូ ដែលទូលអង្វរព្រះបិតារបស់ព្រះអង្គ ឬឲ្យយើងទៅដូចជាព្រះនាងម៉ារី ដែលតែងតែទទួលព្រះយេស៊ូនៅក្នុងចិត្តគំនិតព្រះនាង។

***ទីបញ្ចប់ ៖*** ថ្វាយខ្លួនចំពោះព្រះអម្ចាស់ ហើយសូមទទួលការប្រោសប្រណីពីព្រះអង្គផង។

# ធ្វើជាសាវ័ក

ត្រូវមានបំណងប្រាថ្នាមួយយ៉ាងធំ គឺប្រើពេលវេលាសព្វថ្ងៃនេះ ដូចជាពេលវេលាចុងក្រោយបំផុត នៃពិភពលោកនេះ។

## ដំណាក់កាលទី១

ព្រះអម្ចាស់! ព្រះអម្ចាស់របស់ខ្ញុំអើយ! ខ្ញុំម្ចាស់ស្វែងរកព្រះអង្គគ្រប់ពេលវេលា ព្រលឹងខ្ញុំម្ចាស់ ស្រេកឃ្លានចង់ជួប ចង់ស្គាល់ព្រះអង្គណាស់ -ទន ៦៣-

**ក្នុងដំណាក់កាលនេះមាន** ៖ ខ្ញុំត្រូវមានបំណងប្រាថ្នា៖

- រួមផ្សំជាមួយខ្លួនខ្ញុំផ្ទាល់
- ជួបនឹងបំណងមួយទៀត ដែលមានពីមុនមក... គឺជាបំណងរបស់ព្រះជាម្ចាស់ដែលមានព្រះហឫទ័យទតឃើញមនុស្សជាតិទាំងមូល ឲ្យចូលរួមចំណែកក្នុងសុភមង្គលរបស់ព្រះអង្គ។
- ព្រះជាម្ចាស់មានព្រះហឫទ័យ ឲ្យខ្ញុំចូលរួមចំណែកក្នុងព្រះជន្មផ្ទាល់របស់ព្រះអង្គក្នុង...ដោយ...ជាមួយ...ព្រះយេស៊ូ ។

ក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ ខ្ញុំត្រូវនឹកគិតដល់លក្ខណៈជាមនុស្សរបស់ខ្ញុំដែលគ្មានអ្វី ដែលមើលមិនឃើញ ដែលមិនដឹង...

- ដោយគិតទុកជាមុនថា ខ្ញុំមើលមិនឃើញ ខ្ញុំរង់ចាំព្រះអង្គ...
- ខ្ញុំត្រៀមខ្លួនជាស្រេច ដើម្បីទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់។

**គោលដៅនៃដំណាក់កាលនេះ** ៖

- ចេញពីបំណងប្រាថ្នាច្រើនបែបរបស់ខ្ញុំ ដោយចាប់យកបំណងប្រាថ្នាតែមួយ
- បញ្ជាក់បង្ហាញថា តើបំណងរបស់ខ្ញុំមានអ្វីខ្លះ ក្នុងទំនាក់ទំនងជាមួយអ្នកដទៃ ក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់
- ពង្រឹងបំណងទាំងនោះឲ្យកាន់តែជ្រាលជ្រៅ
- រកឲ្យឃើញចំណុចសម្គាល់ក្នុងព្រះគម្ពីរដំណឹងល្អ ដែលអាចឲ្យខ្ញុំយល់ឃើញថា តើបំណងទាំងនោះ មកពីព្រះជាម្ចាស់ដែរឬទេ?
- ធ្វើឲ្យការស្រេកឃ្លានចង់ជួបព្រះជាម្ចាស់កាន់តែខ្លាំងក្លា

នៅចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំត្រូវតែខិតខំស្វែងយល់អំពីបំណងប្រាថ្នាតែមួយរបស់ខ្ញុំ និងបំណងប្រាថ្នាជាច្រើនរបស់ខ្ញុំ។

**ទុកពេលមួយ ដើម្បីបើកចិត្តឲ្យទូលាយ និងដើម្បីទទួលព្រះអង្គ**

១ - រកមធ្យោបាយ ដើម្បីផ្អាកកិច្ចការប្រចាំថ្ងៃ ឬសកម្មភាពផ្សេងៗ

២ - គិតគូឡើងវិញ ។ រើសយកកន្លែងណាមួយ ដែលជាទីរីករាយ ជាកន្លែងដែលខ្លួនពេញចិត្ត

៣- ផ្លាស់ប្តូររបៀបរស់នៅ...ដើរលេងសប្បាយ...ស្គាល់រាងកាយខ្លួនឲ្យច្បាស់លាស់ ដូចជាការដកដង្ហើម... ស្តាប់ភ្លេង...ដើម្បីស្គាល់ខ្លួនឯងឲ្យកាន់តែច្បាស់ ។

៤- យល់ឃើញអំពីអ្វីៗ ដែលមាននៅក្នុងខ្លួនយើង ដែលនាំឲ្យមានការព្រួយបារម្ភ ដែលជាឧបសគ្គមករាំងស្ទះដល់ការសិក្សា...យល់អំពីជម្រៅចិត្តរបស់យើង...បើកចិត្តបន្តិចម្តងៗ ធ្វើឲ្យចិត្តនោះទំនេរបម្រុងនឹងទទួលព្រះបន្ទូល។

៥- រិះគិតអំពីបំណងប្រាថ្នាផ្សេងៗរបស់ខ្ញុំ...តើខ្ញុំចង់បានព្រះជាម្ចាស់?

ខ្ញុំបើកចិត្តឲ្យទូលាយ... ខ្ញុំបែករំលែកចិត្ត... ខ្ញុំស្តាប់ ខ្ញុំទទួល...

## រឿងនិទានបូព៌ាប្រទេស

ត្រូវតែមានបំណងយ៉ាងខ្លាំងក្លា ទើបអាចជួបព្រះជាម្ចាស់បាន។

ថ្ងៃមួយមានសិស្សម្នាក់ទៅជួបគ្រូគាត់ ហើយសួរថា៖ លោកគ្រូខ្ញុំចង់ជួបព្រះជាម្ចាស់។ គ្រូសម្លឹងមើលទៅយុវជននោះ ដោយឥតស្តីមួយម៉ាត់ ហើយញញឹម ។

បុរសក្មេងនោះ តែងតែមកដណ្តឹងសួរគ្រូរាល់ថ្ងៃថា ខ្លួនចង់បានសាសនា។ ប៉ុន្តែលោកគ្រូដឹងច្បាស់ថា ត្រូវធ្វើដូចម្តេចហើយ។ ថ្ងៃមួយធាតុអាកាសក្តៅស្អុះស្អាប់យ៉ាងខ្លាំង លោកគ្រូហៅសិស្សឲ្យទៅហែលទឹកទន្លេ ជាមួយគាត់។

បុរសក្មេងលោតចុះក្នុងទឹក។ លោកគ្រូហែលតាមសិស្ស ហើយប្រឹងចាប់ក្បាលយុវជននោះជ្រមុជចុះក្នុងទឹក។ នៅពេលដែលសិស្សនោះប្រឹងរើបម្រាស មួយសន្ទុះគាត់ព្រលែងគេឲ្យងើបមកដកដង្ហើម ហើយសួរថា ពេលដែលគេលិចក្នុងទឹក តើគេចង់បានអ្វីខ្លាំងជាងគេ ។

- ចង់បានខ្យល់! សិស្សឆ្លើយ

- តើឯងចង់ស្គាល់ព្រះជាម្ចាស់ខ្លាំងដូច្នោះទេ? គ្រូសួរ ។

បើឯងមានបំណងខ្លាំងក្លាដូច្នោះ ឯងនឹងជួបព្រះជាម្ចាស់ភ្លាមៗនេះ។ បើឯងគ្មានបំណង និងស្រេកឃ្លានយ៉ាងខ្លាំងក្លាទេ ទោះជាឯងតស៊ូដោយប្រាជ្ញាស្មារតី ដោយបបូរមាត់ និងដោយកម្លាំងឯងយ៉ាងណា ក៏ឯងរកមិនឃើញព្រះជាម្ចាស់ដែរ។ បើបំណងប្រាថ្នានេះ មិនស្ថិតនៅជាប់ជាប្រចាំក្នុងខ្លួនឯងទេ នោះឯងមិនគ្រាន់បើជាងអ្នកគ្មានសាសនាឡើយ។ ទោះជាយ៉ាងណាក៏អ្នកគ្មានសាសនាហ៊ាននិយាយការពិតដែរ ចំណែកឯងវិញមិនហ៊ានទេ ។

**ទុកពេល ដើម្បីស្ញើងស្ញាធិ៍ និងអរព្រះគុណព្រះជាម្ចាស់**

១- រកនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ថា តើព្រះជាម្ចាស់សម្តែងឲ្យដឹងអំពីព្រះបំណងប្រាថ្នារបស់ព្រះអង្គដូចម្តេចខ្លះ?

○ លោកម៉ូសេរង់ចាំព្រះជាម្ចាស់ -សរ ៣៣,២-

○ ព្រះជាម្ចាស់ទាក់ទាញចិត្តលោកយេរេមី ២០,៧

○ ស្មូតទំនុកតម្កើង

**ទំនុកតម្កើង ៦៣ (៦២) ស្រេកឃ្លានចង់ជួប និងស្គាល់ព្រះជាម្ចាស់**

១ ទំនុកតម្កើងរបស់ស្ដេចដាវីឌ នៅគ្រាដែលទ្រង់គង់នៅវាលរហោស្ថានស្រុកយូដា។

៦៣ ២ ឱ ! ព្រះជាម្ចាស់អើយ! ព្រះអង្គពិតជាព្រះនៃទូលបង្គំមែន ទូលបង្គំស្វែងរកព្រះអង្គ
ទូលបង្គំចង់នៅក្បែរព្រះអង្គណាស់ ទូលបង្គំចង់នៅជាប់ជាមួយព្រះអង្គ
ដូចដីដ៏ស្ងួតបែកក្រហែងត្រូវការទឹក។

៣ ទូលបង្គំបានឃើញព្រះអង្គនៅក្នុងទីសក្ការៈ
ទូលបង្គំបានឃើញឫទ្ធានុភាព និង សិរីរុងរឿងរបស់ព្រះអង្គ

៤ ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គប្រសើរលើសជីវិតទៅទៀត
ទូលបង្គំនឹងពោលពាក្យសរសើរតម្កើង សិរីរុងរឿងព្រះអង្គ។

៥ ទូលបង្គំនឹងអរព្រះគុណព្រះអង្គអស់មួយជីវិតទូលបង្គំ
ហើយទូលបង្គំនឹងលើកដៃឡើងថ្វាយបង្គំព្រះកិត្តិនាមព្រះអង្គ។

៦ ទូលបង្គំនឹងបានសប្បាយ មានសុខុដុមរមនា
ហើយទូលបង្គំនឹងបន្លឺសំឡេងឡើង ច្រៀងសរសើរតម្កើងព្រះអង្គ។

៧ ពេលទូលបង្គំចូលដំណេក ទូលបង្គំនឹកដល់ព្រះអង្គ
ហើយពេញមួយយប់ ទូលបង្គំរិះគិតអំពីព្រះអង្គ

៨ ដ្បិតព្រះអង្គជួយទូលបង្គំ ទូលបង្គំច្រៀងយ៉ាងសប្បាយក្រោមម្លប់បារមីព្រះអង្គ។

៩ ចិត្តគំនិតទូលបង្គំ នៅជាប់ជំពាក់នឹងព្រះអង្គជានិច្ច
ព្រះអង្គគាំទ្រទូលបង្គំ ដោយព្រះចេស្ដារបស់ព្រះអង្គ។

១០ រីឯអស់អ្នកដែលចង់បំផ្លាញជីវិតទូលបង្គំ
សូមឲ្យគេធ្លាក់ទៅក្នុងរណ្ដៅដ៏ជ្រៅ។

១១ សូមឲ្យគេត្រូវស្លាប់ដោយមុខដាវ
សូមឲ្យគេបានទៅជាចំណីរបស់ចចក។

១២ ពេលនោះ ព្រះរាជានឹងមានអំណរ ដោយព្រះកិត្តិនាមព្រះជាម្ចាស់
អ្នកណាស្បថក្នុងព្រះនាមព្រះជាម្ចាស់ អ្នកនោះនឹងលើកតម្កើងព្រះអង្គ
រីឯអ្នកដែលចូលចិត្តនិយាយកុហក នឹងត្រូវបាត់មាត់សូន្យឈឹងទៅ។

**២**. រកទំនាក់ទំនងរវាងព្រះយេស៊ូ ជាមួយនឹងព្រះបិតារបស់ព្រះអង្គ ក្នុងសម្ពន្ធមេត្រីថ្មី

- មើលឡើងវិញគម្ពីរដំណឹងល្អតាមសន្តៈយ៉ូហាន ហើយធ្វើការស្នើងស្មាធ៏អំពីបំណងប្រាថ្នារបស់ព្រះយេស៊ូចំពោះព្រះបិតាព្រះអង្គ។
- កត់ត្រាចំណុចសម្គាល់ ដែលអាចធ្វើឲ្យយើងយល់ថា បំណងប្រាថ្នារបស់យើង ដូចព្រះបំណងរបស់ព្រះជាម្ចាស់ដែរឬទេ។

៣. អានឡើងវិញ សេចក្តីអធិដ្ឋានរបស់សន្តៈយ៉ូហានអើដ ហើយសាកល្បងធ្វើតាមបទពិសោធន៍របស់លោក។

## បំណងប្រាថ្នាតែមួយគត់របស់ខ្ញុំ

ពិតមែនហើយព្រះយេស៊ូអើយ! ទូលបង្គំប្រាថ្នាចង់ស្រឡាញ់ព្រះអង្គខ្លាំងណាស់ ខ្ញុំម្ចាស់មិនចង់បានអ្វីក្រៅពីនេះទេ។ លាហើយគំនិតវង្វេងទាំងអស់នេះ ភាពទោរទន់ទៅរកអ្វីផ្សេងៗ និងបំណងប្រាថ្នាផ្សេងទៀតទាំងអស់! ឱព្រះអង្គដ៏ជាទីស្រឡាញ់តែមួយគត់របស់ខ្ញុំអើយ! ព្រះយេស៊ូអើយ! សូមឲ្យព្រះអង្គទៅជាព្រះជន្មនៃជីវិតរបស់ខ្ញុំម្ចាស់ ព្រលឹងខ្ញុំម្ចាស់ ព្រះហឫទ័យនៃទឹកចិត្តរបស់ខ្ញុំម្ចាស់។ ខ្ញុំម្ចាស់មិនអាចរស់នៅដោយគ្មានព្រះអង្គទេ។ ខ្ញុំម្ចាស់មិនអាចធ្វើអ្វីមួយ ក្រៅពីព្រះអង្គបានឡើយ។

ព្រះយេស៊ូអើយ! ខ្ញុំម្ចាស់ប្រាថ្នាឲ្យគំនិត សម្តី និងកិច្ចការទាំងអស់របស់ខ្ញុំម្ចាស់ សូមឲ្យការដកដង្ហើមចលនាបេះដូងរបស់ខ្ញុំម្ចាស់ ពេលវេលានៃជីវិតទាំងអស់របស់ខ្ញុំម្ចាស់ ប្រែក្លាយទៅជាសំឡេង ដើម្បីទូលថ្វាយថា ខ្ញុំម្ចាស់ប្រាថ្នាចង់ស្រឡាញ់ព្រះអង្គឥតស្រាកស្រាន្ត និងអស់កល្បជានិច្ច ទូលបង្គំស្រឡាញ់ព្រះអង្គ ទូលបង្គំស្រឡាញ់ព្រះអង្គពិតហើយ ព្រះអម្ចាស់យេស៊ូអើយទូលបង្គំស្រឡាញ់ព្រះអង្គ។

*ដកស្រង់ចេញពីកិច្ចការនៃសេចក្តីស្រឡាញ់ព្រះរាជ្យព្រះយេស៊ូ*

## *ក្នុងចំណោមអត្ថបទទាំងអស់ដែលខ្ញុំបានអាន*

ខ្ញុំរើសយកអត្ថបទមួយ, ខ្ញុំអានអត្ថបទនោះឡើងវិញ
ខ្ញុំឈប់អានពេលមកដល់ល្បះមួយ ពាក្យមួយម៉ាត់, ខ្ញុំអានយឺតៗ ដើម្បីក្រេបជញ្ជក់
ដើម្បីឲ្យបានជ្រួតជ្រាបក្នុងខ្លួន, ដើម្បីជ្រៀតចូលទៅក្នុងព្រះហឫទ័យនៃព្រះជាម្ចាស់
ខ្ញុំសម្តែងសេចក្តីស្រឡាញ់នោះមកដោយ, ការថ្វាយបង្គំ, ការអរព្រះគុណ ការលើកតម្កើងសិរីរុងរឿង
និងទូលថ្វាយអំពីបំណងប្រាថ្នាទាំងអស់របស់ខ្ញុំចំពោះព្រះអង្គ។

## ទុកពេល ដើម្បីទទួលការលើកលែងទោស

១ - ក្នុងការស្វែងរកព្រះជាម្ចាស់ យើងឃើញថា ក្នុងខ្លួនយើងៗមានបំណងជាច្រើនលាយឡំគ្នាចំពោះ
- ខ្លួនឯងផ្ទាល់
- អ្នកដទៃ
- ព្រះជាម្ចាស់

ត្រូវកត់សម្គាល់បំណងទាំងអស់នោះ ហើយត្រូវដឹងថា បំណងទាំងអស់នោះជាអ្វី !

**២**- ដោយរកសេចក្តីពិតអំពីខ្លួនឯងផ្ទាល់ ពិនិត្យមើលថាខ្លួនជាអ្វី បណ្តាលឲ្យឃើញការរាំងស្ទះ ស្នាមរបួសចិត្ត...

៣- ត្រូវដឹងឲ្យច្បាស់ថា ស្នាមរបួសទាំងអស់នោះ មិនមែនគួរឲ្យអស់សង្ឃឹមទេ។ ត្រូវធ្វើបទពិសោធន៍នៃសេចក្តីស្រឡាញ់ឥតព្រំដែនរបស់ព្រះជាម្ចាស់សម្រាប់ខ្លួនឯងផ្ទាល់។

ដោយជឿទុកចិត្ត ខ្ញុំដាក់ខ្លួនក្រោមព្រះនេត្រាព្រះជាម្ចាស់ ខ្ញុំទទួលយកនូវអ្វីដែលខ្ញុំមានជាមួយនឹងការរាំងស្ទះកំណត់ព្រំដែនទាំងអស់របស់ខ្ញុំ។

**ទុកពេលដើម្បីថ្វាយខ្លួនចំពោះព្រះយេស៊ូ**

ត្រូវដឹងឲ្យច្បាស់ថា បំណងប្រាថ្នាជាទីដៅនៃជីវិតរបស់យើង។ ត្រូវព្យាយាមពិចារណារំពឹកមើលជីវិតរបស់ខ្លួនឡើងវិញ។

ត្រូវធ្វើដូចម្ដេច ដើម្បីឲ្យបំណងប្រាថ្នារបស់ព្រះជាម្ចាស់អាចកើតឡើងក្នុងជីវិតរបស់ខ្ញុំ?

ធ្វើដូចម្ដេច ដើម្បីឲ្យបំណង ការរង់ចាំ តម្រូវទៅតាមបំណង ដែលមានទំនាក់ទំនងជាមួយខ្លួនឯងផង ជាមួយអ្នកដទៃផង និងជាមួយព្រះជាម្ចាស់ផងដែរ ?

តើព្រះជាម្ចាស់ត្រាស់ហៅយើងយ៉ាងដូចម្ដេច? តាមមាគ៌ា ដែលយើងដើរកន្លងមក តើយើងយល់យ៉ាងដូចម្ដេចអំពីព្រះបំណងរបស់ព្រះជាម្ចាស់ចំពោះយើង? ព្រះអង្គត្រាស់ហៅយើងដើម្បីអ្វី?

## ការថ្វាយខ្លួនរបស់សន្តៈយ៉ូហាន អើដ

*“ឱព្រះយេស៊ូជាអម្ចាស់អើយ! ខ្ញុំម្ចាស់ជាកម្មសិទ្ធិរបស់ព្រះអង្គគ្រប់បែបយ៉ាង ប៉ុន្តែខ្ញុំម្ចាស់ស្ម័គ្រចិត្តធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គផងដែរ។ ហេតុដូច្នេះហើយ បានជាខ្ញុំម្ចាស់សូមថ្វាយ សូមប្រគល់ សូមបូជារូបកាយទាំងស្រុង ព្រមទាំងព្រលឹង ជីវិតទឹកចិត្ត ស្មារតី គំនិត ពាក្យសម្ដី កិច្ចការ និងអ្វីៗផ្សេងទៀត ដែលខ្ញុំម្ចាស់មានពីមុនមក ហើយនឹងមានទៅថ្ងៃមុខទៀត ទាំងអស់ជាកម្មសិទ្ធទាំងស្រុងជាដាច់ខាតតែមួយគត់ និងអស់កល្បជានិច្ចចំពោះព្រះអង្គ។ ទូលបង្គំ បូជាខ្ញុំម្ចាស់ផ្ទាល់មិនត្រឹមតែកម្លាំងពលំ និងអំណាចប៉ុណ្ណោះទេ ប៉ុន្តែដើម្បីឲ្យតង្វាយនោះកាន់តែមានប្រសិទ្ធិភាព និងកាន់តែវិសុទ្ធថែមទៀតនោះ ខ្ញុំម្ចាស់សូមថ្វាយ និងប្រគល់ខ្លួនខ្ញុំផ្ទាល់ ដោយសារព្រះហឫទ័យប្រោសប្រណីព្រះអង្គ ឫទ្ធានុភាពនៃព្រះវិញ្ញាណព្រះអង្គ និងកម្លាំងពលំទាំងអស់ ដែលជាសេចក្ដីស្រឡាញ់របស់ព្រះអង្គបានប្រទានមកដល់ទូលបង្គំ ពីព្រោះអ្វីៗជារបស់ព្រះអង្គ ជារបស់ខ្ញុំម្ចាស់ផងដែរ។ ទូលបង្គំសូមអង្វរព្រះអង្គជាព្រះសង្គ្រោះរបស់ខ្ញុំអើយ ដោយធម៌មេត្តាករុណាដ៏ធំធេងរបស់ព្រះអង្គ សូមព្រះអង្គប្រើកម្លាំងនៃព្រះហស្តព្រះអង្គ ឫទ្ធានុភាព នៃព្រះវិញ្ញាណព្រះអង្គ និងសេចក្ដីស្រឡាញ់របស់ព្រះអង្គធក់យកអ្វីៗពីរូបខ្ញុំម្ចាស់ផ្ទាល់ និងអ្វីៗដែលមិនមែនជារបស់ព្រះអង្គទៅចុះ ដើម្បីឲ្យខ្ញុំម្ចាស់ទៅជាកម្មសិទ្ធិដ៏គ្រប់លក្ខខណ្ឌជារៀងរហូតតទៅរបស់ព្រះអង្គ ហើយដើម្បីឲ្យព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គប្រកបដោយសិរីរុងរឿង បរិសុទ្ធថែមទៀតផង។*

***ព្រះរាជ្យព្រះយេស៊ូ***

ខ្ញុំដាក់ខ្លួនចំពោះព្រះជាម្ចាស់ ខ្ញុំថ្វាយខ្លួនខ្ញុំចំពោះព្រះអង្គ ខ្ញុំថ្វាយព្រះអង្គវិញនូវអ្វីៗដែលខ្ញុំបានទទួល !

# អានប្រវត្តិរបស់ខ្លួនឡើងវិញ

នឹករលឹកទៅដល់ព្រះអំណោយទានទាំងប៉ុន្មាន ដែលខ្ញុំបានទទួលពីព្រះជាម្ចាស់ហើយត្រូវលើកតម្កើង សិរីរុងរឿង និងអរព្រះគុណព្រះអង្គឥតឈប់ឈរ។

## ដំណាក់កាលទី ២

ខ្ញុំនាំអ្នកដើរតាមផ្លូវ ដែលអ្នកកំពុងដើរ !

**ក្នុងដំណាក់កាលនេះមាន ៖** បំណងប្រាថ្នាចង់ជួបព្រះជាម្ចាស់ ទាមទារឲ្យយើងមានការចងចាំអំពីព្រះអំណោយទានដែលខ្ញុំបានទទួលពីព្រះអង្គ។ ជាពិសេសឲ្យខ្ញុំរំឭកឡើងវិញ នៅពេលខ្ញុំបានជួបនឹងព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ។ រំឭកឡើងវិញ គឺអរព្រះគុណចំពោះវត្តមានព្រះអង្គ ក្នុងព្រឹត្តិការណ៍ទាំងអស់ នៃជីវិតរបស់ខ្ញុំ។ ខ្ញុំរំឭកឡើងវិញ ដោយសរសេរប្រវត្តិដ៏វិសុទ្ធរបស់ខ្ញុំ ដើម្បីថ្លែងអំណរ ព្រះគុណចំពោះការប្រោសប្រណីរបស់ព្រះអង្គ ដ្បិតព្រះជាម្ចាស់សង្គ្រោះខ្ញុំ តាមរយៈកិច្ចការប្រចាំថ្ងៃ។ ខ្ញុំរំឭកឡើងវិញ ដោយបញ្ជាក់ឲ្យដឹងអំពីមាគ៌ាដែលត្រូវដើរឆ្ពោះទៅរកព្រះជាម្ចាស់។

**គោលដៅនៃដំណាក់កាលនេះ ៖**...អានប្រវត្តិរបស់ខ្លួនឡើងវិញ ដោយទទួលហេតុការណ៍ទាំងល្អទាំងអាក្រក់

...ដាក់ចិត្តព្រមទទួលយកហេតុការណ៍ដែលកើតមានក្នុងអតីតកាល និងបច្ចុប្បន្នកាលបន្តិចម្តងៗ

...កត់សម្គាល់ខ្សែចង្វាក់ ដែលចេញមកពីហេតុកាណ៍ប្លែកៗក្នុងជីវិតរបស់ខ្ញុំ...

...រៀនថ្លែងអំណរព្រះគុណដល់ព្រះជាម្ចាស់ ដែលបានប្រទានជីវិតនេះ។ អនុស្សាវរីយ៍ទាំងអស់របស់ខ្ញុំ គឺជាការអរគុណចំពោះព្រះជាម្ចាស់ -សន្តៈអូគូស្ទីន

...រកឲ្យឃើញមាគ៌ាផ្ទាល់ខ្លួនរបស់ខ្ញុំ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំត្រូវតែពិនិត្យមើលថា តើខ្ញុំយល់ព្រមតាមព្រះហឫទ័យព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការនៃជីវិតរបស់ខ្ញុំឬទេ?

**ទុកពេល ដើម្បីបើកចិត្តទូលាយ និងទទួលព្រះជាម្ចាស់**

១ - ប្រុងប្រៀបខ្លួន ដើម្បីទទួលអតីតកាល និងបច្ចុប្បន្នកាលនៃជីវិតខ្ញុំ

- យល់អំពីទុក្ខលំបាក ដែលបាននាំឲ្យយើងចាក់ឫសក្នុងជំនឿ
- ត្រូវកត់សម្គាល់ ពេលដែលយើងបានជួបព្រះជាម្ចាស់ដែលនាំឲ្យយើងរីករាយ
- រំឭកអំពីមិត្តសម្លាញ់ដ៏ស្និតស្នាល ដែលបានជួយយើង
- និយាយរំឭកឡើងវិញ នូវពេលវេលាដ៏ឈឺចាប់ជាងគេ ដែលយើងបានជួបប្រទះក្នុងជីវិតនេះ

❍ យើងកាន់តែរីករាយខ្លាំងឡើងៗ នៅពេលដែលគិតទៅដល់វត្តមានរបស់ព្រះអម្ចាស់ក្នុងជីវិតយើង

❍ រំឭកអំពីព្រះបន្ទូលព្រះអម្ចាស់ ដែលបានជួយបំភ្លឺជាថ្មីម្តងទៀត និងបានជួយលើកទឹកចិត្តយើង

❍ ទូលព្រះជាម្ចាស់អំពីសេចក្តីសង្ឃឹមរបស់យើង

២- របៀបរាប់ឈ្មោះអស់អ្នកដែលបានជួយយើងច្រើនជាងគេ ក្នុងការដើរតាមមាគ៌ាឆ្ពោះទៅរកព្រះជាម្ចាស់ តើក្នុងបំណោមអ្នកទាំងអស់នោះ អ្នកណាជាអ្នកជួយយើង ឬរាំងស្ទះយើង?

តើយើងបានរៀនអ្វីខ្លះអំពីមនុស្សម្នាក់ៗនោះ?

តាមរយៈអ្នកទាំងអស់នោះ តើយើងយល់ឃើញអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់យើងដូចម្តេច?

*ខ្ញុំទទួលជីវិតរបស់ខ្ញុំក្រោមព្រះនេត្រាព្រះជាម្ចាស់។*

*ខ្ញុំទទួលអ្វីៗទាំងអស់ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ខ្ញុំរកឃើញវត្តមានរបស់ព្រះអង្គតាមរយៈអស់អ្នកដែលបានជួយលើកទឹកចិត្តខ្ញុំ។*

## ទុកពេល ដើម្បីស្ញឹងស្មាធិ៍ និងអរព្រះគុណព្រះជាម្ចាស់

១. សម្លឹងមើលយ៉ាងយូរទៅព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅ ហើយដែលអរព្រះគុណព្រះបិតាជានិច្ច

❍ ព្រះបិតាអើយ ព្រះអង្គតែងតែព្រះសណ្តាប់ពាក្យទូលអង្វរទូលបង្គំ-យហ ១១,៤១-

❍ មុនសោយទិវង្គត ព្រះយេស៊ូពិចារណាឡើងវិញអំពីជីវិតព្រះអង្គ ដោយអរព្រះគុណព្រះជាម្ចាស់ -យហ ១៧-

២. ព្រះនាងម៉ារីក៏រស់នៅដោយអរព្រះគុណព្រះជាម្ចាស់ដែរ -លក ១,៤៦-៥៥-

៣. សន្តបុគ្គលគ្រប់ជំនាន់យល់ឃើញថា ពួកលោកបានរកឃើញវត្តមានរបស់ព្រះជាម្ចាស់ និងបានអរព្រះគុណព្រះអង្គ ក្រោយពីបានពិចារណាអំពីជីវិតរបស់ពួកលោកឡើងវិញ។ ជាឧទាហរណ៍ ចូរយើងមើលទៅសន្តៈយ៉ូហានអើដ ដែលបានរំឭកឡើងវិញ នូវព្រះអំណោយទាន ព្រមទាំងហេតុការណ៍អាក្រក់ទាំងប៉ុន្មាន ដែលលោកបានទទួលពីព្រះជាម្ចាស់៖

### សន្តៈយ៉ូហាន អើដ

១. ព្រះជាម្ចាស់បានប្រោសប្រទានឲ្យខ្ញុំកើតមកទទួលអគ្គសញ្ញាជ្រមុជទឹក ទទួលព្រះកាយព្រះគ្រីស្ត និងបើកបេសកកម្មក្នុងព្រះសហគមន៍ឧទ្ទិសដល់ព្រះនាងព្រហ្មចារីម៉ារី ជាឧបការិនី។

២.ព្រះជាម្ចាស់បានប្រោសប្រទានឲ្យខ្ញុំកើតពីឪពុកម្តាយ ដែលមានជីវភាពមធ្យម រស់នៅដោយមានជំនឿ និងការគោរពកោតខ្លាចព្រះជាម្ចាស់។ ខ្ញុំអាចជឿថា ពួកគាត់ស្លាប់ទៅវិញ នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។

៦. ដោយកាលនោះ គ្រីស្តបរិស័ទ ដែលខ្ញុំរស់នៅនោះ មានការចេះដឹងផ្នែកជំនឿបន្តិចបន្តួច លុះបានអាយុប្រហែលជាដប់ពីរឆ្នាំ ខ្ញុំក៏បានចាប់ផ្តើមស្គាល់ព្រះជាម្ចាស់ ដោយសារព្រះហឫទ័យប្រណីសន្តោស ពិសេសរបស់ព្រះដ៏មានព្រះហឫទ័យសប្បុរស ហើយបានទទួលព្រះកាយរៀងរាល់ខែ បន្ទាប់ពីបានទទួលការលើក

លែងទោស។ ដល់បុណ្យព្រះវិញ្ញាណយាងមក ទើបព្រះអង្គប្រោសប្រណីឲ្យខ្ញុំទទួលព្រះកាយដំបូងបង្អស់។ ក្រោយពេលនោះបន្តិច ព្រះអង្គក៏ប្រោសប្រណីឲ្យខ្ញុំបូជារូបកាយរបស់ខ្ញុំជា ព្រហ្មចរិយបុគ្គលៈ សូមលើកតម្កើងព្រះអង្គជារៀងរហូត។

៧. ក្រោយពីបានធ្វើស្រែចម្ការអស់មួយរយៈពេលដ៏ខ្លីជាមួយលោកគ្រូម្នាក់ ជាបូជាចារ្យម្នាក់ឈ្មោះ យ៉ាកុប ដែលជាគំរូ ហើយដែលការបង្រៀនរបស់គាត់មានប្រយោជន៍ដល់ខ្ញុំច្រើនណាស់ ឪពុករបស់ខ្ញុំបានបញ្ជូនខ្ញុំទៅទីក្រុងកង់ ដើម្បីបន្តការសិក្សាជាមួយលោកបូជាចារ្យក្រុមយេស៊ូត។ នៅទីនោះ គេទទួលឲ្យខ្ញុំចូលរៀននៅថ្នាក់ទីបួនក្នុងឆ្នាំ ១៦១៥ នៅសាលា សន្តៈដឺនីស៍ បង្រៀនដោយបូជាចារ្យរ៉ូប៉ាំង ដែលជាអ្នកគ្រប់គ្រងម្នាក់ប្រកបដោយគុណធម៌ ហើយគោរពកោតខ្លាចព្រះអម្ចាស់យ៉ាងខ្លាំង។ លោកតែងតែនិយាយប្រាប់យើងអំពីព្រះជាម្ចាស់ ដោយមានជំនឿយ៉ាងមុតមាំអស្ចារ្យចំពោះព្រះអង្គ។ អ្វីៗទាំងអស់នេះហើយដែលបានជួយខ្ញុំយ៉ាងច្រើនរាប់មិនអស់ ដើម្បីជាប្រយោជន៍ដល់ខ្ញុំ។

៨. ខ្ញុំត្រូវបានទទួលឲ្យចូលរួមក្នុងក្រុមគ្រួសារបព្វជិតព្រះមាតានៃយើង នៅអនុវិទ្យាល័យទៅកង់ប្រហែលឆ្នាំ ១៦១៨។ នៅទីនោះហើយដែលព្រះអម្ចាស់នៃយើង មានព្រះហឫទ័យសន្តោសប្រណីយ៉ាងធំធេងក្រៃលែងចំពោះរូបខ្ញុំ តាមរយៈព្រះមាតាដ៏វិសុទ្ធ ។

១៧. នៅឆ្នាំ ១៦២៥ និង ១៦២៦ ព្រះអម្ចាស់ប្រទានឲ្យខ្ញុំក្លាយទៅជាជនពិការរាងកាយ ធ្វើការមិនកើតពីរឆ្នាំ។ ខ្ញុំប្រើពេលវេលាឈប់សម្រាកនោះ ដើម្បីធ្វើសំណាក់ធម៌ អានសៀវភៅ ដែលនិយាយអំពីការគោរពស្រឡាញ់ព្រះអង្គ និងធ្វើលំហាត់ផ្សេងៗទៀត ដែលទាក់ទងនឹងជំនឿ។ កាលនោះ ជាការប្រោសប្រទានមួយយ៉ាងពិសេស ដែលខ្ញុំត្រូវតែអរព្រះគុណចំពោះសប្បុរសធម៌របស់ព្រះអង្គអស់កល្បជានិច្ចតរៀងទៅ។

២២. ឆ្នាំ១៦៣៦ ពេញមួយរដូវក្តៅ ខ្ញុំបានបំពេញបេសកកម្ម ជាច្រើននៅភូមិភាគ សន្តៈម៉ាឡូ នៅប្រឺតាញ នៅផ្លើទ្វី នៅ ភ្លូអ៊ែរ និងកង់កាល។

៦០. ដោយខ្ញុំបានទទួលគ្រោះថ្នាក់ធំៗជាច្រើនដង បាត់បង់ការសន្តោសប្រណីធ្លាក់ទៅក្នុងស្ថាននរកនៃបាបកម្ម ព្រះអម្ចាស់បានស្រោចស្រង់ខ្ញុំ តាមរយៈព្រះមាតាព្រហ្មចារិនីដ៏វិសុទ្ធ និងសប្បុរសបំផុត។

៧០. នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៦៦២ ព្រះអម្ចាស់នៃយើង សព្វព្រះហឫទ័យសន្តោសប្រណីបញ្ជូនជំងឺធំមួយមកឲ្យខ្ញុំ អស់រយៈពេលប្រាំមួយសប្តាហ៍។

៧១. នៅឆ្នាំ ១៦៦៣ តាមរយៈព្រះមាតាដ៏វិសុទ្ធ ព្រះអម្ចាស់នៃយើងបានប្រទានព្រះអំណោយទានដ៏មានតម្លៃមួយដល់យើងជាឈើឆ្កាងយ៉ាងធំធេង ដែលទ្រង់សន្តោសប្រណីឲ្យយើងលី។ គឺជាមរណភាពនៃលោកម៉ង់សុង ជាបងប្រុសជាទីស្រឡាញ់របស់យើង នៅថ្ងៃទី ៦ កុម្ភៈ នៅរូអង់។ លោកជាបុគ្គលដ៏វិសុទ្ធមួយរូបដែលបានបម្រើការងារអស់រយៈពេលជាងម្ភៃឆ្នាំ ដើម្បីសង្គ្រោះព្រលឹង និងបំពេញបេសកកម្មបម្រើព្រះអម្ចាស់។ យើងទទួលដំណឹងមរណភាពរបស់លោកនៅថ្ងៃ ៨ ខែកុម្ភៈ ក្នុងឱកាសបុណ្យព្រះហឫទ័យដ៏វិសុទ្ធរបស់ព្រះនាងព្រហ្មចារិនី ដែលបានលួងលោមចិត្តយើង។

បទទំនុកតម្កើងដើម្បីថ្លែងអរព្រះគុណព្រះជាម្ចាស់មានច្រើន។ ខ្ញុំជ្រើសយកបទមួយដែលបញ្ជាក់អារម្មណ៍

របស់ខ្ញុំនៅពេលនោះ ក្នុងចំណោមបទចម្រៀងដែលមានដូចតទៅនេះ៖ ព្រះអម្ចាស់ជាគង្វាលរបស់ខ្ញុំ (ទន ២២) អស់អ្នកដែលគោរពកោតខ្លាចព្រះជាម្ចាស់ សូមអញ្ជើញមកស្តាប់ខ្ញុំរ៉ាយរ៉ាប់អំពីការអស្ចារ្យរបស់ព្រះអង្គចំពោះរូបខ្ញុំ (ទន ៦៥) តាមប្រវត្តិនៃការសង្គ្រោះ ព្រះជាម្ចាស់បំពេញបន្ទូលសន្យាចំពោះលោកអាប្រាហាំ (ទន ១០៤) ក្នុងប្រវត្តិសាស្រ្តព្រះជាម្ចាស់ស្រោចស្រង់ប្រជាជនរបស់ព្រះអង្គចេញពីវិបត្តិទាំងឡាយ ដែលពួកគេឆ្លងកាត់ (ទន ១០៦)ចូរលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដោយព្រះអង្គ បានរំដោះប្រជាជនរបស់ព្រះអង្គឲ្យផុតពីទាសភាព! សេចក្តីស្រឡាញ់របស់ព្រះអង្គមានអស់កល្បជានិច្ច! (ទន ១៣៥) ឱព្រះជាម្ចាស់អើយ! ព្រះអង្គស្គាល់កូន ហើយសេចក្តីស្រឡាញ់របស់ព្រះអង្គណែនាំកូន(ទន ១៣៨) ព្រះអង្គបំពេញកិច្ចការទាំងអស់ដោយព្រះហឫទ័យអាណិតអាសូរ (ទន ១៤៤)។

## ទុកពេល សម្រាប់ការលើកលែងទោស

១-នៅពេលដែលសន្តៈអូគូស្ទីនត្រួតពិនិត្យជីវិតលោកសាឡើងវិញ លោកពោលថា៖ រាល់ពេលខ្ញុំនឹកគិតដល់ហេតុការណ៍ទាំងអស់ ដែលបានកើតមានឡើងក្នុងជីវិតខ្ញុំ ខ្ញុំតែងតែអរព្រះគុណព្រះជាម្ចាស់! តើយើងអាចនិយាយដូចលោកបានឬទេ?

២- មានការនឹករលឹកខ្លះរបស់យើង ដែលត្រូវការព្យាបាល។ សូមពិនិត្យហេតុការណ៍នោះឡើងវិញ តាមសម្រួលក្រោមក្រសែព្រះនេត្ររបស់ព្រះអង្គជាម្ចាស់ ហើយមើលឲ្យឃើញថា តើឥឡូវនេះយើងរំឭកហេតុការណ៍ទាំងអស់នោះយ៉ាងដូចម្តេច? តើយើងគួរលើកលែងទោសឲ្យនរណា?

កូនសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រព្រឹត្តកិច្ចការ តាមរយៈហេតុការណ៍ទាំងឡាយ ដែលកើតមានក្នុងជីវិតរបស់កូន ទោះជាបានឆ្លងកាត់ការឈឺចុកចាប់ខ្លាំងក៏ដោយ។ កូនសូមឲ្យព្រះអង្គជួយព្យាបាលអ្វីៗដែលត្រូវការ សូមឲ្យខ្ញុំបានជាសះស្បើយ...សូមព្រះអង្គជួយឲ្យកូនសម្រុះសម្រួលនឹងជីវិតរបស់កូន។

## ទុកពេល ដើម្បីថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- ដោយត្រួតពិនិត្យជីវិតសាជាថ្មី តើយើងយល់ឃើញថា តើព្រះអម្ចាស់ត្រាស់ហៅយើងយ៉ាងណាខ្លះ? តើអត្ថបទនៃព្រះបន្ទូលព្រះជាម្ចាស់ណាខ្លះ ដែលមកបំភ្លឺជីវិតយើងនេះ ហើយត្រាស់ហៅយើងឲ្យទៅមុខ?

២-ការទទួលស្គាល់សប្បុរសធម៌របស់ព្រះជាម្ចាស់ ជំរុញឲ្យយើងប្រព្រឹត្តកិច្ចការចំពោះបងប្អូន ព្រោះមានតែតាមរយៈពួកគាត់ទេ ទើបយើងអាចបង្ហាញបញ្ជាក់បានល្អជាងគេថា យើងអរព្រះគុណព្រះអម្ចាស់។ អ្នករាល់គ្នាបានទទួលដោយឥតបង់ថ្លៃ ចូរឲ្យទៅវិញដោយមិនគិតថ្លៃ (មថ ១០,៨)។យើងដឹងថា យើងបានទទួលអ្វីៗជាច្រើន ត្រូវគិតថា តើធ្វើដូចម្តេចដើម្បីអាចសងនូវអ្វីៗ ដែលយើងបានទទួលយ៉ាងច្រើននោះឲ្យទៅអ្នកឯទៀត?

ខ្ញុំកត់ចូលសៀវភៅកំណត់ហេតុរបស់ខ្ញុំ ដោយយកគំរូតាមសន្តៈយ៉ូហាន អើដ...
ដើម្បីនឹករលឹកដល់ព្រះអម្ចាស់ ដូចព្យាការីអេសាយធ្លាប់និយាយដែរ (៦២,៦-៧)។

### ខ្ញុំបានចាក់ឫសក្នុងអង្គព្រះអង្គ

១- ព្រះអម្ចាស់អើយ ពេលនៅឯកោ ខ្ញុំម្ចាស់បានចាក់ឫស ក្នុងចិត្តរបស់ខ្ញុំ

| | | | | |
|---|---|---|---|---|
| | ព្រះអម្ចាស់អើយ | ពេលនៅឯកោ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ។ |
| ២- | ព្រះអម្ចាស់អើយ | ពេលជួបជុំគ្នា | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលជួបជុំគ្នា | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ។ |
| ៣- | ព្រះអម្ចាស់អើយ | ពេលស្រឡាញ់ខ្លាំង | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលស្រឡាញ់ខ្លាំង | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ។ |
| ៤- | ព្រះអម្ចាស់អើយ | ពេលឆ្លងកាត់ឧបសគ្គធំៗ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលឆ្លងកាត់ឧបសគ្គធំៗ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |
| ៥- | ព្រះអម្ចាស់អើយ | ពេលព្រះអង្គមិននៅ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលព្រះអង្គមិននៅ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |
| ៦- | ព្រះអម្ចាស់អើយ | ពេលព្រះអង្គយាងមក | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលព្រះអង្គយាងមក | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |
| ៧- | ព្រះអម្ចាស់អើយ | ពេលបាត់ព្រះអង្គយូរ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលបាត់ព្រះអង្គយូរ | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |
| ៨- | ព្រះអម្ចាស់អើយ | ពេលព្រះអង្គមានព្រះបន្ទូល | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលព្រះអង្គមានព្រះបន្ទូល | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |
| ៩- | ព្រះអម្ចាស់អើយ | ពេលមានក្តីសង្ឃឹម | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងចិត្តរបស់ខ្ញុំ |
| | ព្រះអម្ចាស់អើយ | ពេលមានក្តីសង្ឃឹម | ខ្ញុំម្ចាស់បានចាក់ឫស | ក្នុងព្រះហឫទ័យព្រះអង្គ ។ |

# ជួបព្រះយេស៊ូ

ច្បាស់ជាបំណងរបស់យើង ការខិតខំ និងកិច្ចការសំខាន់ៗរបស់យើងហើយ
ទើបព្រះយេស៊ូយាងមកសណ្ឋិតក្នុងចិត្តយើង

## ដំណាក់កាលទី ៣

ព្រះគ្រូ! តើព្រះអង្គគង់នៅទីណា?
សូមអញ្ជើញមក អ្នកនឹងឃើញ (យហ ១,៣៨)

**ក្នុងដំណាក់កាលនេះមាន៖** សាវ័កចាប់ផ្តើមស្តាប់លោកគ្រូម្នាក់។ ធ្វើជាសាវ័ករបស់ព្រះយេស៊ូ គឺត្រូវប្រុងប្រៀបស្តាប់អ្នកដែលយើងហៅថា ជាផ្លូវនៃសេចក្តីពិត និងជាជីវិត។ សាវ័កម្នាក់ៗត្រូវមានអាកប្បកិរិយាចម្បងគឺស្តាប់ព្រះអង្គប៉ុន្តែត្រូវមានចិត្តស្អាតស្មោះត្រង់មិនក្លែងបន្លំ។ ព្រះយេស៊ូអញ្ជើញខ្ញុំឲ្យមក និងឃើញជំបូងក្នុងព្រះរាជ្យព្រះអង្គ បន្ទាប់មកក្នុងពិភពលោកដែលនៅជុំវិញខ្លួនខ្ញុំ ដើម្បីរកឲ្យឃើញព្រះវត្តមានរបស់ព្រះអង្គ។

**គោលដៅនៃដំណាក់កាលនេះ៖** ជួបព្រះយេស៊ូក្នុងដំណឹងល្អ «ក្លាយទៅជាសាវ័ករបស់ព្រះអង្គ។

**១- អានគម្ពីរដំណឹងល្អមួយ**

...អានដំណឹងល្អតាមសន្តៈម៉ាកុស ដែលនាំខ្ញុំឲ្យមានទំនាក់ទំនងជាមួយយេស៊ូ គឺម្នាក់ទៀតនៅចំពោះមុខខ្ញុំ...ខ្ញុំបណ្តោយចិត្តឲ្យជួប និងភ្ញាក់ផ្អើលដោយសារព្រះយេស៊ូនៅក្នុងគម្ពីរដំណឹងល្អនោះ តើបុរសនេះទាក់ទាញចិត្តខ្ញុំដោយសារអ្វី?

**២- ក្លាយទៅជាសាវ័កម្នាក់**

...រិះគិតអំពីអស់អ្នកដែលព្រះយេស៊ូបានទាក់ទាញចិត្ត (ពួកសាវ័ក)។ សព្វថ្ងៃខ្ញុំបណ្តោយឲ្យព្រះអង្គទាក់ទាញចិត្តដូចពួកគេដែរ។
នៅទីបញ្ចប់នៃដំណាក់កាលនេះ ខ្ញុំអាចរៀបរាប់អំពីមូលហេតុអ្វីខ្លះ ដែលធ្វើឲ្យខ្ញុំក្លាយទៅជាសាវ័ករបស់ព្រះយេស៊ូ ។

**ទុកពេល សម្រាប់បើកចិត្ត និងទទួលយក**

១- ទៅជួបអ្នកដទៃ...សួរខ្លួនឯងទៅតាមសម្រួលថា តើយើងបានជួបនរណា តើការជួបគ្នានោះប្រព្រឹត្តិទៅយ៉ាងដូចម្តេច? សរសេរឈ្មោះអស់អ្នកដែលយើងបានជួបនៅសប្តាហ៍ចុងក្រោយនេះ។ នៅពេលជួបគេ

តើមានអ្វីខ្លះដែលយើងស្រឡាញ់...ស្រឡាញ់តិច...ឬឥតស្រឡាញ់សោះ ?

២- យើងត្រិះរិះអំពីការជួបនេះទៅតាមសម្រួល...សួរខ្លួនឯងថា តើតាមធម្មតា ខ្ញុំពិនិត្យទំនាក់ទំនងរបស់ខ្ញុំឡើងវិញឬទេ ? តើការជួបទាំងអស់នោះ ប្រែរបៀបរស់នៅ របៀបទាក់ទងជាមួយអ្នកដទៃយ៉ាងដូចម្ដេច ?

៣- តើយើងរង់ចាំអ្វី នៅពេលជួបគេ ?

៤- នៅពេលជួបគេ តើមានអ្វីពិបាក ?

ខ្ញុំទទួលយកអ្វីៗដែលខ្ញុំត្រិះរិះដោយមិនបាច់វិនិច្ឆ័យទេ ខ្ញុំទទួលយកអ្នកដទៃ ដោយមិនគិតពីខ្លួនឯង ទោះជាខ្ញុំខ្លាចមិនទុកចិត្ត ឬចង់ការពារខ្លួនខ្ញុំយ៉ាងណាក៏ដោយ...កុំឲ្យខ្ញុំទៅជាឈ្លើយនៃការភ័យខ្លាចរបស់ខ្ញុំ...

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- អានដំណឹងល្អតាមសន្តៈម៉ាកុស។ អានម្ដងមួយផ្នែកៗដោយព្យាយាមជួបព្រះយេស៊ូ ដែលពួកសាវ័កក៏បានជួបដែរ...ដូចនរណាម្នាក់ដែលឈរពីមុខយើង ហើយដែលយើងចង់ស្គាល់។

២- ឈប់ពីមុខអ្វីដែលជាលក្ខណៈទាក់ទាញរបស់ព្រះយេស៊ូ ហើយកត់ត្រាទំនាក់ទំនងទាំងអស់រវាងព្រះយេស៊ូ និងព្រះបិតា ព្រះយេស៊ូ និងមាតាព្រះអង្គ ព្រះយេស៊ូ និងសាវ័កព្រះយេស៊ូ និងអស់អ្នកដែលមកសូមឲ្យព្រះអង្គជួយព្យាបាលគេ... តើយើងដូចជាតួអង្គណាមួយ...? កុំនិយាយស្ដី ហើយសញ្ជឹងគិតនៅក្នុងចិត្តអំពីតួអង្គណាមួយ ដែលយើងជ្រើសរើសយក ពីព្រោះយើងមើលស្គាល់តួអង្គនោះ តាមរយៈអាកប្បកិរិយានៃសាវ័កដែលយើងពេញចិត្ត គួរតែធ្វើតាម។

៣- សន្តៈយ៉ូហានអើដ បានសញ្ជឹងគិតអំពីភាពជាមនុស្សរបស់ព្រះយេស៊ូ តាមរយៈការអានព្រះគម្ពីរដំណឹងល្អជាគន្លឹះដ៏សំខាន់មួយនៃជីវិតជាគ្រីស្តបរិស័ទ។ ដើម្បីក្លាយទៅជាគ្រីស្តបរិស័ទ បូរយើងក្រឡេកមើលទៅព្រះយេស៊ូយ៉ាងលម្អិត ហើយបណ្ដោយខ្លួនឲ្យជ្រួតជ្រាបទៅ ដោយនឹកគិតដល់ព្រះបន្ទូល និងកាយវិការរបស់ព្រះអង្គ... ដើម្បីបង្ហើយកិច្ចការរបស់ព្រះអង្គមកក្នុងជីវិតរបស់យើង។

## អានអត្ថបទដូចតទៅ ៖

ដោយខ្លួនខ្ញុំនៅជាមួយព្រះបិតា ទទួលជីវិតពីព្រះជន្មព្រះអង្គ ដែលបញ្ជូលមកឲ្យខ្ញុំ អ្នករាល់គ្នាក៏ស្ថិតនៅជាមួយខ្ញុំដែរ រស់នៅដោយជីវិតខ្ញុំ ហើយខ្ញុំស្ថិតនៅក្នុងអ្នករាល់គ្នា ដោយបញ្ជូនជីវិតនេះទៅអ្នករាល់គ្នា...

ព្រះយេស៊ូជាព្រះបុត្រានៃព្រះជាម្ចាស់ និងជាបុត្ររបស់មនុស្ស ព្រះមហាក្សត្ររបស់មនុស្សលោក និងរបស់ទេវទូតទាំងឡាយ ព្រះអង្គមិនគ្រាន់តែជាព្រះជាម្ចាស់ ព្រះសង្គ្រោះ ព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតរបស់យើងទេ ព្រះអង្គក៏ជាអ្នកដឹកនាំយើងដែលជាអវយវៈ និងជាព្រះកាយរបស់ព្រះអង្គ ដូចសន្តៈប៉ូលធ្លាប់និយាយ (អភ ៥,៣០) ហេតុនេះហើយបានជាយើងដែលរួបរួមជាមួយព្រះអង្គយ៉ាងជិតស្និទ្ធបំផុត ដូចជាសមាជិករួបរួមជាធ្លុងមួយនឹងមេដឹកនាំរបស់ខ្លួន យើងរួបរួមចិត្តគំនិតជាមួយព្រះអង្គដោយសារជំនឿ និងចិត្តមេត្តាករុណា ដែលព្រះអង្គបានប្រោសប្រទានមកយើង តាមរយៈអគ្គសញ្ញាជ្រមុជទឹក យើងរួមរស់ជាមួយព្រះអង្គ ដោយរូបកាយយើងទទួលព្រះកាយ ដ៏វិសុទ្ធរបស់ព្រះអង្គ តាមរយៈអភិបូជាដ៏វិសុទ្ធ។ យើងចាំបាច់ត្រូវតែបំពេញកិច្ចការទាំងពួង ទៅតាមព្រះវិញ្ញាណព្រះអង្គរស់នៅក្នុងព្រះជន្មព្រះអង្គ ដើរតាមមាគ៌ារបស់ព្រះអង្គដោយមានអារម្មណ៍ និងបំណងប្រាថ្នារបស់ព្រះអង្គបំពេញកិច្ចការទៅតាមតម្រូវការ និងព្រះបំណងរបស់ព្រះអង្គ។ និយាយឲ្យចំទៅ

យើងត្រូវបន្ត និងបំពេញគោលដៅនៃជីវិតយ៉ាងខ្ជាប់ខ្ជួន ទៅតាមការណែនាំកន្លងមករបស់ព្រះអង្គនៅលើផែនដីនេះ ឲ្យដូចជាសមាជិកដែលបំពេញកិច្ចការតាមការចាត់ចែងរបស់មេ និងរស់នៅជាមួយនឹងមេដឹកនាំរបស់ខ្លួនដូច្នោះដែរ។

**សំណើរនេះ ចាក់ឫសលើព្រះបន្ទូលដ៏វិសុទ្ធផ្ទាល់របស់ព្រះនៃសេចក្ដីពិត ៖** ខ្ញុំជាជីវិត ហើយខ្ញុំមកនេះដើម្បីឲ្យអ្នករាល់គ្នាមានជីវិត ខ្ញុំមានព្រះជន្មរស់នៅ អ្នករាល់គ្នាក៏នឹងមានជីវិតរស់នៅដែរ។ នៅថ្ងៃនោះ អ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅជាមួយព្រះបិតាខ្ញុំ ឯអ្នករាល់គ្នានៅជាមួយខ្ញុំ ហើយខ្ញុំនៅជាមួយអ្នករាល់គ្នាដែរ ( យហ ១៤,៦ ; ១០, ១០ ; ១៤,១៩-២០ )។ មានន័យថា ដោយខ្ញុំនៅជាមួយព្រះបិតាខ្ញុំ ខ្ញុំមានជីវិតដោយសារព្រះជន្មព្រះអង្គដែល ទ្រង់បញ្ជូនមកឲ្យខ្ញុំ អ្នករាល់គ្នាក៏ដូច្នោះដែរ អ្នករស់នៅក្នុងព្រះជន្មរបស់ខ្ញុំ ហើយខ្ញុំវិញក៏រស់នៅជាមួយអ្នករាល់គ្នាដែរ ដោយបញ្ជូនជីវិតតែមួយនេះ។ ដូច្នេះហើយខ្ញុំមានព្រះជន្មរស់នៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាក៏នឹងរស់នៅជាមួយខ្ញុំដែរ។

អត្ថបទដ៏វិសុទ្ធទាំងអស់នោះ បង្ហាញឲ្យយើងដឹងថា ព្រះយេស៊ូគ្រីស្តត្រូវតែមានព្រះជន្មនៅក្នុងយើង យើងត្រូវតែរស់នៅក្នុងអង្គព្រះអង្គ ជីវិតរបស់យើងគឺជាការបន្តនូវកិច្ចការរបស់ព្រះអង្គ នឹងជាការបង្ហាញឲ្យដឹងអំពីព្រះជន្មរបស់ព្រះអង្គ។

ដូចដែលសន្តៈប៉ូលបានបញ្ជាក់ប្រាប់យើងថា លោកបានបំពេញទុក្ខលំបាករបស់ព្រះយេស៊ូគ្រីស្ត ដូច្នោះតាមការពិតយើងអាចនិយាយថា គ្រីស្តបរិស័ទដ៏ពិតប្រាកដម្នាក់ជាអវយវៈរបស់ព្រះយេស៊ូគ្រីស្ត ហើយរួបរួមជាមួយព្រះអង្គ ដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ គេបន្ត និងបំពេញរាល់កិច្ចការដែលព្រះយេស៊ូគ្រីស្តបានបំពេញ ក្នុងវេលាដែលព្រះអង្គមានព្រះជន្មនៅលើផែនដី។ ដូច្នេះក្នុងពេលអធិដ្ឋានទាល់តែគ្រីស្តបរិស័ទម្នាក់ៗបន្ត និងបំពេញកិច្ចការទៅតាមការអធិដ្ឋានរបស់ព្រះយេស៊ូគ្រីស្ត កាលដែលព្រះអង្គមានព្រះជន្មនៅលើផែនដីនេះ។ នៅពេលដែលគ្រីស្តបរិស័ទធ្វើការ គាត់បន្ត និងធ្វើឲ្យព្រះជន្មដ៏ឧស្សាហ៍ព្យាយាមនៃព្រះយេស៊ូគ្រីស្តបានសម្រេច ព្រមទាំងកិច្ចការផ្សេងៗទៀត ដែលគ្រីស្តបរិស័ទត្រូវបំពេញ។

តាមរយៈនេះ អ្នកមើលឃើញថា ជីវិតជាគ្រីស្តបរិស័ទ គឺជាការបន្ត និងការបង្ហើយកិច្ចការរបស់ព្រះយេស៊ូកិច្ចការរបស់យើងទាំងអស់ ត្រូវតែជាកិច្ចការបន្តនៃកិច្ចការរបស់ព្រះយេស៊ូ យើងត្រូវតែធ្វើខ្លួនឲ្យដូចព្រះយេស៊ូគង់នៅលើផែនដី ដើម្បីបន្តព្រះជន្មព្រះអង្គនៅលើផែនដីនេះ បន្តស្នាព្រះហស្តព្រះអង្គ និងរងទុក្ខលំបាកទៅតាមព្រះហឫទ័យព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណនៃព្រះយេស៊ូ បានសេចក្ដីថា ដូចកាលព្រះយេស៊ូបានបំពេញកិច្ចការ និងរងទុក្ខលំបាកដូច្នោះដែរ។

ដោយអានអត្ថបទរបស់សន្តៈយ៉ូហាន អើងនេះ ខ្ញុំរិះគិតទៅដល់អាកប្បកិរិយាពិតប្រាកដនៃសាវ័ក ដែលខ្ញុំអាចធ្លាប់ឃើញក្នុងគម្ពីរដំណឹងល្អតាមសន្តម៉ាកុសនេះ ហើយក្នុងអត្ថបទនេះ ខ្ញុំអាចថ្លែងអំណរគុណដល់សាវ័កទាំងអស់នោះ ដែលសម្ដែងឲ្យខ្ញុំដឹងថា កាលនោះពួកលោកបានជួបនឹងព្រះគ្រីស្តយ៉ាងដូចម្ដេច។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ចំពោះព្រះយេស៊ូ សាវ័ករបស់ព្រះអង្គជាអ្នកស្ដាប់ព្រះបន្ទូលព្រះអង្គ ហើយយកមកអនុវត្ត...ពេលខ្លះព្រះបន្ទូលនេះ រំខានហើយនាំឲ្យអ្នកខ្លះនិយាយថា យល់ស្របពិតមែនហើយ ព្រះអង្គមានព្រះបន្ទូលអំពីជីវិត

អស់កល្បជានិច្ច! ឯអ្នកខ្លះទៀតឆ្លើយថា ទេ! មិនយល់ស្រប តើលោកធ្វើទីសម្គាល់មួយណា ដើម្បីឲ្យខ្ញុំអាចជឿលោកបាន? ចុះយើងវិញ តើយើងគួរឆ្លើយដូចម្ដេចសព្វថ្ងៃ?

២- ពិចារណាសាឡើងវិញ អំពីពេលជួបអ្នកដទៃ អំពីរបៀបដែលយើងទាក់ទងគ្នា រាល់ពេលយើងបានជួបគ្នា? ថែមទាំងពិចារណាថា តើយើងមិនព្រមជួបនឹងព្រះគ្រីស្តនៅពេលណាយ៉ាងដូចម្ដេច?

ខ្ញុំបណ្ដោយខ្លួនឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយប្រសាសន៍របស់សន្តៈយ៉ូហាន អើដចូលជ្រាបក្នុងដួងចិត្តខ្ញុំនេះ ហាក់ដូចជាទទួលអញ្ជើញខ្ញុំឲ្យធ្វើតាមលោក ដើម្បីក្លាយទៅជាសាវ័ក។ ខ្ញុំគ្រាន់តែសូមឲ្យព្រះបិតាលើកលែងទោសខ្ញុំចំពោះចិត្តរឹងរូស ដែលខ្ញុំមិនព្រមឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះបុត្រាព្រះអង្គ រហូតបន្តដល់ថ្ងៃនេះ។ ខ្ញុំបើកចិត្តទូលាយទទួលព្រះវិញ្ញាណ ដែលមានព្រះបំណងឲ្យខ្ញុំស្គាល់ព្រះអំណោយទានរបស់ព្រះបិតាដើម្បីឲ្យខ្ញុំអាចដើរតាមព្រះអង្គ។ ខ្ញុំសូមថ្វាយនូវការខ្វះខាតទាំងឡាយណាដែរខ្ញុំបានធ្វើកន្លងមក។

**ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...**

១- ក្រោយពីបានអានដំណឹងល្អតាមសន្តៈម៉ាកុស តើយើងអាចនិយាយបានថា យើងបានបណ្ដោយខ្លួនឲ្យជាប់ចិត្តជាមួយព្រះយេស៊ូឬនៅ? តើយើងបានរកឃើញអាកប្បកិរិយានៃពួកសាវ័កខ្លះ ដែលអាចប្រដូចមកអាកប្បកិរិយាយើងបានឬទេ?

២- រៀបរាប់អំពីមូលហេតុ ដែលនាំឲ្យទៅជាសាវ័ករបស់ព្រះយេស៊ូ?

៣-តើគ្មានចំណុចជាក់លាក់ណាមួយនៃជីវិតរបស់យើង ដែលគួរតែអាចសមស្របទៅនឹងសាវ័កដែលបានស្រឡាញ់ចាប់ពីពេលនេះទៅទេឬ?

ឱព្រះយេស៊ូអើយ! ព្រះអង្គដែលមានព្រះជន្មគង់នៅក្នុងព្រះនាងម៉ារី! សូមយាងមក ហើយគង់ជាមួយអ្នកបម្រើ របស់ព្រះអង្គ ក្នុងភាពដ៏វិសុទ្ធនៃព្រះវិញ្ញាណព្រះអង្គ។ ដោយឫទ្ធានុភាពសព្វប្រការ មាគ៌ាដ៏ល្អឥតខ្ចោះសេចក្ដីពិតនៃគុណធម៌ សូមព្រះអង្គជួយបង្ក្រាបសត្រូវកំណាច ដែលតែងតែមកយាយីយើង ដើម្បីឲ្យពួកយើងបានជ្រកកោនក្រោមម្លប់នៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គផង ដើម្បីឲ្យព្រះបិតាពោរពេញទៅដោយសិរីរុងរឿង។

# ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់

ព្រះយេស៊ូដ៏សប្បុរសអើយ! សូមព្រះអង្គបើកត្រចៀកខ្ញុំម្ចាស់
ដើម្បីបានស្តាប់ព្រះបន្ទូល និងព្រះសូរសៀងរបស់ព្រះអង្គផង!

## ដំណាក់កាលទី ៤

អ្នកដែលស្រឡាញ់ខ្ញុំនឹងរក្សាទុកព្រះបន្ទូលរបស់ខ្ញុំ (យហ ១៤,២៣)

**ក្នុងដំណាក់កាលនេះ** ៖ ធ្វើជាសាវ័ក គឺចង់ស្គាល់ព្រះយេស៊ូ មានន័យថា ចង់ស្គាល់ចិត្តគំនិតព្រះអង្គ។ លើសពីនេះទៅទៀត ត្រូវស្រេកឃ្លានព្រះបន្ទូលព្រះអង្គ ដែលបង្ហាញប្រាប់យើងនូវព្រះហឫទ័យពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះបិតា។ ខ្ញុំអាចស្គាល់ចិត្តគំនិត អ្នកណាម្នាក់ទាល់តែខ្ញុំស្តាប់គេនិយាយ។ ស្តាប់ព្រះបន្ទូល...អនុវត្តតាមព្រះបន្ទូល ...

**គោលដៅនៃដំណាក់កាលនេះ** ៖ រៀនស្តាប់ព្រះបន្ទូល (ព្រះគម្ពីរ) បណ្តោយខ្លួនឲ្យស្តាប់ព្រះបន្ទូល។ ស្តាប់...មានន័យថា បើកត្រចៀកបែរទៅរកសំឡេងមកពីណា ធ្វើតាម... មានន័យថា ស្តាប់បង្គាប់។

...ព្រះបន្ទូលនេះ គឺជាសម្តីរបស់នរណាម្នាក់៖ ព្រះយេស៊ូ...ព្រះអង្គមានព្រះបន្ទូលតាមរយៈព្រះគម្ពីរ និងតាមរយៈហេតុការណ៍ដែលកើតមាននៅក្នុងជីវិតដែរ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចប្រើប្រាស់ព្រះគម្ពីរ ដើម្បីប្រុងប្រៀបស្តាប់ព្រះបន្ទូលព្រះជាម្ចាស់។

### ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- ពាក្យសម្តីដែលបំភ្លឺ...កាលណាយើងចង់ដឹងអំពីអត្ថន័យនៃហេតុការណ៍មួយ ដែលយើងជួបប្រទះ តើយើងទៅរកពាក្យសម្តីអ្វី ដើម្បីបំភ្លឺឲ្យយើងយល់? ទៅរកក្នុងធម្មជាតិក្នុងសិល្បៈក្នុងសៀវភៅផ្សេងៗ? ទៅរកមិត្តភ័ក្តិ ព្រះគម្ពីរយើងអធិដ្ឋាន? ស្វង់មើលបទពិសោធន៍ផ្ទាល់ខ្លួនយើង។

២- ពាក្យសម្តី និងទំនាក់ទំនង... កត់ទុកពាក្យសម្តីដែលយើងឮពេញមួយថ្ងៃ (គ្រួសារ ការងារ ព័ត៌មាន) យើងពិនិត្យឃើញថា យើងអាចជ្រើសរើសខ្លះបានភ្លាមៗ ខ្លះអត់។ តើយើងយកចិត្តទុកដាក់លើពាក្យសម្តីណាខ្លះ?

៣- ពាក្យសម្តី និងជីវិត ៖ តាំងពីទើបនឹងកើតមក កុមារស្តាប់ឮគេនិយាយ ហើយមានបំណងចង់មានទំនាក់ទំនងជាមួយអ្នកនៅជុំវិញខ្លួនដែរ។ពាក្យសម្តីសម្តែងនូវសេចក្តីស្រឡាញ់ និងតម្រូវការដែលនាំឲ្យគេបេះ

ដឹង។ ត្រូវនឹកឡើងវិញតាមសម្រួល៖

❍ ក្នុងជីវិតរបស់ខ្ញុំ សម្ដីណាខ្លះដែលបានជួយខ្ញុំឲ្យចេះដឹងឲ្យទៅមុខ?

❍ តើខ្ញុំបានរកឃើញថា សម្ដីរបស់ខ្ញុំបានជួយអ្នកណាម្នាក់ដែរឬទេ?

៤- **ព្រះបន្ទូលព្រះជាម្ចាស់** ៖ នៅក្នុងព្រះគម្ពីរដំណឹងល្អ តើមានព្រះបន្ទូលណាខ្លះដែលយើងចាំត់មាត់ដែរឬទេ? ត្រូវកត់ទុកហើយរកមើលក្នុងព្រះគម្ពីរឡើងវិញ។ ត្រូវស្ដាប់ព្រះបន្ទូលព្រះអម្ចាស់តាមរយៈពាក្យសម្ដីទាំងអស់។

ខ្ញុំទទួលព្រះបន្ទូលព្រះយេស៊ូ ទៅតាមសម្រួល
ខ្ញុំទន្ទេញព្រះបន្ទូលចាំត់មាត់
ខ្ញុំស្ដាប់ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ

**ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ**

១- ទូលបង្គំស្ដាប់ តើព្រះអម្ចាស់នឹងមានព្រះបន្ទូលមកទូលបង្គំយ៉ាងណាខ្លះ? ចំពោះសាវ័កម្នាក់ពេលយើងអានព្រះគម្ពីរ យើងក៏យល់ឃើញថា ព្រះជាម្ចាស់មានព្រះបន្ទូលមកយើង។

«ព្រះជាម្ចាស់មានព្រះបន្ទូល» ប្រយោគនេះ ប្រាប់យើងឲ្យដឹងអំពីព្រះជាម្ចាស់ផង មនុស្សផង...ជាគម្រោងការដ៏អស្ចារ្យ ពោរពេញទៅដោយសេចក្ដីស្រឡាញ់...ព្រះជាម្ចាស់ចងសម្ពន្ធមេត្រី។

ក្រោយពីព្រះជាម្ចាស់មានព្រះបន្ទូលជាច្រើនលើកច្រើនសា និងតាមរបៀបផ្សេងៗទៅកាន់បុព្វបុរសយើងកាលពីមុន តាមរយៈពួកព្យាការីជាច្រើននាក់ ព្រះអង្គមានព្រះបន្ទូលមកយើងតាមរយៈព្រះបុត្រាព្រះអង្គ (ហប ១,១-២)។

រកអត្ថន័យនៃពាក្យដំណឹងល្អ ហើយប្រុងប្រៀបស្ដាប់ព្រះបន្ទូលព្រះយេស៊ូគ្រីស្ត។

២- អ្នកដែលមានត្រចៀកសម្រាប់ស្ដាប់ សូមស្ដាប់! (លក ១៤,៣៥) សាវ័កត្រូវស្ដាប់ព្រះយេស៊ូ ដែលព្រះអង្គផ្ទាល់ ជាព្រះបន្ទូលដែលព្រះជាម្ចាស់ប្រោសប្រទាន។ សូមអានជំពូកទីមួយនៃដំណឹងល្អតាមសន្ដះយ៉ូហាន រហូតដល់(ខទី ៨) ហើយកត់ទុកអ្វីដែលយើងបានរកឃើញ។

៣- ក្នុងដំណឹងល្អ ព្រះយេស៊ូសម្ដែងឲ្យយើងដឹងថា អ្នកណាជាព្រះជាម្ចាស់ ហើយធ្វើយ៉ាងណា ដើម្បីមានរបៀបរស់នៅដូចបុត្រធីតារបស់ព្រះជាម្ចាស់។

## ព្រះអង្គមានព្រះបន្ទូលមកយើង

- តាមរយៈការប្រៀនប្រដៅរបស់ព្រះអង្គ (មថ ១៣ ; លក ៦,១៧-៤៩ ; លក ១២,១៣-១៤ ; លក ១៥)
- តាមរយៈកាយវិការ ការអស្ចារ្យផ្សេងៗ និងរបៀបរស់នៅរបស់ព្រះអង្គ (មក ១,២១-៤៥ ; លក ៧,៣៦-៥០)

៤- សាវ័កស្ដាប់ព្រះបន្ទូល ហើយយកមកអនុវត្ត (មក ៧,២៤-២៧)

៥- ដូច្នោះ សាវ័កចូលទៅក្នុងសម្ពន្ធមេត្រីជាមួយព្រះជាម្ចាស់ ព្រមទាំងក្រុមគ្រួសារព្រះយេស៊ូទៀតផង (មក ៣,៣១-៣៥)។

**សូមយកពេលវេលាស្ញឹងស្មាធិ៍អំពីអត្ថបទណា ដែលយើងចាប់អារម្មណ៍។**

៦- សន្តៈយ៉ូហាន អើដ ចូលចិត្តមានប្រសាសន៍ថា៖ សូមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដឹកនាំយើងគ្រប់កិច្ចការទាំងអស់។ ពេលយើងស្ដាប់ព្រះបន្ទូល យើងអនុវត្តតាមដោយមានចិត្តស្រឡាញ់ និងដោយជឿទុកចិត្តចំពោះអ្នកដែលមានបន្ទូលមកយើង ពីព្រោះព្រះអង្គស្រឡាញ់យើង ហើយមានព្រះហឫទ័យចង់ចងសម្ពន្ធមេត្រីជាមួយយើង។ ពេលយើងស្ដាប់ព្រះបន្ទូល យើងគោរពតាមព្រះបំណងព្រះជាម្ចាស់។ ព្រះអង្គហៅគ្រីស្តបរិស័ទទាំងអស់ឲ្យសញ្ជឹងគិត ហើយត្រាប់តាមព្រះយេស៊ូដែលគោរពតាមព្រះបន្ទូលរបស់ព្រះបិតាព្រះអង្គ។

ការស្ដាប់បង្គាប់ ដែលយើងត្រូវធ្វើជានិច្ច តាមព្រះបំណងដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ គឺជាគុណធម៌សកលជាងគេ ហើយដែលយើងធ្លាប់តែប្រើប្រាស់ជាធម្មតា ពីព្រោះគ្រប់ពេលមានឱកាស ឲ្យយើងលះបង់បំណងផ្ទាល់ខ្លួនរបស់យើង ដើម្បីស្ដាប់បង្គាប់តាមព្រះបំណងព្រះជាម្ចាស់។

តាំងពីព្រះអង្គនៅវ័យក្មេង ហើយយាងមកជួបមនុស្សទាំងឡាយ ព្រះយេស៊ូជាអម្ចាស់នៃយើងបានសន្យាថា មិនធ្វើអ្វីតាមព្រះបំណងព្រះអង្គផ្ទាល់ទាល់តែសោះ ប៉ុន្តែព្រះអង្គបំពេញកិច្ចការផងទាំងពួង ទៅតាមព្រះបំណងរបស់ព្រះបិតាព្រះអង្គ។ នេះជាសក្ខីភាពដ៏ពិតប្រាកដមួយ ដែលសន្តៈប៉ូលសរសេរប្រាប់ទៅពួកហេប្រឺ៖ ព្រះយេស៊ូយាងចូលទៅក្នុងពិភពលោកមានព្រះបន្ទូល (ទៅកាន់ព្រះបិតាដែលមានព្រះជន្មអស់កល្បជានិច្ច) ថា ៖ «ទូលបង្គំមកដល់ហើយ ព្រះអម្ចាស់អើយ!» មានចែងទុកមកថា ៖ «ឲ្យទូលបង្គំធ្វើតាមព្រះបំណងរបស់ព្រះអង្គ»។ ខ្ញុំចុះមកពីស្ថានបរមសុខ មិនមែនដើម្បីធ្វើតាមបំណងចិត្តរបស់ខ្ញុំទេ ប៉ុន្តែដើម្បីធ្វើតាមព្រះហឫទ័យរបស់អ្នកដែលបានចាត់ខ្ញុំឲ្យទៅ (ហប ១០,៥ ; យហ ៦,៣៨)។ ដូច្នោះហើយ ព្រះអង្គមិនប្រព្រឹត្តតាមព្រះបំណងរបស់ព្រះអង្គផ្ទាល់ទាល់តែសោះ ទោះជាបំណងនោះវិសុទ្ធ គួរឲ្យស្រឡាញ់យ៉ាងណាក៏ដោយ ព្រះអង្គត្រូវតែលះបង់ និងបំភ្លេចចោលបំណងចិត្តព្រះអង្គ ហើយព្រះអង្គបានប្រតិបត្តិតាមព្រះបំណងរបស់ព្រះបិតាព្រះអង្គវិញ។ ឱ! ព្រះបិតាអើយ! សូមឲ្យបានសម្រេចមិនមែនតាមបំណងចិត្តរបស់ទូលបង្គំទេ ប៉ុន្តែសូមឲ្យបានសម្រេចតាមព្រះហឫទ័យព្រះអង្គចុះ (លក ២២,៤២)។

នេះហើយជាការស្ដាប់បង្គាប់របស់គ្រីស្តបរិស័ទ គឺចេះបន្តការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណៈ ដែលព្រះយេស៊ូគ្រីស្តបានប្រតិបត្តិតាម មិនត្រឹមតែប្រតិបត្តិតាមព្រះបំណងរបស់ព្រះបិតា ដែលព្រះអង្គប្រកាសដោយអង្គឯងនោះទេ ថែមទាំងបំណងរបស់ព្រះមាតាដ៏វិសុទ្ធ សន្តៈយ៉ូសែប ទេវទូតដែលនាំព្រះអង្គទៅស្រុកអេស៊ីប ជនជាតិយូដា ស្ដេចហេរ៉ូដ និងលោកពីឡាតបំណងទាំងអស់នោះ ដែលសម្ដែងព្រះហឫទ័យព្រះបិតា ក៏ព្រះអង្គប្រតិបត្តិតាមដែរ។ ព្រោះព្រះអង្គមិនគ្រាន់តែស្ដាប់បង្គាប់ព្រះបិតាព្រះអង្គប៉ុណ្ណោះទេ ព្រះអង្គដាក់ព្រះកាយចុះចូលក្រោមសត្វលោកទាំងអស់ ដើម្បីសិរីរុងរឿងនៃព្រះបិតាព្រះអង្គ និងដោយសារព្រះអង្គស្រឡាញ់ដល់យើងដែរ។

ព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង មិនគ្រាន់តែប្រតិបត្តិតាមព្រះហឫទ័យព្រះបិតាប៉ុណ្ណោះទេ ព្រះអង្គស្ដាប់បង្គាប់ព្រះបិតា ហើយនឹងអ្វីៗទាំងអស់ ដោយសារព្រះអង្គស្រឡាញ់ព្រះបិតា។ លើសពីនេះទៅទៀត ព្រះអង្គសប្បាយព្រះហឫទ័យនឹងប្រព្រឹត្តតាម។ ព្រះអង្គមានព្រះបន្ទូលថា៖ អាហាររបស់ខ្ញុំ គឺឲ្យខ្ញុំគាប់ព្រះហឫទ័យរបស់អ្នកដែលបានចាត់ខ្ញុំឲ្យមក (យហ ៤,៣៤) គឺខ្ញុំគ្មានប្រាថ្នាចង់បានអ្វីជាងគេ ឬត្រេកអរលើអ្វីជាងគេ ក្រៅពីបានគាប់ព្រះហឫទ័យព្រះបិតាខ្ញុំនោះទេ។ តាមការពិតទៅព្រះអង្គបានបំពេញគ្រប់កិច្ចការទាំងអស់ ពោរពេញទៅដោយអំណរសប្បាយ ព្រោះជាព្រះហឫទ័យរបស់ព្រះបិតា។ ពេលព្រះអង្គរងទុក្ខលំបាក ព្រះអង្គពោរពេញទៅដោយអំណរ និងសុភមង្គល ព្រោះព្រះអង្គបំពេញព្រះហឫទ័យព្រះបិតារបស់ព្រះអង្គ។ ហេតុនេះហើយ ថ្ងៃ

ដែលព្រះអង្គរងទុក្ខលំបាក និងចូលទិវង្គត ព្រះវិញ្ញាណដ៏វិសុទ្ធហៅថ្ងៃនោះថា ជាថ្ងៃរីករាយរបស់ព្រះហឫទ័យព្រះអង្គ (បប ៣, ១១)។

ដូចគ្នានេះដែរ ព្រះអង្គបានយល់ឃើញអ្វីៗទាំងអស់ ដែលបានកើតឡើង និងត្រូវកើតឡើងនោះ ព្រះអង្គបានស្ងប់ព្រះហឫទ័យ ដ្បិតព្រះអង្គទតឃើញថា អ្វីៗទាំងអស់នោះ មកពីព្រះហឫទ័យគួរឲ្យស្រឡាញ់របស់ព្រះបិតាព្រះអង្គ។

ជាមួយគ្នានេះដែរ ដើម្បីឲ្យទៅជាគ្រីស្តបរិស័ទ យើងត្រូវស្លៀកដណ្ដប់ទៅដោយអារម្មណ៍របស់មេដឹកនាំរបស់យើង គឺយើងមិនគ្រាន់តែស្ដាប់បង្គាប់ព្រះជាម្ចាស់ និងស្ដាប់បង្គាប់អ្វីៗទាំងអស់ទេ យើងក៏ត្រូវពេញចិត្តនឹងធ្វើតាមការទាំងអស់នោះដែរ។ នេះគឺជាការអធិដ្ឋានប្រចាំថ្ងៃ ដែលយើងទូលអង្វរទៅព្រះជាម្ចាស់៖សូមឲ្យព្រះហឫទ័យព្រះអង្គបានសម្រេចនៅលើផែនដីដូចនៅស្ថានបរមសុខដែរ។

ខ្ញុំមិននិយាយថា អ្នកបានទទួលអំណរចំពោះអ្វីដែលអ្នកបានធ្វើ និងរងទុក្ខលំបាក ព្រមទាំងអ្វីទៀត ដែលកើតមានលើពិភពលោកនេះទេ ពីព្រោះអ្វីៗទាំងនោះជារបស់អ្នកបានសុភមង្គលនៅស្ថានបរមសុខ គឺអ្នកអាចទទួលបានយ៉ាងងាយ ដោយគ្រាន់តែនិយាយថា៖ ព្រះអម្ចាស់អើយ សូមព្រះអង្គមេត្តាឲ្យខ្ញុំម្ចាស់មានបំណងចង់ធ្វើ ឬរងទុក្ខលំបាកសព្វគ្រប់ទាំងអស់ ព្រោះជាព្រះហឫទ័យរបស់ព្រះអង្គ។ ដោយសារមធ្យោបាយនេះអ្នកនឹងទទួលបានអំណរសប្បាយខាងវិញ្ញាណ។ ការអនុវត្តច្រើនដងនេះទៀត នឹងលុបបំបាត់ទុក្ខលំបាក ចំពោះអ្វីៗដែលអ្នកពិបាកទ្រាំ។

៧- សន្តៈយ៉ូហាន អើដ មើលស្គាល់ព្រះបន្ទូល និងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅក្នុងហេតុការណ៍នៃជីវិតរបស់លោក៖

ពិនិត្យពិច្ច័យមើលលើកិច្ចការប្រចាំថ្ងៃ ឬប្រចាំសប្ដាហ៍ តើមានអ្វីកើតឡើង? កត់ចំណាំនូវអ្វីៗដែលនាំឲ្យយើងពិបាកចិត្ត អ្វីៗដែលរាំងស្ទះយើង អ្វីៗដែលនាំឲ្យយើងមានសន្ទុះ។

បើកចិត្តទទួលឲ្យព្រះយេស៊ូ ដើម្បីទទួលព្រះអំណោយទាន ស្ដាប់ព្រះបន្ទូលព្រះអង្គ ស្រឡាញ់ផ្លូវដែលព្រះអង្គស្នើឲ្យយើងដើរ។

ខ្ញុំកត់ត្រាទុកព្រះបន្ទូល ដែលបានទុកស្លាកស្នាមក្នុងជីវិតរបស់ខ្ញុំ ខ្ញុំអរព្រះគុណព្រះយេស៊ូចំពោះអ្វីៗដែលខ្ញុំបានរកឃើញ អ្វីៗដែលខ្ញុំបានទទួលដោយបានស្ដាប់ព្រះបន្ទូលព្រះអង្គ។ ខ្ញុំស្រឡាញ់ព្រះអង្គ!

## ទុកពេល ដើម្បីសូមលើកលែងទោស

១- តើគេអាចស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ដូចម្ដេច បើគេមិនចេះស្ដាប់សម្ដីមនុស្សផង?
តើមានអ្វីពិបាកជាងគេ ដើម្បីបានស្ដាប់អ្នកឯទៀត? តើមកពីអត្តទត្ថភាព ភាពក្រអឺតក្រទម ភាពល្ងីល្ងើមិនព្រមជួបអ្នកដទៃយ៉ាងពិតប្រាកដ...

២- ព្រះយេស៊ូបង្រៀនយើងដោយអង្គឯង អំពីអ្វីដែលឃាត់យើងមិនឲ្យទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់៖ សូមអានប្រស្នារបស់អ្នកសាបព្រោះគ្រាប់ពូជ និងសេចក្ដីពន្យល់ (មក ៤។
សម្គាល់ឲ្យច្បាស់ថា តើអ្វីដែលមករាំងស្ទះយើងថ្ងៃនេះមិនឲ្យទទួលព្រះបន្ទូល? កង្វល់នៃការរស់នៅចិត្តពិបាកយល់ ការភ័យខ្លាចព្រះបន្ទូលព្រះអង្គ...?

៣- តើមានព្រះបន្ទូលណាមួយនៅក្នុងដំណឹងល្អ ធ្វើឲ្យយើងរំជួលចិត្ត ហើយដែលយើងប្រតិបត្តិតាមមិនកើត?

ចូរយើងគោរពថ្វាយបង្គំព្រះជាម្ចាស់ ដែលមានព្រះបន្ទូលមកយើង តាមព្រះបុត្រាព្រះអង្គ ហើយដែលរំដោះយើង ដោយសេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះអង្គ។ ចូរយើងអរព្រះគុណព្រះយេស៊ូ ដែលបានណែនាំយើងឲ្យស្គាល់ព្រះបិតាដែលមើលមិនឃើញ ហើយដែលទ្រង់ជាសាក្សីពិតប្រាកដរហូតដល់ពេលសុគត។ សូមឲ្យព្រះអង្គលើកលែងទោសឲ្យយើង ដែលមិនសូវយកចិត្តទុកដាក់នឹងដំណឹងល្អ ហើយដោយសារយើងមិនមែនជាសាក្សីល្អៗទេ។ ចូរយើងថ្វាយខ្លួនចំពោះព្រះអង្គ ដើម្បីឲ្យព្រះអង្គប្រោសយើងឲ្យចេះទទួលព្រះបន្ទូល ឲ្យយើងមានសេចក្ដីក្លាហាន ឲ្យយើងទៅជាសាក្សីដ៏ស្មោះត្រង់ចំពោះព្រះអង្គ។

**ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...**

១- ពីមួយថ្ងៃទៅមួយថ្ងៃ សាវ័ករបស់ព្រះយេស៊ូរកឃើញទ្រព្យសម្បត្តិ ដែលមិនចេះរីងស្ងួតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជ្រើសយកផ្លូវមួយ ហើយពិចារណាឲ្យល្អិតល្អន់ដោយខ្លួនឯង៖

○ ព្រះបន្ទូលអំពីកំណើតពិភពលោក (កណ ១និង ២ ; មថ៨,១៦ ; យហ ១)

○ព្រះបន្ទូលផ្ដល់ធម្មវិន័យ ដែលរំដោះយើង (សរ ២០,១-៣; សរ ២០,២០-២៦; ទក ៣២,១៤-២០; ទន ១១៨; មថ ៥,៦-៧; លក ៦,២០-៤៦)

○ព្រះបន្ទូលត្រាស់ហៅ និងចាត់ឲ្យទៅ (១សម ៣; មថ ៩,៩-១០)

២- សូមដកពិសោធន៍ អាន ស្ដាប់ និងចែករំលែកព្រះបន្ទូលជាមួយអ្នកជឿផ្សេងទៀត (ក្រុមអ្នកចែករំលែកព្រះបន្ទូល ក្រុមអ្នកអានព្រះគម្ពីរ ក្រុមអ្នកពិចារណាជីវិតឡើងវិញ អំពីធម្មទេសនាក្នុងអភិបូជា)

៣-សូមប្រៀបធៀបអត្ថបទខាងក្រោមនេះ ជាមួយអត្ថបទរបស់សន្ទះយ៉ូហាន អើដ ហើយដកស្រង់យកចំណុចណាដែលអាចជួយអប់រំអ្នក។

ក្រឡេកមើលថា តើព្រះយេស៊ូធ្វើដូចម្ដេចជាមួយសាវ័ករបស់ព្រះអង្គនៅភូមិអេម៉ាអូស (លក ២៤)។

យើងត្រូវយល់អត្ថន័យនៃព្រះបន្ទូលព្រះជាម្ចាស់ តាមរយៈសម្ដីអាកប្បកិរិយា ហេតុការណ៍ទាំងឡាយរបស់មនុស្ស។ ប្រសិនបើព្រះបន្ទូលព្រះជាម្ចាស់បានធ្លាក់ចុះពីលើមេឃមកនោះ យើងគ្រាន់តែថាតាមព្រះបន្ទូលនោះបានហើយ។ ព្រះបន្ទូលមានតាមហេតុការណ៍ ដែលកើតមានចំពោះមនុស្ស ព្រះបន្ទូលនៅតែបន្តប្រាប់យើងឲ្យយល់អំពីព្រះហឫទ័យព្រះជាម្ចាស់តាមហេតុការណ៍ទាំងឡាយ ដែលកើតមានសព្វថ្ងៃនេះ។

ការអានព្រះគម្ពីរនាំយើងឲ្យប្រព្រឹត្តអ្វីៗ ដែលដូនតាយើងបានធ្វើដោយជឿព្រះជាម្ចាស់។ ត្រូវតែអានព្រះបន្ទូលក្នុងជីវិតយើង និងជីវិតពិភពលោក។

ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះវិញ្ញាណនឹងប្រាប់អ្នករាល់គ្នា អំពីអ្វីដែលខ្ញុំបានប្រាប់រួចហើយ ហើយព្រះអង្គនឹងណែនាំអ្នករាល់គ្នាឲ្យស្គាល់សេចក្ដីពិតទាំងស្រុង (យហ ១៦,៣)។

ព្រះបន្ទូលស្ថិតនៅក្នុងចិត្តអ្នក ដើម្បីឲ្យអ្នកប្រតិបត្តិតាម (ទក ៣០,១៤)។ ខ្ញុំរៀបចំខ្លួនរាល់ថ្ងៃ រាល់សប្ដាហ៍ ដើម្បីទទួលព្រះបន្ទូលព្រះជាម្ចាស់យកមកទុកក្នុងចិត្ត និងក្នុងជីវិតខ្ញុំ។

# សម្លឹងមើលព្រះនាងម៉ារី

អ្នកណាមើលឃើញព្រះយេស៊ូ អ្នកនោះមើលឃើញព្រះនាងម៉ារី!
អ្នកណាស្រឡាញ់ព្រះយេស៊ូ អ្នកនោះស្រឡាញ់ព្រះនាងម៉ារីដែរ។

## ដំណាក់កាលទី៩

ព្រះមាតាព្រះអង្គរក្សាហេតុការណ៍ទាំងអស់នោះ ទុកក្នុងដួងចិត្តព្រះនាង (លក ២,៥១)

**ក្នុងដំណាក់កាលនេះមាន ៖** អ្នកណាយល់ព្រះហឫទ័យព្រះបិតាជាងព្រះនាងម៉ារី? ព្រះយេស៊ូមានព្រះបន្ទូលថា កាលនោះព្រះនាងត្រេកអរ មិនមែនដោយសារព្រះនាងទ្រង់ព្រះគភ៌ព្រះអង្គដែលជាព្រះបុត្រាព្រះជាម្ចាស់ទេ ប៉ុន្តែមកពីព្រះនាងស្តាប់ព្រះបន្ទូល ហើយប្រតិបត្តិតាម។ ព្រះនាងចេះលះបង់ខ្លួនឯង ដើម្បីផ្សារភ្ជាប់ជាមួយព្រះយេស៊ូ។

សូមរិះគិតឲ្យដឹងថា តើនៅក្នុងដំណឹងល្អ ព្រះនាងម៉ារីអញ្ជើញយើងឲ្យស្តាប់ព្រះបុត្រាព្រះនាងដែលជាព្រះបន្ទូលតែម្តង។ ដូច្នោះចូរយើងបណ្តោយខ្លួនឲ្យព្រះនាងនាំយើងទៅជួបព្រះយេស៊ូ ដើម្បីចូលរួមក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ និងទទួលសេចក្តីស្រឡាញ់ដែលជួយសង្គ្រោះយើង។

**គោលដៅនៃដំណាក់កាលនេះ ៖** រិះគិតឲ្យដឹងថា តើខ្ញុំគិតយ៉ាងដូចម្តេចអំពីព្រះនាងម៉ារី?
សូមស្វែងយល់អំពីព្រះនាងម៉ារី៖ ព្រះនាងជាសត្វលោកតែមួយគត់ ដែលផ្សារភ្ជាប់គ្រប់លក្ខណៈជាមួយព្រះយេស៊ូ រួបរួមជាធ្លុងមួយជាមួយព្រះអង្គ...ព្រះនាងជាគំរូឲ្យយើងផ្សារភ្ជាប់ជាមួយព្រះយេស៊ូ...បង្ហាញផ្លូវដែលនាំយើងឲ្យរួបរួមជាមួយព្រះអង្គ។

ទីបញ្ចប់នៃដំណាក់កាលនេះ ខ្ញុំគួរតែអាចចង្អុលបង្ហាញនូវអ្វីៗដែលខ្ញុំបានស្វែងយល់អំពីព្រះនាងម៉ារី។

**ទុកពេល សម្រាប់បើកចិត្ត និងទទួល**

១-ទទួលយកមកទុកក្នុងខ្លួន នូវអ្វីដែលកើតមានឡើង កាលបើយើងឮគេនិយាយអំពីព្រះនាងម៉ារី ព្រះនាងព្រហ្មចារីយ៍ព្រះនាងដ៏វិសុទ្ធ។

២-តើយើងបានរៀនអំពីព្រះនាងដូចម្តេចខ្លះ? តើមាននៅចាំទេ តើអ្នកណាខ្លះ ដែលនិយាយប្រាប់យើងអំពីព្រះនាង? តើគេនិយាយអំពីអ្វីខ្លះ? អ្វីៗដែលយើងរកឃើញក្នុងសៀវភៅ...ទស្សនាវដ្តី...រូបភាព។

៣- តើយើងស៊ីសង្វាក់ជាមួយអ្វីខ្លះជាងគេ? ហើយអ្វីខ្លះដែលមិនស៊ីសង្វាក់ជាមួយយើង?

៤- ព្រះសហគមន៍អធិដ្ឋានដល់ព្រះនាងម៉ារី។ ចុះយើងវិញ យើងអធិដ្ឋានដល់ព្រះនាងទេ? បើសិនជាមាន តើយើងអធិដ្ឋានយ៉ាងណា? បើគ្មានតើយើងអាចនិយាយឬទេថា ព្រោះហេតុអ្វី?

ខ្ញុំអង្គុយចុះតាមសម្រួល...ខ្ញុំខិតខំនៅស្ងប់ស្ងាត់...ខ្ញុំទទួលព្រះមាតាចូលមកក្នុងខ្លួនខ្ញុំ ហើយនិយាយទូលព្រះនាងអំពីបំណងរបស់ខ្ញុំថា ខ្ញុំចង់ទទួលព្រះយេស៊ូ ដូចកាលដែលព្រះនាងទទួលព្រះអង្គដូច្នោះដែរ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

### អត្ថបទនៃព្រះគម្ពីរ

១- សម្លឹងមើលព្រះនាងម៉ារី ក្នុងអត្ថបទដំណឹងល្អ តាមសម្រួល

- ព្រះនាងម៉ារីទទួលយកព្រះជាម្ចាស់ឲ្យយាងចូលក្នុងជីវិតរបស់ព្រះនាង (លក ១,២៦-៣៨)
- ជាការទទួលមួយ ដែលនាំឲ្យព្រះនាងយកចិត្តទុកដាក់នឹងការស្រឡាញ់អ្នកដទៃ (យហ ២,១-៤)
- បំណងរបស់ព្រះនាងដើម្បីរស់នៅក្រោមព្រះនេត្រាព្រះជាម្ចាស់(លក២,១៩-៥)គឺរស់នៅដោយរួបរួមជាមួយព្រះយេស៊ូជាបុត្ររបស់ព្រះនាង ជាព្រះបុត្រា (លក ១១,២៨)។

២-ក្រឡេកមើលទៅព្រះនាងម៉ារីគង់ក្បែរឈើឆ្កាង ក្នុងដំណឹងល្អតាមសម្រួល...វត្តមានរបស់ព្រះនាងចំពោះព្រះយេស៊ូនៅវេលានោះ...វត្តមានរបស់ព្រះនាងចំពោះមុខលោកយ៉ូហាន ដែលព្រះនាងទទួលយកពីព្រះយេស៊ូជាបុត្ររបស់ព្រះនាង (លក ១៩,២៥-២៧)

៣-នៅក្នុងកិច្ចការគ្រីស្តទូត យើងរកឃើញព្រះនាងម៉ារីរស់នៅ ដោយព្រះជន្មព្រះជាម្ចាស់ ក្នុងព្រះវិញ្ញាណ ...ព្រះនាងអធិដ្ឋានជាមួយគ្រីស្តទូតទាំងឡាយ ដោយពោលទៅពួកលោកថា ឲ្យតាមព្រះបន្ទូលព្រះអង្គសព្វគ្រប់។ ព្រះនាងជាផ្លូវមួយនាំយើងទៅរកព្រះវិញ្ញាណ។ ខ្ញុំចង្អុលបង្ហាញចំណុចណាដែលធ្វើឲ្យខ្ញុំស្រឡាញ់ព្រះនាង ខ្ញុំចូលចិត្តរបៀបដែលព្រះនាងទទួលព្រះយេស៊ូ ទទួលព្រះបន្ទូលព្រះជាម្ចាស់មកទុកក្នុងចិត្តព្រះនាង។

៤- ព្រះជន្មព្រះយេស៊ូនៅក្នុងចិត្តព្រះនាងម៉ារី ហើយជីវិតរបស់ព្រះនាងនៅក្នុងអង្គព្រះយេស៊ូ។

## សន្តៈយ៉ូហាន អើដ

*ពេលយើងស្រឡាញ់អ្នកណាម្នាក់ យើងត្រូវរៀនស្គាល់អ្នកនោះឲ្យច្បាស់ ឲ្យស្គាល់គាត់បន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ យើងចូលក្នុងជីវិតអ្នកនោះបន្តិចម្តងៗ។ ពេលយើងស្រឡាញ់អ្នកណាម្នាក់ យើងបណ្តោយឲ្យគេចូលមកក្នុងជីវិតយើងឲ្យយល់គំនិត អ្នកនោះមួយថ្ងៃបន្តិចៗ ហើយថ្ងៃណាមួយគំនិតខ្ញុំ និងគំនិតអ្នកនោះនឹងចូលគ្នាជាផ្លូវមួយ។*

*ដូច្នោះហើយដោយលោក យ៉ូហាន អើដ សញ្ជឹងគិតអំពីព្រះនាងម៉ារី ជាអ្នកថែរក្សាទុកក្នុងចិត្តព្រះនាងនូវព្រះបន្ទូល និងកិច្ចការទាំងប៉ុន្មានរបស់បុត្រព្រះនាង លោកក៏ពិចារណាអំពីព្រះយេស៊ូនៅក្នុងជីវិតព្រះនាងដែរ។ យើងអាចមើលឃើញព្រះបំណងប្រាថ្នារបស់ព្រះជាម្ចាស់ ឲ្យយើងរួបរួមជាមួយព្រះអង្គតាមរយៈព្រះនាងម៉ារី។ ព្រះជាម្ចាស់បានបង្កើតមនុស្សជារូបតំណាងព្រះអង្គ ហើយបំណងរបស់យើងផ្ទាល់ គឺរួបរួមជាមួយព្រះជាម្ចាស់ដោយសារព្រះយេស៊ូជាមួយព្រះយេស៊ូ និងក្នុងព្រះអង្គ។*

*ព្រះយេស៊ូអើយ! ទូលបង្គំសញ្ជឹងគិតទៅដល់ព្រះអង្គ និងគោរពកោតខ្លាចព្រះអង្គ ដែលមានព្រះជន្មគង់*

នៅ និងសោយរាជ្យនៅក្នុងព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គ។

ឱព្រះយេស៊ូ ជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់ ជាបុត្រាតែមួយនៃព្រះនាងម៉ារី ខ្ញុំម្ចាស់សញ្ជឹងគិតទៅដល់ព្រះអង្គ និងគោរពក្រាបថ្វាយបង្គំព្រះអង្គ ទ្រង់មានព្រះជន្មគង់នៅ និងសោយរាជ្យនៅក្នុងចិត្តរបស់ព្រះមាតាដ៏វិសុទ្ធ ព្រះអង្គធ្វើអ្វីៗទាំងអស់សព្វប្រការចំពោះព្រះនាង។ តាមក្រុមគ្រីស្តទូត ព្រះអង្គជាអ្វីៗសព្វប្រការទាំងអស់ (អភ ១,២៣; ១ករ ១២,៦) ហើយព្រះអង្គធ្វើអ្វីៗសព្វប្រការ ចំពោះព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គ។ ព្រះអង្គជាអាយុជីវិត ជាព្រលឹង ជាមិត្ត ជាវិញ្ញាណ ជាកំណប់ទ្រព្យរបស់ព្រះនាង។ ព្រះអង្គស្ថិតនៅក្នុងព្រះនាងដោយប្រោសព្រះនាងឲ្យបានវិសុទ្ធ ព្រះនាងដែលលើកតម្កើងសិរីរុងរឿងព្រះអង្គនៅឯស្ថានបរមសុខ។ ព្រះអង្គស្ថិតនៅក្នុងចិត្តព្រះនាង ដោយធ្វើឲ្យព្រះនាងកាន់តែឧត្តុង្គឧត្តម ហើយធ្វើឲ្យសិរីរុងរឿងព្រះនាងកាន់តែថ្កុំថ្កើងខ្ពង់ខ្ពស់ជាងសត្វលោកនានា ទាំងនៅស្ថានបរមសុខ ទាំងលើផែនដីនេះ។ ព្រះអង្គស្ថិតនៅក្នុងព្រះនាង ហើយគុណសម្បត្តិ ភាពគ្រប់លក្ខណៈ ព្រះទ័យសុភាពរាបសា ការទំនុកបម្រុងទាំងអស់មកគ្របដណ្តប់លើព្រះនាងដែលកាន់តែឲ្យព្រះនាងបានគ្រប់លក្ខណៈក្រៃលែង សព្វប្រការទាំងអស់។ ព្រះនាងកាន់តែមានលក្ខណៈដូចព្រះអង្គបេះបិទ។ អ្នកណាឃើញព្រះយេស៊ូ អ្នកនោះឃើញព្រះនាងម៉ារីមាតា ហើយអ្នកណាឃើញព្រះនាងក៏ឃើញព្រះយេស៊ូដែរ។ ឱព្រះយេស៊ូអើយ! ទូលបង្គំសូមកោតសរសើរព្រះអង្គចំពោះអ្វីៗទាំងអស់ដែលជាលក្ខណៈរបស់ព្រះអង្គ និងចំពោះអ្វីៗទាំងអស់ដែលព្រះអង្គប្រព្រឹត្តចំពោះព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គ។ ទូលបង្គំសូមថ្វាយនូវអំណររីករាយសេចក្តីស្រឡាញ់ និងសិរីរុងរឿងដែលព្រះអង្គបានទទួលពីព្រះនាងម៉ារី។ ឱព្រះមាតាព្រះយេស៊ូអើយ ទូលបង្គំសូមលើកតម្កើង និងកោតសរសើរចំពោះជីវិតដ៏វិសុទ្ធគួរឲ្យស្ញប់ស្ញែង ដែលព្រះនាងបានទទួលពីព្រះបុត្រាយេស៊ូជាជីវិតដែលតុបតែងលំអ ដោយគុណធម៌គ្រប់ប្រការ និងគ្រប់លក្ខណៈ។ ចំពោះព្រះជាម្ចាស់ជីវិតនេះ មានតម្លៃជាងពួកទេវទូត និងជីវិតមនុស្សផងទាំងពួង។ ជាជីវិតដែលផ្តល់នូវសិរីរុងរឿង សេចក្តីស្រឡាញ់ ចំពោះព្រះជាម្ចាស់ លើសជីវិតផ្សេងទៀតនៅលើផែនដី ទាំងនៅស្ថានបរមសុខ។ ព្រះមាតាព្រហ្មចារីយ៍ដ៏វិសុទ្ធអើយ! ទូលបង្គំសូមកោតសរសើរចំពោះព្រះនាង ដែលបានផ្តល់សិរីរុងរឿងដល់ព្រះបុត្រាជាទីស្រឡាញ់ពេញមួយជីវិតរបស់ព្រះនាង។ ខ្ញុំម្ចាស់សូមថ្វាយជីវិតទាំងស្រុងចំពោះព្រះនាង។ ឱព្រះមាតាអើយ! ខ្ញុំម្ចាស់សូមបូជាជីវិតនេះចំពោះព្រះនាង ហើយខ្ញុំម្ចាស់សូមទូលអង្វរព្រះបុត្រាយេស៊ូ ដែលជាម្ចាស់នៃជីវិត និងជាសេចក្តីស្រឡាញ់ សូមព្រះអង្គធ្វើយ៉ាងណាឲ្យពេញមួយជីវិតខ្ញុំម្ចាស់នេះ បានគោរពថ្វាយបង្គំព្រះមាតា និងព្រះអង្គជារៀងរហូតតទៅ និងអស់កល្បជានិច្ច។

ឱព្រះយេស៊ូជាព្រះជាម្ចាស់នៃជីវិត និងចិត្តខ្ញុំអើយ! ព្រះអង្គមានព្រះបំណងយ៉ាងខ្លាំងក្លាចំពោះរូបខ្ញុំម្ចាស់ឲ្យព្រះអង្គយាងមករស់នៅក្នុងចិត្តខ្ញុំម្ចាស់ ដើម្បីឲ្យខ្ញុំម្ចាស់រស់នៅក្នុងជីវិតដ៏វិសុទ្ធ និងអស់កល្បជានិច្ច។ សូមព្រះអង្គមេត្តាលើកលែងទោសឲ្យខ្ញុំម្ចាស់ផង ចំពោះការរាំងស្ទះទាំងអស់ រហូតដល់ពេលនេះ ដែលខ្ញុំម្ចាស់បានប្រព្រឹត្តមិនឲ្យព្រះបំណងព្រះអង្គបានសម្រេច ដោយសារអំពើបាប និងចិត្តសាវារបស់ខ្ញុំម្ចាស់។ សូមព្រះអង្គយកព្រះជន្មដ៏វិសុទ្ធ និងគ្រប់លក្ខណៈមកសណ្ឋិតក្នុងខ្លួនខ្ញុំម្ចាស់។ សូមព្រះអង្គមានព្រះជន្មគ្របដណ្តប់ពាសពេញក្នុងស្មារតី ក្នុងចិត្ត និងក្នុងព្រលឹងរបស់ខ្ញុំម្ចាស់។ សូមព្រះអង្គលើកតម្កើងជីវិតនេះដោយអង្គឯង តាមរបៀបដែលព្រះអង្គប្រាថ្នាទៅចុះ។ ឱព្រះមាតានៃព្រះយេស៊ូអើយ! សូមមេត្តាជួយឲ្យព្រះបុត្រាព្រះនាងបំពេញបំណងរបស់ខ្ញុំម្ចាស់ទាំងអស់នេះផង។

## ៥- ហេតុដូចម្តេចបានជាយើងត្រូវគោរពព្រះហឫទ័យព្រះនាងម៉ារី?

សម្រាប់មាតាម្នាក់ តើអ្វីដែលមានសិទ្ធិ មានតម្លៃជាងជីវិតកូនៗរបស់គាត់? ចំពោះគាត់ គាត់សរសើរកូនគាត់ជាងសរសើរខ្លួនគាត់ផ្ទាល់។ កូនគាត់ គឺជាសាច់នៃសាច់របស់គាត់។ នេះជាការពិតចំពោះមាតាគ្រប់រូប ចំណែកឯព្រះនាងម៉ារី មានលើសពីគេទៅទៀត។ បើយើងចង់លើកតម្កើងព្រះនាងម៉ារី យើងក៏ត្រូវលើកតម្កើងព្រះយេស៊ូ។ ពេលយើងទូលអង្វរព្រះមាតាយើងក៏ទូលអង្វរព្រះយេស៊ូដែរ។ ពេលយើងនិយាយអំពីព្រះយេស៊ូ យើងក៏និយាយអំពីព្រះបិតាដែរ! ព្រះយេស៊ូជាព្រះហឫទ័យនៃព្រះបិតា។ ព្រះយេស៊ូជាព្រះហឫទ័យនៃព្រះនាងម៉ារី។ ព្រះអង្គជាព្រះហឫទ័យនៃហឫទ័យព្រះនាង។

ចិត្តតំណាងឲ្យអ្វីៗទាំងអស់នៅក្នុងខ្លួន ប៉ុន្តែមិនគ្រាន់តែដូច្នោះទេ ចិត្តមានន័យយ៉ាងសំខាន់ថា ជាសេចក្តីស្រឡាញ់។ ដូច្នេះពេលយើងគោរពព្រះនាងម៉ារី យើងមិនគោរពអាថ៌កំបាំងណាមួយ ឬគុណធម៌ណាមួយរបស់ព្រះនាងព្រហ្មចារិយ៍ប៉ុណ្ណោះទេ ប៉ុន្តែយើងគោរពប្រភព និងដើមកំណើតនៃភាពថ្លៃថ្លា និងភាពវិសុទ្ធនោះ គឺយើងគោរពសេចក្តីស្រឡាញ់ និងសប្បុរសធម៌របស់ព្រះនាង។ តាមពិតទៅសេចក្តីស្រឡាញ់នេះ បានប្រោសឲ្យសកម្មភាពទាំងអស់របស់ព្រះនាងបានវិសុទ្ធ។ នេះហើយដែលនាំឲ្យព្រះនាងស័ក្តិសមជាព្រះមាតារបស់ព្រះយេស៊ូ និងជាព្រះមាតានៃសមាជិកទាំងអស់នៃព្រះអង្គ។

អ្នករាល់គ្នាដែលស្រេកទឹក! ចូរមកផឹកទឹកនៅប្រភពនេះទៅ។ ប្រញាប់ឡើង! ហេតុអ្វីបានជារង់ចាំដូច្នេះ? តើអ្នករាល់គ្នាខ្លាចធ្វើបាបសប្បុរសធម៌របស់ព្រះសង្គ្រោះយើង បើអ្នករាល់គ្នាទូលអង្វរព្រះនាងដូច្នេះ? ប៉ុន្តែអ្នករាល់គ្នាមិនដឹងទេឬថា ព្រះនាងម៉ារីគ្មានអ្វីសោះ ហើយមិនអាចធ្វើអ្វីកើតទេ បើគ្មានព្រះយេស៊ូ? មានតែព្រះយេស៊ូទេ ដែលធ្វើអ្វីៗគ្រប់ប្រការ ហើយព្រះអង្គនេះ ដែលប្រទានឲ្យព្រះនាងមានអ្វីៗទាំងអស់នោះ? អ្នករាល់គ្នាមិនដឹងទេថា ព្រះយេស៊ូមិនគ្រាន់តែស្ថិតគង់នៅក្នុងព្រះនាងប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គផ្ទាល់ជាហឫទ័យនៃព្រះហឫទ័យរបស់ព្រះនាង ដូច្នោះហើយបានជាពេលយើងទូលអង្វរព្រះនាង យើងក៏ទូលអង្វរព្រះយេស៊ូដែរ។ លើសពីនេះទៅទៀត ព្រះបិតាអស់កល្បជានិច្ចបានប្រគល់ឲ្យព្រះមាតាអាចប្រសូតព្រះបុត្រាជាលើកទីមួយក្នុងចិត្តព្រះនាង បន្ទាប់មកទៀត នៅក្នុងផ្ទៃព្រះនាងដែលជាព្រហ្មចារិនីយ៉ាងណា ព្រះអង្គក៏ប្រទានឲ្យព្រះនាងអាចបង្កើតព្រះបុត្រានៅក្នុងចិត្តកូនចៅលោកអដាំយ៉ាងនោះដែរ។ ហេតុនេះហើយ ព្រះនាងសហការណ៍ជាមួយនឹងស្នាព្រះហស្តរបស់ព្រះសង្គ្រោះយើង ដោយប្រើអំណាចពិសេសនេះ ដោយមានចិត្តស្រឡាញ់ដ៏មហិមា។ ដោយពេលមុនព្រះនាងបីបមព្រះបុត្រាយេស៊ូក្នុងចិត្តព្រះនាង ដូច្នោះព្រះនាងក៏នឹងប្រោសប្រណីជនដ៏វិសុទ្ធទាំងឡាយដូចជាផលផ្លែ និងជាតង្វាយថ្វាយចំពោះព្រះជាម្ចាស់ ជាស្តេចនៃស្ថានបរមសុខជារៀងរហូត។

## ៦- ព្រះនាងម៉ារីបានបីបម ព្រះគ្រីស្តក្នុងដួងចិត្តព្រះនាង

ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបណ្តោយឲ្យព្រះយេស៊ូកើត ពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងខ្លួនយើង (កាឡ ៤,១៩ ២)។

ដោយសញ្ជឹងគិតទៅដល់ព្រះនាងម៉ារី យើងយល់ឃើញយ៉ាងច្បាស់ថា ជាស្ត្រីដូចយើងដែលបានដើរទៅមុខ ដោយសារជំនឿ ដោយនាងរកឃើញពីមួយថ្ងៃទៅមួយថ្ងៃ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះបំណងប្រាថ្នា

របស់ព្រះអង្គ ព្រះនាងបានរស់នៅដើម្បីតែព្រះជាម្ចាស់ ព្រះនាងរីករាយនឹងគាប់ព្រះហឫទ័យព្រះបិតា។ យើងក៏ដូចព្រះនាងម៉ារីដែរ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យមានពេលឡើងថា៖ ព្រះគ្រីស្តគង់នៅក្នុងខ្ញុំ។

សូមឲ្យព្រះនាងព្រះហ្មចារិនីម៉ារី ពោរពេញដោយសុភមង្គល ដោយបានទ្រង់ព្រះគភ៌ព្រះអម្ចាស់ ជាអ្នកបានបង្កើតពិភពលោក ហើយសូមឲ្យព្រះនាងកាន់តែរីករាយថែមទៀត ដែលបានទុកព្រះអង្គក្នុងដួងចិត្តរបស់ព្រះនាងដែរ។

សន្តៈអូគូស្ទីនផ្តល់សក្ខីភាពអំពីចិត្តគោរពចំពោះព្រះមាតានៃព្រះជាម្ចាស់ ដែលមានការវាយតម្លៃដ៏ប្រសើរក្រៃលែងចំពោះព្រះហឫទ័យដ៏វិសុទ្ធរបស់ព្រះនាង៖ព្រះមាតុភាពរបស់ព្រះនាងម៉ារីដូចជាគ្មានប្រយោជន៍អ្វីទេ ប្រសិនបើព្រះនាងមិនរីករាយ នឹងទទួលយកព្រះយេស៊ូមកដាក់ក្នុងដួងចិត្តព្រះនាង ជាងទទួលព្រះអង្គក្នុងព្រះកាយ។ តាមការពិតលោកលើកតម្កើងព្រះនាងឲ្យបានខ្ពង់ខ្ពស់បំផុត ដោយមានមូលហេតុត្រឹមត្រូវ។ **ទីមួយ** ពីព្រោះព្រហ្មចារិនីដ៏ប្រសើរលើសលប់ បានបង្កកំណើតព្រះបុត្រានៃព្រះជាម្ចាស់នៅក្នុងដួងចិត្តព្រះនាង មុននឹងបង្កកំណើតព្រះអង្គក្នុងព្រះកាយ។ **ទីពីរ** ពីព្រោះព្រះនាងបង្កកំណើតព្រះបុត្រានៅក្នុងផ្ទៃព្រះនាង ដោយបានរៀបចំដួងចិត្តព្រះនាង។ **ទីបី** ពីព្រោះព្រះនាងបានបង្កកំណើត ព្រះអង្គនៅក្នុងផ្ទៃតែប្រាំបួនខែប៉ុណ្ណោះ ប៉ុន្តែព្រះនាងទុកព្រះអង្គក្នុងដួងចិត្តព្រះនាង ចាប់ពីពេលដែលព្រះអង្គប្រសូត ហើយព្រះនាងទុកព្រះអង្គក្នុងដួងចិត្តព្រះនាងអស់កល្បជានិច្ច។ **ទីបួន** ព្រោះព្រះនាងទុកព្រះអង្គ ក្នុងដួងចិត្តព្រះនាងយ៉ាងស័ក្តិសមបំផុត យ៉ាងវិសុទ្ធបំផុត ជាងពេលព្រះនាងទ្រង់ព្រះគភ៌ ដ្បិតដួងចិត្តព្រះនាងនេះជាស្ថានបរមសុខ ដែលព្រះអង្គជាព្រះមហាក្សត្រនៃស្ថានបរមសុខ និងរបស់ផែនដីទទួលសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត។ **ទីប្រាំ** ពីព្រោះព្រះមាតានៃព្រះសង្គ្រោះបានទុកព្រះអង្គក្នុងផ្ទៃ ប៉ុន្តែព្រះនាងទុកព្រះអង្គក្នុងដួងចិត្តព្រះនាងអស់កល្បជានិច្ច គឺនៅពេលដែលព្រះអង្គប្រកបដោយសិរីរុងរឿង។ ហេតុដូច្នោះហើយ សន្តៈអូគូស្ទីន និយាយត្រឹមត្រូវដោយមានប្រសាសន៍ថា ព្រះនាងបានពរព្រះអង្គ ក្នុងដួងចិត្តប្រសើរជាងពរព្រះអង្គនៅក្នុងផ្ទៃ។

ខ្ញុំសម្លឹងមើលព្រះនាងម៉ារីយ៉ាងយូរ ដែលរួបរួមជាមួយព្រះយេស៊ូ...ហើយព្រះយេស៊ូរួបរួមជាមួយនឹងព្រះនាងដែរ...

ខ្ញុំបណ្តោយខ្លួនឲ្យរំពឹងគិតអំពីល្បះមួយ ពាក្យមួយ ព្រះភ័ក្ត្ររបស់ព្រះមាតា ដែលខ្ញុំរកឃើញក្នុងអត្ថបទទាំងអស់នោះ...

ខ្ញុំកោតសរសើរព្រះអម្ចាស់ ខ្ញុំអរព្រះគុណព្រះអង្គ ចំពោះព្រះនាងម៉ារី ដែលរួបរួមជាធ្លុងតែមួយនឹងព្រះអង្គ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- តើយើងជួបឧបសគ្គណាខ្លះ ដើម្បីទទួលព្រះជាម្ចាស់ ក្នុងជីវិតប្រចាំថ្ងៃរបស់យើង? ដើម្បីទទួលព្រះនាងម៉ារីក្នុងចិត្តយើង? ដើម្បីឲ្យយើងបានបណ្តោយខ្លួនឲ្យព្រះអម្ចាស់កែច្នៃយើង ដូចព្រះអង្គបានប្រែចិត្តព្រះនាងម៉ារីដែរ?

២-ព្រះនាងម៉ារីឃើញ ហើយប្រតិបត្តិតាម។ ព្រះនាងស្តាប់ ហើយប្រតិបត្តិតាម។ ក្នុងជីវិតយើងតើការកាត់ផ្តាច់រវាងជំនឿនឹងការរស់នៅមានអ្វីខ្លះ? តើការកាត់នោះមកពីណា?

៣-ព្រះនាងម៉ារីសប្បាយរីករាយ ព្រោះព្រះនាងស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ ហើយយកមកអនុវត្តតាម។

តើព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យផ្លាស់ប្ដូរអ្វីខ្លះ?

*ខ្ញុំលុតជង្គង់ចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ជាមួយនឹងព្រះបន្ទូល។ សូមឲ្យខ្ញុំលើកលែងទោសខ្លួនឯង ដោយមិនទាន់បានចាប់យកសារៈប្រយោជន៍នៃព្រះអំណោយទាន ដែលព្រះអង្គប្រទានឲ្យខ្ញុំ នៅពេលព្រះអង្គប្រទានព្រះនាងម៉ារីឲ្យខ្ញុំ។ ខ្ញុំសូមព្រះអង្គលើកលែងទោសឲ្យខ្ញុំ ដែលមិនបានសម្លឹងមើលទៅព្រះនាងដូចព្រះយេស៊ូទតមើលព្រះនាងដែរ...ដែលមិនទុកឲ្យព្រះយេស៊ូឲ្យយាងមកក្នុងដួងចិត្តខ្ញុំដូចព្រះនាងម៉ារីដែរ។*

**ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ...ដើម្បី...**

១- កត់ទុកនូវអ្វីខ្លះដែលយើងបានរកឃើញអំពីព្រះនាងម៉ារី។

២- សព្វថ្ងៃនេះ តាមផ្លូវរបស់ព្រះនាងម៉ារី តើអ្វីខ្លះដែលនាំឲ្យយើងសម្រេចចង់ធ្វើជាសាវ័កព្រះយេស៊ូ ដូចព្រះនាងដែរ? ប្រើមធ្យោបាយអ្វីខ្លះ ដើម្បីសម្រេច?

៣-ព្រះនាងម៉ារីជាស្នាព្រះហស្តដ៏ថ្លៃថ្លាបំផុតរបស់ព្រះជាម្ចាស់។

ចូលចិត្តក្រឡេកមើលទៅព្រះនាង ដោយពោលពាក្យជូនច្នោះថា៖

| | |
|---|---|
| ពួកយើងសូមក្រាបថ្វាយបង្គំព្រះមាតា | បុត្រីនៃព្រះជាម្ចាស់ជាព្រះបិតា |
| ពួកយើងសូមក្រាបថ្វាយបង្គំព្រះមាតា | មាតានៃព្រះជាម្ចាស់ ជាព្រះបុត្រា |
| ពួកយើងសូមក្រាបថ្វាយបង្គំព្រះមាតា | មហេសីនៃព្រះវិញ្ញាណដ៏វិសុទ្ធ |
| ពួកយើងសូមក្រាបថ្វាយបង្គំព្រះមាតា | ព្រះដំណាក់នៃព្រះជាម្ចាស់ |
| ពួកយើងសូមក្រាបថ្វាយបង្គំព្រះមាតា | បុប្ផាដែលបញ្ចេញរស្មីនៃព្រះត្រៃឯក មិនចេះប្រែប្រួល |

ដែលពោរពេញទៅដោយធម៌មេត្តាករុណាហើយ ព្រះអម្ចាស់ក៏គង់នៅជាមួយព្រះនាងដែរ។

ដល់វេនខ្ញុំ ខ្ញុំសរសេរកំណាព្យយ៉ាងវែងមួយ ដើម្បីពោលពាក្យសរសើរ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះនាងម៉ារី។

សន្តៈយ៉ូហានអើដ

# យល់ឃើញថា ព្រះជាម្ចាស់ ប្រសូតជាមនុស្សដូចយើងបេះបិទ

ព្រះបុត្រាព្រះជាម្ចាស់មានគម្រោងការដ៏អស្ចារ្យឲ្យប្រសូតជាមនុស្សក្នុងខ្លួនយើង!

## ដំណាក់កាលទី ៦

ព្រះបន្ទូលប្រសូតជាមនុស្ស !

**ក្នុងដំណាក់កាលនេះមាន ៖** ហួសពីការប៉ងប្រាថ្នារបស់ខ្ញុំទៅលើព្រះអង្គ ព្រះជាម្ចាស់ប្រសូតជាមនុស្សនៅក្នុងអង្គព្រះយេស៊ូ។ ព្រះយេស៊ូបង្ហាញព្រះជាម្ចាស់នោះ ជាភាពមនុស្សជាកាយវិការមនោសញ្ចេតនា...ឥឡូវនេះព្រះអង្គបង្ហាញព្រះអង្គឲ្យឃើញក្នុងកិច្ចការកាយវិការមនោសញ្ចេតនា...របស់សាក្សីនៃព្រះយេស៊ូ។

ចុះចំណែកខ្ញុំវិញ ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យបង្ហាញអំពីព្រះអង្គ ដោយកិច្ចការកាយវិការមនោសញ្ចេតនារបស់ខ្ញុំឬទេ?

**គ្រីស្តបរិស័ទម្នាក់៖** បង្ហាញព្រះយេស៊ូនៅលើផែនដីនេះ ទៅជាព្រះយេស៊ូក្នុងជីវិតប្រចាំថ្ងៃ ដើម្បីឲ្យព្រះយេស៊ូគង់នៅជារៀងរហូតលើផែនដីនេះ ព្រះជាម្ចាស់ត្រាស់ហៅអ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក បណ្ដោយខ្លួនឲ្យព្រះយេស៊ូគង់នៅក្នុងចិត្ត ដោយថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ។

**គោលដៅនៃដំណាក់កាលនេះ ៖** ត្រូវចងចាំថា សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់បានចាប់កំណើតក្នុងអង្គព្រះយេស៊ូ។

**យើងអាចនិយាយបានដែរថា ៖**

មនុស្សទាំងអស់អាចបង្ហាញខ្ញុំអំពីព្រះជាម្ចាស់ដែរ។

ត្រូវតែជឿថា ជីវិតជាមនុស្សរបស់ខ្ញុំជាទីកន្លែង ដែលខ្ញុំអាចជួបព្រះជាម្ចាស់...

**ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ៖**

ឲ្យផ្ដល់មុខមនុស្សទៅជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ឲ្យស្វែងរកព្រះភ័ក្ត្រព្រះយេស៊ូក្នុងខ្លួនអ្នកទាំងអស់ដែលដើរតាមផ្លូវនៃជីវិតជាមួយខ្ញុំ។ ចុងបញ្ចប់នៃដំណាក់កាលនេះ ខ្ញុំគួរតែខិតខំប្រុងប្រយ័ត្នថែមទៀត ដើម្បីបង្ហាញចេញពីកាយវិការប្រចាំថ្ងៃរបស់ខ្ញុំ និងកិច្ចការរបស់ព្រះយេស៊ូ ដែលបង្ហាញអំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

**ទុកពេល សម្រាប់បើកចិត្ត និងទទួលយក...**

**១- យើងនឹកឡើងវិញតាមសម្រួល ៖** ការអានសៀវភៅ ឬការជួបម្នាក់ ទស្សនីយភាព បទយកព័ត៌មានណាមួយ...ដែលបាននាំឲ្យយើងរកឃើញនូវអ្វីៗ ដែលមនុស្សអាចធ្វើបានជាវិជ្ជមានក្តី ឬអវិជ្ជមានក្តី ហើយអ្វីដែលទង្វើនោះបានប្រព្រឹត្តនៅក្នុងខ្លួនយើង។

**២-ជនបរទេស ចូរនិយាយអំពីការសម្ងាត់ក្នុងចិត្តអ្នកប្រាប់ខ្ញុំមក ៖** មនុស្សម្នាក់ៗសុទ្ធតែមានអាថ៌កំបាំងដែលគេគិតមិនដល់។ ជាញឹកញយ សេចក្តីស្លាប់បង្ហាញឲ្យដឹងអំពីអត្ថន័យនៃជីវិតមួយ។ ប៉ុន្តែជួនកាលអាថ៌កំបាំងនោះលែងមានទៀតហើយ ដោយគេនិយាយប្រាប់យើងអំពីរឿងសម្ងាត់របស់គេ។ សូមនឹកគិតឡើងវិញ ហើយកត់ត្រាពេលវេលាណាដែលអ្នកណាម្នាក់ប្រាប់អំពីការសម្ងាត់របស់គេ អំពីប្រភពនៃការសម្ងាត់នោះ អំពីព្រះរបស់គេ...

**៣-អ្នកនិពន្ធម្នាក់សរសេរថា ៖** ខ្ញុំដឹងទាំងអស់នូវអ្វីៗដែលជារបស់មនុស្ស ហើយអ្វីៗដែលជារបស់មនុស្សនោះមិនចម្លែកចំពោះខ្ញុំទេ។ តើយើងទទួលការអះអាងនេះយ៉ាងដូចម្តេច?
ខ្ញុំទទួលយកអាថ៌កំបាំងរបស់ខ្ញុំ ព្រមទាំងអាថ៌កំបាំងនៃបងប្អូនប្រុសស្រី និងអាថ៌កំបាំងនៃពិភពលោក... ហួសពីអ្វីៗដែលអាចមើលឃើញ ខ្ញុំបើកចិត្តទៅរកព្រះជាម្ចាស់ ដែលខ្ញុំមើលមិនឃើញ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១-ព្រះជាម្ចាស់បានមកបែករំលែកលក្ខណៈជាមនុស្សនៅក្នុងព្រះយេស៊ូ។ ព្រះអង្គបានយាងចូលមកក្នុងពេលវេលា។ ព្រះអង្គបានស្គាល់អំណររីករាយ និងការទុក្ខព្រួយ សេចក្តីសង្ឃឹម និងការព្រួយបារម្ភ ជោគជ័យ និងបរាជ័យ ព្រមទាំងសេចក្តីស្លាប់ផងដែរ។

- សូមអានព្រះគម្ពីរដំណឹងល្អមួយ ហើយសូមបង្ហាញអំពីព្រះយេស៊ូនៅភូមិណាសារ៉ែត៖
- ជីវប្រវត្តិសង្ខេបមួយ (ការរៀនសូត្រ សមត្ថភាព សកម្មភាព)
- សេចក្តីពណ៌នា (បំណង់ចូលចិត្ត គុណសម្បត្តិ ទំនាក់ទំនង ទម្លាប់)

២-គ្រីស្តបរិស័ទប្រកាសអំពីព្រះយេស៊ូថា ព្រះអង្គជាព្រះបុត្រានៃព្រះជាម្ចាស់ប្រសូតជាមនុស្ស/មនុស្សផងព្រះជាម្ចាស់ផង/ជាព្រះជាម្ចាស់ពិតប្រាកដផង ជាមនុស្សពិតប្រាកដផង។ ទុកឲ្យពាក្យពេចន៍ទាំងនេះជ្រួតជ្រាបក្នុងចិត្តយើង ទុកឲ្យពាក្យនោះមកប៉ះទង្គិចចិត្តយើង។

៣-ព្រះជាម្ចាស់បានស្រឡាញ់មនុស្សលោកខ្លាំងណាស់ បានជាព្រះអង្គបានប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ (យហ ៣,១៦)។

- ព្រះអំណោយទាននេះ បង្ហាញឲ្យយើងនឹកអំពីឋានៈដ៏ថ្លៃថ្នូររបស់មនុស្ស។
- នៅចំកណ្តាលសភាពពិតប្រាកដនៃមនុស្ស ដែលព្រះយេស៊ូប្រកាសអំពីការសង្គ្រោះ។

## ព្រះអង្គប្រកាសការសង្គ្រោះនេះតាមរយៈ ៖

- ការងារនៃបុរស និងស្ត្រីទាំងឡាយ (លក ១៣,១៨-២១ ; មថ ១៣ ; យហ ១០,១-៥)
- ការរស់នៅក្នុងស្រែចម្ការ និងធម្មជាតិ (មថ ១៣,៤-៩ ; លក ១២,២២-៣២ ; មថ ១៣,២៤-៣០)
- អ្នកជិតខាង ក្មេងៗ អ្នកទារពន្ធ។ល។ (លក ១១,៥-៨ ; មក ១០,១៣-១៦ ; មថ ១៧,២៤-២៧)
- មិត្តភាពពិធីបុណ្យ (យហ ១១,១-៥ ; យហ ២,១-១២)

១ អ្នកជំងឺ ទុក្ខលំបាក (មថ៨ និង៩)។

៤- ដោយទៅជាដូចបងប្អូនរបស់ព្រះអង្គបេះបិទ (ហប ២,១៧) ព្រះយេស៊ូយកចិត្តទុកដាក់ចំពោះជីវិតជាមនុស្សរបស់យើង ដែលទទួលពីព្រះអង្គ បានៈថ្មីមួយ (យហ ១០,១០) ព្រះអង្គមានព្រះបំណងបន្តព្រះជន្មព្រះអង្គនៅក្នុងពួកយើង។

**សូមអានប្រស្នាទាំងពីរនោះ៖**

១ ដើមទំពាំងបាយជូរពិតប្រាកដ (យហ ១៥)

១ រូបកាយ (១ករ ១២)

**៥- សូមអាន ហើយស្មឹងស្មាធ៏អំពីអត្ថបទនោះ៖**

គ្រប់ពេលដែលអ្នករាល់គ្នាមិនបានធ្វើកិច្ចការនោះ ចំពោះបងប្អូនប្រុសស្រីតូចៗជាងគេរបស់ខ្ញុំ អ្នកក៏មិនបានធ្វើកិច្ចការនោះចំពោះរូបខ្ញុំដែរ -ប្រស្នាអំពីការកាត់ទោសនៅគ្រាចុងក្រោយបង្អស់ (**មថ** ២៥)។

ខ្ញុំបានធ្វើជាគំរូ ដើម្បីឲ្យអ្នករាល់គ្នាប្រព្រឹត្តដូចកាលដែលខ្ញុំធ្វើចំពោះអ្នករាល់គ្នាដែរ -ពិធីលាងជើង (យហ ១៣)។

៦- សន្តៈយ៉ូហានអើដ មានកម្មវិធីបង្កើតព្រះយេស៊ូនៅក្នុងខ្លួនយើង ហើយបន្តព្រះជន្មព្រះអង្គទៅតាមដែរ។ លោកបង្ហាញ និងស្នើសុំកម្មវិធីនេះ ឲ្យគ្រីស្តបរិស័ទទាំងអស់អនុវត្តតាម។ ដោយជាទំនាក់ទំនងដ៏សំខាន់បំផុត និងដ៏អាថ៌កំបាំងរវាងព្រះយេស៊ូ និងអវយវៈទាំងអស់នៃព្រះកាយព្រះអង្គ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យបង្ហាញព្រះជាម្ចាស់ក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ យើងពិតជាអាចធ្វើបាន ដ្បិតជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

ដូចសន្តៈប៉ូលមានប្រសាសន៍ថា ព្រះយេស៊ូដែលប្រសូតក្នុងចិត្តយើង ជាគម្រោងការដ៏អស្ចារ្យជាទីបំផុត៖ ម្នាលកូនចៅអើយ! ខ្ញុំរងទុក្ខលំបាកដូចជាស្ត្រីសម្រាលកូន ដើម្បីឲ្យព្រះគ្រីស្តប្រសូតក្នុងខ្លួនម្នាលកូនចៅ(កាឡ ៤,១៩)។ នេះគឺជាព្រះគម្រោងការដ៏អស្ចារ្យ និងជាស្នាព្រះហស្តដ៏ប្រសើរជាងគេ ដែលកើតមាននៅស្ថានបរមសុខ និងនៅលើផែនដីដោយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ រួមជាមួយព្រះនាងព្រហ្មចារីដ៏វិសុទ្ធបំផុត និងព្រះសហគមន៍ដ៏វិសុទ្ធផង។

ព្រះបិតាបំពេញសកម្មភាពធំធេងជាងគេ ក្នុងពេលដែលព្រះអង្គជាប់រវល់ជានិច្ច ដើម្បីប្រសូតព្រះបុត្រានៅក្នុងអង្គឯង ។ ក្រៅពីនេះ ព្រះអង្គធ្វើឲ្យព្រះបុត្រាចាប់កំណើតនៅក្នុងផ្ទៃនៃព្រហ្មចារិនី ជាកិច្ចការដ៏ប្រសើរបំផុតដែរ។ នៅពេលព្រះបុត្រាបានប្រសូតក្នុងព្រះមាតា និងនៅពេលអភិបូជា ព្រះអង្គបានប្រព្រឹត្តស្នាព្រះហស្តដ៏អស្ចារ្យ ហើយជាកិច្ចការដ៏ឧត្តុង្គឧត្តមបំផុតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។ ដោយរួមសហការជាមួយព្រះវិញ្ញាណក្នុងការប្រសូតព្រះបុត្រា ព្រះនាងម៉ារីបានប្រព្រឹត្តកិច្ចការដ៏អស្ចារ្យប្រសើរដែរ។ ឯព្រះសហគមន៍ដ៏វិសុទ្ធប្រព្រឹត្តកិច្ចការដ៏អស្ចារ្យបំផុត នៅពេលដែលព្រះសហគមន៍ថ្វាយអភិបូជា គឺនៅពេលដែលព្រះសហគមន៍ប្រសូតព្រះបុត្រាសព្វថ្ងៃ។

ហេតុដូច្នេះហើយ បានជាបំណងប្រាថ្នារបស់យើងក៏ដូច្នោះដែរ យើងត្រូវបំពេញកិច្ចការតែមួយ គឺសូមឲ្យយាងព្រះអង្គគង់នៅក្នុងចិត្តយើង សូមឲ្យព្រះអង្គមានព្រះជន្ម និងគ្រងរាជ្យក្នុងចិត្តយើង ដើម្បីឲ្យសេចក្តី

ស្រឡាញ់គុណធម៌ និងអារម្មណ៍របស់ព្រះអង្គគង់នៅក្នុងចិត្តយើងដែរ។

ខ្ញុំស្ញឹងស្ញាធឺលើអត្ថបទដំណឹងល្អ ដែលបានទាក់ទាញចិត្តរបស់ខ្ញុំ។
ខ្ញុំក្រាបថ្វាយបង្គំព្រះយេស៊ូ ជាព្រះភ័ក្ត្រ ជាមនុស្សនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។
ខ្ញុំត្រេកអរយ៉ាងខ្លាំង ចំពោះអ្វីៗទាំងអស់ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់
ដើម្បីឲ្យខ្ញុំរស់នៅក្នុងអង្គព្រះបុត្រា។

## ទុកពេល សម្រាប់ការលើកលែងទោស

១-ព្រះយេស៊ូយកព្រះទ័យទុកដាក់ខ្លាំងមែនទែន ចំពោះការរស់នៅជាមនុស្សរបស់ព្រះអង្គ។ តើយើងយកចិត្តទុកដាក់លើជីវិតជាមនុស្សរបស់យើង ក្នុងគ្រប់កិច្ចការទាំងអស់ហើយឬនៅ?

០ ជីវិតផ្ទាល់ខ្លួនរបស់យើង

០ ជីវិតអ្នកឯទៀត

២- ព្រះយេស៊ូមិនដែលឈប់មានទំនាក់ទំនងជាមួយនឹងព្រះបិតាទេ។
តើការត្រិះរិះរបស់យើងបានធ្វើឲ្យដឹងអំពីការផ្ដាច់រវាងជំនឿ និងជីវិតប្រចាំថ្ងៃរបស់យើងដែរឬទេ?

៣-ព្រះយេស៊ូមានព្រះបន្ទូលប្រាប់យើងថា៖ អ្វីៗដែលអ្នកប្រព្រឹត្តចំពោះអ្នកទន់ទាបជាងគេ គឺអ្នកបានប្រព្រឹត្តចំពោះខ្ញុំដែរ។
តើខ្ញុំជួបប្រទះនឹងការលំបាកអ្វីខ្លះ ដើម្បីបានស្គាល់ព្រះយេស៊ូនៅក្នុងអ្នកដទៃ?

៤-ខ្ញុំរកព្រះភ័ក្ត្ររបស់ព្រះអម្ចាស់
ខ្ញុំរកព្រះភ័ក្ត្ររបស់ព្រះអម្ចាស់នៅក្នុងដួងចិត្តបងប្អូន!
បងប្អូនជាព្រះកាយព្រះគ្រីស្ដ
បងប្អូនជាព្រះលោហិតព្រះគ្រីស្ដ
បងប្អូនជាសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ដ

## តើបងប្អូនបានធ្វើអ្វីខ្លះនឹងព្រះអង្គ?

គេបានតែងបទចម្រៀងនេះ ដើម្បីឲ្យសួរខ្លួនឯងថា តើយើងជាតំណាងព្រះគ្រីស្ដយ៉ាងដូចម្ដេចខ្លះ ក្នុងជីវិតយើង? តើនរណាខ្លះរង់ចាំពីយើងឲ្យបង្ហាញព្រះភ័ក្ត្រព្រះអង្គ តាមរយៈកិច្ចការ និងពាក្យសម្ដីយើង?

៥- ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យបន្តកាយវិការព្រះយេស៊ូក្នុងជីវិតយើងសព្វថ្ងៃ៖ តើយើងត្រូវកែប្រែចិត្តគំនិតអំពីអ្វីខ្លះ?
ខ្ញុំទទួលស្គាល់ថា នៅពេលខ្លះ ខ្ញុំប្រឆាំងនឹងព្រះជាម្ចាស់ ខ្ញុំបដិសេធមិនព្រមទទួលព្រះអង្គ
ខ្ញុំសូមឲ្យព្រះអង្គលើកលែងទោសឲ្យខ្ញុំ ហើយសូមអង្វរព្រះអង្គ ឲ្យព្រះយេស៊ូប្រសូតក្នុងចិត្តខ្ញុំ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- ព្រះយេស៊ូជាព្រះភ័ក្ត្រនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

សូមកត់ត្រាអំពីអ្វីដែលទាក់ទាញចិត្តខ្ញុំនៅក្នុងព្រះភ័ក្ត្រនេះ។

២- អ្នកដទៃជាព្រះភ័ក្ត្រនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែរ។

តើយើងនឹងប្រើមធ្យោបាយអ្វីខ្លះ ដើម្បីជួយយើងឲ្យយល់ឃើញថា អ្នកដទៃជាព្រះភ័ក្ត្រនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់?

យើងជាព្រះភ័ក្ត្រនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះអង្គក៏ត្រាស់ហៅយើងឲ្យបន្តជីវិតរបស់ព្រះយេស៊ូ។

*ខ្ញុំអធិដ្ឋានតាមអត្ថបទដូចខាងក្រោមនេះ ហើយខ្ញុំសួរខ្លួនឯងថា តើក្នុងពេលបច្ចុប្បន្ននេះ ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់តាមរបៀបណា?*

## ចំពោះអស់អ្នក ដែលបង្ហាញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់

ឱព្រះអម្ចាស់យេស៊ូអើយ!
ចំពោះអស់អ្នកដែលបង្ហាញព្រះភ័ក្ត្ររបស់ព្រះអង្គ
ដោយចាក់បង្ហូរសេចក្តីស្រឡាញ់របស់ព្រះអង្គ នៅក្នុងពិភពលោក
យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ។

ឱព្រះអម្ចាស់យេស៊ូអើយ!
ចំពោះអស់អ្នក ដែលបង្ហាញអំពីព្រះហស្តរបស់ព្រះជាម្ចាស់
ដោយប្រព្រឹត្តអំពើល្អសម្រាប់អ្នកដទៃ
យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ។

ឱព្រះអម្ចាស់យេស៊ូអើយ!
ចំពោះអស់អ្នកដែលបង្ហាញអំពីព្រះឱស្ឋរបស់ព្រះអង្គ
ដោយជួយការពារអ្នកទន់ទាប ដែលត្រូវគេជិះជាន់
យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ ។

ឱព្រះអម្ចាស់យេស៊ូអើយ!
ចំពោះអស់អ្នកដែលបង្ហាញអំពីព្រះនេត្ររបស់ព្រះជាម្ចាស់
ដោយកោតសរសើរគ្រាប់ពូជដ៏ល្អិតនៃសេចក្តីស្រឡាញ់ក្នុងចិត្តមនុស្ស
យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ។

ឱព្រះអម្ចាស់យេស៊ូអើយ!
ចំពោះអស់អ្នកដែលបង្ហាញអំពីព្រះបេះដូងរបស់ព្រះជាម្ចាស់
ដោយស្រឡាញ់អ្នកក្រីក្រខ្លាំងជាងអ្នកមាន ដោយស្រឡាញ់អ្នកទន់ទាបច្រើនជាងអ្នកកាន់អំណាច

យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ។

ឱព្រះអម្ចាស់យេស៊ូអើយ!

ចំពោះអស់អ្នក ដែលបង្ហាញអំពីព្រះហស្តរបស់ព្រះជាម្ចាស់

ដោយប្រព្រឹត្តអំពើល្អសម្រាប់អ្នកដទៃ

យើងខ្ញុំសូមអបអរសាទរចំពោះព្រះអង្គ។

ព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំអើយ! ព្រះអង្គជាព្រះដែលមានព្រះភ័ក្ត្ររាប់ពាន់ ក៏ប៉ុន្តែគ្មាននរណាម្នាក់អាចសម្តែងឲ្យច្បាស់បាន។ មានតែព្រះភ័ក្ត្រនៃព្រះកុមារនៅភូមិបេត្លេហិមប៉ុណ្ណោះ។ យើងខ្ញុំសូមទូលថ្វាយអង្វរព្រះអង្គ៖

សូមព្រះអង្គបន្តគម្រោងការដ៏អស្ចារ្យនៃបុណ្យព្រះយេស៊ូប្រសូតក្នុងជីវិតយើងខ្ញុំផង។ សូមឲ្យព្រះបុត្រាយេស៊ូចាប់កំណើតនៅក្នុងយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំទៅជាអ្នកសម្តែងសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះអ្នកដទៃ ដែលជាបងប្អូនរបស់យើងខ្ញុំផង។

# ដឹងខ្លួនថា បានទទួលការសង្គ្រោះ

ព្រះជាម្ចាស់បានប្រគល់ព្រះយេស៊ូ ដើម្បីជួយសង្គ្រោះពួកយើង!

## ដំណាក់កាលទី ៧

ព្រះជាម្ចាស់ជាព្រះសង្គ្រោះយើង បានសម្ដែងសប្បុរសធម៌ឲ្យយើងដឹងហើយ...

**ក្នុងដំណាក់កាលនេះមាន ៖** ខ្ញុំគ្មានសមត្ថភាព ដើម្បីចូលរួមក្នុងគម្រោងការនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់លើរូបខ្ញុំ និងលើពិភពលោក ដូចលោកអដាំកាលពីដើមកំណើតពិភពលោក ឬដូចប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស ឬដូចនៅពេលសម័យព្រះយេស៊ូ។

**ព្រះយេស៊ូមានព្រះបន្ទូលប្រាប់ខ្ញុំថា ៖** ខ្ញុំមកដើម្បីសង្គ្រោះអស់អ្នកដែលវង្វេង។ ដូច្នេះព្រះអង្គជួយសង្គ្រោះមនុស្សឲ្យបេះស្រឡាញ់គ្នាទៅវិញទៅមក

- យើងប្រព្រឹត្តអំពើបាប នៅពេលដែលយើងមិនព្រមធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់
- ដោយសារព្រះអង្គស្រឡាញ់ព្រះហឫទ័យព្រះបិតា ព្រះអង្គក៏បូជាព្រះជន្ម ដោយគ្មានអ្នកណាអាចយកព្រះជន្មព្រះអង្គបានឡើយ។

ព្រះអង្គបូជាព្រះជន្មព្រះអង្គដើម្បីសង្គ្រោះខ្ញុំអំពីការឥតន័យ ធ្វើឲ្យជីវិតខ្ញុំមានន័យ គឺរួបរួមជាមួយព្រះជាម្ចាស់ និងជាមួយបងប្អូនប្រុសស្រី។

ព្រះអង្គមានព្រះជន្មថ្មី ហើយនាំខ្ញុំ និងមនុស្សលោកឲ្យចូលរួមនៅក្នុងព្រះជន្មថ្មីរបស់ព្រះអង្គ។ យើងក៏បានរួបរួមជាមួយព្រះជាម្ចាស់ និងមនុស្សម្នាក់ជាថ្មីម្ដងទៀត។ ព្រះអង្គសង្គ្រោះយើងទាំងអស់គ្នា ព្រះអង្គសង្គ្រោះខ្ញុំ សង្គ្រោះយើង -នេះជាគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លង...

**គោលដៅនៃដំណាក់កាលនេះ ៖** ខ្ញុំធ្វើឲ្យប្រវត្តិនៃការសង្គ្រោះទៅជាប្រវត្តិរបស់ខ្ញុំផ្ទាល់...

...តាមរយៈប្រវត្តិនៃការសង្គ្រោះចំពោះប្រជាជនព្រះជាម្ចាស់ -ក្នុងព្រះគម្ពីរ... យល់ឲ្យច្បាស់ថា ខ្លួនខ្ញុំផ្ទាល់កើតនៅលើពិភពលោកនេះ ដែលព្រះជាម្ចាស់ស្រឡាញ់ និងសង្គ្រោះ។

សូមយល់ឃើញនូវអ្វីដែលត្រូវសង្គ្រោះក្នុងខ្លួនខ្ញុំ...ក្នុងការរស់នៅរបស់ខ្ញុំ...ក្នុងទំនាក់ទំនង ការជ្រើសរើសការងាររបស់ខ្ញុំ...ដើម្បីថ្វាយខ្លួនចំពោះព្រះជាម្ចាស់ជាព្រះសង្គ្រោះ។

...យល់ឃើញថា ជីវិតកើតចេញមកពីសេចក្ដីស្លាប់។

គម្រោងការនៃបុណ្យចម្លងចាក់ឫសក្នុងជាតិជាមនុស្សសុទ្ធសាធ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចយល់ឃើញថា តើព្រះយេស៊ូត្រូវសង្គ្រោះអ្វីខ្លះ ក្នុងជីវិត... ក្នុងចិត្តខ្ញុំ។

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១-ទុកពេលដើម្បីបើកចិត្ត និងទទួលខ្លួនឯង។ រកពេលណាខ្លះក្នុងជីវិតរបស់ខ្លួនយើងបានយល់ឃើញថាត្រូវការការសង្គ្រោះ។ តើពីអ្វីខ្លះយើងត្រូវបានគេសង្គ្រោះ? តើអ្នកណាបានសង្គ្រោះយើង? យ៉ាងដូចម្ដេច?

២-សូមរកអ្វីៗនៅក្នុងខ្លួន ដែលត្រូវការការសង្គ្រោះ៖ ក្នុងការងារ ក្នុងទំនាក់ទំនង ក្នុងជីវិតខាងវិញ្ញាណ។

៣-ក្នុងអ្វីៗដែលបានរៀបរាប់មកនេះ សូមរកមើលថា តើមានអ្វីខ្លះសង្កត់សង្កិនយើង ឬធ្វើឲ្យយើងបាត់បង់សេរីភាព?

ខ្ញុំរៀបរាប់ទូលព្រះជាម្ចាស់នូវអ្វីៗដែលមានក្នុងខ្លួនខ្ញុំ ដែលត្រូវការការសង្គ្រោះដើម្បីឲ្យបានជាសះស្បើយ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- ក្នុងបទចម្រៀងទំនុកតម្កើង ១១៨ សូមនឹកគិតអំពីប្រវត្តិនៃការសង្គ្រោះ។ សូមក្រឡេកមើល៖

- ព្រះជាម្ចាស់បានប្រព្រឹត្តិជាមួយប្រជាជនព្រះអង្គដូចម្ដេច?
- ព្រះជាម្ចាស់បានដឹកនាំពួកគេយ៉ាងដូចម្ដេច?
- ព្រះជាម្ចាស់បានរួមរស់ជាមួយពួកគេ ក្នុងគ្រាមានអាសន្នយ៉ាងដូចម្ដេច?
- ព្រះជាម្ចាស់បានសង្គ្រោះពួកគេយ៉ាងដូចម្ដេច?

២- ក្នុងព្រះគម្ពីរដំណឹងល្អ

- សូមអានការត្រាស់ហៅរបស់លោកម៉ាថាយ (មថ ៩,៩-១៣)
- សូមរកឲ្យឃើញឥរិយាបថរបស់ព្រះយេស៊ូចំពោះលោកម៉ាថាយ
- សូមអានក្នុង (លក ១៥,១-៧) រឿងនិទានអំពីកូនចៀមដែលវង្វេងបាត់ ហើយរកឃើញវិញផង។

៣- សូមរកឲ្យឃើញផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់នៅក្នុង

- ហប ១១
- អភ ១ ; ២ ; ៣

៤- ក្នុងអត្ថបទនេះ សន្តៈយ៉ូហាន អើដ ណែនាំយើងឲ្យបន្តស្នាព្រះហស្តនៃការសង្គ្រោះក្នុងខ្លួនយើង៖

ដោយយើងចាំបាច់ត្រូវបន្តព្រះជន្មដ៏វិសុទ្ធ និងឥតខ្ចោះរបស់ព្រះយេស៊ូនៅលើផែនដីនេះ យើងក៏ត្រូវតែស្លៀកដណ្ដប់ ទៅដោយមនោសញ្ចេតនា និងអារម្មណ៍របស់ព្រះយេស៊ូដដែលនេះដែរ ទៅតាមការប្រៀនប្រដៅរបស់គ្រីស្តទូតប៉ូល៖ សូមឲ្យអ្នករាល់គ្នាប្រកបដោយព្រះហឫទ័យរបស់ព្រះយេស៊ូគ្រីស្ត។ រីឯព្រះយេស៊ូគ្រីស្តព្រះ

អង្គមានព្រះហឫទ័យពីរបែប ដែលមានសភាពផ្ទុយគ្នាដាច់ស្រឡះ ដូច្នោះព្រះហឫទ័យប្រកបដោយសេចក្តីស្រឡាញ់ឥតគណនា ចំពោះព្រះបិតាព្រះអង្គ និងចំពោះយើង ហើយព្រះហឫទ័យស្អប់ខ្ពើមជាទីបំផុតចំពោះអ្វីៗដែលប្រឆាំងនឹងសិរីរុងរឿងរបស់ព្រះបិតាព្រះអង្គ និងការសង្គ្រោះរបស់យើងគឺថា ព្រះអង្គស្អប់ខ្ពើមអំពើបាប។ ដោយហេតុថាព្រះអង្គស្រឡាញ់ព្រះបិតា និងពួកយើងឥតគណនា ព្រះអង្គក៏ស្អប់ខ្ពើមអំពើបាបឥតគណនាដែរ។ ព្រះអង្គស្រឡាញ់ព្រះបិតាខ្លាំងណាស់ ហើយស្រឡាញ់ពួកយើងក៏ខ្លាំងណាស់ដែរ។ ព្រះអង្គបានបំពេញកិច្ចការធំៗឥតគណនារងទុក្ខលំបាកខ្លាំងៗជាទីបំផុត ហើយបានបូជាព្រះជន្មដ៏ថ្លៃថ្លាបំផុត ដើម្បីសិរីរុងរឿងរបស់ព្រះបិតា និងដើម្បីសេចក្តីស្រឡាញ់ចំពោះពួកយើង។ ផ្ទុយទៅវិញ ព្រះអង្គស្អប់ខ្ពើមអំពើបាបខ្លាំងមែនទែន។ ព្រះអង្គបានចុះពីស្ថានបរមសុខមកលើផែនដីនេះ ទ្រង់លះបង់ព្រះអង្គឯង ដោយក្លាយទៅជាអ្នកបម្រើព្រះអង្គមានព្រះជន្មរស់នៅសាមសិបប្អូនព្រះវស្សា ព្រះអង្គបានធ្វើការដោយមានគេមើលងាយ និងបានរងទុក្ខលំបាក ព្រះអង្គបានបង្ហូរព្រះលោហិតរហូតដល់ដំណាក់ចុងក្រោយ ហើយបានចូលទិវង្គត ក្នុងសភាពគួរឲ្យខ្មាស់អៀនជាទីបំផុត និងសាហាវព្រៃផ្សៃ។ ព្រះអង្គព្រមរងទុក្ខលំបាកបែបនេះ ព្រោះព្រះអង្គស្អប់ខ្ពើមអំពើបាប និងដើម្បីសម្រេចនូវព្រះបំណងដ៏ខ្លាំងក្លាបំផុតឲ្យលុបបំបាត់អំពើបាបពីពួកយើង។

## ព្រះរាជ្យព្រះយេស៊ូ

*ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ចំពោះវត្តមានព្រះអង្គ ដែលទ្រង់ជួយសង្គ្រោះប្រជាជនរបស់ព្រះអង្គនៅក្នុងប្រវត្តិសាស្ត្រ។*
*ខ្ញុំយល់ច្បាស់ថា ប្រវត្តិសាស្ត្រនៅតែបន្តដាប់រហូត ហើយខ្ញុំនៅក្នុងប្រវត្តិសាស្ត្រនេះ។ បច្ចុប្បន្ននេះ ព្រះជាម្ចាស់យាងមកសង្គ្រោះខ្ញុំទៅទៀត។*

## ទុកពេល សម្រាប់ការលើកលែងទោស

១- តើយើងជឿថា ព្រះយេស៊ូបានយាងមក ដើម្បីយើងផ្ទាល់ ឬ?

២- តើយើងជឿថា ព្រះយេស៊ូបានយាងមកសង្គ្រោះអ្វីៗដែលយើងវិនាសបាត់បង់ក្នុងខ្លួនយើង ឬ?

៣- តើយើងអាចយល់ឃើញអំពីអ្វី ដែលត្រូវការ...

- ការសង្គ្រោះ
- ការសម្រុះសម្រួល
- ការរំដោះ...ទៀតឬ?

៤- តើយើងបណ្តោយឲ្យព្រះយេស៊ូបំពេញកិច្ចការក្នុងចិត្ត ក្នុងខ្លួនយើង ឬ?

ដោយយល់ឃើញថា ខ្ញុំត្រូវការការសង្គ្រោះ ខ្ញុំបើកចំហរចិត្តមកឈរក្បែរឈើឆ្កាងព្រះគ្រីស្ត ដែលព្រះអង្គបានសុគត និងមានព្រះជន្មថ្មី ហើយខ្ញុំបណ្តោយឲ្យព្រះអង្គសង្គ្រោះខ្ញុំ ដោយយល់ព្រមឲ្យព្រះអង្គបំពេញកិច្ចការក្នុងខ្លួនខ្ញុំ។

**ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ...ដើម្បី...**

១- សរសេរអ្វីៗដែលយើងបានរកឃើញ អំពីតួនាទីរបស់យើងក្នុងប្រវត្តិនៃការសង្គ្រោះ។

២- កត់ចំណាំហេតុការណ៍ណាខ្លះ ដែលបានធ្វើឲ្យយើងឆ្លងពីសេចក្ដីស្លាប់ទៅដល់ជីវិត។

៣- ព្យាយាមសរសេរប្រវត្តិនៃការសង្គ្រោះរបស់ខ្លួនឯងផ្ទាល់។

៤- ក្នុងការរស់នៅប្រចាំថ្ងៃ តើយើងអាចទៅជាអ្នកសង្គ្រោះជាមួយព្រះយេស៊ូ ដើម្បីអ្នកឯទៀត?

៥- តើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើកិច្ចការអ្វីខ្លះ ដើម្បីជួយសង្គ្រោះអ្នកដទៃ?

*ខ្ញុំថ្វាយខ្លួនចំពោះព្រះយេស៊ូម្ដងទៀត ជាមួយនឹងអ្វីៗដែលខ្ញុំបានរកឃើញក្នុងខ្លួនខ្ញុំ ដែលត្រូវការការសង្គ្រោះ។*

*ខ្ញុំបណ្ដោយឲ្យព្រះអង្គបំពេញគម្រោងការដ៏អស្ចារ្យនៃបុណ្យចម្លងក្នុងខ្លួនខ្ញុំ។*

# ទទួលស្គាល់ថា ខ្លួនមកពីព្រះជាម្ចាស់

ខ្ពង់ខ្ពស់ម្ល៉េះទេ មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់!

**ដំណាក់កាលទី ៨**

ព្រះជាម្ចាស់បង្កើតផ្ទៃមេឃ និងផែនដី... ហើយទ្រង់ទតឃើញថា អ្វីៗទាំងអស់ល្អប្រសើរ (កណ ១)!

**ក្នុងដំណាក់កាលនេះមាន ៖** ព្រះជាម្ចាស់បង្កើតខ្ញុំជារូបតំណាង និងមានលក្ខណៈដូចព្រះជាម្ចាស់បេះបិទ... ព្រះអង្គមិនបានបង្កើតខ្ញុំនៅក្នុងអតីតកាលប៉ុណ្ណោះទេ។ ខ្ញុំត្រូវតែយល់ក្នុងចិត្តថា ព្រះជាម្ចាស់កំពុងបង្កើតខ្ញុំ។ បច្ចុប្បន្ននេះ ព្រះជាម្ចាស់កំពុងតែមានសកម្មភាព...ដោយសារព្រះអង្គជាសេចក្តីស្រឡាញ់ ព្រះអង្គមានព្រះហឫទ័យឲ្យមនុស្សលោក មានសេរីភាពចំពោះព្រះភ័ក្ត្រព្រះអង្គ។ ព្រះអង្គមានព្រះហឫទ័យឲ្យមនុស្សជាតិទាំងអស់ ទាំងប្រុសទាំងស្រី រួមសហការជាមួយព្រះអង្គក្នុងស្នាព្រះហស្តនេះ ដោយបង្កើតកូនចៅ និងអភិវឌ្ឍផែនដី។

**គោលដៅនៃដំណាក់កាលនេះ ៖** ខ្ញុំត្រូវទទួលស្គាល់ថា ព្រះជាម្ចាស់បង្កើតខ្ញុំ ហើយខ្ញុំត្រូវរួមសហការជាមួយព្រះអង្គ...

... តើខ្ញុំយល់អ្វីខ្លះអំពីការបង្កើត

... រកឲ្យឃើញអំពីខ្លួនខ្ញុំ តើខ្ញុំជានរណា?

...ទទួលយកខ្លួនខ្ញុំផ្ទាល់ថា ខ្ញុំជារូបតំណាងរបស់ព្រះជាម្ចាស់

... បើកចិត្តចំពោះអ្នកដទៃ... ចំពោះពិភពលោក...ចំពោះព្រះជាម្ចាស់

... ដឹងច្បាស់ថា ខ្ញុំបន្តស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

ចុងបញ្ចប់ដំណាក់កាលនេះ

ខ្ញុំត្រូវតែអាចវាយតម្លៃអំពីសមត្ថភាពរបស់ខ្ញុំ ឲ្យទទួលស្គាល់ខ្លួនឯង...

ខ្ញុំផ្ទៀងផ្ទាត់ថា តើបច្ចុប្បន្ននេះ ខ្ញុំបន្តស្នាព្រះហស្តរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច?

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- តើយើងយល់ថា ព្រះជាម្ចាស់ជាព្រះបង្កើតយ៉ាងដូចម្តេច?

២- តើយើងយល់យ៉ាងដូចម្តេចអំពីការបង្កើត?

- តាមវិទ្យាសាស្ត្រ? ដែលបានកើតឡើងក្នុងអតីតកាល? តាមព្រះគម្ពីរ? តាមបទពិសោធន៍បច្ចុប្បន្នរបស់យើង?
- តើយើងយល់យ៉ាងណាអំពីមនុស្សប្រុស និងមនុស្សស្រី? តើយើងយល់យ៉ាងដូចម្តេចអំពីមុខងាររបស់គេ៖ អភិវឌ្ឍផែនដី ត្រួតត្រាលើផែនដី...តើពាក្យពេចន៍នេះ ធ្វើឲ្យយើងនឹកឃើញអ្វី?

៣- តើយើងធ្លាប់បានដកពិសោធន៍ថា យើងជាអ្នកចូលរួមក្នុងការបង្កើតឬទេ? តើយើងមានបំណងអ្វីខ្លះ?

បំណងចង់ឲ្យខ្លួនមានប្រយោជន៍ ឲ្យយើងទៅជាអ្នកបង្កើតជាមួយព្រះជាម្ចាស់ ឲ្យយើងដឹងថា ខ្លួនយើងជាអ្នកណា យើងមកពីណា យើងមានប្រយោជន៍អ្វីខ្លះ?

ខ្ញុំបើកចិត្តទៅរកបំណងដែលខ្ញុំបានរកឃើញ ហើយរៀបចំបំណងទាំងនោះ ទៅតាមលំដាប់ថ្នាក់នៃអត្ថប្រយោជន៍របស់បំណងនោះ ក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ។ ខ្ញុំទទួលយកអារម្មណ៍ទាំងប៉ុន្មាន ដែលលេចឡើងក្នុងខ្លួនខ្ញុំ។ ខ្ញុំសម្រួលឥរិយាបថអធិដ្ឋាន ដើម្បីទុកពេលទំនេរទទួលព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗសព្វប្រការ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- នៅក្នុងសម្ពន្ធមេត្រីចាស់ មានពាក្យពេចន៍ជាច្រើនដែលនិយាយអំពីការបង្កើត។

- អានឡើងវិញ រឿងនិទានអំពីកំណើតពិភពលោក (កណ ១,១-៣១ ; ២,៤-២៥... )
- ព្យាយាមចាប់យកអារម្មណ៍របស់អ្នកនិពន្ធ ដែលពួកលោកផ្ទាល់បានសញ្ជឹងគិតអំពីព្រះជាម្ចាស់ ជាព្រះបង្កើត។
- យកប្រស្នាអំពីស្មូនឆ្នាំង ក្នុងអត្ថបទរបស់លោកយេរេមី (យេ ១៨,១-១២) ហើយនឹកស្មឹងស្មាធិ៍នូវអ្វីដែលកើតចេញពីប្រស្នានោះ។
- ជាមួយនឹងបទចម្រៀងទំនុកតម្កើង១៣៩ សូមសញ្ជឹងគិតថា តើខ្លួនយើងជានរណាចំពោះព្រះជាម្ចាស់?

២- នៅក្នុងសម្ពន្ធមេត្រីថ្មី ព្រះគម្ពីរដំណឹងល្អតាមសន្តៈយ៉ូហាន សូមយល់ឃើញថា ព្រះយេស៊ូជាព្រះបន្ទូលព្រះជាម្ចាស់ ដែលទ្រង់បង្កើតអ្វីៗទាំងអស់សព្វសារពើ (យហ ១)។

៣- សន្តៈយ៉ូហាន អើដ ក៏បានស្មឹងស្មាធិ៍អំពីព្រះគម្រោងការដ៏អស្ចារ្យ នៃការបង្កើតលោកនេះ៖

> មហាសាគរពុំអាចពន្លត់ភ្លើងនៃសេចក្តីស្នេហាបានឡើយ រីឯទន្លេទាំងប៉ុន្មានក៏ពុំអាចពន្លិចសេចក្តីស្នេហាបានដែរ ផ្ទុយទៅវិញ អ្នកណាយកទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់ខ្លួន ទិញសេចក្តីស្នេហា អ្នកនោះជាមនុស្សគួរឲ្យមើលងាយ (បច ៨,៧)។

ក្នុងព្រះអំណោយទានជាអនេក ដែលព្រះដ៏សប្បុរសបានប្រព្រឹត្តមកលើមនុស្សលោក ខ្ញុំកត់សម្គាល់ឃើញព្រះអំណោយទានបីដែលសំខាន់ និងធំធេងជាងគេ។ **ទីមួយ** វេលាដែលព្រះជាម្ចាស់បង្កើតមនុស្សលោកនៅពេលកើតផែនដី ព្រះអង្គមិនត្រឹមតែទាញមនុស្សចេញពីភាពសោះសូន្យប៉ុណ្ណោះទេ ព្រះអង្គបាននាំមនុស្សឲ្យទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គផងដែរ។ ព្រះអង្គប្រទានវិញ្ញាណ និងឆន្ទៈដល់មនុស្សដើម្បីឲ្យគេអាចស្គាល់ និងស្រឡាញ់ព្រះអង្គ តែងតាំងគេឲ្យចេះគ្រប់គ្រង និងមានអំណាចជាស្តេចលើអ្វីៗទាំងអស់នៅលើផែនដី។ ប៉ុន្តែដោយសារសប្បុរសធម៌ដ៏លើសលប់នេះ ព្រះអង្គមានព្រះបំណងចង់ឲ្យមនុស្សជារូបតំណាង និងមានលក្ខណៈដូចព្រះអង្គដែរ៖ ចូរយើងបង្កើតមនុស្សជារូបតំណាងរបស់យើងបេះបិទ (កណ ១,២៦)។ មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់ ហើយមានរូបរាងទ្រង់ទ្រាយ និងលក្ខណៈជាព្រះភ័ក្ត្រព្រះជាម្ចាស់។

## លោកនិយាយអំពីព្រះយេស៊ូថា ៖

តាំងពីពេលចាប់ផ្ដើមយាងចូលមកនៅក្នុងពិភពលោកម៉្លេះ ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃយើងបានប្រកាសថា ព្រះអង្គមិនធ្វើតាមព្រះហឫទ័យព្រះអង្គផ្ទាល់ទេ គឺព្រះអង្គប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះបិតាព្រះអង្គ តាមសក្ខីភាពពិតប្រាកដរបស់សន្ដះប៉ូល។ នៅពេលដែលព្រះយេស៊ូយាងមកចូលក្នុងពិភពលោក ព្រះអង្គមានព្រះបន្ទូលទៅព្រះបិតាថា ខ្ញុំចុះពីស្ថានបរមសុខមក ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ដែលបានចាត់ខ្ញុំឲ្យមក គឺពុំមែនធ្វើតាមបំណងចិត្តរបស់ខ្ញុំទេ (យហ ៦,៣៨ ; ហប ១០,៥)។

ខ្ញុំសូមអរព្រះគុណ...

...ព្រះជាម្ចាស់ជាព្រះបង្កើត

...ព្រះយេស៊ូដែលយាងមកពិភពលោកយើងនេះ ដើម្បីបង្ហាញឲ្យយើងដឹងអំពីរបៀបរស់នៅ ដែលឲ្យយើងបានបម្រើព្រះបិតាដូចព្រះអង្គ។

សូមឲ្យខ្ញុំដឹងច្បាស់ក្នុងចិត្តថា ខ្លួនខ្ញុំផ្ទាល់ក៏មានមុខងារក្នុងការបង្កើតនេះដែរ...។

ចូរឲ្យខ្ញុំប្រុងខ្លួនទុកជីវិតរបស់ខ្ញុំទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ចុះ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ពេលយើងដឹងច្បាស់ក្នុងចិត្តថា ព្រះជាម្ចាស់បង្កើតយើងជារូបតំណាង ហើយមានលក្ខណៈដូចព្រះអង្គដែរ យើងត្រូវយល់ឃើញថា ជីវិតយើង និងគោលបំណងរបស់ព្រះជាម្ចាស់មកលើរូបយើងខុសឆ្ងាយពីគ្នា។ យើងទាំងអស់គ្នាត្រូវការលើកលែងទោសចំពោះខ្លួនយើងផ្ទាល់ និងចំពោះអ្នកដទៃ។ តើយើងត្រូវប៉ះទង្គិចនឹងកំណត់ព្រំដែនណាខ្លះ...តើយើងត្រូវទទួលយកអ្វីខ្លះអំពីខ្លួនយើង? តើយើងត្រូវលើកលែងទោសអ្វីខ្លះឲ្យខ្លួនយើង?

២- យើងត្រូវបានណែនាំឲ្យពិនិត្យជីវិតយើងឡើងវិញ ដូចជាអ្នកចូលរួមចំណែកក្នុងការបង្កើតរបស់ព្រះជាម្ចាស់។ យើងសម្រុះសម្រួលជាមួយខ្លួនយើងផ្ទាល់ ដោយយកគោលបំណងរបស់ព្រះជាម្ចាស់មកលើជីវិតរបស់យើងទុកជាបំណងរបស់យើងផ្ទាល់ ដោយបោះបង់ចោលគំនិតក្លែងក្លាយអំពីខ្លួនយើង។

ខ្ញុំទុកពេលសម្រាប់ទទួលយកខ្លួនខ្ញុំតាមលក្ខណៈរបស់ខ្ញុំ។

មានថ្ងៃខ្លះ គ្មានអ្វីធ្ងន់ធ្ងរជាងទម្ងន់របស់ខ្លួនឯងផ្ទាល់ឡើយ... ខ្ញុំមិនញញើតនឹងបណ្ដោយឲ្យ...

...ការតូញត្អូរនៃចិត្តខ្ញុំងើបឡើង... ស្នាមរបួសនៃជីវិតខ្ញុំងើបឡើង

...ការមិនព្រមរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ងើបឡើង

ខ្ញុំទទួលស្គាល់ថា ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ។ ខ្ញុំសន្យាថា នឹងលះបង់ខ្លួនឯងចោល។

ខ្ញុំសូមឲ្យព្រះអង្គប្រោសប្រណីខ្ញុំ ឲ្យខ្ញុំបានពេញលក្ខណៈដូចព្រះយេស៊ូគ្រីស្ដ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- និពន្ធបទចម្រៀងរៀបរាប់អំពីសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ដោយយកគំរូតាមទំនុកតម្កើង ១៣៨, ៨,១០៣។ ក្នុងចម្រៀងនេះ សូមបង្ហាញនូវការកោតសរសើរចំពោះការបង្កើត ហើយសូមសម្ដែងអំពីបំណងប្រាថ្នាចង់ចូលរួមជាមួយព្រះជាម្ចាស់ ក្នុងការបង្កើតពិភពលោកបច្ចុប្បន្ននេះ។

២- យើងអាចយល់ច្បាស់ជាងមុនថា តើយើងជានរណា យើងបានទទួលយកខ្លួនយើង បានយល់ឃើញថា ព្រះជាម្ចាស់បានបង្កើតយើងជារូបតំណាងរបស់ព្រះអង្គ។ សូមប្រាប់អំពីអ្វីដែលយើងយល់ឃើញថា តើព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យបើកចិត្តទទួលអ្នកដទៃ...ទទួលព្រះជាម្ចាស់ថែមទៀត។

៣- មិនទាន់គ្រប់ទេ បើគ្រាន់តែថា មនុស្សគ្រប់រូបត្រូវបន្តស្នាព្រះហស្ដរបស់ព្រះជាម្ចាស់...ត្រូវតែធ្វើឲ្យកិច្ចការនោះ ក្លាយជាជាក់ស្ដែងថែមទៀត...តើយើងត្រូវផ្លាស់ប្ដូររបៀបរស់នៅយ៉ាងណា ដើម្បីបង្ហាញស្នាព្រះហស្ដរបស់ព្រះជាម្ចាស់? ចូរយើងដឹងឲ្យច្បាស់ថា ការសម្រុះសម្រួលជាមួយខ្លួនឯងនេះ នាំឲ្យយើងមានពេលទំនេរសម្រាប់អ្នកដទៃ និងសម្រាប់ព្រះជាម្ចាស់។

ព្រះអង្គបានប្រព្រឹត្តការអស្ចារ្យចំពោះរូបខ្ញុំ ព្រះហឫទ័យព្រះអង្គសប្បុរសណាស់!

ព្រះអង្គបានយកខ្ញុំតាំងពីក្នុងផ្ទៃម្ដាយមកម្ល៉េះ។

ជ្រោះជ្រៅនៃទុក្ខលំបាករបស់ខ្ញុំម្ចាស់បានស្រែកហៅរកជ្រោះជ្រៅ នៃព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

ព្រះហឫទ័យដ៏សប្បុរសនេះ បានឱបក្រសោបខ្ញុំជានិច្ច ដោយសារពរជ័យដ៏បវររបស់ព្រះអង្គ។

ព្រះអង្គបាំងព្រះហស្ដឲ្យខ្ញុំជ្រក

ព្រះអង្គថែរក្សាខ្ញុំដូចកែវព្រះនេត្រ!

ឱព្រះហឫទ័យពោរពេញទៅដោយសេចក្ដីស្រឡាញ់អើយ! ដែលជាប្រភពនៃអំពើល្អគ្រប់យ៉ាង

ព្រះអង្គប្រោសប្រទានឲ្យខ្ញុំម្ចាស់ នូវព្រះអំណោយទានច្រើនឥតគណនា!

ខ្ញុំម្ចាស់សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ

សូមឲ្យព្រះអង្គពោរពេញទៅដោយសេចក្ដីស្រឡាញ់ និងសិរីរុងរឿងយ៉ាងក្រៃលែង!

សូមមនុស្សគ្រប់ៗរូបច្រៀងកោតសរសើរព្រះអង្គ

សូមឲ្យចិត្តមនុស្សទាំងអស់ស្រឡាញ់គោរពព្រះអង្គ។

# បណ្ដោយខ្លួនទៅតាមសេចក្ដីស្រឡាញ់

ព្រះយេស៊ូប្រទានព្រះបេះដូងព្រះអង្គឲ្យយើង!

## ដំណាក់កាលទី ៩

ព្រះអង្គបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសម្រាប់ខ្ញុំ (កាឡ ២,២០)

**ក្នុងដំណាក់កាលនេះមាន** ៖ ព្រះបិតាបានស្រឡាញ់យើង រហូតដល់ហ៊ានប្រគល់ព្រះបុត្រាព្រះអង្គឲ្យយើង។ ដោយប្រគល់ព្រះបុត្រាព្រះអង្គ ព្រះអង្គបានប្រគល់អ្វីៗទាំងអស់ឲ្យយើង។ ព្រះយេស៊ូស្រឡាញ់យើង ដូចព្រះបិតាព្រះអង្គស្រឡាញ់យើងដែរ។ និមិត្តសញ្ញានៃព្រះបេះដូង ឬព្រះឈើឆ្កាង បង្ហាញយ៉ាងខ្លាំងអំពីសេចក្តីស្រឡាញ់រហូតដល់ទីបញ្ចប់។ សេចក្តីស្រឡាញ់បានបោះជំហានមករកយើងមុន។ ចូរយើងបណ្តោយឲ្យព្រះអង្គយាងមករកយើង ដើម្បីឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់បងប្អូនយើងជាមួយនឹងព្រះបេះដូងផ្ទាល់របស់ព្រះយេស៊ូ។

**គោលដៅនៃដំណាក់កាលនេះ** ៖ យល់ឃើញថា ព្រះជាម្ចាស់ស្រឡាញ់យើង...ដឹងឲ្យច្បាស់នូវគម្រោងការរបស់ព្រះជាម្ចាស់ ដើម្បីសង្គ្រោះមនុស្សជាតិទាំងមូលដើម្បីសង្គ្រោះខ្លួនខ្ញុំផ្ទាល់។

...សញ្ជឹងគិតទៅដល់ព្រះយេស៊ូរងទុក្ខលំបាក ការឈឺចាប់រហូតដល់ពេលសុគតរបស់ព្រះអង្គ និងសញ្ជឹងគិតទៅដល់ពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ។

...ទទួលយកការសង្គ្រោះនេះ ដោយប្រព្រឹត្តកិច្ចការ៖ ព្រះបេះដូងរបស់ព្រះយេស៊ូជានិមិត្តរូបនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចយល់ឃើញអំពីអ្វីដែលសម្តែងនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះរូបខ្ញុំ។

### ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- ត្រឡប់មករកអ្វីៗដែលយើងបានពិចារណាក្នុងដំណាក់កាលទី២វិញ "ពិនិត្យជីវិតខ្លួនឡើងវិញ" ដកស្រង់នូវអ្វីដែល បង្ហាញអំពីវត្តមានរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់យើង។ សម្គាល់ឲ្យច្បាស់ថា ក្នុងស្ថានភាពឬហេតុការណ៍នីមួយៗនៃជីវិតយើង តើព្រះអម្ចាស់សម្តែងឲ្យយើងឃើញព្រះភ័ក្ត្រព្រះអង្គបែបណា។ ក្នុងស្ថានភាពតឹងតែង (ពេលពិបាក) ពេលរងទុក្ខលំបាក តើយើងបានពិសោធន៍នូវវត្តមានរបស់ព្រះអម្ចាស់នេះឬទេ? ...ប្រសិនបើមាន តើពិសោធន៍យ៉ាងដូចម្តេច?

២- ឆ្លងកាត់រយៈពេលទាំងនោះ ព្យាយាមកត់សម្គាល់ឲ្យច្បាស់លាស់នូវដំណាក់កាលទាំងឡាយណា ដែលធ្វើឲ្យយើងរកឃើញព្រះជាម្ចាស់...

- តើយើងអាចនិយាយបានថា ព្រះភ័ក្ត្រពិតប្រាកដរបស់ព្រះជាម្ចាស់បានសម្ដែង បង្ហាញឲ្យយើងឃើញពីដំណាក់កាលមួយទៅដំណាក់កាលមួយបានឬទេ?...បង្ហាញយ៉ាងដូចម្ដេច?
- តើព្រះនាមព្រះជាម្ចាស់អ្វី ដែលយើងនឹកឃើញញឹកញាប់ជាងគេ? តើព្រះនាមមួយណាដែលយើងចងចាំជាងគេបច្ចុប្បន្ននេះ?

អ្នកណាពឹងផ្អែកលើកម្លាំងដែលមកពីព្រះអង្គ អ្នកនោះមានសុភមង្គលហើយ!
ដ្បិតគេធ្វើដំណើរឡើងទៅកាន់ព្រះដំណាក់របស់ព្រះអង្គដោយចិត្តស្មោះសរ។
ខ្ញុំប្រុងប្រៀបខ្លួនជានិច្ច ដើម្បីទទួលព្រះអម្ចាស់ ខ្ញុំទុកឲ្យព្រះអង្គបើកព្រះដំណាក់ឲ្យខ្ញុំ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- ត្រៀមខ្លួន ដើម្បី

- ស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ ដោយយកចិត្តទុកដាក់
- សញ្ជឹងគិតអំពីព្រះភ័ក្ត្រព្រះអម្ចាស់ ដែលសម្ដែងចេញដោយសារព្រះបន្ទូលនេះ...
- រកឲ្យឃើញគម្រោងការប្រកបដោយសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដើម្បីមនុស្សទាំងអស់...ដើម្បីខ្លួនយើងផ្ទាល់...

**ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកទាំងអស់ តាំងពីដំបូងមក៖**

«យើងស្គាល់អ្នកមុនពេលអ្នកកកើតក្នុងផ្ទៃម្ដាយ» (យេ ១,៥)
«យើងស្រឡាញ់អ្នក ដោយចិត្តស្រឡាញ់ ដែលស្ថិតស្ថេរនៅអស់កល្បជានិច្ច...» (យេ ៣១,៣)
«អ្នកមានតម្លៃដ៏លើសលប់ចំពោះយើង...»(អស ៤៣,១-៥)
«ព្រះអង្គក៏ហៅចំឈ្មោះខ្ញុំ» (អស ៤៩,១)

ដើម្បីសង្គ្រោះសត្វលោកទាំងអស់ ព្រះបិតាប្រោសប្រទានព្រះបុត្រាឲ្យយាងមក ដោយមានព្រះហឫទ័យស្រឡាញ់លើសអ្វីៗទាំងអស់។

«ព្រះជាម្ចាស់បានស្រឡាញ់មនុស្សលោកខ្លាំងណាស់ បានជាព្រះអង្គបានប្រោសប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក»(យហ ៣,១៦)
«ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់...ព្រះអង្គបានស្រឡាញ់យើងមុនយើងស្រឡាញ់ព្រះអង្គ...» (១យហ ៤,៧-១០)
«ព្រះបិតាបានចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមក ជាព្រះសង្គ្រោះមនុស្សលោក...» (១យហ ៤,១៤)
«ដល់ពេលកំណត់មកដល់...ព្រះជាម្ចាស់បានចាត់ព្រះបុត្រាព្រះអង្គឲ្យយាងមក...» (កាឡ ៤,៤)
«ព្រះអង្គមានព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់...» (១ធម ២,៤)

ព្រះយេស៊ូផ្ទាល់ស្រឡាញ់យើង និងលះបង់ព្រះជន្ម ដើម្បីសង្គ្រោះមនុស្សទាំងអស់។

«ព្រះអង្គស្រឡាញ់ខ្ញុំ ហើយបានបូជាព្រះជន្មសម្រាប់ខ្ញុំ» (កាឡ ២,២០)

«គ្មានអ្នកណាមានចិត្តស្រឡាញ់ធំធេងជាងអ្នក ដែលស៊ូប្ដូរជីវិត» (យហ ១៥,១៣)។

២- ដើម្បីឲ្យដឹងច្បាស់ថា តើព្រះយេស៊ូបានស្រឡាញ់យើងយ៉ាងណានោះ សូមអានអត្ថបទដំណឹងល្អពីទុក្ខលំបាករបស់ព្រះអង្គដោយ «ក្រសែភ្នែកថ្មី និងចិត្តថ្មី» (យហ ១១,៥៣-២១,២៥)។

សូមសញ្ជឹងគិតទៅដល់ព្រះយេស៊ូ នៅពេលព្រះអង្គរងទុក្ខលំបាក ដោយមានចិត្តស្រឡាញ់។ សូមបណ្ដោយខ្លួនយើងឲ្យលង់ចូលក្នុងទុក្ខលំបាកនៃសេចក្ដីស្រឡាញ់នេះ...ឲ្យយើងចេះដឹងគុណព្រះអង្គ អរព្រះគុណព្រះអង្គ។

៣- សន្ដៈយ៉ូហាន អើដ បានបណ្ដោយឲ្យសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ផ្លាស់ប្ដូរចិត្តលោក...នៅក្នុងពាក្យបណ្ដាំចុងក្រោយ គាត់ប្រគល់កម្មសិទ្ធិដ៏មានតម្លៃជាងគេឲ្យយើង គឺព្រះបេះដូងរបស់ព្រះយេស៊ូ និងព្រះនាងម៉ារីដែលជានិមិត្តរូបនៃសេចក្ដីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់ ចំពោះមនុស្សយើងគ្រប់រូប។

## « ខ្ញុំប្រគល់ព្រះបេះដូងនេះ ដែលជាកម្មសិទ្ធិរបស់ខ្ញុំ »

ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារព្រះកិត្តិនាម និងសម្ពន្ធមេត្រីដែលព្រះយេស៊ូរបស់ខ្ញុំបានធ្វើនៅថ្ងៃចុងក្រោយ នៃព្រះជន្មព្រះអង្គជាមនុស្សនៅលើផែនដីនេះ ខ្ញុំធ្វើពាក្យបណ្ដាំនេះ ដើម្បីតែសិរីរុងរឿងរបស់ព្រះជាម្ចាស់នៃខ្ញុំ ដែលមានបែបបទដូចតទៅ៖

ខ្ញុំថ្វាយខ្លួនយ៉ាងស្មោះស្ម័គ្រចំពោះព្រះសង្គ្រោះរបស់ខ្ញុំ ដើម្បីបង្រួបបង្រួមខ្ញុំទៅនឹងជំនឿគ្រប់លក្ខណៈនៃព្រះមាតាដ៏វិសុទ្ធក្រៃលែងរបស់ព្រះអង្គ គ្រីស្ដទូតរបស់ព្រះអង្គ សន្ដបុគ្គលទាំងឡាយ និងព្រះសហគមន៍ទាំងមូល ហើយដោយសារជំនឿនេះ ខ្ញុំសូមបញ្ជាក់ចំពោះមេឃ និងដីថា ខ្ញុំចង់ស្លាប់ទៅវិញ ក្នុងឋានៈជាកូនរបស់ព្រះសហគមន៍ដ៏វិសុទ្ធកាតូលិក ដែលមានក្រុមគ្រីស្ដទូតជាគ្រឹះ ហើយដោយស្ថិតនៅក្នុងជំនឿនៃគ្រីស្ដសាសនាដែលព្រះសហគមន៍នេះបង្រៀន។ ខ្ញុំសូមថ្វាយខ្លួនចំពោះព្រះជាម្ចាស់ដើម្បីរងទុក្ខលំបាក ទុក្ខព្រួយធំៗ និងសេចក្ដីស្លាប់ទាំងអស់ដែលកើតមានបាន។ ខ្ញុំសូមថ្វាយខ្លួនយ៉ាងអស់ពីចិត្តពីថ្លើម ចំពោះសេចក្ដីស្រឡាញ់ជាអនេក ដែលព្រះសង្គ្រោះខ្ញុំបានសុគតលើឈើឆ្កាងដើម្បីខ្ញុំ និងដើម្បីមនុស្សទាំងអស់ ហើយដោយសារសេចក្ដីស្រឡាញ់នេះ ខ្ញុំយល់ព្រមទទួលនូវការស្លាប់តាមកាល តាមកន្លែង និងតាមរបៀបដែលព្រះអង្គនឹងប្រទានមកឲ្យខ្ញុំដើម្បីជាកិច្ចសន្យា ជាការអរព្រះគុណចំពោះការសុគតដ៏វិសុទ្ធនៃព្រះមាតាប្រកបដោយសិរីរុងរឿង។ ដោយសារព្រះ ហឫទ័យដ៏វិសុទ្ធ សេចក្ដីស្រឡាញ់ និងទុក្ខលំបាកលើឈើឆ្កាងចំពោះខ្ញុំ ខ្ញុំសូមទូលអង្វរព្រះអង្គដោយសុភាពរាបសាថា ខ្ញុំសូមអង្វរព្រះអង្គសូមប្រោសប្រណីមកខ្ញុំឲ្យស្លាប់ក្នុងសេចក្ដីស្រឡាញ់ ដោយសារសេចក្ដីស្រឡាញ់ និងនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ ដោយសារបំណងប្រាថ្នាដ៏ធំធេងរបស់ខ្ញុំ ខ្ញុំសូមថ្វាយខ្លួនចំពោះសេចក្ដីស្រឡាញ់មិនអាចយល់បាន ដែលព្រះយេស៊ូ និងព្រះមាតាដ៏សប្បុរសរបស់ខ្ញុំប្រោសប្រទានមកខ្ញុំតាមរបៀបពិសេស ហើយដោយសារសេចក្ដីស្រឡាញ់ដដែលនេះ ខ្ញុំសូមថ្វាយព្រះបេះដូងដដែលនេះ ដូចជាអ្វីមួយដែលជារបស់ខ្ញុំ ហើយដែលខ្ញុំអាចប្រើប្រាស់ ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់របស់ខ្ញុំ។ ខ្ញុំនិយាយប្រាប់ទៅក្រុមគ្រួសារបព្វជិតរបស់ព្រះយេស៊ូ និងព្រះនាងម៉ារីថា ខ្ញុំថ្វាយព្រះបេះដូងនេះ ដើម្បីឲ្យព្រះបេះដូងនេះទៅជាកំណប់ជីវិត និងគំរូដល់បុត្រធីតាពិតប្រាកដ របស់ក្រុមគ្រួសារបព្វជិតនេះ។ ដូច្នេះខ្ញុំថ្វាយ និងឧទ្ទិសដល់ព្រះបេះដូងដ៏វិសុទ្ធនូវក្រុមគ្រួសារបព្វជិតនេះ ដើម្បីព្រះកិត្តិនាមដ៏ថ្លៃថ្លា និងសិរីរុងរឿងរបស់ព្រះអង្គក្នុង

ពេលនេះ និងទីស្ថានបរមសុខ។ ខ្ញុំសូមអង្វរបងប្អូនជាទីស្រឡាញ់របស់ខ្ញុំឲ្យខិតខំយ៉ាងណា ដើម្បីលើកតម្កើង និងធ្វើឲ្យគេលើកតម្កើងសិរីរុងរឿងដ៏វិសុទ្ធរបស់ព្រះអង្គតាមតែអាចធ្វើបាន។ សូមប្រារព្ធពិធីបុណ្យ និងថ្វាយតង្វាយទៅតាមថ្ងៃដែលយើងកំណត់ទុក ដោយគោរពកោតខ្លាចយ៉ាងជ្រាលជ្រៅតាមតែអាចធ្វើបាន។ សូមឲ្យសាសនៈទូតទាំងអស់នោះ ខិតខំរៀនសូត្រ រក្សាទុកក្នុងចិត្តនូវគុណធម៌នៃព្រះបេះដូងដ៏វិសុទ្ធនេះ ហើយសូមសម្លឹងព្រះបេះដូងនេះ ទុកដូចជាវិន័យនៃជីវិត ហើយសូមឲ្យគេថ្វាយខ្លួនចំពោះព្រះយេស៊ូ និងព្រះនាងម៉ារីក្នុងគ្រប់កិច្ចការដោយមានចិត្តស្រឡាញ់ និងសុភាពរាបសារ។ សូមឲ្យគេរៀបចំខ្លួន ដើម្បីទទួលបេះដូងដ៏វិសុទ្ធរបស់ព្រះអង្គ ដែលជាមធ្យោបាយឲ្យគេចេះស្រឡាញ់ និងលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ដោយមានទឹកចិត្តដ៏ស័ក្តិសមនឹង ព្រះអង្គ។ សូមឲ្យគេទៅជាបុត្រធីតាដ៏ពិតប្រាកដរួមជាមួយព្រះយេស៊ូ និងព្រះនាងម៉ារីទៅតាមព្រះហឫទ័យព្រះជាម្ចាស់។ ខ្ញុំសូមប្រគល់ព្រះបេះដូងដ៏ថ្លៃថ្លានេះ ជូនទៅកូនស្រីទាំងអស់របស់ខ្ញុំ ដែលជាដូនជីក្នុងអារាមផ្សេង។ ខ្ញុំសូមសន្យានឹងអ្នកទាំងអស់នោះថា ប្រសិនបើព្រះសង្គ្រោះប្រោសប្រណីដល់ខ្ញុំ ដូចដែលខ្ញុំធ្លាប់សង្ឃឹមនៅស្ថានបរមសុខ ខ្ញុំប្បាស់ជានឹងថែទាំបងប្អូនទាំងអស់នោះ។ ខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់ និងមេត្តាករុណា ឲ្យខ្ញុំបានចូលរួមជាមួយព្រះមាតាព្រហ្មចារីយ៍ដ៏វិសុទ្ធ។ ទីបំផុតខ្ញុំសូមប្រគល់ខ្លួនទាំងស្រុងថ្វាយចំពោះព្រះយេស៊ូជាទីស្រឡាញ់របស់ខ្ញុំ ដើម្បីរួបរួមជាមួយកិច្ចការដ៏វិសុទ្ធទាំងឡាយរបស់ព្រះអង្គ ព្រះមាតាដ៏វិសុទ្ធ និងសន្តបុគ្គលទាំងអស់ ដែលបានបាត់បង់ជីវិតទៅហើយនោះ។ នៅថ្ងៃចុងក្រោយ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមានបំណងឲ្យដង្ហើមចុងក្រោយរបស់ខ្ញុំ ជាកាយវិការដ៏បរិសុទ្ធមួយបង្ហាញនូវសេចក្តីស្រឡាញ់របស់ខ្ញុំចំពោះព្រះអង្គ និងទូលអង្វរសុំឲ្យព្រះអង្គទទួល និងរក្សាទុកឲ្យខ្ញុំនូវអារម្មណ៍ទាំងនោះ នៅពេលខ្ញុំស្លាប់។

*សូមទទួលយកអំណោយដ៏ថ្លៃថ្លាបំផុតនេះ!*

ដោយសញ្ជឹងគិតអំពីសេចក្តីស្រឡាញ់ឥតគណនាក្នុងព្រះបេះដូងព្រះជាម្ចាស់
ខ្ញុំបណ្តោយខ្លួនឲ្យសិរីរុងរឿងដ៏ចិញ្ចែងចិញ្ចាចនៃធម៌មេត្តាករុណា
នៃព្រះហឫទ័យដ៏ស្លូតបូតរបស់ព្រះអង្គឲ្យជ្រាបចូលទៅក្នុងចិត្តខ្ញុំ

...មានតែព្រះអង្គទេ ដែលអាចបំពេញចិត្តយើងបាន
... មានតែព្រះអង្គទេ ដែលអាចដាក់ចិត្តថ្មីមួយទៀត ឲ្យយើង
...ដែលជាចិត្តពោរពេញដោយសេចក្តីស្រឡាញ់
...មានតែព្រះអង្គទេ ដែលអាចដាក់ឲ្យយើងនូវព្រះវិញ្ញាណនៃព្រះយេស៊ូ ដែលជាវិញ្ញាណនៃសេចក្តីស្រឡាញ់
...មានតែព្រះអង្គទេ ដែលអាចជំរុញយើងឲ្យស្ថិតនៅក្នុងសេចក្តីស្រឡាញ់។

## ទុកពេល សម្រាប់ការលើកលែងទោស

១-ព្រះអម្ចាស់ជាព្រះប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងប្រណីសន្តោស ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ ហើយពោរពេញទៅដោយព្រះហឫទ័យមេត្តាករុណា និងស្មោះស្ម័គ្រជានិច្ច ( សរ ៣៤,៦ )

ព្រះអម្ចាស់មានព្រះហឫទ័យពោរពេញទៅដោយធម៌មេត្តាករុណា...ដូចឪពុករបស់កូនពៅវង្វេង ( លក ១៥, ២០-២៤ )។

ចូរបណ្ដោយខ្លួនឲ្យព្រះហឫទ័យដ៏សប្បុរសរបស់ព្រះអម្ចាស់ស្រឡាញ់យើង។

២- សូមព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ (មថ ៦,១២)។ អ្នកមានចិត្តស្រឡាញ់ អ្នកនោះចេះលើកលែងទោស។ កាលដែលយើងទទួលការលើកលែងទោសពីព្រះអម្ចាស់ ហេតុដូចម្ដេចបានជាយើងមិនព្រមលើកលែងទោសឲ្យអ្នកដទៃ? សូមនឹកគិតដល់អស់អ្នកដែលយើងត្រូវលើកលែងទោសឲ្យ...ជាពិសេសអស់អ្នកដែលយើងពិបាកលើកលែងទោស...។ គិតមើលថា ជាក់ស្ដែង តើយើងនឹងប្រព្រឹត្តដូចម្ដេច...តើយើងអាចប្រើកាយវិការបែបណា...

ខ្ញុំនឹងដាក់ចិត្តថ្មីឲ្យអ្នករាល់គ្នា ខ្ញុំនឹងដាក់វិញ្ញាណថ្មីក្នុងចិត្តអ្នករាល់គ្នា (សរ ៣៦,២៦)

ខ្ញុំដឹងច្បាស់ថា ទឹកចិត្តខ្ញុំពិតជាខ្សោយ...

- ខ្ញុំស្ទាក់ស្ទើរមិនជឿថា ព្រះជាម្ចាស់ស្រឡាញ់រូបខ្ញុំផ្ទាល់
- ខ្ញុំមិនប្រញាប់បើកចិត្តទទួលសេចក្ដីស្រឡាញ់នេះ ដែលចង់តែមកគ្របដណ្ដប់ខ្ញុំ និងចង់ប្រែខ្ញុំ
- ខ្ញុំស្រឡាញ់ព្រះជាម្ចាស់វិញ តែតិចតួចប៉ុណ្ណោះ
- ហើយខ្ញុំឃើញថា ខ្ញុំមិនឆ្លុះសេចក្ដីស្រឡាញ់នេះឲ្យបានល្អត្រឹមត្រូវ ក្នុងទំនាក់ទំនងជាមួយអ្នកដទៃ
- ខ្ញុំខ្លាចរងទុក្ខលំបាកបន្តិចបន្តួចក៏ដោយ ដើម្បីឆ្លើយតបនឹងសេចក្ដីស្រឡាញ់នេះ
- កិច្ចការរបស់ខ្ញុំមិនស្របនឹងពាក្យសម្ដី ដើម្បីប្រកាសសេចក្ដីស្រឡាញ់នេះ ក្នុងជីវិតជាក់ស្ដែងរបស់ខ្ញុំ។

**ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...**

១- សន្តៈយ៉ូហាន អើដ ជាគ្រីស្តទូត ដែលមានបំណងយ៉ាងខ្លាំងក្លា ឲ្យគេស្គាល់សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ លោកណែនាំយើងឲ្យអធិដ្ឋានតាមរបៀបរបស់គាត់។ ចូរយើងទុកឲ្យលោកបង្រៀនយើងឲ្យចេះអធិដ្ឋាន...

## ព្រះអង្គប្រទានព្រះបេះដូងមកយើង ដែលជាឫសនៃព្រះអំណោយទានឯទៀតៗ។

ចូរគោរពស្រឡាញ់ព្រះសង្គ្រោះដ៏ជាទីស្រឡាញ់របស់យើង ជាព្រះដ៏សប្បុរសក្រៃលែង ពោរពេញដោយសេចក្ដីស្រឡាញ់ដ៏ធំទូលំទូលាយចំពោះយើង។ តើអ្វីខ្លះ ដែលធំទូលំទូលាយនោះ? នោះគឺព្រះអង្គប្រទានយើងជីវិតជាមួយនឹងអ្វីៗជាច្រើនទៀត ដែលមានប្រយោជន៍សម្រាប់យើង។ ព្រះអង្គប្រទានពិភពលោកដ៏ធំនេះ ពោរពេញទៅដោយវត្ថុជាច្រើនប្លែកៗគ្នា ដែលចាំបាច់សម្រាប់ឲ្យយើងប្រើប្រាស់ ហើយថែមទាំងទុកឲ្យយើងកម្សាន្តសប្បាយទៀតផង។ ព្រះអង្គប្រទានទេវទូត របស់ព្រះអង្គជាច្រើនអង្គ ដើម្បីការពារពួកយើង។ ព្រះអង្គប្រទានជនដ៏វិសុទ្ធជាច្រើននាក់មកឲ្យយើង ដែលជាស្មារតី និងជាអ្នកនាំពាក្យទូលអង្វរយើងថ្វាយព្រះជាម្ចាស់។ ព្រះអង្គប្រទានព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គ មកជាម្ដាយដ៏សប្បុរសរបស់យើង។ ព្រះអង្គប្រទានអគ្គសញ្ញាទាំងអស់មកយើង និងគម្រោងការដ៏អស្ចារ្យនៃព្រះសហគមន៍របស់ព្រះអង្គមកយើង ដើម្បីសង្គ្រោះ និងប្រោសយើងឲ្យបានវិសុទ្ធ។ ព្រះអង្គប្រទានព្រះបិតាព្រះអង្គ ដែលមានព្រះជន្មអស់កល្បជានិច្ច មកជាឪពុកពិតប្រាកដរបស់យើង។ ទ្រង់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទុកជាពន្លឺបំភ្លឺផ្លូវឲ្យយើង។ ព្រះអង្គប្រទានព្រះគំនិតទាំងអស់ ព្រះបន្ទូលកិច្ចការទាំងអស់របស់ព្រះអង្គ និងទុក្ខលំបាកទាំងអស់ព្រមទាំងព្រះជន្ម ដែលព្រះអង្គលះបង់ដើម្បីយើងទាំងអស់គ្នា រហូតដល់ដំណក់ចុងក្រោយនៃព្រះលោហិតរបស់ព្រះអង្គ។

ក្រៅពីនោះ ព្រះអង្គប្រទានមកយើងនូវព្រះបេះដូងគួរឲ្យស្រឡាញ់ ដែលជាដើមហេតុ និងឫសគល់នៃព្រះអំណោយទានឯទៀត ដ្បិតគឺជាព្រះបេះដូងនៃព្រះអង្គ ដែលបានធ្វើឲ្យព្រះអង្គចេញពីព្រះបិតាព្រះអង្គ ហើយ ដែលបានធ្វើឲ្យព្រះអង្គយាងមកដល់លើផែនដី ដើម្បីប្រោសប្រណីពួកយើង។ គឺដោយសារព្រះបេះដូងនេះ ក្នុងឋានៈជាមនុស្សផង ជាព្រះជាម្ចាស់ផង ដែលបានជួយសង្គ្រោះយើងដោយសារទុក្ខលំបាក និងការព្រួយបារម្ភសព្វគ្រប់ ដែលព្រះអង្គទ្រាំទ្រ វេលាដែលព្រះអង្គមានព្រះជន្មនៅលើពិភពលោកនេះ។ ក្រៅពីនេះ តើយើងមានអ្វីសងទៅព្រះសង្គ្រោះដ៏ស្លូតបូតនេះ? ចូរយើងសងសេចក្តីស្រឡាញ់ ចំពោះសេចក្តីស្រឡាញ់ ទឹកចិត្តចំពោះព្រះហឫទ័យរបស់ព្រះអង្គវិញ។

ហេតុនេះហើយ ចូរយើងថ្វាយតង្វាយចំពោះព្រះអង្គ ហើយប្រគល់ទឹកចិត្តដ៏ស្មោះស្ម័គ្ររបស់យើងថ្វាយព្រះអង្គ ដូចកាលព្រះអង្គប្រគល់ព្រះបេះដូងព្រះអង្គឲ្យយើងដែរ។ ព្រះអង្គបានប្រគល់ព្រះបេះដូងទាំងស្រុងមកយើង ចូរយើងថ្វាយទឹកចិត្តរបស់យើងទាំងស្រុង ដោយគ្មានលាក់លៀមទៅព្រះអង្គវិញ។ ព្រះអង្គប្រទានព្រះបេះដូងព្រះអង្គមកយើងជារៀងរហូត យើងថ្វាយទឹកចិត្តរបស់យើងជារៀងរហូតឥតប្រែប្រួល។ ព្រះអង្គបានប្រទានព្រះបេះដូងមកយើងពោរពេញទៅដោយសេចក្តីស្រឡាញ់ជាអនេក យើងថ្វាយចំពោះព្រះអង្គវិញនូវទឹកចិត្តរបស់យើងពោរពេញទៅដោយសេចក្តីស្រឡាញ់ជាអនេកនោះដែរ។ ព្រះអង្គមិនត្រឹមតែប្រទានព្រះបេះដូងព្រះអង្គទេ ថែមទាំងប្រទានព្រះបេះដូងនៃព្រះបិតាអស់កល្បជានិច្ចព្រះបេះដូងនៃព្រះមាតាដ៏វិសុទ្ធ ព្រះបេះដូងនៃទេវទូតទាំងនោះ ទឹកចិត្តរបស់សន្តបុគ្គលទាំងអស់របស់ព្រះអង្គ និងទឹកចិត្តមនុស្សនៅលើសកលលោកនេះ ពីព្រោះព្រះអង្គសូមឲ្យពួកគេស្រឡាញ់ពួកយើងដូចខ្លួនគេដែរ គឺស្រឡាញ់ឲ្យដូចព្រះអង្គបានស្រឡាញ់ពួកយើង។ នេះជាវិន័យរបស់ខ្ញុំ ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ (យហ ១៥, ១២)។ ចូរយើងថ្វាយព្រះបេះដូងនៃព្រះបិតាអស់កល្បជានិច្ច ព្រះបេះដូងព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះអង្គ ព្រះបេះដូងនៃទេវទូតទាំងឡាយ ទឹកចិត្តរបស់សន្តបុគ្គល និងរបស់មនុស្សទាំងអស់ដែរ។ ដោយហេតុថា យើងមានសិទ្ធិយកព្រះបេះដូង និងទឹកចិត្តទាំងនោះ មកប្រើដូចជារបស់ខ្លួនយើងផ្ទាល់ ពីព្រោះគ្រីស្តទូតប៉ូលជានាប្រាប់យើងថា ព្រះបិតាបានប្រទានមកយើងនូវអ្វីៗទាំងអស់ ដោយទ្រង់បានប្រគល់ព្រះបុត្រាព្រះអង្គមកយើង (រម ៨,៣២) ហើយអ្វីៗទាំងអស់នោះ ជារបស់យើងដែរ (១ករ ៣,២២)។ ប៉ុន្តែជាពិសេស ចូរយើងថ្វាយចំពោះព្រះអង្គនូវព្រះបេះដូងរបស់ព្រះអង្គផ្ទាល់ ដោយហេតុថា ព្រះអង្គបានប្រទានព្រះបេះដូងនោះមកយើងដូច្នេះ ព្រះអង្គក៏ជារបស់យើង ហើយយើងមិនដឹងថា ត្រូវថ្វាយអ្វីផ្សេងទៀតទៅវិញ ដើម្បីឲ្យព្រះអង្គរីករាយទេ ដ្បិតពេលយើងថ្វាយព្រះបេះដូងរបស់ព្រះអង្គ យើងក៏ថ្វាយព្រះបេះដូងនៃព្រះបិតារបស់ព្រះអង្គទៅព្រះអង្គវិញ ដែលជាព្រះបេះដូងតែមួយរបស់ព្រះបិតា និងព្រះបុត្រា។ ពេលនោះ យើងថ្វាយព្រះបេះដូងព្រះមាតាដ៏វិសុទ្ធក្រៃលែងថែមទៀត ដែលជាព្រះបេះដូងរបស់ព្រះបុត្រាផងដែរ ដោយមានព្រះបំណង និងសេចក្តីស្រឡាញ់រួមគ្នា។

**២-** ព្រះយេស៊ូប្រគល់ព្រះបេះដូងព្រះអង្គឲ្យយើង ដើម្បីបង្គ្រប់នឹងសេចក្តីស្រឡាញ់របស់យើង មិនសូវចេះស្រឡាញ់។ នៅពេលអធិដ្ឋានផ្ទាល់ខ្លួន សូមទទួលស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ចំពោះយើង... សូមបង្ហាញសេចក្តីស្រឡាញ់របស់យើងថ្វាយព្រះអង្គ...ចូរថ្វាយទឹកចិត្តយើងផ្ទាល់ចំពោះព្រះអង្គ ដើម្បីឲ្យព្រះអង្គប្រែចិត្តឲ្យពោរពេញទៅដោយសេចក្តីស្រឡាញ់...ចូរថ្វាយខ្លួនចំពោះព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គយាងមក

ស្រឡាញ់គេតាមរយៈយើង និងនៅក្នុងយើង... ចូរថ្វាយព្រះបេះដូងពោរពេញទៅដោយសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ និងព្រះនាងម៉ារីដើម្បីបង្គ្រប់សេចក្ដីស្រឡាញ់របស់យើង...

៣- គ្មាននរណាមានចិត្តស្រឡាញ់ខ្លាំងជាងអ្នក ដែលស៊ូប្ដូរជីវិត (យហ ១៥,១៣)

តើយើងអាចឈានទៅមុខថែមទៀត ក្នុងការថ្វាយខ្លួនយើងនេះ? តើយើងអាចបង្ហាញអំពីសេចក្ដីស្រឡាញ់នេះក្នុងជីវិតរបស់យើងឲ្យច្បាស់លាស់ជាងមុនបានយ៉ាងដូចម្ដេច?

៤- សន្តៈយ៉ូហានអើដ បានរៀបរៀងសេចក្ដីអធិដ្ឋានមួយយ៉ាងល្អអស្ចារ្យ ដែលបង្ហាញអំពីមុខមាត់ច្រើនប្រការនៃសេចក្ដីស្រឡាញ់នៃព្រះបេះដូងរបស់ព្រះយេស៊ូ និងព្រះនាងម៉ារី។

សេចក្ដីអធិដ្ឋាននេះ ក៏បានបញ្ជាក់អំពីមុខមាត់ច្បាស់លាស់ ដែលជាសេចក្ដីស្រឡាញ់ អាចកើតមាននៅក្នុងខ្លួនយើង... ប្រសិនបើយើងចូលចិត្ត សូមអានសេចក្ដីអធិដ្ឋាននេះ ដើម្បីសញ្ជឹងគិតអំពីសេចក្ដីស្រឡាញ់ ហើយ សូមបណ្ដោយឲ្យចិត្តថ្មីមួយទៀត យកតម្រាប់តាមសេចក្ដីអធិដ្ឋាននេះ...

យើងសូមវន្ទាចំពោះព្រះបេះដូងដ៏វិសុទ្ធបំផុត
យើងសូមវន្ទាចំពោះព្រះបេះដូងដ៏ស្លូតបូតបំផុត
យើងសូមវន្ទាចំពោះព្រះបេះដូងដ៏សុភាពរាបសារបំផុត
យើងសូមវន្ទាចំពោះព្រះបេះដូងដ៏បរិសុទ្ធបំផុត
យើងសូមវន្ទាចំពោះព្រះបេះដូង ដែលលះបង់អ្វីៗទាំងអស់ឥតលាក់ទុក
យើងសូមវន្ទាចំពោះព្រះបេះដូងប្រកបដោយព្រះប្រាជ្ញាញាណ
យើងសូមវន្ទាចំពោះព្រះបេះដូងដ៏មានអំណត់បំផុត
យើងសូមវន្ទាចំពោះព្រះបេះដូង ដែលចេះស្ដាប់បង្គាប់
យើងសូមវន្ទាចំពោះព្រះបេះដូង ដែលចេះប្រុងប្រយ័ត្ន
យើងសូមវន្ទាចំពោះព្រះបេះដូង ដែលមានភក្ដីភាព
យើងសូមវន្ទាចំពោះព្រះបេះដូង ដែលមានសុភមង្គល
យើងសូមវន្ទាចំពោះព្រះបេះដូង ពោរពេញទៅដោយធម៌មេត្តាករុណា
យើងសូមវន្ទាចំពោះព្រះបេះដូង ពោរពេញទៅដោយសេចក្ដីស្រឡាញ់នៃព្រះយេស៊ូ និងព្រះមាតា
យើងសូមថ្វាយបង្គំចំពោះព្រះបេះដូងព្រះអង្គ
យើងសូមកោតសរសើរចំពោះព្រះបេះដូងព្រះអង្គ
យើងសូមលើកតម្កើងសិរីរុងរឿងព្រះបេះដូងព្រះអង្គ
យើងសូមអរព្រះគុណចំពោះព្រះបេះដូងព្រះអង្គ
យើងស្រឡាញ់ព្រះបេះដូងព្រះអង្គ

អស់ពីដួងចិត្តរបស់យើង
អស់ពីព្រលឹងរបស់យើង
និងអស់ពីកម្លាំងកាយកម្លាំងចិត្តយើង។
យើងសូមថ្វាយចិត្តគំនិតរបស់យើងចំពោះព្រះបេះដូងព្រះអង្គ

យើងសូមប្រគល់ថ្វាយចិត្តគំនិតនេះ
យើងបូជាថ្វាយចិត្តគំនិតយើងចំពោះព្រះបេះដូងព្រះអង្គ
យើងលះបង់ចិត្តគំនិតចំពោះព្រះបេះដូងព្រះអង្គ
សូមព្រះអង្គទទួលទឹកចិត្តនេះទាំងស្រុង
សូមបន្សុទ្ធទឹកចិត្តនេះផង
សូមបំភ្លឺទឹកចិត្តនេះផង
សូមប្រោសទឹកចិត្តនេះឲ្យបានវិសុទ្ធផង
សូមបង្ហាញតេជានុភាពរបស់ព្រះអង្គ
ហើយសូមព្រះអង្គមានព្រះជន្មគង់នៅ និងគ្រងរាជ្យក្នុងចិត្តនេះ នៅពេលនេះ ជារៀងរហូត និងអស់កល្ប
ជានិច្ចផង។ អាម៉ែន។

# រៀនអធិដ្ឋាន

យើងបន្តអធិដ្ឋានរបស់ព្រះយេស៊ូ នៅពេលដែលយើងអធិដ្ឋាននៅក្នុងអង្គព្រះវិញ្ញាណរបស់ព្រះយេស៊ូ... ដូចព្រះអង្គផ្ទាល់បានអធិដ្ឋាន... និងដូចព្រះអង្គគួរតែអធិដ្ឋានប្រសិនបើព្រះអង្គជាយើងវិញ

## ដំណាក់កាលទី ១០

ព្រះអម្ចាស់អើយ! សូមបង្រៀនយើងឲ្យចេះអធិដ្ឋានផង ( លក ១១,)

**ក្នុងដំណាក់កាលនេះមាន ៖** ពេលយើងអធិដ្ឋាន យើងព្យាយាមឆ្លើយតបនឹងអ្នកដែលមានសេចក្ដីស្រឡាញ់បានទាក់ទាញយើង។ ត្រូវតែរៀនអធិដ្ឋានដោយដឹងថា ចាំបាច់ខ្ញុំមិនអាចរៀនអធិដ្ឋានដោយខ្លួនឯងទេ។ ព្រះយេស៊ូបានបង្ហាញផ្លូវឲ្យខ្ញុំចេះអធិដ្ឋាន។ ព្រះអង្គមានព្រះហឫទ័យឲ្យខ្ញុំរៀនអធិដ្ឋាន។ ខ្ញុំសម្លឹងមើលព្រះអង្គ ដែលកំពុងអធិដ្ឋាន ខ្ញុំស្ដាប់ព្រះអង្គ ខ្ញុំអធិដ្ឋានជាមួយព្រះអង្គ ខ្ញុំអធិដ្ឋានតាមសេចក្ដីអធិដ្ឋានរបស់ព្រះអង្គ។

**គោលដៅនៃដំណាក់កាលនេះ ៖** យល់ឃើញថា ពេលយើងចង់អធិដ្ឋាន យើងត្រូវចូលទៅក្នុងសេចក្ដីអធិដ្ឋានរបស់ព្រះយេស៊ូ

- ឆ្លើយនឹងសួរថា ហេតុអ្វីបានជាត្រូវអធិដ្ឋាន?... ត្រូវអធិដ្ឋានយ៉ាងដូចម្ដេច?
- រិះគិតអំពីការអធិដ្ឋានក្នុងជីវិតរបស់ខ្ញុំសព្វថ្ងៃនេះ...
- រករបៀបផ្សេងៗ ដើម្បីអធិដ្ឋាន នៅក្នុងពិភពលោកសព្វថ្ងៃនេះ...
- ស្វែងរកមើលនៅក្នុងព្រះគម្ពីរដំណឹងល្អថា ព្រះយេស៊ូអធិដ្ឋានដូចម្ដេច...

ទីបញ្ចប់នៃដំណាក់កាលនេះ ខ្ញុំគួរតែមានរបៀបអធិដ្ឋានផ្ទាល់ខ្លួន។

### ទុកពេល សម្រាប់បើកចិត្តទូលាយ និងទទួល

១- បណ្ដោយចិត្តឲ្យនឹកឃើញឡើងវិញ នូវវេលាមួយដែលយើងបានអធិដ្ឋាន។ វេលាមួយណាដែលយើងនៅចងចាំជាងគេ? តើមានអ្វីកើតឡើងនៅពេលនោះ? តើការអធិដ្ឋាននោះកើតមកពីអ្វី?

២- ព្យាយាមទាញចេញពីបទពិសោធន៍នេះនូវអ្វី ដែលគួរតែអាចបញ្ជាក់លក្ខណៈនៃការអធិដ្ឋាន និងរបៀបអធិដ្ឋានរបស់ខ្លួនយើងផ្ទាល់៖

- តើយើងចូលចិត្តពេលវេលា និងកន្លែងណាជាងគេ ដើម្បីអធិដ្ឋាន?
- តើយើងអធិដ្ឋានតាមរបៀបអ្វីខ្លះ? តើយើងអធិដ្ឋានតាមរបៀបដដែលៗឬទេ?
- តើមានអ្វីជំរុញយើងឲ្យអធិដ្ឋាន?
- តើយើងអធិដ្ឋានបានទៀងទាត់ឬទេ? នៅពេលណាខ្លះ?

ខ្ញុំអង្គុយចុះ
ខ្ញុំតាំងខ្លួន ក្នុងឥរិយាបថត្រឹមត្រូវ
ខ្ញុំសូមអង្វរឲ្យព្រះវិញ្ញាណយាងមក
ខ្ញុំទទួលការអធិដ្ឋានពីព្រះអម្ចាស់ ដូចជាព្រះអំណោយទាន
ព្រះវិញ្ញាណរបស់ព្រះអង្គបានប្រោសប្រទានព្រះអំណោយទាននេះមកខ្ញុំយូរមកហើយ។
ខ្ញុំហៅព្រះនាមរបស់ព្រះជាម្ចាស់នៅពេលអធិដ្ឋាន ខ្ញុំទទួលព្រះអង្គ
ខ្ញុំអធិដ្ឋាន ដើម្បីខ្លួនខ្ញុំ និងដើម្បីអ្នកដទៃដែរ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- នៅក្នុងព្រះគម្ពីរ យើងស្គាល់មនុស្សជាច្រើននាក់ ដែលពូកែអធិដ្ឋាន។ មានដូចជា៖ លោកអប្រាហាំ លោកម៉ូសេ លោកអេសាយ លោកយេរេមី លោកហូសេ នាងអេសធ័រ ព្យាការិនីអណ្ណា ព្រះនាងម៉ារី លោកសិលា។ល។ តើយើងចូលចិត្តសេចក្តីអធិដ្ឋានរបស់អ្នកណា? សូមបញ្ជាក់ថាមកពីអ្វី។

២- ធ្វើបញ្ជីមួយ កត់ត្រាពាក្យពេចន៍នៃសេចក្តីអធិដ្ឋាននៅក្នុងព្រះគម្ពីរដំណឹងល្អ (មថ ៦; ៧; មក ១១; លក ១១; ១៨)

៣- ដកស្រង់អត្ថបទ ដែលរៀបរាប់អំពីការអធិដ្ឋានរបស់ព្រះយេស៊ូក្នុងព្រះគម្ពីរដំណឹងល្អ។ ពេលយើងសម្លឹងមើលព្រះអង្គអធិដ្ឋាន តើយើងរកឃើញអ្វី?

៤-ស្តាប់សម្តីសន្តបុគ្គលម្នាក់ ដែលបានសញ្ជឹងគិតយ៉ាងយូរអំពីព្រះយេស៊ូ និយាយប្រាប់យើងអំពីការអធិដ្ឋាន៖

### សន្ត:យ៉ូហាន អើដ

#### ពេលយើងអធិដ្ឋាន យើងបន្តការអធិដ្ឋានរបស់ព្រះយេស៊ូគ្រីស្ត

ត្រូវតែចាត់ទុកថា ការតាំងចិត្តធ្វើសមាធិជាគ្រឹះដ៏សំខាន់នៃជីវិតរបស់គ្រីស្តបរិស័ទ ដែលចង់ទៅជាជនដ៏វិសុទ្ធ ដ្បិតព្រះយេស៊ូបានធ្វើសមាធិជាអចិន្ត្រៃយ៍ ពេញមួយព្រះជន្មរបស់ព្រះអង្គ ដែលយើងត្រូវតែបន្តតទៅទៀត និងបញ្ជាក់បង្ហាញថា ការធ្វើសមាធិសំខាន់ និងចាំបាច់ណាស់ ដូចជាផែនដីដែលទ្រយើង ខ្យល់អាកាសដែលយើងដកដង្ហើម នំប៉័ងដែលចិញ្ចឹមជីវិតយើង បេះដូងកម្រើកនៅក្នុងទ្រូង។ ចំពោះគ្រីស្តបរិស័ទម្នាក់ ការធ្វើសមាធិសំខាន់ និងចាំបាច់លើសអ្វីៗទាំងអស់នោះទៅទៀត។

ដូច្នោះហើយ ពេលធ្វើសមាធិ យើងលើកវិញ្ញាណ និងចិត្តគំនិតឆ្ពោះទៅព្រះជាម្ចាស់។ យើងប្រាស្រ័យទាក់ទងយ៉ាងសុភាពរាបសារ និងសន្ទនាជាមួយព្រះជាម្ចាស់។ ព្រលឹងយើងសម្លឹងមើលព្រះជាម្ចាស់ និងសញ្ជឹងគិតទៅដល់ភាពដ៏វិសុទ្ធគ្រប់លក្ខណៈរបស់ព្រះអង្គ គម្រោងការដ៏អស្ចារ្យ និងស្នាព្រហស្តរបស់ព្រះអង្គ។ ព្រលឹងនេះគោរពប្រណិបត្តិព្រះអង្គថ្វាយព្រះពរដល់ព្រះអង្គ ស្រឡាញ់ព្រះអង្គលើកតម្កើង និងប្រគល់ខ្លួនថ្វាយព្រះអង្គ បន្ទាបខ្លួនពីមុខព្រះអង្គ ដោយនឹកគិតដល់អំពើបាបរបស់ខ្លួន ដោយយល់ឃើញថា មិនចេះដឹងព្រះគុណព្រះអង្គ ហើយទូលអង្វរសូមព្រះអង្គមេត្តាករុណាលើកលែងទោសឲ្យ។ ព្រលឹងនេះខិតខំរៀនធ្វើត្រាប់តាមគុណធម៌ និងលក្ខណៈល្អឥតខ្ចោះរបស់ព្រះអង្គ ដើម្បីឲ្យបានដូចព្រះអង្គ ហើយទីបញ្ចប់ព្រលឹងនេះ ទូល

សូមអ្វីៗដែលខ្លួនត្រូវការដើម្បីបម្រើ និងស្រឡាញ់ព្រះអង្គ។

ហេតុដូច្នោះហើយ ទើបខ្ញុំជំរុញ និងអង្វរអ្នកពាល់គ្នាក្នុងព្រះនាមព្រះជាម្ចាស់ តាមតែខ្ញុំអាចធ្វើបាន (ពីព្រោះព្រះយេស៊ូដ៏ជាទីស្រឡាញ់បំផុតរបស់យើង ព្រះអង្គយល់ព្រមយាងមកសន្ទនាជាមួយយើងតាមរយៈការធ្វើសមាធិ) កុំធ្វើឲ្យព្រះអង្គមិនសប្បាយព្រះហឫទ័យ ប៉ុន្តែសូមដកពិសោធន៍ឲ្យដឹងថា (ដូចព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលត្រឹមត្រូវដូច្នោះមែន)៖ អ្នកនៅជាមួយព្រះប្រាជ្ញាញាណ មិនដែលមានចិត្តជូរចត់ទេ។ ការរួមរស់ជាមួយព្រះប្រាជ្ញាញាណក៏មិនបណ្តោយឲ្យមានទុក្ខព្រួយដែរ គឺមានតែសេចក្តីសុខ និងអំណរសប្បាយប៉ុណ្ណោះ (ប្រាញ ៨,១៦)។ ចូរចាត់ទុកថា ការធ្វើសមាធិនេះ ជាកិច្ចការដំបូងសំខាន់ជាងគេ ចាំបាច់បំផុតដែលមានន័យជ្រាលជ្រៅ លើសកិច្ចការទាំងអស់របស់អ្នកពាល់គ្នា។

## សន្ត:យ៉ូហាន អើដ៖

របៀបផ្សេងៗក្នុងការធ្វើសមាធិ

- ការធ្វើសមាធិក្នុងចិត្ត
- ការធ្វើសមាធិដោយបញ្ចេញសំឡេង
- ធ្វើកិច្ចការទាំងអស់ដោយធ្វើសមាធិ
- ការអានសៀវភៅល្អៗ
- និយាយអំពីព្រះជាម្ចាស់

ខ្ញុំមើលឃើញព្រះយេស៊ូអធិដ្ឋានយ៉ាងយូរ។

ខ្ញុំស្តាប់ព្រះបន្ទូលព្រះអង្គ អំពីរបៀបអធិដ្ឋាន។

ខ្ញុំអរព្រះគុណព្រះអង្គដែលធ្វើជាគ្រូបង្រៀនយើង ឲ្យចេះអធិដ្ឋាន។

ខ្ញុំថ្វាយខ្លួនចំពោះព្រះអង្គ ដើម្បីឲ្យព្រះអង្គបង្រៀនខ្ញុំឲ្យចេះអធិដ្ឋាន។

សូមព្រះអង្គយាងមកអធិដ្ឋានក្នុងចិត្តខ្ញុំ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- តើមានការលំបាកធំៗណាខ្លះ ដែលយើងជួបប្រទះ នៅពេលដែលយើងចង់អធិដ្ឋាន?

- **ការលំបាកមានធម្មតា៖** យើងរវល់គ្មានពេលទំនេរ គ្មានទីកន្លែងស្ងាត់...

ខ្ញុំលុតជង្គង់ពីមុខព្រះជាម្ចាស់។

ខ្ញុំទទួលស្គាល់ថា ខ្ញុំពិបាកអធិដ្ឋាន

ខ្ញុំមិនសូវចេះអធិដ្ឋាន

ខ្ញុំលើកលែងទោសឲ្យខ្លួនឯង...ដែលស្រមៃចង់អធិដ្ឋានល្អឥតខ្ចោះ ប៉ុន្តែតាមការពិតខ្ញុំអធិដ្ឋានបានតិចតួច ... ទោះបីខ្ញុំអធិដ្ឋានយ៉ាងណាក៏ដោយ ក៏ខ្ញុំពុំមានរបៀបរស់នៅត្រឹមត្រូវឥតខ្ចោះដែរ...

ខ្ញុំទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គលើកលែងទោសឲ្យខ្ញុំ ដែលខ្វះទំនាក់ទំនងជាមួយព្រះអង្គ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- តើយើងយល់ឃើញថា ជីវិតរបស់យើង និងការអធិដ្ឋានត្រូវស្របនឹងគ្នាឬ?

២- តើយើងដឹងខ្លួនថា បានប្រកាសជំណឹងល្អនៅពេលអធិដ្ឋានឬទេ? ហើយយើងអធិដ្ឋាននៅពេលដែលយើងប្រកាសដំណឹងល្អឬទេ?

៣- តើយើងគិតដូចម្ដេច ដើម្បីឲ្យរបៀបរស់នៅរបស់យើងស្របនឹងការអធិដ្ឋានរបស់យើង?

៤- ជាធម្មតាសន្ធះយ៉ូហាន អើដ អធិដ្ឋានជាបួនជំណាក់កាល៖ ថ្វាយបង្គំ អរព្រះគុណ សូមទទួលការលើកលែងទោស ថ្វាយខ្លួនជាតង្វាយ។

យើងសូមថ្វាយបង្គំព្រះយេស៊ូ ក្នុងឋានៈជាមហាបូជាចារ្យ
ទូលអង្វរព្រះបិតាសម្រាប់អស់អ្នក ដែលព្រះបិតាបានប្រគល់ឲ្យព្រះបុត្រា។
ចូរយើងអរព្រះគុណព្រះអង្គ ដែលបានទូលអង្វរព្រះបិតាយ៉ាងខ្លាំងក្លា ដើម្បីកូនចៅរបស់ព្រះអង្គ
ហើយដែលគង់ខាងស្ដាំព្រះបិតាជានិច្ច ដើម្បីជួយទូលអង្វរព្រះអង្គសម្រាប់ពួកគេ។
ចូរយើងសូមព្រះអង្គលើកលែងទោសឲ្យយើង
ដែលមិនបានបំពេញកាតព្វកិច្ចជាអ្នកជួយទូលអង្វរព្រះអង្គ សម្រាប់អ្នកដទៃ
ហើយដែលមិនបានប្រុងប្រៀបខ្លួនក្នុងការអធិដ្ឋានឲ្យគ្រប់គ្រាន់ ដើម្បីប្រព្រឹត្តកិច្ចការក្នុងព្រះនាមព្រះអង្គ។
ចូរយើងលះបង់ភាពកំសាក ហើយសូមប្រគល់ខ្លួនថ្វាយព្រះអង្គ
ដើម្បីឲ្យព្រះអង្គបន្តអធិដ្ឋានក្នុងឋានៈជាមហាបូជាចារ្យ ក្នុងចិត្តយើង។

## សូមព្យាយាមរៀបរៀងសេចក្ដីអធិដ្ឋានតាមលំនាំនេះ៖

ការសញ្ជឹងគិត គឺជាការសញ្ជឹងគិតដ៏ពិតប្រាកដ មិនពឹងផ្អែកលើអ្នកទេ។ អ្នកមិនមែនជាកាំរស្មីពណ៌លឿងមុនព្រះអាទិត្យរះទេ។ ព្រះរបស់អ្នកជាកាំរស្មីនេះ បន្ទាប់មកព្រះអង្គជារស្មីនៃអរុណរះ ហើយក្រោយមកទៀត ព្រះអង្គជាព្រះអាទិត្យនាពេលថ្ងៃត្រង់។

អ្នកជាផែនដី ដែលរង់ចាំពន្លឺ អ្នកជាក្ដារឆ្នួនពណ៌ខ្មៅរង់ចាំដីសរបស់អ្នកគូរដែលដើរចូលមករកអ្នក។ ចូរអ្នកអង្គុយ ហើយនៅឲ្យស្ងៀម អង្គុយចុះ ហើយព្យាយាមសង្ឃឹម។

...ព្រះជាម្ចាស់គង់នៅមុខអ្នកហើយ។ ព្រះអង្គយាងមករកអ្នក។ ពេលយើងសញ្ជឹងគិតយើងពុំមើលឃើញទេ ប៉ុន្តែព្រះអង្គទតមើលមកយើងវិញ។ នោះព្រះអង្គកំពុងទតមើលមកអ្នក។ ប្រសិនបើព្រះអង្គមើលឃើញអ្នកនោះព្រះអង្គស្រឡាញ់អ្នក ហើយព្រះអង្គប្រទានអ្វីៗដែលអ្នកស្វែងរក គឺព្រះអង្គផ្ទាល់។ មែនហើយព្រះជាម្ចាស់គង់នៅទីនេះ នៅពីមុខអ្នក ហើយព្រះអង្គទតមកអ្នក។ ក្រសែព្រះនេត្រាព្រះអង្គបង្កើតអ្នក អាចបង្កើតបាននូវអ្វីៗដែលមិនអាចកើតមាន...ព្រះអង្គស្រឡាញ់អ្នក ហើយសេចក្ដីស្រឡាញ់របស់ព្រះអង្គមិនគិតប្រាក់ទេ។ ព្រះអង្គមិនស្រឡាញ់អ្នក ដោយសារគុណសម្បត្តិអ្នកទេ ព្រះអង្គស្រឡាញ់អ្នកដោយហេតុថា ព្រះអង្គមិនអាចឃាត់ឃាំងព្រះហឫទ័យព្រះអង្គមិនឲ្យស្រឡាញ់បានឡើយ៖ ព្រះអង្គជាសេចក្ដីស្រឡាញ់។

# រៀនស្រឡាញ់

ខ្ញុំម្ចាស់ប្រគល់ចិត្តកាយថ្វាយព្រះអង្គ ព្រះយេស៊ូជាអម្ចាស់
ដើម្បីស្រឡាញ់បងប្អូនខ្ញុំម្ចាស់ ដូចព្រះអង្គបានស្រឡាញ់ខ្ញុំម្ចាស់ដែរ!

## ដំណាក់កាលទី ១១

ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ (យហ ១៣,៣៤)

**ក្នុងដំណាក់កាលនេះមាន ៖** អ្នកណាអធិដ្ឋានបណ្ដោយឲ្យសេចក្ដីស្រឡាញ់រឹតរួតខ្លួន។ គេហាត់រៀនស្រឡាញ់ដូចព្រះយេស៊ូស្រឡាញ់ដែរ។
គេសញ្ជឹងគិតយ៉ាងយូរអំពីព្រះយេស៊ូនៅក្នុងព្រះគម្ពីរដំណឹងល្អ។
ព្រះយេស៊ូ ៖ ជារូបតំណាងគ្រប់លក្ខណៈនៃសេចក្ដីស្រឡាញ់របស់ព្រះបិតា។ ...ព្រះបន្ទូលរបស់ព្រះអង្គមកពីព្រះបន្ទូលព្រះបិតា...កិច្ចការ និងសេចក្ដីស្រឡាញ់របស់ព្រះអង្គជាកិច្ចការ និងសេចក្ដីស្រឡាញ់របស់ព្រះបិតាដែរ។ ល។
ដោយសារព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យទៅជាសាវ័ក យើងនឹងទៅជាសាវ័កលុះត្រាតែយើងនឹងស្រឡាញ់ឲ្យដូចព្រះយេស៊ូបានស្រឡាញ់យើងដូច្នោះដែរ។

**គោលដៅនៃដំណាក់កាលនេះ ៖** រៀនស្រឡាញ់ដូចកាលដែលព្រះយេស៊ូបានស្រឡាញ់យើងដូច្នោះដែរ។
- ដោយព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ព្រះអង្គបង្កើតខ្ញុំមក ដើម្បីស្រឡាញ់ដែរ។ សូមយល់ឲ្យច្បាស់ថា ចាំបាច់ត្រូវស្រឡាញ់ ហើយនៅពេលជាមួយគ្នានេះយល់ថា ខ្ញុំមិនចេះស្រឡាញ់ដែរ។ គឺព្រះយេស៊ូដែលនឹងស្រឡាញ់ក្នុងខ្លួនខ្ញុំ...ព្រះអង្គជាប្រភពនៃសេចក្ដីស្រឡាញ់...
- ខ្ញុំមិនអាចស្រឡាញ់ព្រះយេស៊ូដែលបានស្រឡាញ់ខ្ញុំមុនទេ បើខ្ញុំមិនបញ្ចេញកាយវិការបង្ហាញអំពីសេចក្ដីស្រឡាញ់ ដូចព្រះអង្គក្នុងជីវិតប្រចាំថ្ងៃ។
ចុងបញ្ចប់នៃដំណាក់កាលនេះ ខ្ញុំគួរតែអាចត្រួតពិនិត្យសាឡើងវិញនូវសមត្ថភាពរបស់ខ្ញុំ តើខ្ញុំអាចស្រឡាញ់អ្នកដទៃ ដោយមិនចង់គ្រប់គ្រងគេ?

### ទុកពេល សម្រាប់បើកចិត្ត និងទទួល

**១**-«សេចក្ដីស្រឡាញ់» «ស្រឡាញ់» តើពាក្យនោះ ធ្វើឲ្យយើងនឹកគិតអំពីអ្វីខ្លះ (អារម្មណ៍ហេតុការណ៍ មនុស្ស)?

**២**- សូមនឹកគិតដល់អ្នកដទៃ ហើយធ្វើបញ្ជីមួយ៖

- មនុស្សដែលយើងស្រឡាញ់ ហើយដែលស្រឡាញ់យើង...
- មនុស្សដែលមិនសូវស្រឡាញ់យើង ហើយយើងក៏មិនសូវស្រឡាញ់គេដែរ...
- មនុស្សដែលយើងមិនអាចស្រឡាញ់បាន ហើយដែលមិនស្រឡាញ់យើងដែរ...

**យើងព្យាយាមរកឲ្យឃើញថា ហេតុអ្វីបានជាយើងមិនអាចស្រឡាញ់គេ ?**

ខ្ញុំទទួលយកឈ្មោះ និងមុខរបស់អស់អ្នកដែលជ្រៀតចូលមកក្នុងការចងចាំរបស់ខ្ញុំ ហើយខ្ញុំទៅអង្គុយពីមុខព្រះភ័ក្ត្រព្រះអម្ចាស់រួមជាមួយពួកគេ។

ខ្ញុំក៏ទទួលទឹកចិត្តប្រឆាំងជំទាស់ ដែលមាននៅក្នុងចិត្តខ្ញុំ ចំពោះព្រះភ័ក្ត្រព្រះអង្គដែរ។

## ទុកពេលសម្រាប់ សញ្ជឹងគិតនិងអរព្រះគុណ

**១- រកមើលនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មីថា តើសេចក្តីស្រឡាញ់មាននិយមន័យដូចម្តេច៖**

- អ្វីៗដែលអ្នករាល់គ្នាបានប្រព្រឹត្តចំពោះអ្នកតូចតាច (មថ ២៥)
- ចំពោះព្រះយេស៊ូ មិនអាចបំបែកសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ នឹងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃជាដាច់ខាត (មក ១២,២៨-៣៤)។
- ជនជាតិសាម៉ារីដ៏សប្បុរស (លក ១០,២៩-៣៧)
- ពិធីលាងជើង (យហ ១៣)
- វិន័យរបស់ខ្ញុំ (យហ ១៥,១២)
- ត្រូវតែស្រឡាញ់ តាមសេចក្តីពិត (១យហ ៣,១១-២៤)
- អ្នកណាចេះស្រឡាញ់ អ្នកនោះកើតមកពីព្រះជាម្ចាស់ (១យហ ៤,៧-២១)

**២- សន្តៈប៉ូលបន្ថែមនិយមន័យនេះទៅក្នុងអត្ថបទ ដែលគាត់ឧទ្ទិសទៅដល់សេចក្តីស្រឡាញ់** ៖ (១ករ ១៣,១-១៣)។

**៣-** សន្តៈយ៉ូហាន អើដ បានយល់ថា ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យចេះស្រឡាញ់ ដោយសារលោកបានសញ្ជឹងគិតអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលមានព្រះបេះដូងព្រះយេស៊ូជានិមិត្តរូប។

## យើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូគ្រីស្តស្រឡាញ់យើងដែរ

នៅក្នុងព្រះគម្ពីរដំណឹងល្អដ៏វិសុទ្ធ ព្រះបុត្រារបស់ព្រះជាម្ចាស់មានព្រះបន្ទូលថា វិន័យទីមួយជាវិន័យសំខាន់ជាងគេបង្អស់របស់ព្រះជាម្ចាស់ គឺត្រូវស្រឡាញ់ព្រះអង្គឲ្យអស់ពីចិត្ត ពីថ្លើម និងអស់ពីកម្លាំងកាយចិត្ត។ បន្ទាប់មកព្រះអង្គប្រកាសឲ្យយើងដឹងថា វិន័យទីពីរ ដូចវិន័យទីមួយ គឺត្រូវតែស្រឡាញ់អ្នកដទៃដូចខ្លួនយើងផ្ទាល់ ដ្បិតសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ មិនអាចបំបែកចេញពីគ្នាបាន។ សេចក្តីស្រឡាញ់នោះ មិនមែនជាសេចក្តីស្រឡាញ់ពីរទេ គឺជាសេចក្តីស្រឡាញ់តែមួយគត់។ យើងត្រូវស្រឡាញ់អ្នកដទៃដោយទឹកចិត្តតែមួយ និងសេចក្តីស្រឡាញ់ តែមួយដែលយើងស្រឡាញ់ព្រះជាម្ចាស់ ដ្បិតយើងត្រូវស្រឡាញ់អ្នកដទៃមិនមែនដើម្បីគេ ប៉ុន្តែដើម្បីព្រះជាម្ចាស់។ និយាយឲ្យស្រួលស្តាប់ទៅទៀត គឺថាយើងត្រូវស្រឡាញ់ព្រះជាម្ចាស់ផ្ទាល់ដែលគង់នៅក្នុងអ្នកដទៃ។

គឺដូច្នោះហើយទើបព្រះយេស៊ូស្រឡាញ់យើង ព្រះអង្គស្រឡាញ់ព្រះបិតានៅក្នុងយើង គឺព្រះអង្គស្រឡាញ់យើង ដើម្បីព្រះបិតាព្រះអង្គ ឬយើងអាចនិយាយបានទៀតថា ព្រះអង្គស្រឡាញ់ព្រះបិតាព្រះអង្គដែលគង់នៅក្នុងយើង ហើយព្រះអង្គមានព្រះហឫទ័យឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គស្រឡាញ់យើងដែរ។ ព្រះយេស៊ូមានព្រះបន្ទូលថានេះជាវិន័យរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ (យហ ១៥,១២)។

សប្បុរសធម៌នៃគ្រីស្តសាសនាមានដូចតទៅ៖ គឺឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូគ្រីស្តបានស្រឡាញ់យើងដូច្នោះដែរ។ ព្រះអង្គបានស្រឡាញ់យើងរហូតដល់បូជាព្រះជន្ម ព្រះកាយ ព្រះស្មារតីពេលវេលា សភាពអស់កល្បជានិច្ច សភាពជាព្រះ និងសភាពជាមនុស្ស អ្វីៗទៀតដែលជាលក្ខណៈរបស់ព្រះអង្គអ្វីៗទាំងអស់ជាកម្មសិទ្ធរបស់ព្រះអង្គចំពោះយើង។

ចូរយើងក្រឡេកមើលព្រះជាម្ចាស់ ដែលគង់នៅក្នុងអ្នកដទៃ គឺចូរយើងសម្លឹងមើលគេ ដូចជាម្នាក់ដែលបានលេចចេញពីព្រះហឫទ័យ និងសប្បុរសធម៌របស់ព្រះជាម្ចាស់។ ចូរនឹកគិតថា ពួកគេចូលរួមចំណែកក្នុងអង្គព្រះជាម្ចាស់ ព្រះអង្គបានបង្កើតពួកគេ ដើម្បីថ្វាយពួកគេទៅព្រះជាម្ចាស់វិញ ដើម្បីឲ្យពួកគេចូលទៅសណ្ឋិតនៅក្នុងព្រះឱរារបស់ព្រះអង្គវិញ ដើម្បីកោតសរសើរព្រះអង្គអស់កល្បជានិច្ច ហើយពេលនោះព្រះជាម្ចាស់ច្បាស់ជាប្រកបដោយសិរីរុងរឿងអស់កល្បជានិច្ច ដោយសារព្រះហឫទ័យអាណិតអាសូរ ឬដោយសារសេចក្តីសុចរិតរបស់ព្រះអង្គ។ ចូរយើងសម្លឹងមើលពួកគេ ដូចជាអ្នកដែលព្រះជាម្ចាស់ស្រឡាញ់ ទោះជាស្ថិតនៅក្នុងសភាពណាក៏ដោយ ដ្បិតព្រះជាម្ចាស់ស្រឡាញ់អ្វីៗទាំងអស់ ដែលព្រះអង្គបង្កើត ព្រះអង្គមិនស្អប់អ្វីៗដែលព្រះអង្គបានបង្កើតទេ។ មានតែអំពើបាបទេ ដែលព្រះអង្គមិនបានបង្កើត ព្រះអង្គស្អប់ខ្ពើមណាស់។ ចូរយើងមើលពួកគេដូចជាបុត្រាធីតារបស់ព្រះបិតាតែមួយដូចយើងដែរ ដែលព្រះអង្គបានលោះមកក្នុងតម្លៃដូចគ្នា គឺព្រះលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូគ្រីស្ត ជាសមាជិករបស់មេដឹកនាំតែមួយ គឺព្រះយេស៊ូ ហើយជាសមាជិកនៃព្រះកាយតែមួយ គឺព្រះសហគមន៍នៃព្រះយេស៊ូ។ ចូរសម្លឹងមើលពួកគេ ដូចជាអ្នកដែលផ្គត់ផ្គង់ដោយអាហារតែមួយ គឺព្រះកាយ និងព្រះលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូ។ ហេតុនេះ យើងត្រូវតែមានវិញ្ញាណតែមួយ ចិត្តគំនិតតែមួយនឹងពួកគេ។ ចូរយើងសម្លឹងមើលពួកគេទៀតថា ជាព្រះដំណាក់របស់ព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅជាអ្នកដែលផ្ទុកក្នុងខ្លួនគាត់នូវរូបតំណាងនៃព្រះត្រៃឯក និងលក្ខណៈរបស់ព្រះយេស៊ូគ្រីស្តជាឆ្អឹងនៃព្រះអង្គ ជាសាច់នៃព្រះកាយព្រះអង្គ។ ចូរទុកពួកគេដូចជាម្នាក់ដែលព្រះយេស៊ូគ្រីស្តបានខិតខំយ៉ាងលំបាកលំបិន អស់ពេលវេលាយ៉ាងយូរ និងបានចាក់បង្ហូរព្រះលោហិត និងបានបូជាព្រះជន្មរបស់ព្រះអង្គ។ ទីបំផុត ចូរយើងមើលទៅពួកគេដូចជាម្នាក់ដែលព្រះអង្គផ្តាំផ្ញើឲ្យមើលថែដូចព្រះកាយព្រះអង្គ ហើយព្រះអង្គផ្តែផ្តាំថា អ្វីៗដែលអ្នកនឹងប្រព្រឹត្ត ចំពោះអ្នកតូចតាចជាងខ្លួន ព្រះអង្គទុកដូចជាអ្នកនោះបានប្រព្រឹត្តចំពោះព្រះអង្គផ្ទាល់ (មថ ២៥,៤០)

ឱ! បើសិនជាយើងទុកសេចក្តីពិតនេះ ដូចជាអ្វីសំខាន់ៗ យើងនឹងមានចិត្តសប្បុរស ហើយយើងនឹងចេះគោរពគ្នាទៅវិញទៅមកច្រើន ហើយល្អយ៉ាងណា! តើយើងនឹងខ្លាចប្រឆាំងនឹងសេចក្តីស្រឡាញ់ និងសប្បុរសធម៌នៃព្រះគ្រីស្ត តាមរយៈគំនិត ពាក្យសម្តី និងសកម្មភាពរបស់យើង! តើយើងមិនគួរធ្វើអ្វីៗ មិនគួររងទុក្ខលំបាកដោយសារអ្នកនេះ ដើម្បីអ្នកនោះទេឬ! តើយើងនឹងអត់ធ្មត់បែបណា យើងគួរតែទ្រាំទ្រ និងលើកលែងទោសឲ្យគុណវិបត្តិអ្នកដទៃ ដោយមានចិត្តស្លូតបូត និងសុភាពរាបសា ដោយមិនអួតអាង ដោយចេះទប់ចិត្ត! តើយើង

នឹងចាប់អារម្មណ៍បែបណា ដើម្បីឲ្យអ្នកដទៃរីករាយ ដោយមានគោលបំណងឲ្យគេរីកចម្រើនក្នុងសប្បុរសធម៌ (រម ១៥,២)។

ខ្ញុំសញ្ជឹងគិតទៅដល់ព្រះយេស៊ូ ក្នុងសេចក្ដីស្រឡាញ់ ដែលព្រះអង្គទទួលពីព្រះបិតា...
ក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះព្រះបិតា...
ក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះបងប្អូនរបស់ព្រះអង្គ។
ខ្ញុំស្ដាប់ព្រះបន្ទូលព្រះអង្គត្រាស់ហៅខ្ញុំឲ្យស្រឡាញ់ដូចព្រះអង្គស្រឡាញ់។
ខ្ញុំសូមអរព្រះគុណព្រះអង្គចំពោះសេចក្ដីស្រឡាញ់ ដែលព្រះអង្គស្រឡាញ់ខ្ញុំ
...អរគុណព្រះអង្គចំពោះសេចក្ដីស្រឡាញ់ ដែលព្រះអង្គដាក់ទុកក្នុងចិត្តខ្ញុំ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ចូរត្រឡប់មករកបញ្ជីឈ្មោះរបស់អស់អ្នកដែលយើងស្រឡាញ់ ហើយរិះគិតថា តើសេចក្ដីស្រឡាញ់របស់យើង ចំពោះគេអាចឈានទៅដល់ «ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា» យ៉ាងដូចម្ដេច...ជាមួយគ្នានេះដែរ ចូររកបញ្ជីឈ្មោះរបស់អស់អ្នកដែលយើងពិបាកស្រឡាញ់...សូមរិះគិតថា ហេតុអ្វីយើងពិបាកស្រឡាញ់គេ?

២- អ្នកមានចិត្តស្រឡាញ់អ្នកនោះ ដើរចេញពីខ្លួនឯងទៅរកអ្នកដទៃ។ ចូរឆ្លងឲ្យហួសពីរង្វង់របស់បងប្អូនយើង ដើម្បីទៅជួបអស់អ្នកដែលយើងជួបប្រទះរាល់ថ្ងៃ ដោយមិនបានចាប់អារម្មណ៍។ សូមកត់ទុកការជួបប្រទះនេះឲ្យបានពីរបីថ្ងៃ...តើយើងអាចប្រាប់បានទេថា យើងស្របនឹងសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ចំពោះមនុស្សលោកដែរឬទេ?

៣- យើងពិចារណាលើព្រះបន្ទូលនេះ បើនរណាម្នាក់ពោលថា "ខ្ញុំស្រឡាញ់ព្រះជាម្ចាស់" តែស្អប់បងប្អូនរបស់ខ្លួន អ្នកនោះនិយាយកុហកហើយ។ អ្នកណាមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញ ក៏ពុំអាចស្រឡាញ់ព្រះជាម្ចាស់ ដែលខ្លួនមើលពុំឃើញនោះបានដែរ (១យហ ៤,២០)។

ក្នុងពេលតែមួយដដែល ខ្ញុំដឹងខ្លួនថា ខ្ញុំកើតមកដើម្បីស្រឡាញ់
ខ្ញុំក៏ឈានទៅដល់ដែនកំណត់នៃសមត្ថភាពក្នុងការស្រឡាញ់របស់ខ្ញុំដែរ។
ខ្ញុំលាតត្រដាងភាពលំបាកក្នុងការស្រឡាញ់របស់ខ្ញុំទូលព្រះអម្ចាស់។
ខ្ញុំបណ្ដោយឲ្យព្រះអង្គសម្រុះសម្រួលជាមួយនឹងព្រះជាម្ចាស់ ជាមួយបងប្អូនប្រុសស្រីនោះ
ដែលខ្ញុំពិបាកស្រឡាញ់។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- គ្មាននរណាស្រឡាញ់ខ្លាំងជាងអ្នក ដែលស៊ូប្ដូរជីវិត (យហ ១៥,១៣)

ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យស្រឡាញ់ដូចព្រះយេស៊ូ។ សូមបញ្ជាក់ឲ្យច្បាស់នូវការត្រាស់ហៅនេះ...តើយើងអាចឈានទៅដល់ណាទៀតក្នុងការថ្វាយខ្លួន?

តើយើងអាចប្រព្រឹត្តកិច្ចការយ៉ាងដូចម្ដេច ដើម្បីស្រឡាញ់អ្នកដទៃជាងមុន?

២- សូមតែងសេចក្ដីអធិដ្ឋានមួយ ដោយយកលំនាំតាមសេចក្ដីអធិដ្ឋានដូចតទៅនេះ(ថ្វាយបង្គំ ឬអរ

ព្រះគុណ ឬសូមការលើកលែងទោស ឬថ្វាយខ្លួន) ដោយយកអ្វីៗ ដែលយើងនឹកឃើញ កាលណាយើងបណ្ដោយឲ្យព្រះបន្ទូលថា «អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ» លាន់ឮក្នុងចិត្តយើង។

ចូរយើងក្រាបថ្វាយបង្គំចំពោះព្រះជាម្ចាស់ ដែលទ្រង់មានសប្បុរសធម៌ដ៏ទូលំទូលាយ ចំពោះសត្វលោក ជាពិសេសចំពោះយើងរាល់គ្នា។ ចូរយើងថ្វាយព្រះពរដល់ព្រះអង្គស្រឡាញ់ព្រះអង្គ ចូរយើងអរព្រះគុណព្រះអង្គនូវអំពើល្អនៃធម៌ សប្បុរសឥតគណនារបស់ព្រះអង្គ។ ចូរយើងសូមព្រះអង្គលើកលែងទោសឲ្យយើង ដែលមិនចេះដឹងព្រះគុណព្រះអង្គ...ដែលមិនចេះស្រឡាញ់អ្នកដទៃ។ សូមឲ្យយើងថ្វាយខ្លួនចំពោះសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដើម្បីឲ្យសេចក្ដីស្រឡាញ់នេះ កាច់បំបាក់ភាពរឹងរូសរបស់យើងទាំងអស់ ហើយសូមឲ្យសេចក្ដីស្រឡាញ់នេះ គ្រងរាជ្យយ៉ាងគ្រប់លក្ខណៈក្នុងចិត្តយើង។

## រឿង និទានចិន

ថ្ងៃមួយមន្ត្រីម្នាក់បាត់បង់ជីវិត។ មុនដំបូង គាត់បានទៅស្ថាននរក គាត់បានឃើញមនុស្សជាច្រើនអង្គុយនឹងតុពីមុខចានបាយ ប៉ុន្តែស្គមស្គាំងដោយស្រេកឃ្លាន ពីព្រោះគេមានចង្កឹះប្រវែងពីរម៉ែត្រមិនអាចយកមកប្រើបាន។ បន្ទាប់មកគាត់ទៅស្ថានសួគ៌ នៅទីនោះគាត់ក៏បានឃើញមនុស្សជាច្រើនអង្គុយនឹងតុមុខចានបាយ ហើយអ្នកទាំងនោះសប្បាយរីករាយ ទាំងមានសុខភាពល្អ។ ពួកគេក៏មានចង្កឹះប្រវែងពីរម៉ែត្រដែរ ប៉ុន្តែពួកគេម្នាក់ៗអាចប្រើចង្កឹះនោះ មកបញ្ចុកអ្នកដែលអង្គុយពីមុខគេ។

# រួបរួមជាមួយព្រះត្រៃឯក

ពេលយើងថ្វាយបង្គំ និងកោតសរសើរព្រះយេស៊ូ
យើងក៏ថ្វាយបង្គំ និងកោតសរសើរព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធដែរ!

## ដំណាក់កាលទី ១២

សូមឲ្យបងប្អូនបានប្រកបដោយព្រះហឫទ័យសន្ដោសប្រណីរបស់ព្រះអម្ចាស់យេស៊ូ បានប្រកបដោយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងសូមឲ្យបងប្អូនបានរួមរស់ជាមួយគ្នាដោយព្រះវិញ្ញាណដ៏វិសុទ្ធ (២ករ ១៣, ១៣)

**ក្នុងដំណាក់កាលនេះមាន ៖** ព្រះជាម្ចាស់ដែលខ្ញុំស្គាល់ដោយសារសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ គឺជាព្រះមួយអង្គ ដែលមានព្រះបន្ទូលថា «ចូរយើងបង្កើតមនុស្សដូចជារូបតំណាងរបស់យើង ហើយដែលមានលក្ខណៈដូចយើងដែរ...» (កណ ១,២៦)។ ពាក្យថា «យើង» ជាពហុវចនៈ នៅពេលបង្កើតមនុស្ស ព្រះជាម្ចាស់មានព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ។

ភ្ញៀវដែលមកជួបលោកអប្រាហាំ-ព្រះជាម្ចាស់បើតាមអត្ថបទ (កណ ១៨,១) ក្រោមដើមឈើមានបីនាក់...ពួកគេសន្យាឡើងវិញថា ឲ្យកូនប្រុសមួយ។ ព្រះយេស៊ូសម្ដែងឲ្យសាវ័ក ព្រះអង្គដឹងថា ព្រះអង្គយាងមកពីព្រះបិតា ហើយព្រះអង្គនឹងយាងត្រឡប់ទៅរកព្រះបិតាវិញ...ព្រះអង្គនឹងចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក ដើម្បីឲ្យយើងស្គាល់សេចក្ដីពិត។ ព្រះជាម្ចាស់? មិនមែនព្រះណាក៏បានទេ! ព្រះនៃព្រះយេស៊ូគ្រីស្ត ព្រះបិតា...ព្រះបុត្រា...ព្រះវិញ្ញាណដែលត្រាស់ហៅខ្ញុំឲ្យរួបរួមយ៉ាងជិតស្និទ្ធជាមួយ។

**គោលដៅនៃដំណាក់កាលនេះ ៖** យល់ឃើញអំពីទំនាក់ទំនងរវាងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ
-បញ្ជាក់ប្រាប់ខ្ញុំថា តើព្រះជាម្ចាស់ជានរណា?
-កែសម្រួលគំនិតរបស់ខ្ញុំអំពីព្រះជាម្ចាស់...អំពីព្រះដែលព្រះយេស៊ូសម្ដែងឲ្យខ្ញុំស្គាល់នៅក្នុងព្រះគម្ពីរដំណឹងល្អ

**ចូលទៅក្នុងព្រះត្រៃឯក ជាព្រះរបស់ព្រះយេស៊ូ** ៖ ព្រះបិតា...ព្រះបុត្រា...ព្រះវិញ្ញាណ។

នៅចុងដំណាក់កាលនេះ ខ្ញុំគួរតែអាចយល់អំពីព្រះរបស់ព្រះយេស៊ូគ្រីស្ត គឺព្រះបិតា...ព្រះបុត្រា...ព្រះវិញ្ញាណ...បានល្អជាងមុន ហើយយល់ថា ព្រះអង្គត្រាស់ហៅខ្ញុំឲ្យរួបរួមជាមួយព្រះអង្គ។

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- តាំងពីពេលយើងចាប់កំណើត យើងជាមនុស្សមានទំនាក់ទំនងជាមួយអ្នកឯទៀត។ សូមពិនិត្យពិច័យលើបណ្តាញនៃទំនាក់ទំនងរបស់យើង៖

- ទំនាក់ទំនង ដែលយើងជ្រើសរើស...រងទទួល
- ទំនាក់ទំនងរយៈពេលខ្លី...វែង
- ទំនាក់ទំនងដែលសំខាន់ក្នុងការរស់នៅ...ប្រចាំថ្ងៃធម្មតា...ផ្សេងៗទៀត អ្វីក៏ច្រើនម្ល៉េះទេ!

២- បំពោះអ្នកឯទៀត យើងត្រូវតាមកាលៈទេសៈ៖

- អ្នកជិតខាង អ្នកធ្វើការជាមួយគ្នា អតិថិជន ភ្ញៀវ សិស្ស...
- គូប្រយុទ្ធ ឬអ្នកនៅក្នុងក្រុមជាមួយ មិត្តភក្តិ...
- កូនប្រុស ឬកូនស្រី ម្តាយ ឪពុក។ល។...

សូមសម្គាល់មើលថា តើទំនាក់ទំនងទាំងនេះទាមទារអ្វីខ្លះពីយើង? តើទំនាក់ទំនងទាំងនោះបង្កើតផលផ្លែអ្វីខ្លះ ក្នុងជីវិតរបស់យើង?

៣- តើទំនាក់ទំនងណាខ្លះ ដែលបង្ហាញលក្ខណៈរបស់យើងសព្វថ្ងៃនេះបានច្បាស់ជាងគេ?

៤- តើយើងមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់? តើយើងនិយាយអ្វីខ្លះអំពីព្រះជាម្ចាស់?

តាមរយៈទំនាក់ទំនងសំខាន់ៗចំពោះខ្ញុំ ខ្ញុំស្រូបទទួលយកសេចក្តីសង្ឃឹម ការសប្បាយរីករាយ និងការទុក្ខព្រួយ...ខ្ញុំក៏ទទួលយកការត្រាស់ហៅឲ្យទៅជាមានលក្ខណៈផ្ទាល់ខ្លួន...ឲ្យប្រួមជាមួយអ្នកដទៃ...និងទទួលស្គាល់គេដើម្បីគេ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- ព្រះយេស៊ូជាសាក្សីនៃសេចក្តីស្រឡាញ់ ដែលព្រះអង្គមានព្រះហឫទ័យឲ្យមនុស្សលោកទទួល។ សេចក្តីស្រឡាញ់នេះ ជាសេចក្តីស្រឡាញ់របស់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ។

ក្នុងព្រះគម្ពីរដំណឹងល្អតាមសន្តៈលូកា រកឲ្យឃើញនៅពេលដែលព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណសម្តែងព្រះអង្គឲ្យយើងស្គាល់ ហើយបណ្តោយឲ្យសេចក្តីស្រឡាញ់ដ៏រស់រវើករបស់ព្រះអង្គ យាងមកក្នុងចិត្តយើង៖

- ទេវទូតជូនដំណឹងទៅព្រះនាងម៉ារី (លក ១)
- ព្រះយេស៊ូជ្រមុជទឹក (លក ៣)
- មារល្បួងព្រះយេស៊ូ (លក ៤)
- ព្រះយេស៊ូប្រែទ្រង់ទ្រាយ (លក ៩)
- ព្រះយេស៊ូអង្វរព្រះបិតាឲ្យព្រះអង្គចាត់ព្រះវិញ្ញាណឲ្យយាងមក (លក ១១)
- ព្រះយេស៊ូសោយទិវង្គតវគ្គទី (លក ២៣,៤៦)

## សូមកត់អ្វីដែលអ្នករកឃើញទុក

២- សូមអាន និងស្មឹងស្មាធិ៍ ( យហ ១៤ ) សូមដកស្រង់ល្បះ ដែលព្រះយេស៊ូមានព្រះបន្ទូលថា «ខ្ញុំ» ល្បះដែលព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះបិតា...ព្រះវិញ្ញាណ...តើយើងរៀនអ្វីខ្លះអំពីទំនាក់ទំនងរវាងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ ?...អំពីសេចក្ដីស្រឡាញ់ដែលព្រះអង្គប្រទានឲ្យក្រុមសាវ័ករបស់ព្រះយេស៊ូ ?...សូមអាន ( រម ៨,១៤.១៧ ) ។

៣- នៅក្នុងការបង្រៀន និងក្នុងការស្មឹងស្មាធិ៍របស់សន្ដៈយ៉ូហានអើដ សង្កត់ធ្ងន់លើសប្បុរសធម៌ដែលយើងមិនអាចយល់អំពីព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ ដើម្បីឲ្យយើងកោតស្ញប់ស្ញែងចំពោះសប្បុរសធម៌នោះ សូមឲ្យយើងក្រាបថ្វាយបង្គំ កោតសរសើរ និងចូលរួមចំណែកក្នុងការសន្ដោសប្រណីរបស់ព្រះជាម្ចាស់ ដែលយើងបានទទួលក្នុងពិធីអគ្គសញ្ញាជ្រមុជទឹក។ សន្ដៈយ៉ូហាន អើដ និយាយអំពីព្រះទាំងបីព្រះអង្គនៃព្រះត្រៃឯក ហើយលោកលើកជាបទចម្រៀងរៀបរាប់យ៉ាងវែង អំពីសេចក្ដីស្រឡាញ់ ដែលគ្មានទីបញ្ចប់របស់ព្រះអង្គ ហើយដែលយើងនឹងទទួលយ៉ាងបរិបូរណ៍នៅស្ថានបរមសុខ។

ចូរយើងនឹកគិតអំពីទំនាក់ទំនងរវាងព្រះទាំងបីអង្គ។ ព្រះបិតាបញ្ចូលឥតឈប់ឈរសភាវៈ ព្រះជន្មលក្ខណៈ គ្រប់លក្ខណៈទាំងអស់ សិរីរុងរឿង សុភមង្គលដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គឲ្យព្រះបុត្រាព្រះអង្គ។ ព្រះបុត្រាពឹងពាក់ ឥតឈប់ឈរទៅព្រះបិតា អ្វីៗទាំងអស់ដែលព្រះអង្គបានទទួល ដោយមានទំនាក់ទំនងអបិន្ត្រៃយ៍ ដោយលើកតម្កើងសិរីរុងរឿង និងកោតសរសើរព្រះបិតាព្រះអង្គ។

ព្រះបិតា និងព្រះបុត្រាផ្ដល់ឲ្យព្រះវិញ្ញាណនូវអ្វីៗដែលជាលក្ខណៈរបស់ព្រះទាំងពីរនោះ អ្វីៗទាំងអស់ដែលព្រះទាំងពីរអង្គមាន អ្វីៗទាំងអស់ដែលព្រះទាំងពីរអង្គអាចធ្វើបាន និងអ្វីៗទាំងអស់ដែលព្រះទាំងពីរអង្គស្គាល់។ ព្រះវិញ្ញាណដ៏វិសុទ្ធពឹងពាក់ទៅលើព្រះបិតា និងព្រះបុត្រាជានិច្ចនូវអ្វីៗដែលព្រះអង្គបានទទួល ដូចគោលដើមរបស់ព្រះអង្គដែរ។

ដោយសារទំនាក់ទំនងទាំងអស់នោះចំពោះគ្នាទៅវិញទៅមក ព្រះទាំងបីអង្គនេះ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ មានសារជាតុ និងលក្ខណៈជាព្រះតែមួយ មានព្រះជន្មតែមួយ មានតេជានុភាពតែមួយ ព្រះប្រាជ្ញាញាណសប្បុរសធម៌ និងភាពដ៏វិសុទ្ធតែមួយ ហើយរួមជាមួយគ្នាជាថ្កុងតែមួយគ្រប់លក្ខណៈបំផុត។

ព្រះទាំងបីអង្គនេះ ទតឃើញគ្នាទៅវិញទៅមកជានិច្ច ដោយលើកតម្កើងសិរីរុងរឿងចំពោះគ្នាទៅវិញទៅមក និងស្រឡាញ់គ្នាទៅវិញទៅមកជាអបិន្ត្រៃយ៍ «ឱ! ព្រះត្រៃឯកដ៏វិសុទ្ធបំផុតអើយ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះអង្គ សូមថ្វាយព្រះពរចំពោះព្រះអង្គ សូមព្រះអង្គថ្កុំថ្កើនរុងរឿងលើសអ្វីៗសព្វប្រការ។ ខ្ញុំម្ចាស់សូមរួបរួមជាមួយព្រះអង្គ និងចូលរួមក្នុងសេចក្ដីស្រឡាញ់ និងសិរីរុងរឿង ដែលព្រះអង្គលើកថ្វាយទៅវិញទៅមក។ ខ្ញុំម្ចាស់សូមថ្វាយសិរីរុងរឿង ដែលព្រះអង្គមានដោយអង្គឯង ហើយខ្ញុំម្ចាស់រួមជាមួយព្រះសហគមន៍ដ៏វិសុទ្ធទាំងមូល សូមអរព្រះគុណព្រះអង្គ។ ពួកយើងសូមអរព្រះគុណព្រះអង្គជាអនេក បំពោះព្រះមហាសិរីរុងរឿងរបស់ព្រះអង្គ។ ពួកយើងសូមអរព្រះគុណព្រះបិតាអស់កល្បជានិច្ច ព្រះបុត្រាអស់កល្បជានិច្ចរបស់ព្រះអង្គ។ ពួកយើងសូមអរព្រះគុណព្រះបិតា និងព្រះបុត្រា ដែលបានប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ។ ពួកយើងសូមអរព្រះគុណជាអនេក ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណចំពោះសេចក្ដីស្រឡាញ់ សិរីរុងរឿង និងការលើកតម្កើងថ្វាយទៅវិញទៅមក។ ឱព្រះជាម្ចាស់ជាព្រះបិតារបស់ខ្ញុំម្ចាស់អើយ! ខ្ញុំម្ចាស់រីករាយក្នុងចិត្តណាស់ ដោយមើល

ឃើញព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គស្រឡាញ់ និងលើកតម្កើងសិរីរុងរឿងព្រះអង្គ ដោយសេចក្ដីស្រឡាញ់ និងដោយសិរីរុងរឿងស័ក្ដិសមនឹងឧត្ដមភាពរបស់ព្រះអង្គអស់កល្បជានិច្ច! ឱព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់អើយ! ព្រលឹងខ្ញុំម្ចាស់រីករាយក្នុងចិត្ត ដោយឃើញសេចក្ដីស្រឡាញ់ និងសិរីរុងរឿងជាអនេក ដែលព្រះអង្គទទួលពីព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ! ឱព្រះវិញ្ញាណដ៏វិសុទ្ធអើយ! ខ្ញុំម្ចាស់ត្រេកអរខ្លាំងណាស់ ដែលបានឃើញសេចក្ដីស្រឡាញ់ និងព្រះពរទាំងប៉ុន្មានដែលព្រះបិតា និងព្រះបុត្រាប្រទាន ចំពោះព្រះអង្គឥតឈប់ឈរ! ឱសហគមន៍ដ៏វិសុទ្ធអើយ! ឱឯកភាពអើយ! ឱសេចក្ដីស្រឡាញ់អើយ! ឱព្រះជន្មអស់កល្បជានិច្ចនៃព្រះទាំងបីអង្គអើយ! គួរឲ្យរីករាយម្ល៉េះទេ សប្បាយចិត្តម្ល៉េះទេ ខ្ញុំមានសុភមង្គលអ្វីម្ល៉េះទេ ដែលបានដឹងថា ព្រះអង្គបានទទួលសិរីរុងរឿងពេញបរិបូណ៌ ដែលមិនអាចរៀបរាប់បានអំពីសុភមង្គលដ៏អស្ចារ្យដែលគ្មានទីបញ្ចប់ ហើយនឹងដឹងថា ព្រះអង្គជាព្រះជាម្ចាស់ និងជាព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ និងសោយរាជ្យជារៀងរហូតអស់កល្បជានិច្ច!»

ចូរយើងប្រគល់ខ្លួនថ្វាយចំពោះព្រះជាម្ចាស់ ដើម្បីបម្រើ និងកោតសរសើរព្រះអង្គ តាមគ្រប់វិធីទាំងអស់ដែលព្រះអង្គមានព្រះហឫទ័យឲ្យយើងធ្វើ។ ដោយហេតុថា ព្រះអង្គមានព្រះបំណងខ្លាំងជាងគេគឺឲ្យយើងយកតម្រាប់តាមព្រះអង្គ ដោយព្រះអង្គជាគំរូរបស់យើង ដោយព្រះយេស៊ូគ្រីស្ដមានព្រះបន្ទូលមកយើងថា៖ ចូរអ្នករាល់គ្នាបានគ្រប់លក្ខណៈដូចព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខបានគ្រប់លក្ខណៈយ៉ាងនោះដែរ (មថ ៥,៤៨) គ្រីស្ដទូតរបស់ព្រះអង្គមានប្រសាសន៍ថា៖ ចូរបងប្អូនយកតម្រាប់តាមព្រះជាម្ចាស់ (អភ ៥,១) ចូរយើងប្រគល់ខ្លួនថ្វាយចំពោះព្រះអង្គ ដោយមានបំណងប្រាថ្នាមួយយ៉ាងធំ គឺយកតម្រាប់តាមភាពដ៏វិសុទ្ធ ភាពបរិសុទ្ធ សប្បុរសធម៌ ព្រះហឫទ័យអាណិតអាសូរ ភាពអត់ធ្មត់ ការប្រុងប្រយ័ត្ន ព្រះឫទ័យស្លូតបូត និងសភាពគ្រប់លក្ខណៈឯទៀតរបស់ព្រះអង្គ ហើយចូរយើងទូលអង្វរសូមឲ្យព្រះអង្គ ផ្ដិតផ្ដាមមកក្នុងព្រលឹងរបស់យើងនូវភាពដ៏វិសុទ្ធគ្រប់លក្ខណៈនៃព្រះជន្ម និងគុណធម៌ផ្សេងទៀតរបស់ព្រះអង្គ។

ពួកយើងទទួលអគ្គសញ្ញាជ្រមុជទឹកដោយសារព្រះអម្ចាស់នៃយើង គឺព្រះយេស៊ូគ្រីស្ដ ប៉ុន្ដែក្នុងព្រះនាមព្រះត្រៃឯក ដ្បិតព្រះទាំងបីអង្គយាងចុះមកប្រថាប់ក្នុងពិធីជ្រមុជទឹក តាមរបៀបដ៏ពិសេសមួយ។ ព្រះបិតាយាងមក *"ផ្ដល់ព្រះជន្ម"* ឲ្យព្រះបុត្រាមានន័យថា ព្រះអង្គបង្កើតមនុស្សថ្មីម្នាក់ ជីវិតថ្មីមួយថ្វាយព្រះបុត្រា ដើម្បីឲ្យព្រះបុត្រាយាងមកគង់នៅក្នុងយើង។ ព្រះបុត្រាយាងមកចាប់កំណើត និងមានព្រះជន្មក្នុងចិត្តគំនិតយើង ដើម្បីឲ្យយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដូចព្រះយេស៊ូផងដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកបង្កើតព្រះយេស៊ូក្នុងចិត្តគំនិតយើងរាល់គ្នា ដូចកាលព្រះអង្គបង្កើតព្រះបុត្រាក្នុងផ្ទៃព្រហ្មចារីយ៍ដែរ។ ព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកក្នុងពិធីនេះ ដើម្បីឲ្យយើងសក្ដិសម និងភ្ជាប់រួបរួមជាមួយព្រះអង្គតាមរបៀបពិសេស និងដើម្បីឲ្យយើងទៅជារូបតំណាងរបស់ព្រះអង្គ។ ពេលនោះ ព្រះអង្គទុកយើងជាព្រះដំណាក់ ជាសិរីរុងរឿង ជាព្រះរាជ្យ និងជាព្រះជន្មព្រះអង្គ។ បន្ថែមពីលើនេះទៀត ប្រសិនបើអំពើបាបរបស់យើងមិនប្រឆាំងនឹងព្រះអង្គទេនោះព្រះទាំងបីអង្គអស់កល្បជានិច្ច នឹងគង់នៅជារៀងរហូត តាមរបៀបពិសេសមួយដែលមិនអាចនិយាយពន្យល់បាន។ ព្រះទាំងបីអង្គប្រកបដោយសិរីរុងរឿងគួរឲ្យស្ញប់ស្ញែង ព្រះអង្គនឹងគ្រងរាជ្យបានគ្រប់លក្ខណៈ ហើយនឹងមានព្រះជន្មដ៏វិសុទ្ធ និងល្អឥតខ្ចោះ ក្នុងចិត្តយើង។ បន្ទាប់ពីនេះមកទៀត ពួកយើងជាកម្មសិទ្ធរបស់ព្រះជាម្ចាស់ ដូចជាអ្វីមួយដែលគេយកមកថ្វាយព្រះអង្គ។ ដូច្នោះហើយ បានជាយើងមិនអាច

ធ្វើអ្វីក្រៅពីលើកតម្កើងសិរីរុងរឿង និងបម្រើព្រះអង្គឡើយ។

ឱព្រះត្រៃឯកដ៏វិសុទ្ធ គួរឲ្យគោរពសរសើរអើយ! ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំចំពោះព្រះសារជាតុ ជាព្រះត្រៃឯកអស់កល្បជានិច្ច ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំ ដ្បិតព្រះអង្គមានព្រះវត្តមានក្នុងពិធីជ្រមុជទឹករបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមគោរពចំពោះព្រះបំណងទាំងអស់របស់ព្រះអង្គ ចំពោះរូបខ្ញុំម្ចាស់។ សូមព្រះអង្គលើកលែងទោសដល់ខ្ញុំម្ចាស់ ដែលបានធ្វើឲ្យរាំងស្ទះមិនឲ្យព្រះបំណងនោះបានសម្រេច ឲ្យបានពេញលេញ ហើយដើម្បីទូទាត់ ខ្ញុំម្ចាស់សូមថ្វាយព្រះជន្ម កិច្ចការ និងទុក្ខលំបាកទាំងប៉ុន្មានរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត និងព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គ។ ខ្ញុំម្ចាស់សូមបូជាជីវិតទាំងស្រុងចំពោះព្រះអង្គ ឱព្រះត្រៃឯកអើយ! ខ្ញុំម្ចាស់សូមថ្វាយខ្លួនចំពោះព្រះអង្គ ដើម្បីឲ្យព្រះអង្គបំពេញតាមព្រះបំណងទាំងអស់នោះទៅចុះ។ ឱព្រះបិតាអស់កល្បជានិច្ចអើយ! ឱព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់អើយ! ឱព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះបិតា និងព្រះបុត្រាអើយ! សូមព្រះអង្គយាងមកគង់នៅក្នុងចិត្តខ្ញុំម្ចាស់...យាងមកគង់ក្នុងព្រលឹងខ្ញុំម្ចាស់ សូមព្រះអង្គបំបែកចេញពីខ្ញុំម្ចាស់នូវអ្វីៗដែលមិនមែនជារបស់ព្រះអង្គ សូមព្រះអង្គទាក់ទាញខ្ញុំម្ចាស់ទៅរកព្រះអង្គផង សូមព្រះអង្គគង់នៅ និងគ្រងរាជ្យក្នុងចិត្តខ្ញុំម្ចាស់ ហើយកម្ទេចចោលនូវអ្វីៗដែលព្រះអង្គមិនសព្វព្រះហឫទ័យផង។ សូមព្រះអង្គប្រព្រឹត្តយ៉ាងណាឲ្យរូបកាយ និងជីវិតខ្ញុំម្ចាស់លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។

ព្រះជាម្ចាស់
ព្រះអង្គគង់ពីលើអ្វីៗទាំងអស់? ទាំងស្រុង
គ្រប់ទិសទីទាំងអស់
ព្រះជាម្ចាស់ជាព្រះត្រៃឯកដ៏មានសុភមង្គលលើសអ្វីៗទាំងអស់។
អ្វីៗទាំងអស់កើតមកក្រោយព្រះអង្គ

អ្វីៗទាំងអស់មកពីព្រះជាម្ចាស់។ ដោយព្រះបុត្រាតែមួយរបស់ព្រះអង្គ ព្រះបិតាជាប្រភពនៃអ្វីៗទាំងអស់។ ព្រះអង្គជាអ្នកទីមួយដែលបានស្រឡាញ់មុនគេ អ្វីៗទាំងអស់ផុសចេញពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយអ្វីៗទាំងអស់ឆ្លុះបញ្ចាំងពីសិរីរុងរឿងរបស់ព្រះអង្គ។

សេចក្តីស្រឡាញ់របស់ព្រះអង្គនេះ បានធ្វើឲ្យមនុស្សអាចស្គាល់អំណរសប្បាយ ដែលពួកគេទទួលបានមកពីព្រះអង្គ។ ព្រះជាម្ចាស់បានបង្កើតមនុស្សឡើងដើម្បីព្រះអង្គ។

គឺសេចក្តីស្រឡាញ់ប្រកបដោយព្រះហឫទ័យមេត្តាករុណា ព្រះអង្គនេះហើយដែលបានសង្គ្រោះមនុស្សបាប ដោយសារព្រះគ្រីស្តបានរងទុក្ខលំបាក។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រណីឲ្យមនុស្សអាចស្រឡាញ់ដូចព្រះជាម្ចាស់។

អ្វីទាំងអស់ងាកទៅរកព្រះជាម្ចាស់។ សកលលោកទាំងមូលងាកទៅរកព្រះជាម្ចាស់ ហើយគោរពបូជាព្រះអង្គ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសមនុស្សឲ្យបានវិសុទ្ធ ដើម្បីឲ្យគេរីកចម្រើន និងកសាងផែនដីទៅតាមគម្រោងការរបស់ព្រះបិតា ទៅតាមសន្ទុះនៃសេចក្តីស្រឡាញ់ ដោយគ្មានការបង្ខិតបង្ខំ។ នេះហើយជាសក្ការៈបូជា ដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅក្នុងអង្គព្រះយេស៊ូគ្រីស្ត។ ពួកអ្នកបាបមិនអាចធ្វើបានទាល់តែសោះ ប៉ុន្តែព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់មានមហិទ្ធិរិទ្ធខ្លាំងណាស់។ យើងមិនអាច

យល់អ្វីសោះ ក្រៅពីព្រះជាម្ចាស់។

- ០ មើលឃើញអ្វីៗទាំងអស់ ភាពជាក់ស្តែងជាមួយនឹងក្រសែព្រះនេត្រានៃព្រះគ្រីស្ត
- ០ វិនិច្ឆ័យអ្វីៗទាំងអស់ជាមួយនឹងដំណឹងល្អ ក្នុងអង្គព្រះវិញ្ញាណ
- ០ ប្រព្រឹត្តិកិច្ចការតាមព្រះបំណងប្រកបដោយសេចក្តីស្រឡាញ់របស់ព្រះបិតា បំពោះផែនដីរបស់យើង។

សូមឲ្យយើងថ្វាយបង្គំ កោតសរសើរ និងអរព្រះគុណចំពោះសិរីរុងរឿង និងព្រះហឫទ័យសុភាពរាបសារបស់ព្រះជាម្ចាស់ដែលព្រះយេស៊ូគ្រីស្តបានសម្តែងឲ្យយើងស្គាល់។

**បងស្រី អេសីសាបែត នៃព្រះត្រៃឯក ជាដូនជីម្នាក់នៅអារាមកាមែល ដែលបានទទួលមរណភាពនៅឆ្នាំ១៩០៦ បានទូលអង្វរដូចតទៅ៖**

ឱព្រះជាម្ចាស់ជាព្រះត្រៃឯក ដែលខ្ញុំគោរពក្រាបថ្វាយបង្គំអើយ! សូមព្រះអង្គជួយខ្ញុំម្ចាស់ឲ្យបំភ្លេចខ្លួនឯងទាំងស្រុងទៅ ដើម្បីឲ្យខ្ញុំម្ចាស់រួបរួមជាមួយព្រះអង្គយ៉ាងស្ងៀមស្ងាត់ ដូចជាព្រលឹងខ្ញុំម្ចាស់នៅឯស្ថានបរមសុខ! សូមកុំឲ្យមានអ្វីមករំខានសេចក្តីស្ងប់ស្ងាត់របស់ខ្ញុំម្ចាស់ ឬក៏ធ្វើឲ្យខ្ញុំម្ចាស់ចាកចេញពីព្រះអង្គឡើយ។ ឱព្រះដែលមិនចេះប្រែប្រួលរបស់ខ្ញុំម្ចាស់អើយ! សូមព្រះអង្គនាំខ្ញុំម្ចាស់ឲ្យកាន់តែឆ្ងាយទៅៗ រាល់នាទីចូលទៅកាន់ទីជម្រៅនៃគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ!...

ឱព្រះបន្ទូលអស់កល្បជានិច្ចអើយ! ព្រះបន្ទូលនៃព្រះជាម្ចាស់របស់ខ្ញុំម្ចាស់! ខ្ញុំចង់រស់ដើម្បីស្តាប់ព្រះបន្ទូលព្រះអង្គ ខ្ញុំម្ចាស់ចង់ភ្ជាប់ខ្លួនជាមួយព្រះអង្គជារៀងរហូត ដើម្បីរៀនអ្វីៗទាំងអស់ពីព្រះអង្គ ខ្ញុំម្ចាស់ចង់សម្លឹងមើលព្រះអង្គជានិច្ច និងស្ថិតនៅក្រោមពន្លឺដ៏ធំធេងរបស់ព្រះអង្គ ដោយឆ្លងកាត់ភាពងងឹត និងភាពទន់ខ្សោយទាំងអស់...

ឱព្រះវិញ្ញាណដ៏វិសុទ្ធអើយ! ព្រះអង្គជាភ្លើងដ៏រស់រវើក ព្រះអង្គជាសេចក្តីស្រឡាញ់! សូមយាងមកគង់ប្រថាប់ជាមួយខ្ញុំម្ចាស់ ដើម្បីឲ្យព្រះបន្ទូលចាប់កំណើតក្នុងចិត្តខ្ញុំម្ចាស់ ហើយសូមឲ្យខ្ញុំម្ចាស់ជាមនុស្ស ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យបំពេញគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ។

ខ្ញុំអាន (កណ ១៨,១-១៥) ហើយខ្ញុំសញ្ជឹងគិតទៅដល់រូបភាពនៃព្រះត្រៃឯកដ៏វិសុទ្ធ គូរដោយលោករូបប្លេវ (Roublev) ដោយបណ្តោយឲ្យអ្វីដែលខ្ញុំបានយល់ឃើញអំពីព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជ្រួតជ្រាបក្នុងចិត្តខ្ញុំ។ ខ្ញុំសូមក្រាបថ្វាយបង្គំ។

## ទុកពេល សម្រាប់ការលើកលែងទោស

១-ចូរប្រៀបធៀបនូវអ្វីៗ ដែលយើងព្យាយាមនិយាយ អំពីព្រះជាម្ចាស់នៅពេលចាប់ផ្តើមដំណាក់កាលនេះជាមួយនឹងអ្វីៗដែលមាននៅក្នុងចិត្តយើងក្នុងពេលនេះ។

២- ដោយបានខិតទៅជិតសិរីរុងរឿងដ៏វិសុទ្ធនៃព្រះជាម្ចាស់ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណតាមរយៈព្រះគម្ពីរដំណឹងល្អ និងអត្ថបទផ្សេងៗរបស់សន្តៈយ៉ូហាន អើដ តើយើងអាចសូមលើកលែងទោសអំពីអ្វី?

៣- ក្នុងពិធីបុណ្យផ្សេងៗ (អភិបូជា អគ្គសញ្ញា...) សូមរកពាក្យពេចន៍ ដែលនិយាយអំពីព្រះត្រៃឯក។ អត្ថបទខ្លះ ធ្វើឲ្យយើងចូលទៅដល់ការសូមលើកលែងទោសពីព្រះជាម្ចាស់។ ចូរយើងអធិដ្ឋានជាមួយ

នឹងពាក្យពេចន៍ទាំងនោះ។

ខ្ញុំបណ្ដោយឲ្យព្រះវិញ្ញាណនៃព្រះយេស៊ូប្រែក្លាយចិត្តខ្ញុំ ដែលតូចចង្អៀត ហើយខ្ញុំថ្វាយបំណងប្រាថ្នា និងភាពទន់ខ្សោយរបស់ខ្ញុំទៅកាន់ព្រះជាម្ចាស់ជាព្រះបិតា។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- ពេលយើងជឿលើព្រះជាម្ចាស់ ព្រះត្រៃឯកដែលព្រះយេស៊ូណែនាំឲ្យយើងស្គាល់នោះ ប៉ះពាល់នឹងរបៀបរស់នៅរបស់យើង និងរបៀបអធិដ្ឋាន។ សូមរកនឹកឲ្យឃើញឡើងវិញ នូវកាយវិការដ៏ប្រពៃនៃសញ្ញាឈើឆ្កាង ដែលលោកបូជាចារ្យបានធ្វើនៅថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក។

លោកបូជាចារ្យមានប្រសាសន៍ទៅកាន់អ្នកស្វែងយល់ ដែលទទួលការអប់រំជំនឿថា៖

- ចូរអ្នកទទួលសញ្ញាឈើឆ្កាងនៅលើត្រចៀក ដើម្បីឲ្យអ្នកស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្ដ
- ចូរអ្នកទទួលសញ្ញាឈើឆ្កាងលើភ្នែក ដើម្បីឲ្យអ្នកអាចមើលឃើញកិច្ចការរបស់ព្រះយេស៊ូគ្រីស្ដ
- ចូរអ្នកទទួលសញ្ញាឈើឆ្កាងនៅលើបបូរមាត់ ដើម្បីឲ្យអ្នកចេះឆ្លើយតបនឹងព្រះយេស៊ូគ្រីស្ដ ដែលមានព្រះបន្ទូលមករកអ្នក។
- ចូរអ្នកធ្វើសញ្ញាឈើឆ្កាងនៅលើបេះដូង ដើម្បីឲ្យអ្នកចេះទទួលព្រះយេស៊ូគ្រីស្ដក្នុងចិត្តអ្នក។
- ចូរអ្នកធ្វើសញ្ញាឈើឆ្កាងនៅលើស្មា ដើម្បីឲ្យអ្នកទទួលកម្លាំង ដែលមកពីព្រះយេស៊ូគ្រីស្ដ
- ខ្ញុំធ្វើសញ្ញាឈើឆ្កាងលើខ្លួនអ្នក ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យអ្នករួមរស់ជាមួយព្រះយេស៊ូគ្រីស្ដចាប់ពីពេលនេះទៅជារៀងរហូត។ អាម៉ែន

២- សូមសួរខ្លួនឯងនូវសំណួរដូចតទៅ៖

- ព្រះជាម្ចាស់បានបង្កើតយើងជារូបតំណាងរបស់ព្រះអង្គ ជាព្រះបិតា។ តើខ្ញុំនឹងផ្ដល់ជីវិតឲ្យអ្នកឯទៀតយ៉ាងដូចម្ដេច?
- ខ្ញុំបានទទួលឋានៈដ៏ថ្លៃថ្នូរជាបុត្ររបស់ព្រះជាម្ចាស់។ តើខ្ញុំនឹងទទួលស្គាល់ឋានៈដ៏ថ្លៃថ្នូរនេះ នៅក្នុងមនុស្សគ្រប់ៗរូបយ៉ាងដូចម្ដេច?
- ព្រះវិញ្ញាណរបស់ព្រះយេស៊ូណែនាំខ្ញុំ។ តើខ្ញុំនឹងបើកចិត្តឲ្យទូលាយ គោរពអស់អ្នក ដែលគិតប្លែកពីខ្ញុំយ៉ាងដូចម្ដេច?

ខ្ញុំរិះគិតអំពីរបៀបរស់នៅរបស់ខ្ញុំ ដើម្បីចូលទៅក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ។ ខ្ញុំអធិដ្ឋាន។

# ប្រកាសជំនឿរបស់ខ្លួន

ជំនឿជាមូលដ្ឋានគ្រឹះនៃជីវិតជាគ្រីស្តបរិស័ទ!

## ដំណាក់កាលទី ១៣

បើបបូរមាត់អ្នកប្រកាសថា ព្រះយេស៊ូជាព្រះអម្ចាស់ ហើយបើចិត្តអ្នកជឿថា ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មីនោះ អ្នកបានទទួលការសង្គ្រោះ (រម ១០,៩)

**ក្នុងដំណាក់កាលនេះមាន ៖** ខ្ញុំបានទទួលព្រះបន្ទូល ដែលត្រាស់ហៅខ្ញុំឲ្យទៅជាសាវ័កម្នាក់ ដែលស្តាប់ដោយមិនបន្លំ ដែលថែរក្សាព្រះបន្ទូលដូចព្រះនាងម៉ារី...
ខ្ញុំបានស្តាប់ព្រះយេស៊ូមានព្រះបន្ទូលអំពី តើព្រះជាម្ចាស់ជានរណា...
គឺជាព្រះបង្កើតមួយព្រះអង្គ ព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណ ដែលបានបង្កើតមនុស្សលោក ជារូបតំណាងព្រះអង្គ និងមានលក្ខណៈដូចព្រះអង្គ។ ព្រះអង្គត្រាស់ហៅខ្ញុំឲ្យប្រួមជាមួយអ្នកដទៃជាផ្លូងតែមួយ...ខ្ញុំបានយល់ឃើញថា ខ្លួនឯង និងមនុស្សជាតិនេះ បដិសេធមិនព្រមទទួលគម្រោងការរបស់ព្រះជាម្ចាស់ ...ខ្ញុំបានយល់ឃើញអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលព្រះយេស៊ូសម្តែងឲ្យខ្ញុំស្គាល់ដោយសុគត និងមានព្រះជន្មថ្មី...ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យប្រកាសជំនឿលើព្រះយេស៊ូគ្រីស្ត។

**គោលដៅនៃដំណាក់កាលនេះ ៖** ឥឡូវនេះ ខ្ញុំត្រូវប្រកាសជំនឿលើព្រះជាម្ចាស់៖
- ត្រូវឆ្លើយតបនឹងសំណួររបស់ព្រះយេស៊ូ៖ តើខ្ញុំជានរណា? (មថ ១៦,១៥)
- សរសេរធម៌ប្រកាសជំនឿរបស់ខ្ញុំ
- តើមានសភាពស្រូបគ្នា...រវាងធម៌ប្រកាសជំនឿរបស់ខ្ញុំ និងអ្វីៗដែលព្រះគម្ពីរសម្តែងឲ្យដឹងអំពីព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ (ការប្រកាសជំនឿនៃព្រះសហគមន៍)... រវាងអ្វីៗដែលខ្ញុំបាននិយាយជឿ និងធ្វើឬទេ?

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចប្រាប់ថា តើខ្ញុំជឿលើព្រះមួយណា...

### ទុកពេល សម្រាប់បើកចិត្ត និងទទួល

**១**- «ខ្ញុំជឿ» ជាពាក្យពេចន៍ ដែលយើងប្រើរាល់ថ្ងៃ...ហើយពាក្យនេះតែងតែនាំមកជាមួយនូវពាក្យថា... ខ្ញុំជឿថា...ខ្ញុំជឿលើ...កាលដែលយើងប្រើពាក្យទាំងនេះ តើយើងសំអាងទៅលើបទពិសោធន៍ណាខ្លះ? បទពិសោធន៍នៃមិត្តភាព ខ្ញុំជឿលើគាត់... ជឿលើពាក្យសម្តីគាត់? បទពិសោធន៍នៃសេចក្តីពិតជាមួយខ្លួនឯង ជាមួយអ្នកដទៃ?

**២**-កាលដែលយើងអះអាងថា «ជឿថា» «ជឿលើ» តើយើងដឹងខ្លួនទេ ថាពាក្យទាំងនោះនាំយើងឲ្យ

ប្រព្រឹត្តកិច្ចការតាមពាក្យសម្ដីឬទេ?

៣- តើយើងបើកចិត្តយ៉ាងងាយ ដើម្បីទទួល «ការប្រកាសជំនឿ» របស់អ្នកដទៃឬទេ...? តើយើងយល់ព្រមទទួល «សេចក្ដីពិត» ដែលមកពីអ្នកដទៃឬទេ...?

៤- លើកយកពាក្យធាប់ជឿ អ្នកជឿ ជំនឿ ការជឿ។ តើយើងអាចបែកឲ្យដាច់ពីគ្នាឬទេ...?

ខ្ញុំយល់ឃើញអំពីឥរិយាបថរបស់ខ្ញុំចំពោះការជឿ...ចំពោះជំនឿ។

ខ្ញុំទទួលបំណងចង់បានសេចក្ដីពិតរបស់ខ្ញុំ ជាមួយខ្លួនខ្ញុំផ្ទាល់ ជាមួយអ្នកឯទៀតផង។

ខ្ញុំបើកចិត្តឲ្យទូលាយ ដើម្បីជៀសវាងបង្ខាំងខ្លួនក្នុងសេចក្ដីពិតរបស់ខ្ញុំ...

ខ្ញុំផ្ទៀងផ្ទាត់ទំនាក់ទំនងរបស់ខ្ញុំជាមួយអ្នកឯទៀត និងសមត្ថភាពរបស់ខ្ញុំក្នុងការទទួលអ្នកដទៃ ក្រៅពីខ្លួនឯង។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១-សូមអានព្រះបន្ទូលរបស់ព្រះយេស៊ូអំពីជំនឿ៖ (យហ ៦,៤៧; យហ ១៧,៣; យហ ៦,២៨-២៩; យហ ១០,២៥.៣៧-៣៨ )(រកព្រះបន្ទូលផ្សេងទៀតទៅក្នុងដំណឹងល្អតាមសន្ដៈយ៉ូហាន)។

២-សូមស្ដាប់សំណួររបស់ព្រះយេស៊ូសួរទៅពួកសាវ័ក៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថា ខ្ញុំជានរណា?» (មថ ១៦, ១៣ -២០; មក ៨,២៧-៣០; លក ៩,១៨-២១)។

៣-មនុស្សប្រុសស្រីនៅជុំវិញព្រះយេស៊ូប្រកាសជំនឿរបស់ខ្លួន(មក៨,២៤-៣០)សូមឲ្យព្រះយេស៊ូពង្រឹងជំនឿបន្ថែមទៀត(មក ៩,២៤)...ព្រះយេស៊ូទ្រង់កោតស្ញប់ស្ញែង (លក ៧,៩)។

៤- ដោយពិចារណាដល់ជីវិតយើង ជាអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក សន្ដៈយ៉ូហាន អើដ និយាយប្រាប់ថា ថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានប្រកាសអំពីព្រះយេស៊ូគ្រីស្ដ។ គាត់យល់ឃើញថា ការប្រកាសនេះ ប៉ះពាល់ដល់របៀបរស់នៅអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក។

ឱព្រះយេស៊ូជាអម្ចាស់អើយ! ខ្ញុំម្ចាស់សូមថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គជារៀងរហូតតរៀងទៅ។ ខ្ញុំម្ចាស់ប្រាថ្នាសូមភ្ជាប់ខ្លួននឹងលទ្ធិដ៏វិសុទ្ធរបស់ព្រះអង្គដោយសារជំនឿ ចំពោះព្រះបន្ទូលសន្យាដ៏វិសុទ្ធ ដោយសារសេចក្ដីសង្ឃឹមចំពោះវិន័យដ៏ឥតខ្ចោះ និងដំបូន្មានរបស់ព្រះអង្គ ដោយសេចក្ដីស្រឡាញ់ និងសប្បុរសធម៌។ ខ្ញុំម្ចាស់មានបំណងដើរតាមព្រះអង្គ ក្នុងការអនុវត្តអំពើដែលជាគុណធម៌ទាំងអស់របស់ព្រះអង្គ ហើយខ្ញុំម្ចាស់ចង់ធ្វើតាមព្រះអង្គជាមេដឹកនាំរបស់ខ្ញុំម្ចាស់ៗ ដែលជាសមាជិកម្នាក់របស់ព្រះអង្គ។ ខ្ញុំម្ចាស់មានបំណងបន្តព្រះជន្មព្រះអង្គទៅលើផែនដីនេះ តាមដែលអាចធ្វើបាន លុះត្រាតែបានទទួលការសន្ដោសប្រណីពីព្រះអង្គ ដែលខ្ញុំម្ចាស់តែងតែទូលអង្វរជានិច្ច។

គ្រឹះដំបូងនៃជីវិតជាគ្រីស្ដបរិស័ទ គឺជំនឿ ដ្បិតបើយើងចង់ទៅរកព្រះជាម្ចាស់ ហើយចូលទៅជួបព្រះអង្គជំហានទីមួយដែលខ្ញុំត្រូវធ្វើគឺជឿ។ បើគ្មានជំនឿទេ ព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យឡើយ (ហប ១១,៦)។ ជំនឿ គឺជាសារជាតុ និងជាគ្រឹះនៃអ្វីដែលយើងសង្ឃឹមទុកជាមុន (ហប ១១,)។ ជំនឿជាផ្ទាំងសិលា គ្រឹះដ៏សំខាន់របស់ដំណាក់នៃព្រះរាជ្យរបស់ព្រះយេស៊ូគ្រីស្ដ។

គឺជាពន្លឺនៃស្ថានបរមសុខ ដែលល្អឥតខ្ចោះ...ដែលភ្លឺចាំងចែង ជាការចូលរួមក្នុងពន្លឺអស់កល្បជានិច្ច និង

មិនអាចទៅដល់ ជាកាំរស្មីនៃព្រះភ័ក្ត្រព្រះជាម្ចាស់ ឬបើនិយាយឲ្យត្រូវតាមព្រះគម្ពីរ ជំនឿដូចជាលក្ខណៈដ៏ល្អឥតខ្ចោះ ដែលពន្លឺរបស់ព្រះភ័ក្ត្រព្រះជាម្ចាស់ ជាស្នាមសម្រាប់សម្គាល់ក្នុងព្រលឹងយើង( ទន ៤,៧ )។ គឺជាទំនាក់ទំនងមួយ ហើយដូចជាការលោតសន្ទឹងនៃពន្លឺ និងវិទ្យាសាស្ត្រល្អឥតខ្ចោះ ដែលត្រូវបានចាក់បញ្ចូលទៅក្នុងព្រលឹងដ៏វិសុទ្ធនៃព្រះយេស៊ូ នៅពេលដែលព្រះអង្គចាប់កំណើត។ ជំនឿជាវិទ្យាសាស្ត្រដើម្បីសង្គ្រោះ ជាវិទ្យាសាស្ត្ររបស់ជនដ៏វិសុទ្ធ ជាវិទ្យាសាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះយេស៊ូបានដួសចេញពីព្រះឱ៉ានៃព្រះបិតា ដែលព្រះអង្គបាននាំយកមកឲ្យយើងនៅលើផែនដីនេះ ដើម្បីបំបាត់ភាពងងឹតងងុល...ដើម្បីបំភ្លឺចិត្តយើង... ដើម្បីឲ្យយើងមានចំណេះដឹងចាំបាច់... ដើម្បីបម្រើ និងស្រឡាញ់ព្រះជាម្ចាស់បានគ្រប់លក្ខណៈ...ដើម្បីឲ្យវិញ្ញាណយើងចុះចូល និងស្ថិតនៅក្រោមអំណាចនៃសេចក្តីពិត ដែលព្រះអង្គបានបង្រៀន ហើយដែលព្រះអង្គបង្រៀនយើងជារៀងរហូតមក ដោយអង្គឯង និងដោយព្រះសហគមន៍របស់ព្រះអង្គ។ ដោយសារជំនឿ យើងបន្តកិច្ចការព្រះអង្គ និងបំពេញការចុះចូលរបស់ព្រះយេស៊ូគ្រីស្តក្នុងឋានៈជាមនុស្ស ចំពោះសេចក្តីពិតដែលព្រះបិតាអស់កល្បជានិច្ចរបស់ព្រះអង្គបានប្រកាសឲ្យព្រះអង្គ។ គឺពន្លឺ និងវិទ្យាសាស្ត្រនៃព្រះជាម្ចាស់នេះហើយ ដែលផ្តល់ចំណេះដឹងល្អឥតខ្ចោះឲ្យយើង អំពីអ្វីៗទាំងអស់ដែលស្ថិតនៅក្នុងអង្គព្រះជាម្ចាស់ និងនៅខាងក្រៅពីព្រះជាម្ចាស់ទៀតផង។ វិចារណញ្ញាណ និងវិទ្យាសាស្ត្ររបស់មនុស្សបន្លំយើងជាញឹកញយ... ប៉ុន្តែដោយសារអ្នកជឿចូលរួមចំណែកក្នុងសេចក្តីពិត និងពន្លឺនៃព្រះជាម្ចាស់ ជំនឿមិនអាចបន្លំយើងបានទេ ផ្ទុយទៅវិញ ជំនឿធ្វើឲ្យយើងមើលឃើញអ្វីៗទាំងអស់ ដូចព្រះជាម្ចាស់ទតឃើញដែរ។

ហេតុនេះហើយទាល់តែយើងក្រឡេកមើលទៅព្រះជាម្ចាស់ ដោយក្រសែភ្នែកនៃជំនឿ ទើបយើងនឹងមើលឃើញព្រះអង្គក្នុងសេចក្តីពិត ហាក់ដូចនៅទល់មុខគ្នាម្យ៉ាង។ ដោយហេតុថា ជំនឿភ្ជាប់នឹងភាពងងឹត ជំនឿធ្វើឲ្យយើងមើលឃើញព្រះជាម្ចាស់មិនច្បាស់លាស់ទេ ហាក់ដូចជាមើលឃើញព្រះអង្គ មិនមែននៅលើមេឃទេ ប៉ុន្តែដូចជាមានពពកបាំង។ ក៏ប៉ុន្តែជំនឿមិនបង្រួញទ្រង់ទ្រាយរបស់ព្រះអង្គ ឲ្យប្រាជ្ញាយើងឆាប់យល់ព្រះអង្គបាន( ដូចវិទ្យាសាស្ត្រធ្វើ ) ប៉ុន្តែជំនឿជ្រាបចូលឆ្លងកាត់ម្លប់ និងភាពងងឹតរហូតដល់ភាពគ្រប់លក្ខណៈជាអនេករបស់ព្រះអង្គ ហើយធ្វើឲ្យយើងស្គាល់ព្រះអង្គទៅតាមព្រះរូបព្រះអង្គពិត មានន័យថា យើងមើលស្គាល់ព្រះអង្គ និងលក្ខណៈល្អឥតខ្ចោះរបស់ព្រះអង្គ។

ជំនឿធ្វើឲ្យយើងស្គាល់ថា អ្វីៗដែលនៅក្នុងអង្គព្រះជាម្ចាស់ និងនៅក្នុងអង្គព្រះយេស៊ូគ្រីស្តដែលជាមនុស្សផង ជាព្រះជាម្ចាស់ផង មានលក្ខណៈឧត្តុង្គឧត្តមជាអនេក និងគួរឲ្យកោតសរសើរក្រៃលែង គោរពបូជាជាអនេក និងគួរឲ្យស្រឡាញ់ ហើយស័ក្តិសមនឹងទទួលការលើកតម្កើងសិរីរុងរឿង និងសេចក្តីស្រឡាញ់ចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គផ្ទាល់។

ជំនឿធ្វើឲ្យយើងមើលឃើញថា ព្រះជាម្ចាស់ជាព្រះពិតៗ ដែលមានភក្តីភាពចំពោះព្រះបន្ទូលសន្យារបស់ព្រះអង្គ។ ព្រះអង្គជាសប្បុរសធម៌ សុភាពរាបសា ពោរពេញទៅដោយសេចក្តីស្រឡាញ់ ចំពោះអស់អ្នកដែលស្វែងរកព្រះអង្គ ហើយផ្ញើជីវិតលើព្រះអង្គ។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះអ្វីៗដែលខ្ញុំយល់ឃើញអំពីព្រះយេស៊ូ ចំពោះទំនាក់ទំនងរបស់ព្រះអង្គជាមួយបុរស និងស្ត្រីនៅសម័យនោះ...ខ្ញុំបណ្តោយឲ្យអត្ថបទផ្សេងៗ ដែលខ្ញុំបានអានជ្រាបចូលក្នុងចិត្ត។ នៅក្នុងខ្លួនខ្ញុំព្រះវិញ្ញាណធ្វើការឲ្យខ្ញុំមានជំនឿ។ ខ្ញុំបណ្តោយចិត្តតាមកិច្ចការរបស់ព្រះអង្គ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ក្រោយពីបានសញ្ជឹងគិតអំពីជំនឿរបស់នាយទាហានរ៉ូម៉ាំង ជំនឿរបស់ស្ត្រីជនជាតិស៊ីរី-ផេនីស៊ី... ជំនឿរបស់ពួកសាវ័ក ក្នុងពេលដែលគេឆ្លើយតបនឹងសំណួររបស់ព្រះយេស៊ូថា «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថា ខ្ញុំជាអ្នកណា?»...ការស្ញប់ស្ញែងរបស់ព្រះយេស៊ូចំពោះជំនឿរបស់អស់អ្នកដែលមកគាល់ព្រះអង្គ...សូមនិយាយប្រាប់ថា តើអ្វីៗទាំងអស់នោះនាំឲ្យយើងប្រព្រឹត្តអ្វីខ្លះ? អ្វីដែលធ្វើឲ្យយើងភ្ញាក់ផ្អើល? ចំពោះយើង តើព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យពិចារណាឡើងវិញ អំពីជំនឿ និងរបៀបរស់នៅរបស់យើងឬទេ? សូមរកឲ្យឃើញវិស័យខ្លះៗ ដែលជាក់ស្តែងយើងគិតថាត្រូវកែប្រែចិត្តគំនិត...

២- សូមគ្រាន់តែទូលទៅព្រះអម្ចាស់ នូវសេចក្តីអធិដ្ឋានរបស់ឪពុក ដែលមានកូនកើតជំងឺឆ្កួតជ្រូក (ប្រកាច់) (មក៩,២៤)៖ ព្រះអម្ចាស់អើយ! ខ្ញុំជឿប៉ុន្តែសូមព្រះអង្គយាងមកជួយខ្ញុំម្ចាស់ ដែលមានជំនឿតិចតួចនេះផង។

៣- តើយើងនឹងពិនិត្យបញ្ជាក់ជំនឿរបស់យើងសព្វថ្ងៃនេះជាមួយអ្នកណា?

ខ្ញុំសូមព្រះយេស៊ូលើកលែងទោស ដោយបណ្តោយខ្លួនតាមព្រះបន្ទូលរបស់ព្រះអង្គ៖ ទៅចុះជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ...ចំពោះអ្នកដែលមានជំនឿ អ្វីៗក៏អាចកើតឡើងដែរ...ខ្ញុំមកដើម្បីឲ្យអស់អ្នកដែលមើលមិនឃើញបានមើលឃើញវិញ...

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- **សូមឆ្លើយនឹងសំណួររបស់ព្រះយេស៊ូ៖** ចំពោះអ្នករាល់គ្នា តើខ្ញុំជាអ្នកណា?... (មថ ១៦,១៥)

២- សរសេរធម៌ជឿរបស់ខ្លួនឯង...ជាសេចក្តីសង្ខេបនៃជំនឿដែលសព្វថ្ងៃនេះយើងអាចនិយាយបានថា «តាមពិតទៅ»។

៣- បន្ទាប់មក សូមសួរខ្លួនឯងថា រវាងសេចក្តីសង្ខេបនេះ និងអ្វីៗដែលព្រះគម្ពីរសម្តែងឲ្យស្គាល់អំពីព្រះភ័ក្ត្រព្រះជាម្ចាស់...ហើយរវាងសេចក្តីសង្ខេបនេះ នឹងជំនឿរបស់ព្រះសហគមន៍ ដែលជាប្រជាជនរបស់ព្រះជាម្ចាស់...តើស្របគ្នាឬទេ?

៤- សួរខ្លួនឯងថា តើជំនឿ និងរបៀបរស់នៅរបស់យើងស្របគ្នាឬទេ?

## យកសេចក្តីសង្ខេបនៃគ្រីស្តសាសនានេះ ធ្វើជាសេចក្តីអធិដ្ឋាន៖

ខ្ញុំមិនដឹងថា គ្រីស្តសាសនាជាសេចក្តីពិតទេ ហើយខ្ញុំក៏មិនដឹងថា «អារ្យធម៌នៃគ្រីស្តសាសនា» មិនដូចអារ្យធម៌ទាំងប៉ុន្មាន ដែលបាត់បង់ទៅហើយដែរ។ ខ្ញុំគ្រាន់តែដឹងថា តាំងពីពេលដែលខ្ញុំបានជឿ ជីវិតខ្ញុំបានផ្លាស់ប្តូរទាំងស្រុង បានបំភ្លឺរូងជ្រៅដ៏សែនងងឹតនៃចិត្តខ្ញុំ បានធ្វើឲ្យសេចក្តីស្រឡាញ់របស់ខ្ញុំកាន់តែរីកធំធាត់ ហើយបានផ្តល់អត្ថន័យមួយឲ្យខ្ញុំយល់អំពីអ្វីៗ ដែលហាក់ដូចជាមិនអាចយល់បាន។ ជំនឿនេះបាននាំខ្ញុំឲ្យទៅជាកូនក្មេងវិញ ហើយធ្វើឲ្យខ្ញុំត្រេកអរសប្បាយជានិច្ច ទោះជានៅពេលរងទុក្ខលំបាកក៏ដោយ។

# ទៅជាគ្រីស្តទូត

ព្រះជាម្ចាស់បានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក
ដើម្បីបង្កើតព្រះយេស៊ូ និងឲ្យព្រះអង្គមានព្រះជន្មក្នុងចិត្តយើង!

## ដំណាក់កាលទី ១៤

ចូរបងប្អូនបណ្តោយឲ្យព្រះវិញ្ញាណណែនាំបងប្អូន (កាឡ ៥,១៦)

**ក្នុងដំណាក់កាលនេះមាន ៖** ព្រះយេស៊ូមានព្រះបន្ទូលថា ៖ ខ្ញុំនឹងចាត់អ្នកណាម្នាក់មក ដើម្បីឲ្យអ្នករាល់គ្នាយល់គ្រប់ប្រការ...ព្រះវិញ្ញាណនៃសេចក្តីពិតធ្វើឲ្យគ្រីស្តទូតទាំងដប់ពីររូបទៅជាសាក្សីរហូតដល់ចុងផែនដី។

សព្វថ្ងៃនេះ ព្រះវិញ្ញាណបង្កើតយើងសាជាថ្មី។ ព្រះអង្គធ្វើឲ្យយើងមានលក្ខណៈដូចព្រះយេស៊ូ។ ព្រះអង្គជួយទូលអង្វរសម្រាប់យើង។ ព្រះអង្គយាងមកជួយជ្រោងភាពទន់ខ្សោយរបស់យើង។ ព្រះអង្គរំដោះយើងឲ្យមានសេរីភាព។ ព្រះអង្គបន្តកិច្ចការដែលយើងចាប់ផ្តើមឲ្យបានល្អគ្រប់លក្ខណៈ។ ព្រះវិញ្ញាណនេះ ស្ថិតនៅក្នុងយើងដូចជាកម្លាំងមួយដែលជំរុញយើងឲ្យដើរទៅមុខៗ។ ប៉ុន្តែត្រូវស្តាប់ព្រះវិញ្ញាណដែល «អង្វរ» ក្នុងចិត្តយើង...ត្រូវស្តាប់ព្រះវិញ្ញាណនេះ រួមសហការជាមួយព្រះអង្គ ដើម្បីបង្ហើយគ្រប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់។

**គោលដៅនៃដំណាក់កាលនេះ ៖** ត្រូវរស់នៅ និងប្រតិបត្តិតាមព្រះវិញ្ញាណរបស់ព្រះយេស៊ូ។

រកក្នុងដំណឹងល្អតាមសន្តៈយ៉ូហាន នូវព្រះបន្ទូលព្រះយេស៊ូអំពីព្រះវិញ្ញាណ។ ដើម្បីឲ្យព្រះវិញ្ញាណណែនាំជីវិតខ្ញុំ ខ្ញុំត្រូវរៀនឲ្យចេះពិចារណា។ ខ្ញុំរៀនឲ្យស្គាល់អំពីការត្រាស់ហៅនៃព្រះវិញ្ញាណ ក្នុងការរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំខិតខំរីកចម្រើនឲ្យមានសេរីភាព តាមដែលព្រះវិញ្ញាណផ្តល់ឲ្យ ដោយជ្រើសយកតាមដំណឹងល្អ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចទទួលបានលក្ខខណ្ឌខ្លះៗ ដើម្បីរស់នៅតាមព្រះវិញ្ញាណរបស់ព្រះយេស៊ូ។

### ទុកពេលសម្រាប់បើកចិត្ត និងទទួល

១- រកនឹកនូវរយៈពេលដែលកន្លងទៅថ្មីៗនេះថា ក្នុងការសម្រេចចិត្ត ឬក្នុងការប្រព្រឹត្តិកិច្ចការ យើងមានអារម្មណ៍ដូចជាមានការជំរុញពីខាងក្នុង។ សូមបញ្ជាក់ឲ្យច្បាស់អំពីឥទ្ធិពលនេះ។

២- ព្យាយាមយល់ឃើញថា តើ «ឥទ្ធិពល» ទាំងនេះ បានជំរុញយើងឲ្យបានសម្រេចចិត្ត ឬប្រព្រឹត្តកិច្ចការយ៉ាងដូចម្ដេច? តើឥទ្ធិពលនេះ មានលក្ខណៈវិជ្ជមាននៅពេលណា? តើឥទ្ធិពលនេះមានលក្ខណៈអវិជ្ជមាននៅពេលណា? តើឥទ្ធិពលនេះ បានគោរពសេរីភាពក្នុងចិត្តយើងឬទេ? រកឧទាហរណ៍ខ្លះៗមកបញ្ជាក់...

៣- តើយើងដាក់ឈ្មោះឲ្យ «ដង្ហើមខ្យល់» ដែលយើងដឹងក្នុងខ្លួនយើងថាដូចម្ដេច?

ខ្ញុំនៅស្ងប់ស្ងាត់...ដែលកប់ជ្រៅ ហើយខ្ញុំទទួលយកជីវិតស៊ីជម្រៅមកទុកក្នុងចិត្តខ្ញុំ។ ខ្ញុំពិចារណាឡើងវិញ អំពីសប្ដាហ៍កន្លងទៅ អំពីការត្រាស់ហៅរបស់ព្រះអង្គ...ចម្លើយរបស់ខ្ញុំ...ខ្ញុំពិនិត្យឡើងវិញនូវអ្វីៗដែលបានបំភ្លឺអាកប្បកិរិយាខ្ញុំរយៈពេលមួយសប្ដាហ៍កន្លងមកនោះ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- **អត្ថបទព្រះគម្ពីរ៖** ក្នុងដំណឹងល្អតាមសន្តៈលូកា រកនូវអ្វីដែលបំភ្លឺ និងដឹកនាំព្រះយេស៊ូ ឲ្យសម្រេចព្រះហឫទ័យ។ តើព្រះអង្គជួបប្រទះនឹងឧបសគ្គណាខ្លះ?

២- ក្នុងដំណឹងល្អតាមសន្តៈយ៉ូហាន សូមដកស្រង់យកព្រះបន្ទូលរបស់ព្រះយេស៊ូអំពីព្រះវិញ្ញាណដ៏វិសុទ្ធ។

៣- **អត្ថបទរបស់សន្តៈយ៉ូហាន អើដ៖**

គ្រីស្តបរិស័ទត្រូវបណ្ដោយខ្លួនឲ្យព្រះវិញ្ញាណព្រះគ្រីស្តណែនាំ ហើយប្រតិបត្តិអ្វីៗទាំងអស់ក្នុងព្រះនាម និងនៅក្នុងអង្គព្រះវិញ្ញាណព្រះអង្គ។ នៅពេលដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានដណ្ដប់ព្រះគ្រីស្តរួចស្រេចទៅហើយ។ យើងអាចនិយាយដូចសន្តៈប៉ូលថា៖ មិនមែនរូបខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្តដែលមានព្រះជន្មគង់នៅក្នុងចិត្តខ្ញុំ (កាឡ ២,២០) កិច្ចការអ្វីដែលបានចាប់ផ្ដើមហើយ យើងក៏មានភារកិច្ចធ្វើឲ្យកិច្ចការនោះបានផលផ្លែ។ ពីមួយថ្ងៃទៅមួយថ្ងៃ ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យទុកខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ទៅជាខ្យល់ដង្ហើមរបស់ខ្លួនខ្ញុំផ្ទាល់...ខ្យល់ដង្ហើម គឺជាជីវិត! ហេតុនេះហើយ ខ្ញុំក្លាយទៅជានំប៉័ងដ៏ឈ្ងុយឆ្ងាញ់សម្រាប់អ្នកឯទៀតដូចព្រះយេស៊ូដែរ។

ចូរអ្នករាល់គ្នានឹកគិតថា ព្រះជាម្ចាស់ បានប្រោសប្រទានឲ្យអ្នករាល់គ្នានូវសេចក្ដីស្រឡាញ់ដ៏ធំមហិមា ដើម្បីឲ្យអ្នករាល់គ្នាទៅជាបុត្រីធីតារបស់ព្រះអង្គ និងទៅជាបងប្អូនរបស់ខ្ញុំ។ លើសពីនេះទៅទៀត គឺដើម្បីឲ្យអ្នកទៅជាអវយវៈរបស់ខ្ញុំ។ ដូចព្រះបិតាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំស្ថិតនៅជាប់នឹងព្រះបិតា អ្នករាល់គ្នាក៏ស្ថិតនៅជាប់នឹងយើងដែរ។

ខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នា ហើយព្រះបិតាស្ថិតនៅជាប់នឹងខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នារួបរួមគ្នាជាធ្លុងតែមួយឥតខ្ចោះ។ ដោយសារអ្នករាល់គ្នាជាបុត្រាធីតារបស់ព្រះជាម្ចាស់ និងជាអវយវៈរបស់ខ្ញុំ ព្រះបិតាបានចាត់ព្រះវិញ្ញាណរបស់ព្រះអង្គ ដែលជាព្រះវិញ្ញាណរបស់ខ្ញុំដែរនោះ ឲ្យយាងសណ្ឋិតនៅក្នុងចិត្តអ្នករាល់គ្នា ដើម្បីឲ្យព្រះវិញ្ញាណណែនាំអ្នករាល់គ្នា ដែលជាបុត្រធីតារបស់ព្រះជាម្ចាស់។

បើអ្នកណាម្នាក់គ្មានព្រះវិញ្ញាណរបស់ខ្ញុំ អ្នកនោះមិនមែនជាអវយវៈរបស់ខ្ញុំទេ។ វិញ្ញាណដែលអ្នករាល់គ្នាបានទទួលនោះ មិនមែនជាវិញ្ញាណនៃពិភពលោកនេះទេ គឺជាព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់។ ចូរអ្នករាល់គ្នាស្ថិតនៅក្នុងព្រះវិញ្ញាណរបស់ខ្ញុំ ហើយព្រះវិញ្ញាណនឹងស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ។ បើអ្នករាល់គ្នារស់នៅក្នុងព្រះវិញ្ញាណរបស់ខ្ញុំ ដើរតាមព្រះវិញ្ញាណរបស់ខ្ញុំ នោះអ្នករាល់គ្នានឹងមិនបំពេញសេចក្ដីលោភលន់

នៃកិលេសតណ្ហាទៀត។ ផលផ្លែនៃព្រះវិញ្ញាណរបស់ខ្ញុំ គឺសប្បុរសធម៌ អំណរសប្បាយ សេចក្ដីសុខសាន្ត អំណត់ ចិត្តទូលាយរាក់ទាក់ ចិត្តល្អ ចូលចិត្តធ្វើអំពើល្អ ចេះទ្រាំទ្រទុក្ខលំបាក ចិត្តស្លូតបូត ភក្ដីភាព ចេះបន្ទាបខ្លួន សុភាពរាបសារ ចេះទប់ចិត្តខ្លួនឯង ព្រហ្មចារិយធម៌ ចិត្តស្អាតគ្មានមន្ទិល។ អ្វីៗដែលអ្នករាល់គ្នាធ្វើ ទោះជាពាក្យសម្ដី ឬកិច្ចការផងទាំងពួង ចូរធ្វើអ្វីៗទាំងអស់នោះ ក្នុងព្រះនាមរបស់ខ្ញុំ ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់។

**៤-ព្រះវិញ្ញាណដ៏វិសុទ្ធ និងគ្រីស្ដបរិស័ទ** ៖ នៅពេលដែលទេវទូតជូនដំណឹងអំពីកំណើតព្រះយេស៊ូ ព្រះវិញ្ញាណគង់ជាមួយព្រះនាងម៉ារី។ ព្រះអង្គបង្កកំណើតព្រះយេស៊ូក្នុងផ្ទៃព្រះនាង។ ពេលទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះវិញ្ញាណយាងមកគង់ជាមួយយើង ដើម្បីបង្កើតព្រះយេស៊ូក្នុងចិត្តយើង និងដើម្បីធ្វើឲ្យយើងទៅជាអវយវៈរបស់ព្រះកាយព្រះអង្គ ដែលជាព្រះសហគមន៍។ ចាប់ពីថ្ងៃនោះមក ព្រះអង្គគង់នៅជាមួយខ្ញុំរាល់ថ្ងៃ។ ព្រះអង្គត្រាស់ហៅខ្ញុំឲ្យលះបង់អំពើបាប ដើម្បីរស់នៅក្នុងឋានៈជាបុត្ររបស់ព្រះបិតា ហើយទៅជាព្រះគ្រីស្ដ។ គ្រប់ពេលទាំងអស់ ខ្ញុំជាកូនរបស់ព្រះបិតានៅក្នុងព្រះគ្រីស្ដ។ ខ្ញុំបានទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ ជាព្រះវិញ្ញាណរបស់ព្រះអង្គ ហើយខ្ញុំទទួលកម្លាំង ដើម្បីស៊ូទ្រាំទុក្ខលំបាករួមជាមួយព្រះយេស៊ូ។ ព្រះអង្គណែនាំខ្ញុំឲ្យចេះធ្វើការសម្រេចចិត្ត ជាពិសេសក្នុងទំនាក់ទំនងជាមួយអ្នកដទៃ។ ជំរើសទាំងនោះបណ្ដាលឲ្យមានពាក្យថា «ទេ» ទៅជា «មែន» វិញ។ ជំរើសនោះក៏នាំឲ្យមានចិត្តរឹងប៉ឹង ចំពោះពាក្យសន្យារបស់ខ្ញុំដែរ។ ភក្ដីភាពចំពោះពាក្យសន្យានៅក្នុងពិធីជ្រមុជទឹកនោះ ខ្ញុំទុកឱកាសដើម្បីទទួលព្រះវិញ្ញាណ ដែលបង្កើតព្រះភ័ក្ត្ររបស់ព្រះយេស៊ូនៅក្នុងចិត្តខ្ញុំ។ ព្រះអង្គជំរុញខ្ញុំឲ្យទៅទាក់ទងជាមួយនឹងអ្នកដទៃ តាមរយៈកិច្ចការផងទាំងពួងរបស់ខ្ញុំ។ ដោយរួមជាមួយបងប្អូនប្រុសស្រី ខ្ញុំជាព្រះបេះដូង ជាព្រះហស្ដ ជាព្រះភ័ក្ត្ររបស់ព្រះយេស៊ូ។

ព្រះជាម្ចាស់បានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបង្កើតព្រះយេស៊ូ
និងឲ្យព្រះអង្គមានព្រះជន្មគង់នៅក្នុងចិត្តយើង...
ដើម្បីបញ្ចូនយើងឲ្យរួបរួមជាមួយព្រះអង្គ...ដើម្បីឲ្យយើងកើត និងរស់នៅក្នុងអង្គព្រះអង្គ

ព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះដែលធ្វើឲ្យយើងទៅជាគ្រីស្ដបរិស័ទ ដ្បិតព្រះអង្គបានបង្កើតក្នុងផ្ទៃព្រហ្មចារិយ៍ដ៏វិសុទ្ធ អ្នកដែលរំដោះយើងឲ្យរួចអំពីបាប អ្នកដែលលុបលាងកំហុសយើង អ្នកដែលជាមេដឹកនាំយើង។ ព្រះវិញ្ញាណបានណែនាំព្រះអង្គក្នុងគ្រប់គំនិត កិច្ចការព្រះបន្ទូល ទុក្ខលំបាករបស់ព្រះអង្គ ជាពិសេសក្នុងការបូជាព្រះជន្មនៅលើឈើឆ្កាង ដើម្បីឲ្យយើងទៅជាគ្រីស្ដបរិស័ទ៖ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គបានបូជាព្រះជន្ម (ហប ៩,១៤)។ ក្រោយពីព្រះអម្ចាស់នៃយើងបានយាងទៅកាន់ស្ថានបរមសុខ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកក្នុងលោកនេះ ដើម្បីបង្កើត និងរៀបចំព្រះកាយរបស់ព្រះយេស៊ូគ្រីស្ដ ដែលជាព្រះសហគមន៍របស់ព្រះអង្គ និងដើម្បីប្រោសប្រទានផលផ្លែនៃព្រះជន្ម ព្រះលោហិត ទុក្ខលំបាក និងការសោយទិវង្គតរបស់ព្រះអង្គ។ បើគ្មានព្រះវិញ្ញាណនោះទេ ព្រះអម្ចាស់នៃយើងបានរងទុក្ខលំបាក និងសោយទិវង្គតដោយឥតប្រយោជន៍។ ម្យ៉ាងទៀតព្រះវិញ្ញាណដ៏វិសុទ្ធយាងមកក្នុងពិធីអគ្គសញ្ញាជ្រមុជទឹករបស់យើង ដើម្បីបង្កើតព្រះយេស៊ូគ្រីស្ដក្នុងចិត្តយើង ហើយឲ្យយើងផ្សារភ្ជាប់ខ្លួនក្នុងអង្គព្រះគ្រីស្ដ...ឲ្យយើងមានជីវិត ឲ្យយើងរស់នៅក្នុងអង្គព្រះអង្គ...ឲ្យយើងទទួលផលនៃព្រះលោហិត និងការសោយទិវង្គតរបស់ព្រះអង្គ...ព្រះវិញ្ញាណណែនាំយើងឲ្យប្រព្រឹត្តកិច្ចការ ឲ្យមានគំនិត ឲ្យយើងកើតទុក្ខស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ ប្រសិនបើគ្មាន

ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំទេ យើងមិនអាចហៅព្រះនាមដ៏វិសុទ្ធនៃព្រះយេស៊ូឲ្យបានត្រឹមត្រូវ ហើយយើងមិនអាចមានគំនិតល្អៗឡើយ (១ករ ១២,៣)។

ដូច្នោះហើយ គ្រីស្តបរិស័ទម្នាក់ ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ សន្តៈប៉ូលមានប្រសាសន៍ថា៖បងប្អូនមិនដឹងទេឬ រូបកាយបងប្អូនជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ? (១ករ ៦,១៩) ដ្បិតយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងជារូបកាយតែមួយជាមួយមេដឹកនាំ ដូច្នោះហើយបានជាយើងចាំបាច់ត្រូវណែនាំ ដោយព្រះវិញ្ញាណតែមួយ។ ដូច្នេះសន្តៈប៉ូលមានប្រសាសន៍ថា៖ ដោយសារបងប្អូនជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រះអង្គបានចាត់ព្រះវិញ្ញាណរបស់ព្រះបុត្រាព្រះអង្គឲ្យយាងមកក្នុងចិត្តបងប្អូន (កាឡ ៤,៦) ហើយអ្នកណាដែលគ្មានព្រះវិញ្ញាណនៃព្រះយេស៊ូទេ អ្នកនោះមិនមែនជាកម្មសិទ្ធិរបស់ព្រះយេស៊ូគ្រីស្តឡើយ (រម ៨,៩)។ ដូច្នោះហើយ ព្រះជាម្ចាស់បានប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង ដើម្បីឲ្យព្រះវិញ្ញាណទៅជាវិញ្ញាណរបស់យើង ទៅជាចិត្តនៃចិត្តរបស់យើង ទៅជាព្រលឹងនៃព្រលឹងរបស់យើង...ហើយដើម្បីឲ្យព្រះអង្គគង់ស្ថិតនៅជាមួយយើង គ្រប់ពេលវេលា មិនគ្រាន់តែជាព្រះដំណាក់ប៉ុណ្ណោះទេ ប៉ុន្តែដូចជាចំណែកមួយនៃព្រះកាយព្រះអង្គបានសេចក្តីថា ក្នុងចំណែកមួយនៃព្រះកាយព្រះយេស៊ូគ្រីស្ត ដែលជាកម្មសិទ្ធរបស់ព្រះអង្គ។ ហើយដែលព្រះវិញ្ញាណណែនាំ ពីព្រោះអវយវៈ និងរាងកាយគ្រប់ផ្នែកទាំងអស់ ត្រូវតែមានវិញ្ញាណតែមួយ ដែលណែនាំ ជាវិញ្ញាណរបស់មេដឹកនាំផងដែរ។

ឱ! ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធបានបំពេញកិច្ចការធំៗអស្ចារ្យខ្លាំងណាស់ ដើម្បីឲ្យយើងទៅរកគ្រីស្តបរិស័ទ! ឱ! ត្រូវតែនិយាយថា គ្រីស្តបរិស័ទអស្ចារ្យបំផុត ឱ! សូមសន្តៈយ៉ូហានបានសុភមង្គល ដ្បិតលោកយល់ត្រូវ ដោយនិយាយប្រាប់ក្នុងនាមនៃគ្រីស្តបរិស័ទទាំងអស់ថា៖ លោកីយ៍នេះមិនស្គាល់យើងទេ (យហ ៣,១)។ ឱ! យើងមានភារកិច្ចត្រូវប្រទានពរ និងស្រឡាញ់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានត្រាស់ហៅយើងនិងលើកយើងឡើងឲ្យមានឋានៈជាគ្រីស្តបរិស័ទ! ឱ! ជីវិតយើងទៅជាជីវិតដ៏វិសុទ្ធដ៏ល្អឥតខ្ចោះ ដ្បិតព្រះអម្ចាស់នៃយើងមានព្រះបន្ទូលថា៖ អ្នកណាកើតមកពីព្រះវិញ្ញាណ អ្នកនោះជាវិញ្ញាណ (យហ ៣,៦)។

ខ្ញុំសញ្ជឹងគិតទៅដល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ គឺព្រះវិញ្ញាណរបស់ព្រះយេស៊ូ។
ខ្ញុំអរព្រះគុណព្រះយេស៊ូ ដែលសម្តែងឲ្យខ្ញុំស្គាល់ជីវិតនេះ ដែលណែនាំខ្ញុំ
និងជំរុញខ្ញុំឲ្យរស់យ៉ាងសកម្ម។
ខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានប្រយុទ្ធប្រឆាំងនឹងភាពងងឹត ដើម្បីឲ្យខ្ញុំភ្លឺ។
ខ្ញុំសូមទូលអង្វរសូមព្រះអង្គ ធ្វើឲ្យចិត្តខ្ញុំរង់ចាំទទួលព្រះវិញ្ញាណដូចព្រះអង្គដែរ។

ឱ! ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់អើយ! ខ្ញុំម្ចាស់សូមថ្វាយខ្លួនចំពោះព្រះអង្គ។ សូមព្រះអង្គទទួលយកខ្ញុំម្ចាស់ ហើយណែនាំខ្ញុំក្នុងគ្រប់កិច្ចការផងទាំងពួង។ សូមឲ្យខ្ញុំម្ចាស់រស់នៅដូចបុត្រម្នាក់របស់ព្រះជាម្ចាស់ ដូចជាអវយវៈរបស់ព្រះយេស៊ូគ្រីស្ត និងដូចជាអ្វីមួយដែលកើតចេញមកពីព្រះអង្គជាកម្មសិទ្ធិរបស់ព្រះអង្គ។

ដូច្នោះហើយអ្នកណាអាចនិយាយ ហើយគិតថាអ្វីទៅដែលជា...ឋានៈរបស់គ្រីស្តបរិស័ទ ឋានៈរបស់បុត្រធីតាព្រះជាម្ចាស់...ឋានៈរបស់អវយវៈព្រះយេស៊ូគ្រីស្ត ដែលមានព្រះវិញ្ញាណរបស់ព្រះអង្គណែនាំ? តើយើង

ត្រូវធ្វើអ្វី ដើម្បីតបស្នងព្រះគុណព្រះជាម្ចាស់? តើជីវិតយើងត្រូវទៅជាវិសុទ្ធយ៉ាងណា? តើអ្នកប្រព្រឹត្តអំពើបាបជាអ្នកធ្វើបាបព្រះអង្គយ៉ាងណា? ដ្បិតអ្នកនោះ បណ្តេញព្រះវិញ្ញាណចេញពីព្រះដំណាក់របស់ព្រះអង្គ ដើម្បីឲ្យវិញ្ញាណអាក្រក់ស្នាក់នៅ អ្នកនោះឆ្កាង ហើយសម្លាប់ព្រះយេស៊ូគ្រីស្តនៅក្នុងចិត្តគេ បន្តប់ដង្ហើមព្រះវិញ្ញាណព្រះអង្គ ដើម្បីឲ្យសត្រូវរបស់ព្រះអង្គ គឺមារសាតាំងស្នាក់នៅ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- សូមរកឲ្យឃើញ និងស្គាល់សកម្មភាពនៃព្រះវិញ្ញាណក្នុងខ្លួនមនុស្ស ក្នុងហេតុការណ៍ផ្សេងៗ ឬក្នុងខ្លួនយើង...តើមានអ្វីប្រឆាំងនឹងព្រះវិញ្ញាណនោះ?

២-ពេលយើងត្រូវធ្វើការជ្រើសរើស យើងប៉ះទង្គិចក្នុងចិត្តខ្លួនឯង ដូចព្រះយេស៊ូផងដែរ។ សូមរើសយកហេតុការណ៍ដ៏ជាក់លាក់មួយក្នុងជីវិតរបស់យើង។ ចូរវិភាគហេតុការណ៍នេះ៖ តើយើងបានជ្រើសរើសយ៉ាងដូចម្តេចខ្លះ?

៣- ព្រះវិញ្ញាណដែលព្រះយេស៊ូប្រទានមកយើង គឺដើម្បីជួយយើងក្នុងការយល់អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។ តើយើងទូលអង្វរចំពោះព្រះអង្គឬទេ?

៤- តាមធម្មតានៅក្នុងជីវិតយើង តើយើងធ្លាប់អធិដ្ឋានចំពោះព្រះវិញ្ញាណដែរឬទេ?

ខ្ញុំនៅពីមុខព្រះជាម្ចាស់ ដើម្បីទទួលស្គាល់ថា ខ្ញុំមិនព្រមទទួលព្រះវិញ្ញាណ ដែលទ្រង់យាងមកគង់នៅក្នុងចិត្តខ្ញុំ...ជួនកាលខ្ញុំសម្រេចចិត្តលឿនពេក...មិនស្តាប់ ឬមិនព្រមស្តាប់ព្រះវិញ្ញាណដែលត្រាស់ហៅខ្ញុំឲ្យរីកចម្រើនដើរទៅមុខ...ខ្ញុំមិនព្រមបុះចាញ់ព្រះវិញ្ញាណ។ ខ្ញុំសូមព្រះអង្គលើកលែងទោសឲ្យខ្ញុំ ព្រោះខ្ញុំមិនប្រើព្រះអំណោយទាននេះតាមរបៀបត្រឹមត្រូវ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១-ក្នុងអត្ថបទទាំងប៉ុន្មានដែលយើងទើបអានរួចហើយ យើងបានយល់ឃើញថា ព្រះវិញ្ញាណណែនាំព្រះយេស៊ូ។

២- តើយើងសម្គាល់ឃើញលក្ខណៈណាខ្លះ ដើម្បីជួយយើងក្នុងជីវិតរបស់យើង?

លក្ខណៈដែលយើងសម្គាល់ឃើញនោះ ជួយយើងឲ្យរស់នៅក្នុងជីវិតថ្មី ក្រោយពីបានទទួលអគ្គសញ្ញាជ្រមុជទឹក។ សូមផ្ទៀងផ្ទាត់លក្ខណៈទាំងអស់នោះ ជាមួយនឹងផលផ្លែនៃព្រះវិញ្ញាណ ដែលសន្តៈប៉ូលបានលើកមកនិយាយ ក្នុងលិខិតរបស់លោកផ្ញើរទៅកាន់គ្រីស្តបរិស័ទនៅកាឡាទី (៥,២២-២៥)និងលិខិតទីមួយផ្ញើរទៅគ្រីស្តបរិស័ទនៅកូរិនថូ (១៣)។ តើយកមកអនុវត្តយ៉ាងដូចម្តេច ក្នុងជីវិតរបស់យើង? សូមរើសយកចំណុចជាក់លាក់ និងផ្ទៀងផ្ទាត់ឡើងវិញ។

៣- ប្រឈមនឹងការសម្រេចចិត្តមួយ ដែលត្រូវប្រកាន់យកយ៉ាងរហ័ស សូមព្យាយាមសម្គាល់យោបល់ដែលយើងយល់ថា មិនត្រឹមត្រូវ ដោយអនុវត្តតាមលក្ខណៈដែលយើងកំណត់។

៤- សូមចងក្រងសេចក្តីអធិដ្ឋាន ទៅតាមបែបបទរបស់សន្តៈយ៉ូហាន អើដ៖ ក្រាបថ្វាយបង្គំ អរព្រះគុណ សូមលើកលែងទោស ប្រគល់ខ្លួនថ្វាយ... ដើម្បីថ្វាយការសម្រេចចិត្តនេះទុកជាតង្វាយចំពោះព្រះអម្ចាស់។

ខ្ញុំម្ចាស់បន្ទាបខ្លួនចំពោះព្រះភ័ក្ត្រព្រះអង្គ សូមព្រះអង្គទតឃើញថា ខ្ញុំម្ចាស់មានបំណងចង់ធ្វើការសម្រេចចិត្តត្រឹមត្រូវ...ដោយតែតាមព្រះហឫទ័យព្រះអង្គ។ ព្រះអង្គគង់នៅក្នុងជីវិតខ្ញុំម្ចាស់ ពេលខ្ញុំម្ចាស់ស្វែងរក... ស្ទាក់ស្ទើរ... រារែក... សង្ស័យ... ភិតភ័យ... សូមអរព្រះគុណព្រះអម្ចាស់ចំពោះព្រះវត្តមាននេះ។ ព្រះអម្ចាស់អើយ! ឥឡូវនេះ ខ្ញុំមានការលំបាកនឹងទទួលយកលក្ខណៈរបស់ខ្ញុំម្ចាស់...ខ្ញុំម្ចាស់គួរតែចង់បានអ្វីតាមព្រះហឫទ័យព្រះអង្គ ប៉ុន្តែខ្ញុំម្ចាស់ស្វែងរកផលប្រយោជន៍ និងទីពេញចិត្តរបស់ខ្ញុំម្ចាស់។ ចំណែកឯព្រះអង្គវិញ ព្រះអម្ចាស់អើយ! ព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់តាមលក្ខណៈដែលខ្ញុំម្ចាស់មាន។ សូមសន្តោសប្រណីឲ្យខ្ញុំម្ចាស់បើកចិត្តទទួលខ្លួនឯង លើកលែងទោសឲ្យខ្លួនឯង នៅពេលដែលខ្ញុំម្ចាស់ស្លឹកស្រពន់ផង...សូមឲ្យខ្ញុំម្ចាស់ស្គាល់ព្រះអង្គនៅពេលដែលខ្ញុំសម្រេចចិត្តធ្វើអ្វី។ សូមព្រះអង្គលើកលែងទោសឲ្យខ្ញុំផង។ ព្រះជាម្ចាស់អើយ! ខ្ញុំម្ចាស់បន្ទាបខ្លួនចំពោះព្រះភ័ក្ត្រព្រះអង្គ...ខ្ញុំម្ចាស់សូមថ្វាយខ្លួនចំពោះព្រះអង្គ ដោយមានបំណងឲ្យព្រះវិញ្ញាណណែនាំខ្ញុំម្ចាស់ ពេលខ្ញុំម្ចាស់ត្រូវសម្រេចចិត្តអ្វីមួយ។ សូមឲ្យខ្ញុំម្ចាស់សម្រេចចិត្តរួមជាមួយព្រះអង្គ ក្នុងអង្គព្រះអង្គ និងដោយសារព្រះអង្គ។

# រកមុខងាររបស់ខ្លួននៅក្នុងព្រះសហគមន៍

អ្វីទៅជាព្រះសហគមន៍? គឺជាក្រុមគ្រួសារគ្រីស្តបរិស័ទ ដែលមានជំនឿតែមួយ ហើយចូលរួមក្នុងអគ្គសញ្ញា ក្រោមការណែនាំរបស់ព្រះយេស៊ូគ្រីស្ត !

## ដំណាក់កាលទី ១៩

ដោយបងប្អូនរួមជាមួយព្រះអង្គ បងប្អូនបានផ្គុំគ្នាឡើង
ធ្វើជាព្រះដំណាក់របស់ព្រះជាម្ចាស់ ក្នុងព្រះវិញ្ញាណ (អភ ២,២២)

**ក្នុងដំណាក់កាលនេះមាន** ៖ សូមឲ្យមនុស្សគ្រប់សាសន៍ទៅជាសាវ័ក (មថ ២៨,១៩) ពេលយើងបណ្ដោយឲ្យព្រះវិញ្ញាណ ដែលគង់ក្នុងចិត្តយើងណែនាំឲ្យការបង្កើតបានសម្រេច យើងធ្វើការដោយមានប្រសិទ្ធភាព ដើម្បីកសាងព្រះរាជ្យព្រះជាម្ចាស់ដែលមានរួចមក និងមិនទាន់មានផង។

**ព្រះរាជ្យព្រះអង្គយាងមកហើយ** ៖ ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ដែលយើងមើលឃើញជាសញ្ញាសម្គាល់នៃព្រះរាជ្យនេះ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលរួបរួមជាមួយគ្នា ដោយមានចិត្តស្រឡាញ់។ ព្រះគ្រីស្តបានបូជាព្រះជន្មដើម្បីឲ្យមនុស្សលោកទៅជាធ្លុងតែមួយ។

- **ព្រះរាជ្យព្រះអង្គមិនទាន់បានមកដល់ទេ** ៖ រហូតដល់ពេលព្រះគ្រីស្តនឹងយាងត្រឡប់មកវិញ នៅអវសានកាលនៃពិភពលោក ព្រះជាម្ចាស់ត្រាស់ហៅព្រះសហគមន៍ឲ្យប្រកាសដំណឹងល្អ នៃការសង្គ្រោះ ដើម្បីឲ្យមនុស្សទាំងអស់រួបរួមគ្នាដោយមានចិត្តស្រឡាញ់។

សូមឲ្យគ្រីស្តបរិស័ទម្នាក់ៗបង្ហាញកាយវិការ និងប្រកាសព្រះបន្ទូលតាមព្រះគ្រីស្តនោះ ព្រះរាជ្យព្រះជាម្ចាស់កាន់តែមានវត្តមានជាក់ជាពុំខាន...សូមឲ្យមនុស្សទាំងឡាយបង្ហាញកាយវិការ ហើយប្រកាសព្រះបន្ទូលតាមព្រះគ្រីស្តនោះ ព្រះរាជ្យព្រះអង្គនឹងកសាងរួចរាល់ហើយ។

ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឲ្យប្រកាសដំណឹងល្អ...ឲ្យរស់នៅតាមដំណឹងល្អ ...ព្រះសហគមន៍ គឺ«យើង»...ព្រះយេស៊ូមានរូបរាងនៅក្នុងព្រះសហគមន៍ព្រះអង្គ បន្តបេសកកម្មព្រះអង្គនៅក្នុងយើង យើងក៏ជួយជ្រោមជ្រែងដើម្បីឲ្យព្រះរាជ្យព្រះអង្គបានគ្រប់លក្ខណៈ និងពេញបរិបូរណ៍ (អភ ១,២២ ២៣)។

**គោលដៅនៃដំណាក់កាលនេះ ៖** ឲ្យខ្ញុំបានដឹងខ្លួនថា ខ្ញុំនៅក្នុង និងជាមួយប្រជាជនរបស់ព្រះជាម្ចាស់ ដោយដើរឆ្ពោះទៅរកព្រះរាជ្យ។

- ដឹងខ្លួនច្បាស់ថា ខ្ញុំនៅក្នុងព្រះសហគមន៍ ដែលមានមុខងារប្រកាសដំណឹងល្អ។
- ពិចារណាថា ខ្ញុំជាកម្មសិទ្ធិរបស់សហគមន៍គ្រីស្តបរិស័ទ។
- ត្រូវដឹងច្បាស់ថា កិច្ចការតិចតួច ដែលខ្ញុំប្រព្រឹត្តទៅតាមព្រះហឫទ័យរបស់ព្រះវិញ្ញាណ នៃព្រះយេស៊ូធ្វើឲ្យព្រះរាជ្យព្រះជាម្ចាស់មានការរីកចម្រើន។
- ឲ្យខ្ញុំសន្សាជួយបម្រើព្រះសហគមន៍ តាមសមត្ថភាពរបស់ខ្ញុំហើយឲ្យខ្ញុំប្រកាសដំណឹងល្អ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចដឹងថាព្រះសហគមន៍ គឺពួកគេ គឺខ្ញុំ គឺពួកយើង។

## ទុកពេលសម្រាប់បើកចិត្ត និងទទួល

១- កាលណាយើងឮពាក្យ «ព្រះសហគមន៍» តើពាក្យនេះ ធ្វើឲ្យយើងនឹកឃើញអំពីអ្វីសម្រាប់យើង? តើយើងនឹកទៅដល់អ្នកណា? តើពាក្យនេះ ធ្វើឲ្យយើងនឹកឃើញអំពីពេលវេលាណាមួយក្នុងជីវិតយើង? សកម្មភាពណាខ្លះ?

២- កាលណាយើងនិយាយអំពី «ព្រះសហគមន៍» តើយើងនិយាយអំពីព្រះសហគមន៍នោះ យ៉ាងដូចម្តេច? តើយើងដឹងខ្លួនថា យើងជាសមាជិកនៃព្រះសហគមន៍នេះឬទេ? តើយើងដឹងថា យើងរួមសាមគ្គីជាមួយឬទេ? តើយើងមានមុខងារអ្វីខ្លះ ក្នុងព្រះសហគមន៍នេះ? ជាអ្វី? ឬមួយក៏យើងនៅខាងក្រៅធ្វើឲ្យយើងមិនស្រណុកចិត្ត?

៣-តាំងពីថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹកមក យើងជាកម្មសិទ្ធិរបស់ព្រះសហគមន៍នេះ។ សូមសរសេរអំពីអ្វី ដែលយើងបានទទួលពីព្រះសហគមន៍ ពីគ្រីស្តបរិស័ទដែលយើងស្គាល់ច្បាស់។

៤- តើយើងយកចំណែកណាខ្លះ នៃខ្លួនយើងទៅរួបរួមជាមួយព្រះសហគមន៍នេះ? សូមបញ្ជាក់អំពីសកម្មភាពដែលយើងធ្វើនៅបច្ចុប្បន្ននេះ...សកម្មភាពដែលយើងចូលចិត្តធ្វើ។

ឥឡូវនេះ ខ្ញុំទុកពេលសម្រាប់ទទួលអ្វីៗ ដែលខ្ញុំរកឃើញអំពីខ្លួនខ្ញុំ និងអំពីអ្នកដទៃ។
ខ្ញុំទទួលស្គាល់ថា សកម្មភាពទាំងប៉ុន្មានដែលខ្ញុំប្រព្រឹត្ត មកពីព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅ...
ព្រះអង្គមានព្រះបន្ទូលហៅខ្ញុំ ខ្ញុំជាសមាជិកម្នាក់នៃប្រជាជនព្រះជាម្ចាស់... នៃព្រះសហគមន៍...
ខ្ញុំមានមុខងារតែមួយគត់ក្នុងចំណោមប្រជាជននេះ។

## ទុកពេលសម្រាប់សញ្ជឹងគិត និងអរព្រះគុណ

**១- អត្ថបទព្រះគម្ពីរ ៖** ពេលយើងចូលរួមកសាងព្រះសហគមន៍របស់ព្រះយេស៊ូគ្រីស្ត យើងកសាងសំណង់ធំមួយអំពីថ្មដែលមានជីវិត ហើយដែលកាន់ដៃគ្នាពីម្នាក់ទៅម្នាក់ ដោយសារជំនឿ សេចក្តីសង្ឃឹម

និងសេចក្ដីស្រឡាញ់...ព្រះគ្រីស្ដជាសិលាមាំមួននៃសំណង់នោះ...ម្នាក់ៗមានភារកិច្ចខុសៗគ្នាទាំងអស់ យើងបំពេញគ្នាទៅវិញទៅមក...រួមគ្នា យើងជាព្រះកាយ ជាអវយវៈ ជាព្រះហស្ដ ជាព្រះភ័ក្ត្រនៃព្រះយេស៊ូ...

**២- នេះជាអត្ថបទខ្លះៗ សូមអានទៅតាមសម្រួល។ សូមគូសពីក្រោយអ្វីដែលយើងយល់ថាសំខាន់៖** (១ករ ៣,៩; ១ស ២,៥-៧; ១ករ ១២,១២-២៧; អភ ២,១៩-២២; ៤,១១-១៣; មថ ២៥,៣១-៤០)

## អត្ថបទនៃសន្ដៈយ៉ូហាន អើដ

៣- គ្រីស្ដបរិស័ទត្រូវស្ថិតនៅក្នុងព្រះគ្រីស្ដ ហើយបង្កើតផលផ្លែក្នុងអង្គព្រះអង្គ។ នៅក្នុងសេចក្ដីអធិដ្ឋានព្រះសហគមន៍ និយាយអំពីគ្រីស្ដបរិស័ទដោយហៅពួកគេថា ជា «អ្នកមានភក្ដីភាព» គឺអស់អ្នកដែលមានចិត្តភក្ដីចំពោះព្រះគ្រីស្ដ ឬអស់អ្នកដែលព្រះគ្រីស្ដភក្ដីនឹងគេ។

ព្រះជាម្ចាស់ត្រាស់ហៅយើង ជាអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក ឲ្យបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់...ដើម្បីធ្វើឲ្យសេចក្ដីស្រឡាញ់នេះ រីកចម្រើន និងធំធាត់ ហើយធ្វើឲ្យសេចក្ដីស្រឡាញ់នេះ អាចបង្កើតផលផ្លែ។ គឺនៅក្នុងព្រះសហគមន៍នេះ ដែលជាព្រះកាយព្រះគ្រីស្ដ ដែលយើងទទួលព្រះកាយព្រះគ្រីស្ដ ដើម្បីទៅជាព្រះកាយព្រះគ្រីស្ដ។

ដើមឈើណា ដែលផ្លែមិនបានល្អ នឹងត្រូវកាត់ចោល បោះទៅក្នុងភ្លើង។ អ្វីដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតាខ្ញុំ គឺឲ្យអ្នករាល់គ្នាបង្កើតផលផ្លែជាច្រើន ហើយឲ្យអ្នករាល់គ្នាទៅជាសាវ័ករបស់ខ្ញុំ។ ខ្ញុំជាដើមទំពាំងបាយជូរពិតប្រាកដ ហើយព្រះបិតាខ្ញុំជាម្ចាស់ចំការទំពាំងបាយជូរ។ មែកណាដែលមិនបង្កើតផលផ្លែទេ ព្រះបិតាខ្ញុំនឹងកាត់មែកនោះចោល ហើយមែកណាដែលមានផលផ្លែ ព្រះអង្គនឹងលោះមែកនោះ ដើម្បីឲ្យវាបង្កើតផលផ្លែកាន់តែច្រើន។ ចូរអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នករាល់គ្នាដែរ។ ខ្ញុំជាដើមទំពាំងបាយជូរ ហើយអ្នករាល់គ្នាជាមែក៖ មែកណាដែលនៅជាប់នឹងខ្ញុំ ហើយដែលខ្ញុំនៅជាប់នឹងវា មែកនោះបង្កើតផលផ្លែជាច្រើន ដ្បិតបើគ្មានខ្ញុំទេ អ្នករាល់គ្នាមិនអាចធ្វើអ្វីកើតឡើង។ អ្នកណាដែលរក្សាវិន័យរបស់ខ្ញុំ អ្នកនោះជាអ្នកជាប់នឹងខ្ញុំហើយខ្ញុំនៅជាប់នឹងអ្នកនោះដែរ។អ្នកណាដែលបរិភោគសាច់និងផឹកព្រះលោហិតខ្ញុំ អ្នកនោះនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះដែរ។ អ្នកណាដែលនៅជាប់នឹងខ្ញុំ ត្រូវប្រកាន់ឥរិយាបថដូចខ្ញុំដែរ។

**៤- គម្រោងការដ៏អស្ចារ្យនៃព្រះគ្រីស្ដ និងជីវិតរបស់ព្រះសហគមន៍៖** សូមអានអត្ថបទរបស់សន្ដៈយ៉ូហានអើដក្នុងដំណាក់កាលទី ១៦។

**៥- យើងចូលរួមជាមួយព្រះត្រៃឯក៖** ប្រជាជននៃព្រះជាម្ចាស់ ដែលជាព្រះកាយព្រះគ្រីស្ដ ត្រូវបានរៀបចំធ្វើឲ្យមានចលនា។អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកម្នាក់ៗមិនដូចគ្នាទេ នៅក្នុងព្រះសហគមន៍។ម្នាក់ៗមានមុខងារប្លែកពីគ្នា។ សន្ដៈយ៉ូហាន អើដ រំឭកឲ្យបងប្អូនជាបូជាចារ្យរបស់លោកថា ព្រះជាម្ចាស់បានប្រោសប្រណីដល់ពួកគេ ដើម្បីឲ្យពួកគេបម្រើព្រះសហគមន៍ធ្វើឲ្យព្រះសហគមន៍នេះ ចូលរួមជាមួយព្រះជន្មនៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ។

**ខ្ញុំសម្លឹងមើលមកអ្នករាល់គ្នា ដូចជាអ្នករួបរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ**

អស់លោកជាបូជាចារ្យទាំងឡាយអើយ! លោកជាចំណែកមួយដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះកាយដ៏អាថ៌កំបាំង

របស់ព្រះបុត្រាព្រះជាម្ចាស់។ អស់លោកជាព្រះនេត្រា ជាព្រះឱស្ឋ ជាព្រះជីវ្ហា និងជាព្រះបេះដូងនៃព្រះសហគមន៍របស់ព្រះយេស៊ូ ឬនិយាយឲ្យស្រួលស្ដាប់ទៅ អស់លោកជាព្រះឱស្ឋ ជាព្រះជីវ្ហា និងជាព្រះបេះដូង នៃព្រះយេស៊ូដដែលនេះផង។

**អស់លោកជាព្រះនេត្រាព្រះអង្គ** ៖ ដោយសារអស់លោក ទើបអ្នកគង្វាលដ៏ល្អនេះ នៅតែបន្តឃ្វាលហ្វូងចៀមព្រះអង្គឥតឈប់ឈរ ព្រះអង្គបំភ្លឺ ហើយណែនាំហ្វូងចៀម ដោយសារអស់លោក ព្រះអង្គទ្រង់ព្រះកន្សែងចំពោះអស់ចៀមព្រះអង្គ ដែលធ្លាក់ចូលក្នុងក្រញ៉ាំចចក ក៏ដោយសារអស់លោកដែរ។

**អស់លោកជាព្រះឱស្ឋ និងជាព្រះជីវ្ហារបស់ព្រះអង្គ** ៖ ដោយសារពួកលោក ទើបព្រះអង្គមានព្រះបន្ទូលទៅកាន់មនុស្សទាំងឡាយ...ទើបព្រះអង្គនៅតែបន្តប្រកាសព្រះបន្ទូលដដែលនេះ និងដំណឹងល្អដដែលនេះ ដែលព្រះអង្គបានប្រកាសដោយខ្លួនឯង កាលព្រះអង្គគង់នៅលើផែនដី។

**អស់លោកជាព្រះបេះដូងព្រះអង្គ** ៖ ដោយសារអស់លោក ទើបព្រះអង្គប្រគល់ព្រះជន្មពោរពេញទៅដោយធម៌មេត្តាករុណា នៅលើផែនដីនេះ និងព្រះជន្មប្រកបដោយសិរីរុងរឿងនៅស្ថានបរមសុខ ទៅឲ្យអវយវៈពិតរបស់ព្រះកាយព្រះអង្គ។

ខ្ញុំក្រឡេកមើលទៅអស់លោក ហើយខ្ញុំគោរពអស់លោក ដូចជាអ្នកចូលរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធតាមរបៀបមួយខ្ពង់ខ្ពស់បំផុត គួរឲ្យកោតសរសើរបំផុត ដែលមិនអាចនិយាយបាន។ ព្រះបិតាអស់កល្បជានិច្ចប្រោសអស់លោកឲ្យចូលរួមក្នុងប្រតិបត្តិការដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះអង្គ គឺឲ្យបង្កើតព្រះបុត្រា របស់ព្រះអង្គ ដែលព្រះអង្គបានចាត់ឲ្យទៅចាប់កំណើតតាំងពីដើមផងមកនៅក្នុងព្រះឱរាព្រះអង្គ។ អស់លោក ដូចជានេត្រាដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះបុត្រាព្រះអង្គម្យ៉ាងដែរ ដ្បិតព្រះជាម្ចាស់បានប្រគល់អំណាចឲ្យអស់លោក ឲ្យបង្កើតព្រះបុត្រាព្រះអង្គ ក្នុងព្រលឹងរបស់គ្រីស្តបរិស័ទ។ ព្រះអង្គបានជ្រើសរើសយកអស់លោកឲ្យទៅជា ឪពុករបស់ពួកគេដែរ។ ធ្វើបែបនេះ ទើបអស់លោកជារូបតំណាងរស់រវើករបស់ព្រះបិតាល្អឥតខ្ចោះ ដែលគង់ នៅស្ថានបរមសុខ។

ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រោសអស់លោកឲ្យរួមជាមួយព្រះអង្គ ដ្បិតអស់លោករួមជាមួយព្រះអង្គក្នុងឋានៈជាស្ពានរវាងព្រះជាម្ចាស់ និងមនុស្សលោក និងក្នុងឋានៈជាចៅក្រមនៃសកលលោក។ ព្រះបុត្រាប្រគល់អំណាចឲ្យអស់លោកអាចថ្វាយចំពោះព្រះបិតាព្រះអង្គ នូវតង្វាយតែមួយដូចគ្នា ដែលព្រះអង្គបានថ្វាយនៅលើឈើឆ្កាង ហើយដែលព្រះអង្គបូជារាល់ ថ្ងៃនៅលើតុតង្វាយរបស់យើងជាកិច្ចការយ៉ាងធំធេង និងវិសុទ្ធជាងគេដែលព្រះអង្គបានបំពេញ។

ព្រះវិញ្ញាណដ៏វិសុទ្ធក៏ប្រោសអស់លោកឲ្យចូលរួមជាមួយដែរ នៅក្នុងកិច្ចការទាំងឡាយដែលព្រះអង្គបានបំពេញហើយដែលព្រះអង្គបំពេញរាល់ថ្ងៃ។ ហេតុអ្វីបានជាព្រះវិញ្ញាណដ៏វិសុទ្ធយាងមកក្នុងលោកនេះ? តើព្រះវិញ្ញាណមិនបានយាងមកដើម្បីកម្ចាត់បង់នូវភាពងងឹតល្ងង់ខ្លៅ និងអំពើបាបដែលគ្របដណ្ដប់ផែនដី?... ដើម្បីបំភ្លឺវិញ្ញាណមនុស្សដោយព្រះពន្លឺនៃស្ថានបរមសុខ?...ដើម្បីកម្ដៅចិត្តមនុស្សដោយភ្លើងដ៏វិសុទ្ធ នៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់?...ដើម្បីសម្រុះសម្រួលអ្នកបាបជាមួយព្រះជាម្ចាស់?...ដើម្បីលុបបំបាត់បាបកម្ម?...ដើម្បីសន្ដោសប្រណី?...ដើម្បីធ្វើឲ្យព្រលឹងបានវិសុទ្ធ?...ដើម្បីរៀបចំព្រះសហគមន៍?...ដើម្បីឲ្យព្រះសហគមន៍បានទទួលផលផ្លែនៃទុក្ខលំបាក និងការសុគតរបស់បុត្រា?...ដើម្បីជួយលុបលាងទោសបំផ្លាញ និង

បំបាត់សភាពទ្រុឌទ្រោមនៃមនុស្សចាស់?...ដើម្បីបង្ក និងផ្តល់កំណើតឲ្យព្រះយេស៊ូ? បើដូច្នោះ កិច្ចការបម្រើ និងកិច្ចការធម្មតារបស់អ្នក គឺធ្វើការងារទាំងអស់ដែលមានចែកខាងលើមែនឬទេ? តើព្រះជាម្ចាស់មិនបានត្រាស់ហៅអស់លោក ដើម្បីបង្កើតព្រះបុត្រាព្រះអង្គនៅក្នុងចិត្តមនុស្សឬទេ?

ហេតុនេះហើយ បានជាអស់លោកបានទទួលសម្ពន្ធមេត្រីដ៏ល្អអស្ចារ្យ ជាមួយព្រះត្រៃឯក អស់លោកជានិច្ច។ អស់លោកចូលរួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធ អស់លោកជាសហការីនៃព្រះដ៏មានតេជានុភាព ក្នុងការបង្កើតស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ។

ខ្ញុំសម្លឹងមើលព្រះជាម្ចាស់ដែលកសាង និងរៀបចំព្រះសហគមន៍ព្រះអង្គ ដោយតេជានុភាពនៃព្រះវិញ្ញាណព្រះអង្គ។ ខ្ញុំស្តាប់អ្វីៗទាំងអស់ ដែលទ្រង់មានព្រះបន្ទូលមកខ្ញុំនៅថ្ងៃនេះ...ព្រះអង្គអញ្ជើញខ្ញុំឲ្យកាន់មុខងារមួយនៅក្នុងព្រះសហគមន៍នេះ... «បើអ្នកចង់» បើខ្ញុំចង់...ខ្ញុំអរព្រះគុណព្រះអង្គ ដែលប្រគល់មុខងារឲ្យមនុស្សគ្រប់ៗរូប និងខ្លួនខ្ញុំឲ្យបានបំពេញមុខងារមួយ ភារកិច្ចមួយដែលមានតែមួយក្នុងព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្ត។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ពេលយើងរស់នៅជាគ្រីស្តបរិស័ទ យើងដឹងខ្លួនថា ជាចំណែកមួយនៃព្រះសហគមន៍។ តើការលំបាកធំៗណាខ្លះ ដែលយើងជួបពេលយើងជាសមាជិកព្រះសហគមន៍នេះ?

២- ប្រហែលជាយើងរស់នៅដោយផ្ទាល់ខ្លួន ចេញពីព្រះសហគមន៍នេះ ចាកចេញឆ្ងាយបន្តិចម្តងៗ...ប្រហែលជាយើងបានសម្រេចនឹងបញ្ឈប់ទាំងអស់...តើចំពោះខ្លួនយើងឧបសគ្គណាខ្លះជុំវិញខ្លួនយើង ដែលនាំឲ្យយើងចង់ផ្តាច់ខ្លួន?

៣- ពេលយើងរស់នៅជាគ្រីស្តបរិស័ទ យើងជួបជុំជាមួយអ្នកឯទៀត ដូចគ្រីស្តបរិស័ទដើមដំបូង (កក ២, ៤២-៤៧) ដើម្បីអធិដ្ឋានចែករំលែក និងផ្តល់សក្ខីភាពដោយមានចិត្តស្រឡាញ់ ហើយដោយសារកិច្ចការរបស់យើង អាចកែប្រែពិភពលោកដែលយើងរស់នៅ។ តើការលំបាកណាខ្លះ ដែលយើងជួបប្រទះក្នុង៖

- ការថ្វាយអភិបូជានៅថ្ងៃអាទិត្យ?
- ការភ្ជាប់ពាក្យសន្យាជាមួយអ្នកដទៃ?
- ការចែករំលែកជំនឿ ព្រះអំណោយទានរបស់យើងក្នុងក្រុម ក្នុងក្រុមអធិដ្ឋាន SSVP?
- សក្ខីភាព៖ តើជីវិតយើងផ្តល់សក្ខីភាពអ្វីសម្រាប់អ្នកដទៃ?

៤- ក្នុងការស្រាវជ្រាវមុខងាររបស់យើងនៅក្នុងព្រះសហគមន៍ តើអ្វីជាការភ័យខ្លាចរបស់យើង? ក្នុងចំណោមការភ័យខ្លាចទាំងនោះ ដែលមាននៅក្នុងខ្លួនយើង ហើយដែលបន្ទុចបង្អាក់យើង តើការភ័យខ្លាចណាមួយ ដែលទាក់ទងទៅនឹងការត្រាស់ហៅរបស់ព្រះអម្ចាស់ ចំពោះយើងសព្វថ្ងៃនេះ?

ខ្ញុំលុតជង្គង់ពីមុខព្រះអម្ចាស់ ដែលមានវត្តមាននៅទីនេះ ខ្ញុំទូលជាសម្ងាត់ចំពោះព្រះហឫទ័យសុភាពរាបសាររបស់ព្រះអង្គអំពីការភ័យខ្លាច ដែលខ្ញុំបានរកឃើញ។ ខ្ញុំអត់ទោសឲ្យខ្លួនឯង ដែលដើរតាមផ្លូវនោះ... ខ្ញុំសូមព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ ដោយមិនបានទទួលរាក់ទាក់នឹងការត្រាស់ហៅរបស់ព្រះអង្គ...ដោយ

មិនសូវយកចិត្តទុកដាក់ចំពោះបងប្អូនប្រុសស្រី...ដោយមិនសូវបានបម្រើពួកគេ...ដោយមិនសូវបានទុកខ្លួនជាព្រះភ័ក្ត្រ ជាព្រះហស្ត ជាព្រះបេះដូងរបស់ព្រះអង្គចំពោះបងប្អូនរបស់ខ្ញុំ...

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- បងប្អូនជាព្រះកាយព្រះគ្រីស្ត។ អវយវៈនីមួយៗមិនដូចគ្នាទេ មានប្រយោជន៍ខានមិនបានចំពោះព្រះកាយទាំងមូល។ សូមអានលិខិតទីមួយរបស់សន្តៈប៉ូល ចំពោះគ្រីស្តបរិស័ទនៅកូរិនថូ (១ករ ១២ និង ១៣)។សូមសួរខ្លួនឯងថា ព្រះអំណោយទានណា សមត្ថភាពណា ដែលខ្ញុំអាចយកមកប្រើនៅពេលនេះ ដើម្បីបម្រើព្រះសហគមន៍? ក្នុងព្រះកាយព្រះគ្រីស្ត តើកន្លែងខ្ញុំនៅឯណា?

២- តើយើងជួយអ្នកឯទៀតឲ្យអភិវឌ្ឍព្រះអំណោយទាន សមត្ថភាពរបស់ពួកគេ ដើម្បីយកមុខងារមួយនៅក្នុងសហគមន៍គ្រីស្តបរិស័ទយ៉ាងដូចម្ដេច?

៣- គ្រប់កាលៈទេសៈទាំងអស់ សន្តៈយ៉ូហាន អើដ ត្រាស់ហៅយើងឲ្យប្រគល់ខ្លួនថ្វាយទៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយសូមឲ្យព្រះអង្គណែនាំជីវិតយើងក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

ឱ! ព្រះយេស៊ូដ៏សប្បុរសអើយ! មានតែព្រះអង្គទេ ដែលខ្ញុំម្ចាស់ជឿទុកចិត្ត។

ឱ! ព្រះដ៏មានតេជានុភាពតេជានុភាព និងជាទីជ្រកកោនតែមួយរបស់ខ្ញុំអើយ! ខ្ញុំម្ចាស់សូមថ្វាយខ្លួន និងលះបង់អ្វីៗទាំងអស់ចំពោះព្រះអង្គ។ សូមឲ្យព្រះអង្គប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គទៅចុះ។

ឱ! សេចក្ដីស្រឡាញ់ដ៏ផ្អែមល្ហែមរបស់ខ្ញុំម្ចាស់អើយ! ព្រះអង្គជាទីសង្ឃឹមរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមថ្វាយខ្លួនទាំងស្រុងចំពោះព្រះអង្គ ហើយខ្ញុំម្ចាស់សូមលះបង់រូបកាយ ជីវិត ព្រលឹង និងអ្វីៗដែលជារបស់ខ្ញុំម្ចាស់ដើម្បីព្រះអង្គ តាមតែព្រះអង្គគាប់ព្រះហឫទ័យ ដើម្បីសិរីរុងរឿងរបស់ព្រះអង្គផងចុះ។

ខ្ញុំថ្វាយខ្លួនចំពោះព្រះអម្ចាស់ ដើម្បីទុកពេលឲ្យព្រះអង្គធ្វើសកម្មភាពមកក្នុងខ្លួន ហើយដើម្បីទទួលពីព្រះអង្គផ្ទាល់នូវមុខងារដែលជារបស់ខ្ញុំ ក្នុងព្រះកាយព្រះអង្គដែលជាព្រះសហគមន៍។

# អធិដ្ឋានរួមជាមួយព្រះសហគមន៍

យើងត្រូវបន្ត និងសម្រេចកិច្ចការទាំងអស់របស់ព្រះយេស៊ូ ហើយត្រូវអធិដ្ឋានចំពោះព្រះអង្គជារឿយៗ ដើម្បីឲ្យកិច្ចការទាំងអស់នោះ បានសម្រេចតាមព្រះហឫទ័យព្រះអង្គ។

## ដំណាក់កាលទី ១៦

អ្វីៗទាំងអស់សុទ្ធតែមកពីព្រះអង្គ ដោយសារព្រះអង្គ និងសម្រាប់ព្រះអង្គ!។
សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គអស់កល្បជានិច្ច! អាម៉ែន! (រម ១១,៣៦)។

**ក្នុងដំណាក់កាលនេះមាន** ៖ អធិដ្ឋានជាមួយព្រះយេស៊ូ! គឺព្រះវិញ្ញាណព្រះយេស៊ូផ្ទាល់ ដែលអធិដ្ឋាននៅក្នុងខ្ញុំ នៅក្នុងយើង។

នៅពេលដែលព្រះសហគមន៍ប្រជុំគ្នា ដើម្បីប្រារព្ធនឹករលឹកព្រះយេស៊ូបានចូលទិវង្គត និងមានព្រះជន្មថ្មី ព្រះសហគមន៍ដកពិសោធន៍ថា ព្រះអម្ចាស់ប្រគល់ព្រះអង្គជាតង្វាយឲ្យពួកយើងឥតឈប់ឈរ ដោយមិនប្រែប្រួល។

ដោយសារពិធីបុណ្យ ព្រះអង្គគង់នៅក្នុងព្រះសហគមន៍ព្រះអង្គ ដែលជាព្រះកាយព្រះអង្គ។ ព្រះអង្គជាការលើកតម្កើងសិរីរុងរឿង ជាការទូលអង្វរ ជាតង្វាយដើម្បីមនុស្សទាំងអស់។

ព្រះគ្រីស្តត្រាស់ហៅយើងឲ្យអធិដ្ឋានដូចព្រះអង្គ ដោយរួមគ្នាជាប្រជាជនតែមួយរបស់ព្រះអង្គ...ឲ្យនឹករំឭកដំណាក់កាលនីមួយៗនៃជីវិតរបស់ព្រះអង្គ...ឲ្យយើងម្នាក់ៗ និងយើងទាំងអស់គ្នាបន្តគម្រោងការពេញមួយជីវិតរបស់ព្រះអង្គ គឺជា «ពីធីបុណ្យប្រចាំឆ្នាំ» ។

**គោលដៅនៃដំណាក់កាលនេះ** ៖ ចូលទៅក្នុងការអធិដ្ឋាននៃពិធីបុណ្យរបស់ព្រះសហគមន៍។

- ដឹងខ្លួនយ៉ាងច្បាស់ថា ខ្លួនយើងជាគ្រីស្តបរិស័ទត្រូវតែចូលរួមជាមួយនឹងព្រះកាយទាំងមូលនៃព្រះគ្រីស្ត គឺព្រះសហគមន៍ មិនអាចនិយាយថា មិនចូលរួមបានឡើយ។

- ដោយសារខ្ញុំចូលរួមក្នុងពិធីបុណ្យនានា ខ្ញុំសម្តែងឲ្យឃើញថា ខ្ញុំជាកម្មសិទ្ធិរបស់ព្រះសហគមន៍...ការអធិដ្ឋានរបស់ខ្ញុំទៅជាការអធិដ្ឋាននៃគ្រីស្តបរិស័ទទាំងអស់ ហើយតួឯកសំខាន់គឺព្រះគ្រីស្ត។

- អគ្គសញ្ញា គឺជាកាយវិការរបស់ព្រះគ្រីស្តនៅក្នុងព្រះសហគមន៍។ តើអគ្គសញ្ញាទាំងអស់នោះ សំខាន់យ៉ាងដូចម្តេចក្នុងជីវិតខ្ញុំ?

- យល់ឃើញថា ពិធីបុណ្យប្រចាំឆ្នាំជាចង្វាក់នៃជីវិតរបស់ព្រះសហគមន៍ ដែលអាចឲ្យយើងចូលរួមជា

មួយសភាព និងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះយេស៊ូ។ ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចនិយាយប្រាប់បានថា ខ្ញុំនឹងចូលរួមក្នុងការអធិដ្ឋានរបស់ព្រះសហគមន៍យ៉ាងដូចម្តេច។

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១-រំឭកឡើងវិញនូវពិធីផ្សេងៗ...បុណ្យកំណើតបុណ្យជួបជុំគ្នាជាថ្មី។ល។...តើយើងអាចស្រមៃទៅដល់បុណ្យមួយដែលគ្មានការប្រជុំគ្នា និងគ្មានធ្វើពិធីណាមួយដែរឬទេ? សូមយល់ឃើញអំពីពិធីទាំងនោះដែលនាំឲ្យយើងនូវអ្វីខ្លះ។ តើមានពិធីណាដែលយើងពេញចិត្តជាងគេ? តើយើងប្រកាន់យកអាកប្បកិរិយាបែបណានៅឱកាសនោះ? តើអាកប្បកិរិយាជាក់ស្តែងនោះ បញ្ចេញមកយ៉ាងដូចម្តេច?

២- តើយើងធ្លាប់អធិដ្ឋានជាក្រុមដែរឬទេ? តើការអធិដ្ឋាននេះសំខាន់ចំពោះយើងឬទេ? ពីព្រោះអ្វី?

៣-តើយើងអាចនឹករលឹកអំពីការប្រជុំណាមួយ របស់ព្រះសហគមន៍បានដែរឬទេ? អ្វីដែលបញ្ជាក់លក្ខណៈនៃការប្រជុំនោះ? តើសញ្ញាអ្វីដែលនាំឲ្យយើងយល់ថា ជាការប្រជុំនៃព្រះសហគមន៍? អ្វីទៅជាព្រះសហគមន៍ចំពោះយើង? តើការអធិដ្ឋានរួមគ្នាក្នុងព្រះសហគមន៍មានន័យដូចម្តេចចំពោះយើង?

ព្រះយេស៊ូជាអ្នកត្រាស់ហៅយើងឲ្យមកជួបជុំគ្នា។ ខ្ញុំទុកមួយរយៈ ដើម្បីគិតឲ្យយល់អំពីសេចក្តីនេះ។ ខ្ញុំបើកចិត្តទទួលវត្តមានរបស់ព្រះអង្គ។ ខ្ញុំព្យាយាមទទួលព្រះអង្គក្នុងដួងចិត្តខ្ញុំ។ ខ្ញុំក្រាបថ្វាយបង្គំព្រះអង្គ ដែលជាអ្នកផ្តើមការប្រជុំទាំងអស់...ព្រះអង្គយាងមក ដើម្បីឲ្យយើងរួមឯកភាព ជាពិសេសឯកភាពនៅក្នុងខ្លួនយើងរាល់គ្នា...ខ្ញុំទទួលព្រះអង្គដែលអញ្ជើញខ្ញុំឲ្យជួបប្រជុំជាមួយបងប្អូនប្រុសស្រីរបស់ខ្ញុំ។ ខ្ញុំបណ្តោយឲ្យព្រះអង្គបំពេញតាមព្រះបំណងរបស់ព្រះអង្គនៅក្នុងខ្លួនខ្ញុំ...។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- សូមសញ្ជឹងគិតយ៉ាងយូរទៅដល់ព្រះយេស៊ូ ដែលជាអ្នកប្រមូលផ្តុំមនុស្ស...ជាសិប្បករនៃឯកភាព...ទីណាមានគ្នាពីរបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំនៅកណ្តាលពួកគេដែរ (មថ ១៨,២០)។ ព្រះយេស៊ូត្រូវសោយទិវង្គត ដើម្បីប្រមូលផ្តុំបុត្រធីតារបស់ព្រះជាម្ចាស់ដែលបែកបាក់ខ្ចាត់ខ្ចាយ (យហ ១,៥២)។

២- ព្រះយេស៊ូមានព្រះបំណងដ៏ធំ គឺឲ្យមនុស្សប្រុសស្រីទាំងអស់រួបរួមគ្នា ក្នុងព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ ដោយអរព្រះគុណព្រះអង្គ...

ចូរអ្នករាល់គ្នារួបរួមជាធ្លុងមួយ ដោយសារជំនឿ (អភ ៤,១២-១៣)

ចូរអ្នករាល់គ្នាអរព្រះគុណព្រះជាម្ចាស់ជានិច្ច (កូឡ ៣,១៦-១៧)

ព្រះសហគមន៍ដើមដំបូង (កក ២,៤២)

៣- សូមអធិដ្ឋានតាមសន្តៈប៉ូល (កូល ១,១២-២០) ដើម្បីអរព្រះគុណព្រះអម្ចាស់ ដែលបង្រួបបង្រួមយើងជាមួយនឹងសន្តៈបុគ្គលទាំងឡាយ។

៤- យើងក៏អាចអធិដ្ឋានតាមទំនុកតម្កើង (៨៧ ១១៦,១២-១៥) ផងដែរ។

៥- សូមយល់ឲ្យច្បាស់ថា ការអធិដ្ឋានអរព្រះគុណ ដែលសមស្របនឹងព្រះអំណោយទានរបស់ព្រះជាម្ចាស់ គឺការអរព្រះគុណរបស់ព្រះយេស៊ូ...នៅពេលពិធីជប់លៀងចុងក្រោយ...ដែលយើងតែងតែធ្វើរាល់ពេលប្រារព្ធពិធីអភិបូជា...ត្រៀមខ្លួន ដើម្បីរួបរួមជាមួយព្រះអង្គ ដោយសារព្រះអង្គក្នុងអង្គព្រះអង្គ។

៦- សូមបើកចិត្ត វិញ្ញាណយើងថែមទៀត ហើយសូមរៀនតាមសន្តៈយ៉ូហាន អើដ៖

## សន្តៈយ៉ូហាន អើដ

ព្រះបុត្រារបស់ព្រះជាម្ចាស់មានព្រះបំណងណែនាំយើងឲ្យចូលរួម ហើយខិតខំពង្រីក និងបន្តគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គចំពោះខ្លួនយើង និងចំពោះព្រះសហគមន៍ព្រះអង្គទាំងមូល។

យើងត្រូវតែបន្តកិច្ចការព្រះអង្គ និងសម្រេចកិច្ចការនោះក្នុងខ្លួនយើង ហើយទូលអង្វរព្រះអង្គជារឿយៗ សូមឲ្យកិច្ចការនោះ បានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គ ដ្បិតគម្រោងការនៃព្រះយេស៊ូមិនទាន់បានគ្រប់លក្ខណៈ និងមិនទាន់បានសម្រេចទាំងស្រុងទេ។ ទោះជាបានគ្រប់លក្ខណៈ និងបានសម្រេចនៅក្នុងអង្គព្រះយេស៊ូក៏ដោយ គម្រោងការនោះមិនទាន់បានគ្រប់លក្ខណៈ និងមិនទាន់បានសម្រេចនៅក្នុងខ្លួនយើង ដែលជាអវយវៈរបស់ព្រះអង្គ និងនៅក្នុងព្រះសហគមន៍ដែលជាព្រះកាយព្រះអង្គទេ។ ព្រះបុត្រាមានព្រះបំណងឲ្យយើង និងព្រះសហគមន៍ចូលរួមក្នុងគម្រោងការនោះ តាមមធ្យោបាយដែលព្រះអង្គមានព្រះហឫទ័យប្រើប្រាស់។

ហេតុនេះហើយ បានជាសន្តៈប៉ូលមានប្រសាសន៍ថា ព្រះសហគមន៍បំពេញកិច្ចការរបស់ព្រះគ្រីស្ត ហើយយើងទាំងអស់គ្នា រួមចំណែកជាមួយព្រះអង្គ ដើម្បីឲ្យព្រះអង្គបានគ្រប់លក្ខណៈសម្បត្តិ (អភ ១,២២-២៣; ៤,១៣) បានសេចក្តីថានោះនឹងបានសម្រេចបរិបូណ៌ដល់ថ្ងៃវិនិច្ឆ័យទោសមនុស្សលោក។ ក្រៅពីនេះលោកមានប្រសាសន៍ថា ក្នុងរូបកាយលោក លោកបំពេញទុក្ខលំបាករបស់ព្រះយេស៊ូគ្រីស្ត (១កូឡ ១,២៤)។

ដូច្នោះ ព្រះបុត្រារបស់ព្រះជាម្ចាស់ មានព្រះហឫទ័យសម្រេចនូវសភាព និងគម្រោងការទាំងអស់របស់ព្រះអង្គនៅក្នុងយើង។ ព្រះអង្គមានព្រះបំណងនឹងសម្រេចគម្រោងការ នៃការចាប់កំណើតរបស់ព្រះអង្គ ការកើតមក ការរស់នៅដោយលាក់បំពួនជាមួយយើងឲ្យបានគ្រប់លក្ខណៈ ដោយមកចាប់កំណើតនៅក្នុងយើង កើតនៅក្នុងព្រលឹងរបស់យើង ដោយសារអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាអរព្រះគុណ ហើយដោយសារយើងរស់នៅជាមួយព្រះអង្គ។

ព្រះអង្គមានព្រះបំណងនឹងសម្រេចគម្រោងការ នៃទុក្ខលំបាក ការសោយទិវង្គត និងការមានព្រះជន្មថ្មីរបស់ព្រះអង្គឲ្យបានគ្រប់លក្ខណៈ ដោយធ្វើឲ្យយើងរងទុក្ខលំបាក ស្លាប់ និងរស់ឡើងវិញជាមួយព្រះអង្គ និងក្នុងអង្គព្រះអង្គ។ ព្រះអង្គមានព្រះបំណងនឹងសម្រេចព្រះជន្មប្រកបដោយសិរីរុងរឿង និងអស់កល្បជានិច្ច ដែលព្រះអង្គបានទទួលពីស្ថានបរមសុខឲ្យបានគ្រប់លក្ខណៈ ដោយធ្វើឲ្យយើងរស់នៅជាមួយព្រះអង្គ និងក្នុងអង្គព្រះអង្គ ពេលដែលយើងនឹងទៅរស់នៅស្ថានបរមសុខប្រកបដោយសិរីរុងរឿង និងអស់កល្បជានិច្ច។ ដូច្នោះហើយព្រះអង្គមានព្រះបំណងនឹងសម្រេចកិច្ច និងគម្រោងការផ្សេងៗទៀតនៅក្នុងយើង និងនៅក្នុងព្រះសហគមន៍របស់ព្រះអង្គ ដោយធ្វើឲ្យយើងចូលរួមជាមួយព្រះអង្គ។

ដូច្នោះហើយគម្រោងការរបស់ព្រះយេស៊ូ នឹងមិនបានសម្រេចទាល់តែរហូតដល់ពេលដែលព្រះអង្គបានកំណត់ទុកក្នុងការបំពេញគម្រោងការនោះ នៅក្នុងបិត្តខ្លួនឯង និងក្នុងព្រះសហគមន៍ព្រះអង្គបានសេចក្តីថា រហូតដល់ទីបញ្ចប់នៃពិភពលោក។

ព្រះជាម្ចាស់ប្រទានឲ្យយើងមានជីវិតនៅលើផែនដីនេះ ដើម្បីឲ្យយើងបំពេញព្រះបំណងធំៗ ដែលព្រះ

យេស៊ូមានចំពោះយើងតែប៉ុណ្ណោះទេ។ ហេតុដូច្នោះហើយ យើងត្រូវប្រើប្រាស់ពេលវេលា ថ្ងៃ ខែ ឆ្នាំ របស់យើង ដើម្បីសហការ និងធ្វើកិច្ចការជាមួយព្រះយេស៊ូ។ យើងត្រូវសហការជាមួយព្រះអង្គ ដោយខិតខំធ្វើអំពើល្អ ដោយអធិដ្ឋាន និងដោយថ្វាយខ្លួនចំពោះព្រះអង្គ។ សូមឲ្យព្រះអង្គប្រតិបត្តិគម្រោងការនោះ ក្នុងខ្លួនយើងទៅតាមព្រះបំណងព្រះអង្គ និងដើម្បីសិរីរុងរឿងដ៏វិសុទ្ធរបស់ព្រះអង្គ។

## លោកបូជាចារ្យ ប៉េរណារ ប្រូ

ការអធិដ្ឋានរបស់ព្រះសហគមន៍៖ ស័ក្តិសម ខ្ញុំមិនបានច្នៃប្រឌិតជំនឿ និងសេចក្តីអធិដ្ឋានរបស់ខ្ញុំទេ។ ខ្ញុំទទួលជំនឿ និងសេចក្តីអធិដ្ឋាននោះពីព្រះសហគមន៍។

មុនដំបូង ពិធីបុណ្យព្រះសហគមន៍ជាមជ្ឈដ្ឋាននៃជីវិត ជាបរិយាកាសកើតឡើងដោយព្រះគ្រីស្តដែលបង្ហាញព្រះជាម្ចាស់ ដើម្បីឲ្យព្រះជន្មផ្ទាល់របស់ព្រះអង្គនេះចាប់កំណើត និងរីកចម្រើននៅក្នុងមនុស្ស។ សហគមន៍គ្រីស្តបរិស័ទជាកន្លែងមួយដែលគ្រីស្តបរិស័ទម្នាក់ៗ រៀនរស់នៅតាមទំនៀមទម្លាប់របស់ព្រះគ្រីស្ត ជាកន្លែងដែលជួយគាំទ្រ និងបំភ្លឺចិត្តមនុស្ស។ រៀមច្បងណែនាំប្អូនៗឲ្យចូលទៅក្នុងការរស់នៅ តាមទំនៀមទម្លាប់របស់ព្រះគ្រីស្ត។ អ្នកជំនាន់ក្រោយអប់រំ ហើយបញ្ជូនអ្នកថ្មីទៅតាមការអធិដ្ឋាន ដែលកើតចេញមកពីព្រះគ្រីស្ត ហើយរង់ចាំពេលព្រះអង្គយាងត្រឡប់មកវិញ។

(...)ព្រះសហគមន៍ស្នើឲ្យខ្ញុំអធិដ្ឋានតាមព្រះគ្រីស្ត ហើយទទួលខ្ញុំឲ្យនៅក្នុងមជ្ឈដ្ឋានរស់រវើក ដែលការអធិដ្ឋាននេះ អាចចាប់កំណើត និងរីកចម្រើន។ ខ្ញុំមិនច្នៃប្រឌិតជីវិតយ៉ាងណា ខ្ញុំក៏មិនច្នៃប្រឌិតជំនឿរបស់ខ្ញុំយ៉ាងនោះដែរ ប៉ុន្តែខ្ញុំទទួលបានជីវិត និងជំនឿនេះ។ ដូចគ្នានេះដែរ ខ្ញុំមិនច្នៃប្រឌិតសេចក្តីអធិដ្ឋានរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំទទួលការអធិដ្ឋានរបស់ព្រះគ្រីស្ត ដែលជាការអធិដ្ឋានកើតចេញពីព្រះវិញ្ញាណព្រះជាម្ចាស់ ហើយដែលបានកើតរួចស្រេចទៅហើយ នៅក្នុងសហគមន៍នៃបុត្រធីតារបស់ព្រះអង្គ។ ដូច្នេះគ្រីស្តបរិស័ទម្នាក់មិនអាចគ្មានសហគមន៍របស់ខ្លួនបានឡើយ ដូចអវយវៈមួយមិនអាចដាច់ចេញពីសេរីរាង្គរបស់ខ្លួនបានឡើយ។ គេជាគ្រីស្តបរិស័ទទាល់តែគេជាអវយវៈរបស់ព្រះគ្រីស្ត ហើយគេជាអវយវៈរបស់ព្រះគ្រីស្ត ទាល់តែគេរួបរួមជាមួយបងប្អូន ដោយសារជំនឿ និងការអធិដ្ឋាន...

មានមូលហេតុមួយទៀតធ្វើឲ្យយើងយល់ថា ការអធិដ្ឋានរួមចាំបាច់។ យើងមិនចាំបាច់ច្នៃប្រឌិតទេ ប៉ុន្តែយើងត្រូវទទួលការអធិដ្ឋានពិតប្រាកដ ដូចជាអំណោយមួយដែលកើតមកពីស្ថានលើ គឺការអធិដ្ឋានរបស់ព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅ ហើយយើងរៀនអធិដ្ឋានតាមព្រះគ្រីស្ត ដោយសារព្រះសហគមន៍របស់ព្រះអង្គ។ ប៉ុន្តែកុំយល់ច្រឡំថានៅតែស្ងៀមៗ ក៏បានទទួលចំណែកដែរនោះ។ ដើមទំពាំងបាយជូរទទួលជីវិតពីព្រះអាទិត្យ និងពីខ្យល់ ប៉ុន្តែដើមទំពាំងបាយជូរនោះ មិនមែនជាព្រះអាទិត្យ ឬខ្យល់ទេ។

(...) **គេអាចឆ្លើយចំពោះសកម្មភាពនៃសិល្បករ** ៖ ហេតុអ្វីបានជាគាត់ត្រូវការធ្វើឲ្យសោភ័ណភាពដែលគាត់ស្រឡាញ់យកទៅបញ្ចេញមកខាងក្រៅ? ហេតុអ្វីក៏គាត់មិនរក្សាទុកសោភ័ណភាពនេះ សម្រាប់តែខ្លួនគាត់ទៅ? តន្ត្រីករ ប៊ីថូវែន ទៅជាថ្លង់... ហេតុអ្វីក៏លោកចង់បោះពុម្ពផ្សព្វផ្សាយសៀវភៅបទភ្លេង ដែលគាត់លែងឮទៅហើយនោះធ្វើអ្វី? គឺដោយសារគាត់ត្រូវការឲ្យបទភ្លេងនោះ ចាប់កំណើត...ឲ្យបទភ្លេងនោះមានជីវិត ហើយគាត់ចង់ចែករំលែកសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅនៅក្នុងចិត្ត ដើម្បីលើកតម្កើងសោភណភាពនេះ ដែល

គាត់ជាប់បិត្ត។ យ៉ាងណាមិញចំពោះការអធិដ្ឋានរួមរបស់យើង គឺការអធិដ្ឋានរួមបង្ហាញអំពីជីវិតមួយ...ព្រលឹងមួយនៅខាងក្នុង។ ការអធិដ្ឋាននេះ កើតចេញពីសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅ ដូចព្រះជាម្ចាស់បង្កើតមនុស្សដើម្បីឲ្យព្រះអង្គចែករំលែកសេចក្ដីស្រឡាញ់របស់ព្រះអង្គ។

(...) ក្នុងការអធិដ្ឋានរួម តើយើងបារម្ភយកការអធិដ្ឋានរបស់ព្រះគ្រីស្ត ធ្វើជាប្រភពឬ? ក្រៅពីនេះ គ្មានការអធិដ្ឋានទេ។ បើគ្មានការអធិដ្ឋានក្នុងចិត្តទេ ការអធិដ្ឋានរួមគ្មានតម្លៃទាល់តែសោះ។ ឧបករណ៍ភ្លេងមួយមិនបាត់បង់គុណភាពទេ ពេលចូលរួមប្រជុំក្នុងវង់តូរ្យតន្ត្រី ផ្ទុយទៅវិញឧបករណ៍នោះ រីកចម្រើនថ្កុំថ្កើនទៅតាមឧបករណ៍ឯទៀតៗដែរ ហើយជាមួយគ្នានេះដែរ ឧបករណ៍ឯទៀតៗ នៅតែមានតម្លៃរបស់ខ្លួនទៅតាមគុណភាពនៃឧបករណ៍នីមួយៗដែរ។

ខ្ញុំក្រាបថ្វាយបង្គំ អរព្រះគុណព្រះអង្គ ដែលមានព្រះបំណងរួមជាមួយយើង...ក្នុងចិត្តខ្ញុំ...ព្រះអង្គមានព្រះបំណងឲ្យយើងទៅជាព្រះកាយតែមួយ នៅក្នុងព្រះសហគមន៍...ខ្ញុំថ្វាយខ្លួនចំពោះព្រះអង្គ ដើម្បីឲ្យព្រះអង្គអាចបំពេញគម្រោងការទាំងប៉ុន្មានរបស់ព្រះអង្គក្នុងចិត្តខ្ញុំ។ ខ្ញុំយល់ឃើញថា ខ្ញុំមិនឆ្នៃប្រឌិតជំនឿ និងសេចក្ដីអធិដ្ឋានរបស់ខ្ញុំទេ គឺខ្ញុំទទួលជំនឿ និងសេចក្ដីអធិដ្ឋាន ដោយរួបរួមជាមួយព្រះសហគមន៍។ ខ្ញុំអរព្រះគុណចំពោះអស់អ្នកដែលបានណែនាំខ្ញុំ ក្នុងការស្វែងរកព្រះជាម្ចាស់។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ការប្រមូលផ្ដុំនៃគ្រីស្តបរិស័ទ មិនមែនដូចជាប្រជុំធម្មតាទេ គឺជាអាថ៌កំបាំងមួយ។ នៅពេលដែលគ្រីស្តបរិស័ទជួបជុំគ្នា មានអ្វីមួយកើតឡើង «នៅទីណាមានពីបីរនាក់ជួបជុំគ្នា ក្នុងនាមខ្ញុំនៅទីនោះ ខ្ញុំស្ថិតនៅជាមួយគេ» (មថ ១៨,២០)។ ព្រះគ្រីស្តដែលមានព្រះជន្មថ្មី យាងមករកយើងតាមព្រះបន្ទូលសន្យា «ឥឡូវនេះ ខ្ញុំនៅជាមួយអ្នករាល់គ្នារហូតដល់ទីបញ្ចប់» (មថ ២៨, ២០)។

២-សូមដឹងច្បាស់ថា របៀបរស់នៅរបស់យើងខុសឆ្ងាយពីអ្វី ដែលព្រះគ្រីស្តត្រាស់ហៅឲ្យយើងប្រព្រឹត្ត។

៣-សូមពិចារណាអំពីអ្វីដែលយើងមិនសូវពេញចិត្តក្នុងព្រះសហគមន៍...បទពិសោធន៍អវិជ្ជមាន...អ្វីៗដែលធ្វើឲ្យយើងខកចិត្ត...

ដោយរំឭកទៅដល់កំណត់របស់ខ្លួនខ្ញុំផ្ទាល់ និងការលើកលែងទោស ដែលខ្ញុំបានទទួល ខ្ញុំព្យាយាមទទួលយកកំណត់របស់ព្រះសហគមន៍នៃព្រះយេស៊ូ...ហើយខ្ញុំព្យាយាមលើកលែងទោសឲ្យលក្ខណៈប្លែកៗគ្នាទាំងនោះ ដែលធ្វើឲ្យខ្ញុំខកចិត្ត។ ខ្ញុំទុកឲ្យសេចក្ដីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះហឫទ័យនៃព្រះយេស៊ូ និងព្រះនាងម៉ារីមករកខ្ញុំ។ ខ្ញុំទុកឲ្យព្រះអង្គលើកលែងទោសឲ្យខ្ញុំ...ខ្ញុំទុកឲ្យព្រះអង្គផ្លាស់ប្ដូរចិត្តខ្ញុំ ទៅជាចិត្តពោរពេញទៅដោយធម៌មេត្តាករុណា។ ខ្ញុំយល់ច្បាស់ថា តើខ្ញុំអាចលើកលែងទោសឲ្យគេយ៉ាងពិតប្រាកដដូចម្ដេចខ្លះ? តើគួរអធិដ្ឋានជាមួយព្រះសហគមន៍?...ប្រារព្ធពិធីអគ្គសញ្ញាលើកលែងទោស?...

## ទុកពេលសម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- ចុងបញ្ចប់ជំណាក់កាលនេះ តើឥឡូវនេះយើងយល់អំពីការអធិដ្ឋានរួមនៅក្នុងព្រះសហគមន៍ មានអត្ថន័យយ៉ាងណា?

២- «ពិធីបុណ្យប្រចាំឆ្នាំ» ទុកឱកាសឲ្យយើងរិះគិតទៅតាមហេតុការណ៍ ដែលបានកើតឡើងចំពោះព្រះយេស៊ូ («សភាពទាំងឡាយ និងគម្រោងការរបស់ព្រះយេស៊ូ» តាមសន្តៈយ៉ូហាន អើដ)។ តើយើងអាចនិយាយថា តើហេតុការណ៍ណាខ្លះដែលយើងចាប់អារម្មណ៍?

៣- «រាល់ពេលដែលយើងរំឭកពិធីសក្ការបូជានេះ យើងទទួលការសង្គ្រោះ» (អធិដ្ឋានចូលនៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ)។ ចំពោះយើង តើអគ្គសញ្ញាអរព្រះគុណ ពិតជាការអធិដ្ឋានដ៏ប្រសើរឬទេ? សូមមើលឲ្យឃើញថា តើយើងអាចធ្វើអ្វីខ្លះ ដើម្បីយល់អភិបូជាច្បាស់ជាងមុន។

៤- អគ្គសញ្ញាជា «សញ្ញាសម្គាល់ពិតៗ នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ចំពោះយើងរាល់គ្នា» តើអគ្គសញ្ញាសំខាន់យ៉ាងដូចម្តេចក្នុងជីវិតរបស់យើង?

៥-«ព្រះយេស៊ូបានបូជាព្រះជន្មព្រះអង្គ ដើម្បីប្រមូលផ្តុំបុត្រធីតារបស់ព្រះជាម្ចាស់ ដែលបានខ្ចាត់ខ្ចាយ»។ចុះយើងវិញ តើការជួបជុំនៃគ្រីស្តបរិស័ទធ្វើឲ្យយើងយល់យ៉ាងណា? តើយើងត្រៀមខ្លួននឹងថ្វាយអ្វីខ្លះ ដើម្បីឲ្យព្រះរាជ្យព្រះអង្គយាងមកដល់? តាមពិតទៅ តើយើងអាចរួបរួមជាមួយនឹងតង្វាយរបស់ព្រះយេស៊ូដូចម្តេច?

៦- សន្តៈយ៉ូហាន អើដ បានទុករបៀបអធិដ្ឋានមួយ ដែលអាចកែប្រែចិត្តយើងបន្តិចម្តងៗ។ សូមឲ្យយើងតាក់តែងសេចក្តីអធិដ្ឋានរបស់ខ្លួនឯង ដោយយកតាមលំនាំនៃសេចក្តីអធិដ្ឋានដូចតទៅ៖

ចូរយើងក្រាបថ្វាយបង្គំចំពោះព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលស្ថិតនៅក្នុងគម្រោងការនៃ...ដែលពិធីបុណ្យនៅពេលនេះប្រារព្ធធ្វើ ( ឬថ្ងៃនេះ)។ ចូរយើងអរព្រះគុណព្រះអង្គ ដែលមានព្រះបំណងបំពេញគម្រោងការនេះ ដើម្បីលើកតម្កើងសិរីរុងរឿង ព្រះបិតាព្រះអង្គ និងដើម្បីឲ្យយើងបានចូលរួមដែរ។ ចូរយើងសូមព្រះអង្គលើកលែងទោសនូវកំហុសណា ដែលយើងបានប្រព្រឹត្តប្រឆាំងនឹងគម្រោងការនោះ។ ចូរយើងថ្វាយខ្លួនចំពោះព្រះយេស៊ូ ដើម្បីលើកតម្កើងគម្រោងការនោះ និងដើម្បីអនុវត្តតាមឲ្យបានល្អឥតខ្ចោះគ្រប់លក្ខណៈ តាមសំណូមពររបស់ព្រះអង្គ។ ចូរយើងទូលអង្វរព្រះអង្គឲ្យបានបំបាត់អស់ពីខ្លួនយើង នូវអ្វីៗដែលប្រឆាំងនឹងគម្រោងការនេះ ហើយសូមព្រះអង្គសន្តោសប្រណីដល់យើងនូវអ្វីៗ ដែលយើងត្រូវការដើម្បីបំពេញសំណូមពរនោះ។

# អនុវត្តពិធីជ្រមុជទឹក

យើងប្រកាសជំនឿលើព្រះយេស៊ូគ្រីស្ត នៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹកដ៏វិសុទ្ធ!

## ដំណាក់កាលទី ១៧

ប្រសិនបើអ្នកដឹងអំពីព្រះអំណោយទានរបស់ព្រះជាម្ចាស់ (យហ ៤,១០)

**ក្នុងដំណាក់កាលនេះមាន ៖** សម្ពន្ធមេត្រីរវាងព្រះជាម្ចាស់ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណផ្សារភ្ជាប់ដោយអគ្គសញ្ញាជ្រមុជទឹក ចាប់យកការរស់នៅជាមនុស្សរបស់ខ្ញុំទាំងស្រុង ព្រមទាំងការងារ អារម្មណ៍ និងការទទួលខុសត្រូវទាំងឡាយ...សម្ពន្ធមេត្រីធ្វើឲ្យខ្ញុំជាបុត្រធីតារបស់ព្រះជាម្ចាស់ ជាអវយវៈរបស់ព្រះយេស៊ូគ្រីស្ត ធ្វើឲ្យខ្ញុំបានវិសុទ្ធដោយព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើឲ្យខ្ញុំទៅជាបងប្អូនរបស់មនុស្សទាំងអស់។

ជីវិតរបស់ព្រះយេស៊ូនេះ ចាប់ផ្តើមនៅថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក ត្រូវបានចិញ្ចឹមបំប៉នដោយអគ្គសញ្ញាអរព្រះគុណ «អ្នកណាពិសាខ្ញុំ អ្នកនោះនឹងរស់នៅដើម្បីខ្ញុំ ដោយសារខ្ញុំ»។

ដោយសារអគ្គសញ្ញាលាបប្រេងថ្វាស ព្រះវិញ្ញាណ ដែលព្រះបិតាបានចាត់ឲ្យមកធ្វើឲ្យគ្រីស្តបរិស័ទទៅជាសមាជិកសកម្មរបស់ព្រះសហគមន៍ និងធ្វើឲ្យគេបានគ្រប់លក្ខណៈ តាមការសន្តោសប្រណីរបស់ព្រះជាម្ចាស់ ដែលគេបានទទួលពីអគ្គសញ្ញាជ្រមុជទឹក។

**គោលដៅនៃដំណាក់កាលនេះ ៖** ពិចារណាអំពីអគ្គសញ្ញានានា ដែលបើកផ្លូវឲ្យទៅជាគ្រីស្តបរិស័ទ អគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាអរព្រះគុណ អគ្គសញ្ញាលាបប្រេងថ្វាស។

ថ្ងៃនេះ ខ្ញុំគិតឡើងវិញ អំពីពាក្យសន្យារបស់ខ្ញុំ ក្នុងពេលដែលខ្ញុំបានទទួលពិធីអគ្គសញ្ញាជ្រមុជទឹក

- ដូចជាកិច្ចសន្យាសម្ពន្ធមេត្រីរវាងព្រះជាម្ចាស់ និងខ្លួនខ្ញុំ (សូមរកមើលនៅក្នុងព្រះគម្ពីរនូវអ្វីៗដែលទាក់ទងនឹងសម្ពន្ធមេត្រី)

- ដូចជាការចូលរួមជាមួយនឹង«សភាព និងគម្រោងការរបស់ព្រះយេស៊ូ» ក្នុងអគ្គសញ្ញាអរព្រះគុណ ធ្វើឲ្យខ្ញុំនឹកឃើញថា គ្មានអ្នកណាមានចិត្តស្រឡាញ់ខ្លាំងជាងអ្នកដែលស៊ូប្តូរជីវិត ដើម្បីអ្នកដែលខ្លួនស្រឡាញ់ទេ ។

- ដូចជាការចាត់ឲ្យទៅដោយសារព្រះវិញ្ញាណ ដើម្បីបញ្ជាក់ថា យើងជាសមាជិកសកម្មក្នុងព្រះសហគមន៍ - អគ្គសញ្ញាលាបប្រេងថ្វាស។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចចុះកិច្ចសន្យាជាថ្មីម្តងទៀត នៃអគ្គសញ្ញាជ្រមុជទឹករបស់ខ្ញុំ។

## ទុកពេលសម្រាប់បើកចិត្ត និងទទួល

១- អគ្គសញ្ញាជ្រមុជទឹក៖ តើយើងនិយាយអំពីអគ្គសញ្ញានោះយ៉ាងដូចម្ដេច? នៅក្នុងតារាងដូចតទៅ តើពាក្យពេចន៍ណាដែលយើងចូលចិត្ត? មុជក្នុងពន្លឺជួបនឹងព្រះជាម្ចាស់ កំណើតថ្មី កាយវិការនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ការចូលជាប្រជាជនជាអ្នកជឿព្រះសហគមន៍ រួមជាមួយព្រះយេស៊ូគ្រីស្ត ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រះអំណោយទានរបស់ព្រះជាម្ចាស់ អគ្គសញ្ញាផ្ដល់បិត្តគំនិតថ្មី...តើយើងគួរបន្ថែមពាក្យពេចន៍ណាខ្លះទៀត?

២- ពាក្យពេចន៍ ដែលយើងបានជ្រើសរើស មានអត្ថន័យដូចម្ដេចចំពោះយើង?

៣-តើយើងដឹងអ្វីខ្លះ អំពីអគ្គសញ្ញាជ្រមុជទឹករបស់យើង? តើយើងនិយាយអំពីអគ្គសញ្ញានោះដូចម្ដេច? និយាយក្នុងអតីតកាល? បច្ចុប្បន្នកាល?

**៤- គ្រីស្តទូតប៉ូល បានសរសេរលិខិតមួយ ផ្ញើរទៅលោកធីម៉ូថេឲ្យគាត់រំឭកឡើងវិញ៖** ដោយសារសន្តៈប៉ូលបានដាក់ដៃលើគាត់ គាត់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីទៅជាគ្រីស្តទូត និងអភិបាល (២ធម ១,៦)។ យើងបានទទួលព្រះអង្គក្នុងពិធីជ្រមុជទឹក។ ប្រហែលជាយើងបានទទួលពិធីដាក់ដៃ នៅថ្ងៃដែលយើងទទួលអគ្គសញ្ញាលាបប្រេងថ្វាស។ តើការដាក់ដៃនេះ មានអត្ថន័យដូចម្ដេច?

ខ្ញុំសូមខ្ចីសៀវភៅដែលរៀបរាប់អំពីពិធីអគ្គសញ្ញាជ្រមុជទឹក ពីអ្នកដែលណែនាំខ្ញុំ។ ខ្ញុំមើលអំពីរបៀបប្រារព្ធពិធីនេះ។ ខ្ញុំសរសេរអ្វីៗ ដែលជាអគ្គសញ្ញាជ្រមុជទឹកសម្រាប់ខ្ញុំថ្ងៃនេះ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

### ១- អត្ថបទព្រះគម្ពីរ

**ចូររកនៅក្នុងព្រះគម្ពីរ នូវអត្ថបទណាដែលទាក់ទងនឹង៖**

- សម្ពន្ធមេត្រី ភក្ដីភាព ការរួបរួមក្នុងជំនឿ ឧទាហរណ៍ដូចជា៖ (យេ ៣១,៣១-៣៤; អស ៣៧,៥,៩,១៤;១ករ ១,៩; ១យហ ៣,១; យហ ១៧,២២-២៣; យហ ១៤,២៣)។
- ការចាប់កំណើតជាថ្មី សេរីភាពនៃបុត្រធីតារបស់ព្រះជាម្ចាស់ ឧទាហរណ៍ដូចជា៖ (យហ ៣,៥; កូឡ ១, ១២-១៤)។
- ជីវិតថ្មីនៅក្នុងអង្គព្រះយេស៊ូ សម្ពន្ធមេត្រីថ្មី ឧទាហរណ៍ដូចជា៖ (អស ១១,២; អស ៦១,១-២; លក ៤, ១៦-២១; យហ ១៤-១៧; ១ថស ១,២-១០)។
- ការចូលក្នុងប្រជាជនព្រះជាម្ចាស់ ឧទាហរណ៍ដូចជា៖ (សរ ៣៦,២៤-២៨)
- ការធ្វើតាមព្រះយេស៊ូ ការត្រាស់ហៅឲ្យបន្តសកម្មភាព ឧទាហរណ៍ដូចជា៖ (កាឡ ៣,២៧)

### ២- អត្ថបទរបស់សន្តៈ យ៉ូហាន អើដ

អគ្គសញ្ញាជ្រមុជទឹក គឺជាសម្ពន្ធមេត្រីគួរឲ្យកោតសរសើរ រវាងព្រះជាម្ចាស់ និងមនុស្ស។

ព្រះជាម្ចាស់ជាអ្នកចាប់ផ្ដើមចងសម្ពន្ធមេត្រី។ ដោយសារ «ការយល់ព្រម» យើងទៅជាសហការីរបស់ព្រះអង្គ។ យើងមុជជ្រៅទៅក្នុងព្រះជន្មព្រះជាម្ចាស់ គឺព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណ។ ឥឡូវនេះ យើងមានលក្ខណៈរួមជាមួយនឹងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ។ បន្តិចម្ដងៗ អ្វីៗទាំងអស់នៅក្នុងខ្លួនយើងទៅជា

ព្រះយេស៊ូ។

«អគ្គសញ្ញាជ្រមុជទឹក ធ្វើឲ្យយើងរួមរស់យ៉ាងអស្ចារ្យជាមួយព្រះជាម្ចាស់»

អគ្គសញ្ញាជ្រមុជទឹកជាសន្ធិសញ្ញារវាងមនុស្ស និងព្រះជាម្ចាស់ដែលនៅក្នុងនោះ មានហេតុការណ៍ជាច្រើនបានកើតឡើង។

ដោយសារធម៌មេត្តាករុណា និងសប្បុរសធម៌ ដែលយើងមិនអាចយល់បាន ព្រះជាម្ចាស់រំដោះយើងឲ្យរួចផុតពីសម្ពន្ធមេត្រី ដែលយើងបានចងជាមួយមារសាតាំង ដែលបានធ្វើឲ្យយើងក្លាយជាបុត្រធីតារបស់មារដោយសារអំពើបាប ហើយព្រះអង្គនាំយើងចូលជាសមាជិករបស់ព្រះអង្គ។ សន្តះប៉ូលមានប្រសាសន៍ថា៖ ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនឲ្យរួបរួមជាមួយព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត (១ករ ១,៩)។ សន្តះយ៉ូហានមានប្រសាសន៍ថា៖ យើងសូមជូនដំណឹងអំពីព្រះបន្ទូលដែលយើងបានឃើញ និងបានឮនោះដល់បងប្អូន ដើម្បីឲ្យបងប្អូនបានចូលរួមរស់ជាមួយយើង រីឯយើងវិញ យើងក៏រួមរស់ជាមួយព្រះបិតា និងជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ (១យហ ១,៣)។

**សម្ពន្ធមេត្រីនោះ គឺជាអ្វី?** គឺជាសម្ពន្ធមេត្រីដ៏ខ្ពង់ខ្ពស់បំផុត និងគ្រប់លក្ខណៈបំផុត ដែលអាចកើតមានពីព្រោះមិនមែនគ្រាន់តែជាសម្ពន្ធមេត្រីរវាងមិត្តភក្តិ បងប្អូន កូនៗជាមួយឪពុក ប្រពន្ធជាមួយប្ដីប៉ុណ្ណោះទេ ប៉ុន្តែជាសម្ពន្ធមេត្រីនៃសមាជិកជាមួយនឹងមេដឹកនាំ ជាសម្ពន្ធមេត្រីដ៏ជិតស្និទ្ធបំផុត ហើយស្អិតល្មួតបំផុត ជាងសម្ពន្ធមេត្រីផ្សេងៗទៀត។

លើសពីនេះទៅទៀត គឺជាការរួបរួមរវាងមែក និងដើមទំពាំងបាយជូរ រវាងអវយវៈ និងរាងកាយមនុស្សជាមួយនឹងមេដឹកនាំរបស់ពួកគេ។ ទោះជាការរួបរួមទាំងអស់នោះ ជិតស្និទ្ធយ៉ាងណាក៏ដោយ ក៏គ្រាន់តែជារូបភាព និងស្រមោលមួយនៃការរួបរួមផ្នែកវិញ្ញាណ និងហួសពីធម្មជាតិដែលយើងមានជាមួយព្រះយេស៊ូគ្រីស្តក្នុងអគ្គសញ្ញាជ្រមុជទឹកប៉ុណ្ណោះ។

លើសពីនេះទៅទៀត គឺថាសម្ពន្ធមេត្រីដែលយើងចងដោយអគ្គសញ្ញាជ្រមុជទឹក នៅក្នុងអង្គព្រះយេស៊ូគ្រីស្ត ហើយដោយសារព្រះអង្គជាមួយនឹងព្រះបិតាអស់កល្បជានិច្ចនោះ ជាសម្ពន្ធមេត្រីដ៏ខ្ពង់ខ្ពស់បំផុត និងល្អឥតខ្ចោះ ដែលស័ក្តិសមនឹងប្រៀបធៀបសម្ពន្ធមេត្រីនេះជាមួយនឹងឯកភាព ដែលមានរវាងព្រះយេស៊ូគ្រីស្ត និងព្រះបិតា៖ ឲ្យគេរួមគ្នាជាអង្គតែមួយដូចយើងជាអង្គតែមួយដែរ គឺឲ្យទូលបង្គំនៅក្នុងគេ ព្រះអង្គនៅក្នុងទូលបង្គំ ដើម្បីឲ្យគេរួមគ្នាជាអង្គតែមួយពិតប្រាកដមែន (យហ ១៧,២២-២៣)។ ដូច្នោះហើយ ឯកភាពនៃព្រះបិតា និងព្រះបុត្រាជាគំរូនៃការរួបរួម ដែលយើងមានជាមួយព្រះជាម្ចាស់ នៅពេលដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ហើយការរួបរួមនេះជារូបភាពដ៏រស់រវើកនៃឯកភាពដ៏គួរឲ្យគោរពស្រឡាញ់នេះ។

លើសពីនេះទៅទៀត អគ្គសញ្ញាជ្រមុជទឹកលើកតម្កើងឲ្យបានខ្ពង់ខ្ពស់អស្ចារ្យ សម្ពន្ធមេត្រីជាមួយព្រះជាម្ចាស់ ព្រោះព្រះលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូគ្រីស្ត បង្កើតសម្ពន្ធមេត្រីនេះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាឯកភាពរវាងព្រះបិតា និងព្រះបុត្រា ជាអ្នកចងសម្ពន្ធមេត្រីនេះ។ បើតាមពាក្យពេចន៍ដ៏វិសុទ្ធនៃព្រះសហគមន៍៖ ក្នុងឯកភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំអាចនិយាយថា ព្រះវិញ្ញាណដដែលនេះ ជាចំណងដ៏វិសុទ្ធនៃសម្ពន្ធមេត្រី ដែលយើងចងជាមួយព្រះយេស៊ូគ្រីស្ត និងព្រះបិតាអស់កល្បជានិច្ច ដូចមានចែងព្រះបន្ទូលថា៖ សូមឲ្យពួកគេរួបរួមគ្នាជាធ្លុងតែមួយឲ្យបានគ្រប់លក្ខណៈ។

ដូច្នោះយើងយល់ឃើញថា ដោយសារអគ្គសញ្ញាជ្រមុជទឹក យើងរួបរួមជាធ្លុងមួយជាមួយព្រះយេស៊ូគ្រីស្ត

ហើយដោយសារព្រះយេស៊ូគ្រីស្ត យើងរួបរួមជាមួយព្រះជាម្ចាស់ទៅតាមរបៀបដ៏ខ្ពង់ខ្ពស់បំផុត ដែលអាចកើតមាន។ ឱ!សម្ពន្ធមេត្រីឥតគូប្រៀប! ឱ!សម្ពន្ធមេត្រីដ៏អស្ចារ្យគ្មានពីរ! ឱ!សម្ពន្ធមេត្រីដែលមិនអាចថ្លែងបាន! តើឲ្យយើងត្រូវប្រព្រឹត្តយ៉ាងណា ចំពោះសប្បុរសធម៌ឥតគណនារបស់ព្រះជាម្ចាស់ ដែលបង្កើតសម្ពន្ធមេត្រីដ៏ធំធេងនោះ! តើយើងត្រូវលើកតម្កើង និងអរព្រះគុណព្រះអង្គយ៉ាងណា! សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុត របស់ព្រះអង្គរកថ្លែងពុំបាន (២ករ ៩,១៥)។

ប៉ុន្តែក្រោយពីបានរួបរួមជាមួយព្រះដ៏វិសុទ្ធបំផុត យ៉ាងជិតស្និទ្ធបែបនេះ តើជីវិតយើងត្រូវបានវិសុទ្ធយ៉ាងណាទៅ! ប្រាកដហើយ! ដោយហេតុថា យើងនិងព្រះជាម្ចាស់រួបរួមគ្នាជាធ្លុងតែមួយ ដូច្នោះយើងក៏ត្រូវមានចិត្តតែមួយ វិញ្ញាណតែមួយបំណងឆន្ទៈតែមួយ អារម្មណ៍តែមួយ ហើយសេចក្ដីស្រឡាញ់តែមួយរួមជាមួយព្រះអង្គដែរ។ អ្នកដែលរួបរួមជាមួយព្រះអម្ចាស់មានវិញ្ញាណតែមួយជាមួយព្រះអង្គ (១ករ ៦,១៧)។ យើងត្រូវស្រឡាញ់តែអ្វីៗដែលព្រះអង្គស្រឡាញ់ និងស្អប់តែអ្វីៗ ដែលព្រះអង្គស្អប់ មានអំពើបាបជាដើម។ ឱ! អំពើបាបស័ក្ដិសមនឹងគួរឲ្យស្អប់មែន! ពីព្រោះអ្វីទៅជាអំពើបាបដែលនាំឲ្យស្លាប់? គឺជាការរំលោភបំពាន និងការកាត់ផ្ដាច់សម្ពន្ធមេត្រីដែលយើងចងភ្ជាប់ជាមួយព្រះជាម្ចាស់ ដោយអគ្គសញ្ញាជ្រមុជទឹក ដើម្បីចូលទៅចងសម្ពន្ធមេត្រីជាមួយសត្រូវរបស់ព្រះអង្គ គឺមារសាតាំង។ ពេលនោះយើងបង្អាប់បង្អោនឯកភាពនៃព្រះបិតា និងព្រះបុត្រា ដោយបំផ្លាញរូបតំណាងព្រះអង្គ។ ពេលនោះ យើងប្រមាថមើលងាយព្រះលោហិត ដ៏គួរឲ្យគោរពនៃព្រះយេស៊ូគ្រីស្ត ដែលជាមូលដ្ឋានគ្រឹះនៃសម្ពន្ធមេត្រីនេះ។ ពេលនោះយើងពន្លត់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលជាចំណងដ៏វិសុទ្ធ បើតាមបំរាមនៃស្លានបរមសុខថា៖ សូមបងប្អូនកុំពន្លត់ព្រះវិញ្ញាណដ៏វិសុទ្ធនៅខ្លួនបងប្អូនឲ្យសោះ (១ថស ៥,១៩)។ ត្រូវស្អប់ខ្ពើមអំពើបាបរបស់យើងកន្លងមក! គួរឲ្យញញើតណាស់ ខ្លាចតែធ្លាក់ក្នុងអំពើបាបនៅពេលខាងមុខ! ហើយចុះយើងត្រូវថែរក្សាសម្ពន្ធមេត្រីដ៏ស្អកស្កម្ភ និងថ្លៃថ្លាជាមួយព្រះជាម្ចាស់នេះ ហើយខិតខំបង្រួបបង្រួមអស់អ្នក ដែលចង់រួបរួមជាមួយព្រះអង្គ តាមរបៀបផ្សេងៗណា ដែលយើងអាចធ្វើបាន!

**៣- តើគ្រីស្តបរិស័ទជាអ្វី?** អគ្គសញ្ញាបី ដែលគេហៅថាជាអគ្គសញ្ញាបង្ហាត់ឲ្យទៅជាគ្រីស្តបរិស័ទ គឺធ្វើឲ្យយើងទៅជាព្រះសហគមន៍ គឺអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាអរព្រះគុណ អគ្គសញ្ញាលាបប្រេងថ្វាស។

**ដោយសារអគ្គសញ្ញាជ្រមុជទឹក** យើងលែងរួបរួមសាមគ្គីជាមួយអស់អ្នក ដែលសម្លាប់ព្រះគ្រីស្ត។ យើងដើរចូលទៅក្នុងសហគមន៍នៃសេចក្ដីស្រឡាញ់។ យើងចាប់ផ្ដើមចងក្រងចំណងទាក់ទងជាមួយអស់អ្នក ដែលទទួលយកដំណឹងល្អ ហើយចង់រស់នៅតាមដំណឹងនេះ។

**ដោយសារអគ្គសញ្ញាលាបថ្វាស** យើងទទួលព្រះវិញ្ញាណព្រះគ្រីស្តយ៉ាងពេញបរិបូរណ៍។ យើងអាចដើរតាមព្រះអង្គ និងផ្ទុកវត្តមានរបស់ព្រះអង្គក្នុងចិត្តយើង។ យើងទៅជាមនុស្សពេញវ័យនៅក្នុងព្រះសហគមន៍។ យើងទទួលខុសត្រូវឲ្យសហគមន៍គ្រីស្តបរិស័ទរីកចម្រើន។

សហគមន៍នេះ ប្រព្រឹត្តទៅនៅក្នុងអគ្គសញ្ញាអរព្រះគុណ។ នៅទីនោះ ព្រះយេស៊ូប្រមូលផ្ដុំមនុស្សទាំងឡាយជាព្រះកាយតែមួយ ដោយបូជាព្រះជន្មទាំងស្រុងឲ្យយើងរាល់គ្នា។ បន្តិចម្ដងៗ មនុស្សចូលក្នុងអង្គព្រះជាម្ចាស់។ យើងមានជីវិត ដោយសារព្រះយេស៊ូ យើងបណ្ដោយខ្លួនឲ្យព្រះអង្គចាប់យកចិត្តយើង។

ហេតុការណ៍ដ៏ធំធេងទាំងនោះ ចាប់ផ្ដើមឡើងនៅក្នុងចិត្តគ្រីស្តបរិស័ទម្នាក់ៗ ដោយសារអគ្គសញ្ញាជ្រមុជទឹក ហេតុការណ៍នេះ រីកដុះដាល ហើយមានកម្លាំងមាំមួន ដោយសារអគ្គសញ្ញាលាបថ្វាស...ហេតុការណ៍នោះទទួលបានភាពល្អឥតខ្ចោះយ៉ាងខ្ពង់ខ្ពស់បំផុត ដោយអគ្គសញ្ញាអរព្រះគុណ (សន្ដ:យូហាន អើដ)។

«ពេលយើងជាគ្រីស្តបរិស័ទ យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងជាបងប្អូនរបស់ព្រះយេស៊ូគ្រីស្ត យើងជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ »

ពេលយើងជាគ្រីស្តបរិស័ទ យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយមានព្រះបិតាតែមួយជាមួយព្រះយេស៊ូគ្រីស្ត ដែលជាព្រះបុត្រាតែមួយរបស់ព្រះអង្គ៖ អស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេ អាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (យហ ១,១២)។ ព្រះសង្គ្រោះយើងមានព្រះបន្ទូលថា៖ ខ្ញុំឡើងទៅឯព្រះបិតាខ្ញុំ ដែលជាព្រះបិតារបស់អ្នករាល់គ្នា (យហ ២០,១៧)។ សន្តៈយ៉ូហានមានប្រសាសន៍ថា៖ សូមគិតមើល៍ ព្រះបិតាមានព្រះហឫទ័យស្រឡាញ់យើងខ្លាំងដល់កម្រិតណា គឺព្រះអង្គស្រឡាញ់យើងរហូតដល់ទៅហៅយើងថា ជាបុត្រធីតារបស់ព្រះអង្គ ហើយយើងពិតជាបុត្រធីតារបស់ព្រះអង្គមែន! (១យហ ៣,១)។ព្រះជាម្ចាស់ជាព្រះបង្កើត ជាសារជាតុដើម ជាព្រះមហាក្សត្រ ជាម្ចាស់ជីវិតរបស់យើង ហើយយើងជាសត្វលោកដែលព្រះអង្គបង្កើត យើងជាស្នាព្រះហស្តរបស់ព្រះអង្គ យើងជាប្រជារាស្ត្រ និងជាអ្នកបម្រើព្រះអង្គ។ ប៉ុន្តែដោយសារយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក យើងទទួលកំណើតជាសត្វលោកថ្មី យើងមានជីវិតរបស់ព្រះជាម្ចាស់ផ្ទាល់ ព្រះអង្គក៏ជាព្រះបិតារបស់យើង យើងជាបុត្រធីតារបស់ព្រះអង្គ ហើយយើងអាចនិយាយទូលព្រះអង្គថា៖ ឱ!ព្រះបិតាយើងខ្ញុំដែលគង់នៅស្ថានបរមសុខ!

**ដូច្នេះហើយបានជា៖**

**១**- ដោយពួកយើងបានចេញមកពីព្រះឱរព្រះជាម្ចាស់ ជាព្រះបិតាយើង ដោយសារកំណើតថ្មីនេះ យើងក៏អាចរស់នៅទីនោះជារៀងរហូត ហើយព្រះអង្គចាំបាច់ត្រូវតែបីបមយើងក្នុងព្រះឱរព្រះអង្គជានិច្ចតរៀងទៅ។ បើមិនដូច្នោះទេ បើមានពេលមួយ ព្រះអង្គលែងបីបមយើងនៅពេលនោះ យើងនឹងបាត់បង់ជីវិតថ្មី ដែលយើងបានទទួលពីព្រះអង្គ នៅពេលដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹកហើយ។

**២**- យើងជាបងប្អូនប្រុសស្រីរបស់ព្រះយេស៊ូគ្រីស្ត មកពីព្រះលោហិត និងពូជពង្សជាព្រះមហាក្សត្រ និងជាព្រះជាម្ចាស់របស់ព្រះអង្គ ហើយយើងចូលជាព្រះញាតិវង្សរបស់ព្រះអង្គ។ ហេតុនេះ គ្រីស្តបរិស័ទដែលជាមនុស្សថ្មី និងជាសត្វលោកថ្មី ហើយដែលកើតចេញតែពីព្រះជាម្ចាស់ មិនស្គាល់ព្រះញាតិវង្សណា ក្រៅអំពីព្រះយេស៊ូគ្រីស្ត ឬព្រះបិតាណា ក្រៅពីព្រះជាម្ចាស់ឡើយ៖ កុំហៅនរណាម្នាក់នៅលើផែនដីនេះថា “ព្រះបិតា” ឲ្យសោះ (មថ ២៣,៩)។ សន្តៈប៉ូលមានប្រសាសន៍ថា៖ យើងឈប់រាប់នរណាម្នាក់ តាមរបៀបលោកីយ៍ទៀតឡើយ (២ករ ៥,១៦) ហើយព្រះអម្ចាស់នៃយើងមានព្រះបន្ទូលថា៖ អ្នកដែលកើតពីព្រះវិញ្ញាណវិញ មានព្រះវិញ្ញាណក្នុងខ្លួន (យហ ៣,៦)។

**៣**- ពួកយើងជាអ្នកទទួលមរតករួមជាមួយព្រះបុត្រាព្រះជាម្ចាស់ និងជាអ្នកទទួលមរតកពីព្រះជាម្ចាស់។ ឱ! អស្ចារ្យណាស់! ស័ក្តិសមណាស់! ឱ! គ្រីស្តបរិស័ទមានឋានៈឧត្តុង្គឧត្តម! ចូរយើងលែងដើរតាមមារសាតាំងទៅ ចូរយើងថ្វាយខ្លួនចំពោះព្រះជាម្ចាស់ ដោយមានបំណងដ៏ធំមួយ គឺពីពេលនេះទៅយើងរស់នៅជាបុត្រធីតាពិតប្រាកដនៃព្រះជាម្ចាស់ កុំធ្វើឲ្យខូចពូជពង្សយើង កុំបន្ទាបបន្ថោកព្រះបិតាយើង។

គ្រីស្តបរិស័ទម្នាក់ជាសមាជិករបស់ព្រះយេស៊ូគ្រីស្ត។ ហេតុនេះហើយ យើងមានសម្ពន្ធមេត្រីមួយ និងរួបរួមជាមួយព្រះយេស៊ូគ្រីស្តតាមរបៀបដ៏ឧត្តុង្គឧត្តមជិតស្និទ្ធគ្រប់លក្ខណៈ ជាងអវយវៈនៃរាងកាយរបស់មនុស្សមានជាមួយក្បាល។

ហេតុនេះហើយបានជា៖

១- យើងជាកម្មសិទ្ធិរបស់ព្រះយេស៊ូគ្រីស្ត ដូចជាអវយវៈចំពោះក្បាល

២- យើងពឹងផ្អែកទាំងស្រុងទៅលើព្រះអង្គ ដូចអវយវៈចំពោះក្បាល

៣- យើងរួមរស់ជាមួយព្រះអង្គ ដូចអវយវៈចំពោះក្បាល។

ចូរយើងថ្វាយខ្លួនចំពោះព្រះយេស៊ូគ្រីស្ត ហើយសន្យាថា នឹងរស់នៅជាមួយព្រះអង្គ ចាប់ពីពេលនេះតទៅ ដ្បិតជាការអាក្រក់ខ្លាំងណាស់ ចំពោះអវយវៈមានជីវិតរស់នៅខុសពីក្បាល។ ហេតុនេះហើយ សន្តៈ ក្រេគ័រ នៅនីស មានប្រសាសន៍ថា គ្រីស្តបរិស័ទ គឺជាម្នាក់ដែលសន្យាថា នឹងរស់ដោយព្រះជន្មផ្ទាល់របស់ព្រះយេស៊ូគ្រីស្ត។

គ្រីស្តបរិស័ទម្នាក់ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ សន្តៈប៉ូលមានប្រសាសន៍ថា៖ បងប្អូនមិនដឹងទេឬថា រូបកាយរបស់បងប្អូនជាព្រះវិហាររបស់ព្រះវិញ្ញាណ? (១ករ ៦,១៩) ហើយដោយសារបងប្អូនជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រះអង្គបានចាត់ព្រះវិញ្ញាណនៃព្រះបុត្រាព្រះអង្គ ឲ្យយាងមកក្នុងចិត្តបងប្អូន (កាឡ ៤,៦)។ ព្រះជាម្ចាស់បានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យមកយើង ដើម្បីឲ្យទៅជាវិញ្ញាណនៃវិញ្ញាណរបស់យើង ចិត្តនៃចិត្តរបស់យើង និងព្រលឹងនៃព្រលឹងរបស់យើង ហើយដើម្បីឲ្យព្រះវិញ្ញាណគង់នៅជាមួយយើងជានិច្ច និងនៅក្នុងខ្លួនយើងដូចជាព្រះវិហាររបស់ព្រះអង្គ។

ចូរយើងនឹកគិតដល់សេចក្តីពិតទាំងនេះ ហើយចូរយើងចារឹកទុកសេចក្តីពិតនេះ នៅក្នុងចិត្តយើងគ្រប់គ្នា ដើម្បីជំរុញខ្លួនយើងឲ្យថ្វាយព្រះពរ និងស្រឡាញ់ព្រះជាម្ចាស់ ចំពោះការសន្តោសប្រណីជាអនេក ដែលព្រះអង្គបានប្រទានឲ្យយើងទៅជាគ្រីស្តបរិស័ទ។ ត្រូវស្អប់ខ្ពើមនូវការមិនចេះដឹងគុណ និងអំពើបាបរបស់យើង ដែលបានប្រព្រឹត្តកន្លងមក ហើយចាប់ពីពេលនេះទៅ យើងត្រូវណែនាំជីវិតយើងឲ្យស័ក្តិសមនឹងភាពល្អឥតខ្ចោះគ្រប់លក្ខណៈរបស់ព្រះបិតាដែលយើងជាបុត្រធីតា។ ចូរឲ្យយើងស័ក្តិសមនឹងអ្នកណែនាំដ៏វិសុទ្ធរបស់យើង... ស័ក្តិសមទៅតាមភាពដ៏បរិសុទ្ធនៃព្រះវិញ្ញាណដែលយើងជាព្រះវិហារ។

ក្រោយពីបានសម្លឹងមើលយ៉ាងយូរអំពី «អច្ឆរិយភាព ដែលជាខ្លួនខ្ញុំ» សញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងជីវិតខ្ញុំ សម្ពន្ធមេត្រី និងភក្តីភាពរបស់ព្រះអង្គ សេចក្តីស្រឡាញ់ ដែលព្រះអង្គប្រទានមកខ្ញុំ ខ្ញុំសូមអរព្រះគុណព្រះអង្គជាអនេក។

## ទុកពេល សម្រាប់ការលើកលែងទោស

១- ឥឡូវនេះដល់ពេលត្រូវគិតប្លឹងថ្លែងឡើងវិញ។ ក្នុងជីវិតយើងជាអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក តើយើងជួបការលំបាកណាខ្លះ? ប្រៀបធៀបទៅនឹងពាក្យពេចន៍ ដែលសន្តៈយ៉ូហាន អើដ យកមកប្រើ ដូចជាពាក្យសម្ពន្ធមេត្រី ប្រកាសជំនឿលើព្រះយេស៊ូ សូមរិះគិតអំពីការលំបាកទាំងនោះ ដែលយើងជួបប្រទះ។

២- ដោយមើលឡើងវិញនូវផ្លូវ ដែលយើងបានដើរប៉ុន្មានខែកន្លងមកនេះ សូមរិះគិតអំពីរបៀបរស់នៅជាគ្រីស្តបរិស័ទរបស់យើង។ អ្វីដែលជាការលំបាក អ្វីដែលយើងបានផ្លាស់ប្តូរ អ្វីដែលយើងត្រូវផ្លាស់ប្តូរថែមទៀត។

ខ្ញុំក្រាបថ្វាយបង្គំតាមសម្រួល ចំពោះវត្តមានរបស់ព្រះជាម្ចាស់...ខ្ញុំទទួលស្គាល់ថា ខ្ញុំមិនមែនអ្នកណាដែលខ្ញុំចង់ទៅជា...ឬដែលព្រះជាម្ចាស់មានព្រះហឫទ័យចំពោះខ្ញុំ។ ខ្ញុំទូលអង្វរសូមព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ ដែលមិនបានទុកព្រះអង្គឲ្យយាងចូលក្នុងចិត្តខ្ញុំ...ខ្ញុំដែលបង្កើតឧបសគ្គកុំឲ្យព្រះអង្គរីកចម្រើនក្នុង

ខ្លួនខ្ញុំ...ខ្ញុំដែលមិនបណ្ដោយខ្លួនឲ្យរួមជាមួយព្រះយេស៊ូ ក្នុងការថ្វាយខ្លួនចំពោះព្រះជាម្ចាស់។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- នៅយប់ថ្ងៃបុណ្យចម្លង គ្រីស្ដបរិស័ទមិនយល់ស្របនឹងរបៀបរស់នៅខ្លះ ហើយយល់ស្របនឹងរបៀបរស់នៅខ្លះផ្សេងទៀត៖ សូមចោទសួរថា៖ ក្នុងការរស់នៅសព្វថ្ងៃនេះ តើមានអ្វីខ្លះត្រូវប្រាប់ថាទេ? ហើយអ្វីខ្លះដែលខ្ញុំត្រូវថាព្រម?

២- តើព្រះជាម្ចាស់បានប្រគល់យើងនូវបេសកកម្មណាខ្លះ នៅពេលដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបប្រេង? តើខ្ញុំអាចអនុវត្តអគ្គសញ្ញាជ្រមុជទឹកយ៉ាងដូចម្ដេច?

៣-ឥឡូវនេះ សូមអធិដ្ឋានតាមសម្រួលជាមួយនឹងពាក្យពេចន៍ ដែលសន្ដៈយ៉ូហាន អើដ ជូនយើង៖

ឱព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាបុត្រមនុស្ស ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះអង្គ ដែលមានកំណើតអស់កល្បជានិច្ច និងមានកំណើតនៅលើលោកីយ៍នេះ...ព្រះអង្គមានព្រះបំណងបញ្ជូនព្រះជន្មដ៏វិសុទ្ធនៃស្ថានបរមសុខមកប្រគល់ឲ្យខ្ញុំម្ចាស់ ហើយចារឹកជាប់នឹងរូបខ្ញុំម្ចាស់នូវលក្ខណៈរបស់ព្រះអង្គ។ សូមប្រណីឲ្យខ្ញុំម្ចាស់ទៅជាបុត្រធីតារបស់ព្រះអង្គ ដូចជាព្រះយេស៊ូគ្រីស្ដមួយអង្គទៀត...សូមព្រះអង្គមេត្តាប្រព្រឹត្តយ៉ាងណាឲ្យខ្ញុំម្ចាស់ទៅជារូបតំណាងព្រះអង្គផ្ទាល់ផង...សូមឲ្យខ្ញុំម្ចាស់បានគ្របដណ្ដប់ដោយព្រះអង្គ និងគុណសម្បត្តិរបស់ព្រះអង្គទាំងស្រុងផង...សូមព្រះអង្គប្រែខ្ញុំម្ចាស់ឲ្យទាល់តែគេមើលមកខ្ញុំម្ចាស់ថា ជាព្រះយេស៊ូឲ្យគេមើលឃើញតែព្រះអង្គ ឃើញតែព្រះហឫទ័យសុភាពរាបសា ស្លូតបូត សប្បុរស និងពោរពេញទៅដោយ សេចក្ដីស្រឡាញ់របស់ព្រះអង្គតែប៉ុណ្ណោះ...ដោយហេតុថា ព្រះអង្គមានព្រះហឫទ័យឲ្យខ្ញុំម្ចាស់ទៅជាព្រះជាម្ចាស់មួយអង្គទៀតនៅលើផែនដីនេះ។

**ខ្ញុំបញ្ជាក់ថា ខ្ញុំចង់អនុវត្តតាមអគ្គសញ្ញាជ្រមុជទឹករបស់ខ្ញុំ ដោយសរសេរអំពី៖**

- អ្វីៗដែលខ្ញុំបោះបង់ចោល
- អ្វីដែលខ្ញុំជាប់ចិត្ត។
- ខ្ញុំថ្វាយខ្លួនចំពោះព្រះវិញ្ញាណរបស់ព្រះយេស៊ូ ដើម្បីឲ្យព្រះយេស៊ូយាងមកក្នុងគ្រប់សម្ដីនិងគ្រប់កិច្ចការរបស់ខ្ញុំ។
- ព្រះយេស៊ូដែលបានទទួលអ្វីៗទាំងអស់ពីព្រះបិតា ហើយដែលបញ្ជូនអ្វីៗទាំងអស់ទៅឯព្រះបិតាវិញ។

# ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលខ្លួនឯង

គឺដោយសារកិច្ចការនេះ ដែលព្រលឹងបានរស់ឡើងវិញ
ហើយដែលព្រះយេស៊ូគ្រីស្តចាប់កំណើតជាថ្មី នៅក្នុងព្រលឹងទាំងនោះ!

## ដំណាក់កាលទី ១៨

យើងសូមអង្វរបងប្អូនក្នុងព្រះនាមព្រះគ្រីស្តថា
ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលបងប្អូនឲ្យជានានឹងព្រះអង្គវិញទៅ (១ករ ៥,២០)!

**ដំណាក់កាលនេះមាន ៖** អំពើបាបតែងតែផ្តាច់សម្ពន្ធមេត្រី ដែលព្រះជាម្ចាស់បានចងជាមួយគ្រីស្តបរិស័ទ នៅពេលដែលគេបានទទួលអគ្គសញ្ញាជ្រមុជទឹក៖
- ដោយគ្រីស្តបរិស័ទនោះ បដិសេធមិនព្រមទទួលព្រះបំណងរបស់ព្រះជាម្ចាស់
- ដោយគ្រីស្តបរិស័ទនោះ ជ្រើសរើសរឿងលោកីយ៍ និងគោរពព្រះក្លែងក្លាយ
- ដោយគ្រីស្តបរិស័ទនោះ គិតតែពីខ្លួនឯង...

យើងត្រូវកែប្រែចិត្តគំនិត ឲ្យវិលមករកព្រះជាម្ចាស់វិញ...ដោយស្វែងរកព្រះហឫទ័យរបស់ព្រះអង្គ...ដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះយេស៊ូ ដើម្បីឲ្យយើងអាចចុះកិច្ចសន្យាជាថ្មីបាន។

តើមានទីសម្គាល់អ្វី? គឺមានការលើកលែងទោសរបស់ព្រះជាម្ចាស់ ដែលព្រះអង្គប្រោសប្រទាននៅក្នុងព្រះសហគមន៍ (អគ្គសញ្ញាសម្រុះសម្រួល)។ ទុកឲ្យព្រះគ្រីស្តសម្រុះសម្រួលយើង ហើយចុះកិច្ចសន្យាជាថ្មីតាមរបៀបជាក់ស្តែង។

**គោលដៅនៃដំណាក់កាល ៖** ទទួលស្គាល់ថាខ្លួនជាអ្នកបាប ដែលព្រះជាម្ចាស់បានលើកលែងទោស៖
- យល់ឃើញឲ្យច្បាស់អំពីអំពើបាបក្នុងជីវិតរបស់ខ្ញុំ
- លើកលែងទោសឲ្យខ្លួនឯង នឹងអ្នកឯទៀត
- ការគិតដល់អគ្គសញ្ញាលើកលែងទោស។ ទីបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចព្រមព្រៀងទទួលអគ្គសញ្ញាលើកលែងទោស។

### ទុកពេល សម្រាប់បើកចិត្ត និងទទួល

១-តើយើងធ្លាប់លើកលែងទោសឲ្យគេ? តើគេធ្លាប់លើកលែងទោសឲ្យយើងឬទេ? សូមរកពេលណាខ្លះ ដែលយើងផ្សះផ្សាជាមួយអ្នកដទៃ...ជាមួយខ្លួនឯង...សូមរកពេលណាមួយនោះមកគិត ដើម្បីព្យាយាមកត់សម្គាល់ដំណាក់កាលនីមួយៗ នៃការផ្សះផ្សា។

២- ក្នុងពេលដែលអានប្រវត្តិឡើងវិញនេះ យើងមុខជាបានជួបប្រទះនូវទិដ្ឋភាព ដែលមានសភាពផ្ទុយ

ក្នុងចិត្តយើងវិជ្ជមាន និងអវិជ្ជមាន ភាពងងឹត និងពន្លឺ...ត្រូវតែប្រឈមមុខនឹងការពិត និងទទួលស្គាល់ខ្លួនឯង...

៣- បើសិនជានៅដំណាក់កាលណាមួយយើងសម្គាល់ឃើញថា យើងបិទចិត្តយើងត្រូវកត់ទុក...សូមកុំស្វែងរកហេតុផលមកដោះសារ ឬព្យាយាមដោះស្រាយ...ក្នុងពេលដំណាក់កាលនេះ ផ្លូវផ្សេងៗទៀតអាចបើកចំហចំពោះយើង។ សូមបំរុងខ្លួនទទួលហេតុការណ៍ឥតព្រៀងទុក ហើយដែលយើងមិនបានរង់ចាំ។

## ក្នុងដំណាក់កាលនេះ ខ្ញុំព្យាយាម៖

- ស្តាប់ជម្រៅចិត្តខ្ញុំ
- បម្រុងខ្លួនប្រឈមមុខតទល់នឹងអ្វីៗ ដែលមករុញច្រានខ្ញុំ
- មិនវិនិច្ឆ័យខ្លួនឯង និងអ្នកដទៃ
- ដឹងខ្លួនអំពីខ្លួនឯង។
- គោលដៅរបស់ខ្ញុំ? សេរីភាពខាងផ្លូវចិត្ត។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- សូមយកទំនុកតម្កើង ៥១...សូមស្ងួតយឺតៗ អានឡើងវិញម្តងទៀតតាមវគ្គនីមួយៗ។ អ្នកនិពន្ធនោះដែលឈឺចុកចាប់ខ្លាំងណាស់ ស្រែកអង្វរកព្រះជាម្ចាស់។ សូមគិតថា សំឡេងនេះជារបស់ខ្លួន...តើខ្ញុំស្រែកអង្វរទៅរកព្រះជាម្ចាស់ដែរឬទេ?

២- នៅក្នុង (លក ១៩,១-១០) «លោកសាខេ» (៧,៣៦-៥០) «ស្ត្រីម្នាក់ដែលបានទទួលការលើកលែងទោស»(១៥,១១-៣២) «កូនវង្វេង» (យហ ៨,១-១១)(ស្ត្រីផិតក្បត់) ព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ជាព្រះបិតាព្រះអង្គ... តើយើងគិតយ៉ាងណាចំពោះអស់អ្នកដែលប្រព្រឹត្តអំពើបាប? សូមសញ្ជឹងគិតអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះគ្រីស្ត។

៣- សន្តៈយ៉ូហាន អើដ ណែនាំយើងឲ្យនឹកគិតដល់ការលើកលែងទោស ដែលព្រះបិតាប្រទានឲ្យយើងនៅក្នុងអង្គព្រះយេស៊ូ នៅពេលព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មី។ ដោយសារអគ្គសញ្ញាជ្រមុជទឹកយើងបានសម្លាប់អំពើបាប ដើម្បីបានរស់នៅតែនៅក្នុងអង្គព្រះជាម្ចាស់ និងព្រះយេស៊ូគ្រីស្ត។ អគ្គសញ្ញាលើកលែងទោសនាំយកអគ្គសញ្ញាជ្រមុជទឹកដូចជាកើតសាជាថ្មី។

អគ្គសញ្ញាលើកលែងទោសជាអ្វីមួយដ៏ចាំបាច់វិសុទ្ធណាស់ ដែលមានប្រយោជន៍ខ្លាំងណាស់ ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងប្រោសព្រលឹងគ្រីស្តបរិស័ទឲ្យបានវិសុទ្ធ លុះត្រាតែយើងទទួលអគ្គសញ្ញានេះជាញឹកញាប់ ដោយបានត្រៀមខ្លួនទុកជាមុន។

ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។ យើងស្លាប់មែន ពីព្រោះសន្តៈប៉ូលមានប្រសាន៍ថា ប្រសិនបើអ្នកណាម្នាក់ស្លាប់ ដើម្បីមនុស្សទាំងអស់នោះមានន័យថា អ្នកទាំងអស់នោះ ត្រូវស្លាប់ទាំងអស់គ្នា (២ករ ៥,១៤) គឺអស់អ្នកដែលរួមជាមួយព្រះអង្គ ដូចជាសមាជិករបស់ព្រះអង្គ ដោយអគ្គសញ្ញាជ្រមុជទឹក។ កាលណាយើងជាសមាជិករបស់មេដឹកនាំម្នាក់ដែលស្លាប់ហើយត្រូវគេឆ្កាង យើងក៏ត្រូវគេឆ្កាង ហើយស្លាប់ចំពោះលោកីយ៍ចំពោះបាបកម្ម និង

ចំពោះខ្លួនយើងដែរ។ យើងមានជីវិតថ្មី ដោយសារអគ្គសញ្ញាជ្រមុជទឹក យើងចាកចេញពីសេចក្តីស្លាប់ ដែលមកពីអំពើបាប ដើម្បីចូលទៅក្នុងជីវិតប្រកបដោយព្រះហឫទ័យប្រោសប្រណី។

**ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។**

១ ដោយសារអគ្គសញ្ញាជ្រមុជទឹក ព្រះយេស៊ូដែលសោយទិវង្គត បានជម្រះបាបរបស់យើង។

១ដូចព្រះយេស៊ូដែលមានព្រះជន្មថ្មីយើងត្រូវរស់នៅតាមរបៀបថ្មី(រម៦,៣៤)។ដូច្នោះទាល់តែមានអគ្គសញ្ញាជ្រមុជទឹក នោះយើងរាល់គ្នាត្រូវតែស្លាប់សិន ទើបអាចមានជីវិតរួមជាមួយព្រះយេស៊ូគ្រីស្ត ដែលជាជីវិតនាស្ថានបរមសុខ ហើយគ្មានអ្នកណាម្នាក់ទៀតទេ ដែលមានរបៀបរស់នៅតាមបែបលោកីយ៍ (ភល ៣,២០)៖ ដោយបងប្អូនទទួលជីវិតថ្មីដែរ រួមជាមួយព្រះគ្រីស្ត ដូច្នេះហើយចូរស្វែងរកអ្វីៗនៅស្ថានលើ ជាស្ថានដែលព្រះគ្រីស្តគង់នៅខាងស្តាំព្រះជាម្ចាស់នោះវិញ។ ចូរគិតពីអ្វីៗដែលនៅស្ថានលើ កុំគិតពីអ្វីនៅលើផែនដីនេះឡើយ (កូឡ ៣,១-២)។

ទីបញ្ចប់ ដោយសារអគ្គសញ្ញាជ្រមុជទឹក យើងត្រូវតែផ្ទៀងផ្ទាត់សម្តីដ៏ល្អឥតខ្ចោះនេះមកខ្លួនយើង៖ បងប្អូនបានស្លាប់ផុតទៅហើយ ហើយជីវិតរបស់បងប្អូនក៏កប់ទុកជាមួយព្រះគ្រីស្ត ក្នុងព្រះជាម្ចាស់ដែរ (កូឡ ៣,៣)។ ត្រូវតែសម្លាប់អ្វីៗដែលមិនមែនមកពីព្រះជាម្ចាស់ ដើម្បីរស់តែក្នុងអង្គព្រះអង្គ និងព្រះយេស៊ូ។ សន្តះប៉ូលមានប្រសាសន៍ថា ដូចអ្នករស់រានមានជីវិតត្រឡប់មកពីស្ថាននៃមនុស្សស្លាប់ (រម ៦,៣) យើងក៏ត្រូវរស់ដូចអ្នកដែលមានជីវិតថ្មីដែរ ដូច្នោះហើយត្រូវរស់នៅលើផែនដីនេះ ដូចនៅស្ថានបរមសុខ មានន័យថា ដោយមានរបៀបរស់នៅដ៏វិសុទ្ធ និងលំអទៅដោយគុណធម៌គ្រប់បែបយ៉ាង ពោរពេញទៅដោយសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ហើយដោយគោរពសរសើរ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

**សន្តះយ៉ូហាន អើដ ណែនាំឲ្យយើងកោតសរសើរព្រះជាម្ចាស់ ដែលបានសម្រុះសម្រួលយើងជាមួយព្រះអង្គវិញ៖**

ពេលព្រះជាម្ចាស់លើកលែងទោសឲ្យយើងរួចពីអំពើបាប ព្រះអង្គប្រព្រឹត្តកិច្ចការដ៏ខ្ពង់ខ្ពស់។ ព្រះជាម្ចាស់ លើកលែងទោសដោយ «ឥតគិតថ្លៃ» ដោយមិនគិតដល់ការបន្ទាបបន្ថោក ដែលអ្នកប្រព្រឹត្តអំពើបាបធ្វើចំពោះព្រះតេជានុភាពដ៏ឧត្តុង្គឧត្តមបំផុតរបស់ព្រះអង្គ។ កិច្ចការដ៏ខ្ពង់ខ្ពស់នេះ ព្រោះអ្នកសារភាពទោសកំហុសដែលខ្លួនបានធ្លាក់ចុះសែនជ្រៅទៅក្នុងអន្លង់ នៃអពមង្គលព្រះជាម្ចាស់ក៏ដកស្រង់អ្នកនោះចេញ ដោយសារព្រះហស្តដ៏ស្រទន់នៃធម៌មេត្តាករុណារបស់ព្រះអង្គ។ កិច្ចការដ៏ខ្ពង់ខ្ពស់នេះ ព្រោះព្រះជាម្ចាស់ប្រោសប្រទានព្រះអំណោយទានដែលមិនអាចកាត់ថ្លៃបាន ព្រះអង្គលើកគេឲ្យមានឋានៈជាមិត្តភក្តិ និងជាបុត្រធីតារបស់ព្រះអង្គថែមទៀត។ កិច្ចការដ៏ខ្ពង់ខ្ពស់នេះ ដោយសាររបៀបដែលព្រះជាម្ចាស់ផ្សះផ្សាយើងជាមួយព្រះអង្គ។ គឺព្រះអង្គទេ ដែលស្រឡាញ់យើងមុន គឺព្រះអង្គទេ ដែលជំរុញយើងឲ្យស្វែងរកព្រះអង្គ និងកែប្រែចិត្តគំនិត។ ព្រះនៃសេចក្តីស្រឡាញ់ ព្រះនៃធម៌មេត្តាករុណានេះ ជាអ្នកដេញតាមពីក្រោយយើង...កាលបើយើងឃ្លាតចេញពីព្រះអង្គ ព្រះអង្គដេញតាមពីក្រោយយើង ដោយមានព្រះហឫទ័យស្រឡាញ់ឥតប្រៀបបាន ហើយអង្វរយើងកុំឲ្យយើងឃ្លាតឆ្ងាយពីអ្នកដែលតាមយើងយ៉ាងប្រញាប់ប្រញាល់...

ឱ! ព្រះយេស៊ូដ៏ប្រសើរខ្ពង់ខ្ពស់អើយ! ខ្ញុំម្ចាស់សូមថ្វាយព្រះពរមួយពាន់ដងចំពោះព្រះអង្គ! សូមឲ្យទេវទូតទាំងអស់ សន្តបុគ្គលទាំងអស់ ព្រះមាតាដ៏វិសុទ្ធរបស់ព្រះអង្គថ្វាយព្រះពរចំពោះព្រះអង្គពីឥឡូវនេះ

តទៅរៀងរហូត ដោយព្រះអង្គបានចាត់ចែងឲ្យមានអគ្គសញ្ញាការលើកលែងទោស ក្នុងព្រះសហគមន៍ព្រះអង្គ និងដោយបានប្រទាននូវមធ្យោបាយមួយ ដែលនៅជានិច្ចងាយស្រួលណាស់ និងមានប្ញទ្ធានុភាពណាស់ ដើម្បីលុបបំបាត់បាបកម្មរបស់យើង ហើយផ្សះផ្សាយើងឲ្យជានានឹងព្រះអង្គវិញ! ដោយសារអគ្គសញ្ញានេះ សូមព្រះអង្គប្រកបដោយព្រះពរ សូមឲ្យសិរីរុងរឿងរបស់ព្រះអង្គកាន់តែថ្កុំថ្កើង រហូតដល់គ្រាអវសាននៃផែនដី! សូមថ្វាយព្រះពរចំពោះព្រះយេស៊ូដែរ ដោយសារសិរីរុងរឿង ដែលព្រះអង្គបានថ្វាយចំពោះព្រះបិតាព្រះអង្គ នៅពេលដែលព្រះអង្គគង់នៅក្នុងសួនដើមអូលីវ ដោយសារភាព និងសោកស្តាយកំហុស ដែលយើងបានប្រព្រឹត្ត! ឱ! ព្រះសង្គ្រោះនៃខ្ញុំម្ចាស់អើយ! សូមមេត្តាប្រោសប្រទានឲ្យខ្ញុំម្ចាស់មានចិត្តស្អប់ខ្ពើមអំពើបាប ហើយសូមព្រះអង្គធ្វើឲ្យខ្ញុំម្ចាស់ស្លាប់មួយពាន់ដង ជាជាងឲ្យខ្ញុំម្ចាស់ប្រព្រឹត្តអំពើបាបក្នុងអនាគតទៅចុះ!

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រោសប្រទានឲ្យខ្ញុំជឿជាក់ថា នៅពេលព្រះគ្រីស្តសោយទិវង្គត និងមានព្រះជន្មថ្មី ព្រះអង្គបានឆក់យកយើងពីសេចក្តីស្លាប់...ក្នុងអត្ថបទផ្សេងៗដែលខ្ញុំបានអាន ខ្ញុំចងចាំអត្ថបទ មួយ... ពាក្យពេចន៍មួយ... ហើយខ្ញុំថ្វាយខ្លួនទៅក្នុងព្រះហស្តព្រះជាម្ចាស់ ដែលមានព្រះបន្ទូលមកខ្ញុំថា៖ ចូរអ្នកបណ្តោយខ្លួនឲ្យផ្សះផ្សាជាមួយខ្ញុំ...សូមកុំចចេសរឹងរូស!...ចូរថ្វាយបង្គំនៅទីស្ងៀមស្ងាត់!

## ទុកពេល សម្រាប់ការលើកលែងទោស

១- ដោយបានសញ្ជឹងគិតអំពីព្រះយេស៊ូដែលទទួលអ្នកបាប...ដែលណែនាំគេឲ្យប្រឈមមុខនឹងសេចក្តីពិត...ដែលសម្តែងធម៌មេត្តាករុណា ចំពោះអស់អ្នកដែលបន្ទាបខ្លួន...សូមឲ្យយើងទទួលស្គាល់ថា យើងជាអ្នកបាប ដើម្បីទទួលការលើកលែងទោស! តើយើងមានបំណងទទួលការលើកលែងទោសនេះឬទេ?...សូមកុំភ្លេចថា ព្រះជាម្ចាស់រង់ចាំយើង!

២- សូមស្មូតទំនុកតម្កើង ៥១ ឡើងវិញ ហើយយល់ឃើញថា សេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់ ខ្លាំងជាងអំពើបាបរបស់យើង។

៣- ព្រះជាម្ចាស់ គឺជាអ្នកដែលលើកលែងទោស ពីព្រោះព្រះអង្គស្រឡាញ់ដោយឥតលក្ខខណ្ឌ...នៅតាមផ្លូវ ដែលយើងត្រូវដើរទៅផ្សះផ្សាជាមួយព្រះអង្គ សូមនឹកគិតដល់អំពីអ្វីៗ ដែលប្រឆាំងនឹងព្រះជាម្ចាស់ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង...សូមបើកចិត្តដើម្បីទទួលព្រះអំណោយទានរបស់ព្រះអង្គ ដូចលោកសាខេ ដូចស្ត្រីផិតក្បត់...

ប្រសិនបើចិត្តគំនិតរបស់យើងដាក់ទោសយើងនោះ ព្រះជាម្ចាស់ដែលធំជាងចិត្តរបស់យើង ទ្រង់ឈ្វេងយល់ទាំងអស់ (១យហ ៣,២០)។

- ខ្ញុំអភ័យទោសឲ្យខ្លួនឯង
- ខ្ញុំទទួលស្គាល់ខ្លួនខ្ញុំ
- ខ្ញុំទទួលការលើកលែងទោសពីព្រះជាម្ចាស់

ខ្ញុំបម្រុងខ្លួនបោះបង់អំពើបាបរបស់ខ្ញុំ ថ្វាយទៅព្រះអង្គ ដើម្បីបានរស់នៅក្នុងអង្គព្រះអង្គ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- សូមស្វែងរកក្នុងជីវិតរបស់យើងថា តើអ្វីដែលមកកាត់ផ្តាច់សម្ពន្ធ័មេត្រី ដែលយើងបានសន្យាជាមួយព្រះជាម្ចាស់នៅថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក គឺជាអំពើបាបដូចជា៖

- បដិសេធមិនព្រមទទួលព្រះបំណងរបស់ព្រះជាម្ចាស់លើជីវិតរបស់ខ្លួន
- គោរពព្រះក្លែងក្លាយ ដូចជាការសប្បាយៗ...
- គិតតែពីខ្លួនឯង...

២- ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យកែប្រែចិត្តគំនិត សុខចិត្តដើរតាមព្រះហឫទ័យព្រះបិតា។

៣- សូមទៅជួបបូជាចារ្យម្នាក់ ដើម្បីចងសម្ពន្ធមេត្រីម្តងទៀតជាមួយព្រះជាម្ចាស់ ដោយសារអគ្គសញ្ញាលើកលែងទោស។

៤- តើយើងសម្រេចចិត្តផ្លាស់ប្តូរអ្វីខ្លះបំពោះព្រះជាម្ចាស់ បំពោះខ្លួនយើងផ្ទាល់ និងបំពោះអ្នកដទៃ?

ដោយសារព្រះជាម្ចាស់ ព្រះគ្រីស្តបានទៅជាព្រះសង្គ្រោះយើង... ព្រះអង្គបានប្រោសយើងឲ្យបានសុចរិត និងបានវិសុទ្ធ។ ព្រះអង្គសោយទិវង្គតដើម្បីយើង ដើម្បីកុំឲ្យមនុស្សលោកមានជីវិតដើម្បីតែខ្លួនឯង ប៉ុន្តែដើម្បីឲ្យគេរស់នៅដើម្បីព្រះអង្គ ដែលបានសោយទិវង្គត ហើយមានព្រះជន្មថ្មីដើម្បីគេ។

ព្រះអម្ចាស់យេស៊ូអើយ! សូមព្រះអង្គសោយរាជ្យលើពួកយើងផង...

ព្រះជាម្ចាស់ដ៏មានតេជានុភាពសព្វប្រការ និងពោរពេញទៅដោយព្រះហឫទ័យមេត្តាករុណាអើយ! សូមព្រះអង្គបំផ្លាញនៅក្នុងខ្លួនយើង នូវអ្វីៗដែលប្រឆាំងនឹងព្រះអង្គ សូមព្រះអង្គធ្វើជាម្ចាស់នៃចិត្តគំនិត និងរូបរាងកាយរបស់យើងផង ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គបានគ្រប់លក្ខណៈផង។

# សុភមង្គលដ៏ពិតប្រាកដ

ខ្ញុំលែងចង់បាននូវអ្វីៗទៀត ខ្ញុំសូមតែឲ្យព្រះយេស៊ូគាប់ព្រះហឫទ័យជានិច្ច!

## ដំណាក់កាលទី ១៩

ចូរអ្នកជ្រើសរើសយកជីវិត (ទក ៣០,១៩)

**ក្នុងដំណាក់កាលនេះមាន ៖** ពេលយើងទុកឲ្យព្រះគ្រីស្តសម្រុះសម្រួលនឹងយើង ដោយសុខចិត្តគាប់ព្រះហឫទ័យព្រះបិតា យើងជ្រើសរើសយកជីវិត ទៅតាមដំណឹងល្អរបស់ព្រះយេស៊ូផ្ទាល់។ នេះជាសុភមង្គលដ៏ពិតប្រាកដ។

សុភមង្គលនេះ ជាផ្លូវនៃជីវិត ប៉ុន្តែជាផ្លូវចង្អៀត ដែលមានជំរាលជ្រោះជ្រៅ។ សុភមង្គលនេះ មិនមែនជាការសន្សំបុណ្យកុសលទេ...តាមសុភមង្គលនេះ ព្រះជាម្ចាស់យាងមកជិតយើង ព្រះអង្គយាងមក ដោយគ្មាននរណាបង្ខំព្រះអង្គទេ ព្រះអង្គយាងមកដោយមិនគិតថ្លៃទេ...សូមឲ្យអស់អ្នកដែលដាក់ចិត្តជាអ្នកក្រខ្សត់...ដែលហ៊ានស៊ូប្តូរជីវិតរបស់ខ្លួនឯង បានប្រកបដោយសុភមង្គលនេះ។

**គោលដៅនៃដំណាក់កាលនេះ ៖** ជ្រើសរើសយកសុភមង្គលតាមព្រះគ្រីស្ត។

- សូមបញ្ជាក់ប្រាប់អំពីសុភមង្គលដោយបទពិសោធន៍ផ្ទាល់ខ្លួន។
- សូមស្រាវជ្រាវរកចំណុចណា ដែលជារចនាសម្ពន្ធនៃសុភមង្គល (ច្បាប់ វិន័យ សីលធម៌ ទម្លាប់...)។
- យល់ឃើញអំពីអ្វី ដែលយើងត្រូវតែជ្រើសរើសយក ឬបដិសេធមិនព្រមទទួល ដើម្បីបានសុភមង្គលនេះ។
- ផ្សព្វផ្សាយសុភមង្គលដែលស្ថិតនៅក្នុងចិត្តយើង។ ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចផ្ទៀងផ្ទាត់ថា តើខ្ញុំចង់បានសុភមង្គលបែបណា?

## ទុកពេលសម្រាប់ បើកចិត្ត និងទទួល

១- សួស្តីឆ្នាំថ្មី! រីករាយថ្ងៃកំណើត! ពិធីបុណ្យដ៏រីករាយ!... កាលដែលយើងប្រារព្ធពាក្យជូនពរដល់អ្នកដែលយើងស្រឡាញ់ តើយើងជូនពរឲ្យពួកគេបានសុភមង្គលបែបណា? និយាយឲ្យច្បាស់ក្រៅពីពាក្យធម្មតា តើយើងជូនពរឲ្យពួកគេបានសម្រេចនូវអ្វីខ្លះ?

២- ប៉ុន្មានខែកន្លងមកនេះ តើវេលាណាខ្លះ ដែលយើងមានសុភមង្គល? ជាសុភមង្គលបានទទួលពីគេ? ជាសុភមង្គលដែលយើងឲ្យគេ? ដោយសារការលំបាកលំបិនណាខ្លះ?...

៣- តើយើងបានជួបមនុស្សដែលមានគំនិតយល់អំពីសុភមង្គលខុសប្លែកពីយើងឬទេ? តើយើងបានយល់ឃើញអ្វីខ្លះ នៅពេលដែលយើងប្រាស្រ័យទាក់ទងជាមួយពួកគេ?

៤- ក្រោយពីបានពិនិត្យឃើញហើយ សូមធ្វើបញ្ជីមួយដែលមានដប់ចំណុច ឬលើសពីនេះ «ចំពោះខ្ញុំ ថ្ងៃនេះ សុភមង្គល គឺជា...» ហើយម៉្យាងទៀត « ចំពោះខ្ញុំថ្ងៃនេះ សុភមង្គលមិនមែនជា...»

៥- តាមគម្រោងការនៃសុភមង្គលនេះ តើមនសិការ សេរីភាព សីលធម៌ មតិរបស់អ្នកដទៃ...សំខាន់យ៉ាងដូចម្តេច?

ខ្ញុំស្តាប់ទៅក្នុងចិត្តខ្ញុំថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យស្វែងរកសុភមង្គលពិតប្រាកដ។ ខ្ញុំទទួលយកបំណងរបស់ខ្ញុំឲ្យរស់នៅយ៉ាងបរិបូរណ៍ដូចការត្រាស់ហៅព្រះជាម្ចាស់។ ខ្ញុំជឿទុកចិត្តលើព្រះអម្ចាស់ ដើម្បីឲ្យជីវិតខ្ញុំបានជោគជ័យ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- ក្នុងព្រះគម្ពីរ ជាភាសាហេប្រឺ ពាក្យ «រីករាយ» ជាពាក្យពហុវចនៈ។ ដោយបានអានទំនុកតម្កើងនានា យើងអាចរកឃើញដំណឹងល្អមួយសម្រាប់អស់អ្នកដែលស្រេកឃ្លានសុភមង្គល (ឧទាហរណ៍ ទន ១,៤,៣៤, ៤០,៤១,៨៤,១០៦, ១២៨)។ សុភមង្គលរស់នៅជាមួយបងប្អូន (ទន ៣៣; ១៤៤)...សូមកត់ត្រានូវសុភមង្គលតាមទំនុកតម្កើងនោះ។

២-ព្រះយេស៊ូហៅខ្លួនព្រះអង្គថា ជាព្រះសង្គ្រោះនៅពេលដែលព្រះអង្គប្រកាសអំពី «សុភមង្គលពិតប្រាកដ»។ សូមអាន និងប្រៀបធៀបដំណឹងល្អតាម (មថ ៥,១-១២) និង (លក ៦,២០-២៦)។ តើមានអ្វីដែលថ្មីទាក់ទងនឹងទំនុកតម្កើង? សូមស្ទឹងស្មាធិ៍ទៅដល់ដំណឹងល្អរបស់ព្រះយេស៊ូ ហើយសួរខ្លួនឯងថា តើសុភមង្គលណាដែលជាពន្លឺសម្រាប់ខ្ញុំ និងទាក់ទាញចិត្តខ្ញុំ?

៣-ព្រះយេស៊ូសម្តែងឲ្យស្គាល់ និងប្រទានសុភមង្គលទៅដល់អស់អ្នក ដែលទទួលព្រះអង្គ។ សូមរកនៅក្នុងដំណឹងល្អតាមសន្តៈលូកានូវអ្វីៗ ដែលអាចមានន័យថា សុភមង្គល អំណរសប្បាយ ការសង្គ្រោះពេញបរិបូរណ៍... តាមរយៈព្រះបន្ទូល និងការជួបរបស់ព្រះយេស៊ូ? ដំណឹងល្អណាខ្លះសម្រាប់ខ្លួនយើងផ្ទាល់?

៤- នៅបុណ្យរំឭកទៅដល់សន្តបុគ្គលទាំងអស់ ព្រះសហគមន៍ប្រកាសនូវសុភមង្គលពិតប្រាកដ។ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យទៅជាជនដ៏វិសុទ្ធ (សន្តបុគ្គល)៖ តើការត្រាស់ហៅនេះ អាចផ្តល់សុភមង្គលបានឬទេ?

## សន្តៈយ៉ូហាន អើដ

សូមស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលមានព្រះបន្ទូលមកយើង តាមរយៈគ្រីស្តទូតរបស់ព្រះអង្គថា៖ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺឲ្យបងប្អូនបានវិសុទ្ធ (១ ថស ៤,៣)។

ប្រហែលជាអ្នករាល់គ្នានឹងប្រាប់ខ្ញុំថា ព្រះបន្ទូលនេះ មានតែសម្រាប់អស់អ្នកដែលនៅក្នុងអារាមផ្សេងៗ។ ចំពោះរឿងនេះ ខ្ញុំអាចឆ្លើយតបប្រាប់អ្នករាល់គ្នាថា ជាការពិតហើយដែលអ្នកបួសត្រូវតែជាវិសុទ្ធ ហើយធ្វើជាគំរូគឺជាមុខងាររបស់ពួកលោក។ ម៉្យាងទៀត ពួកលោកមានមធ្យោបាយគ្រប់សព្វ ដើម្បីទៅជាសន្តបុគ្គល។ ប៉ុន្តែអ្នកណាក៏ដោយដែលបានទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ ត្រូវតែទៅជាជនដ៏វិសុទ្ធ ដោយមានមូលហេតុជាច្រើន៖

- ១ ជនដ៏វិសុទ្ធ ពីព្រោះគេមានឈ្មោះថា ជាគ្រីស្តបរិស័ទ ដែលជាឈ្មោះដ៏វិសុទ្ធណាស់។ ជនដ៏វិសុទ្ធ ពីព្រោះគេជាបុត្ររបស់ព្រះដ៏វិសុទ្ធបំផុត ជាគ្រឹះនៃភាពវិសុទ្ធ។
- ១ ជនដ៏វិសុទ្ធ ពីព្រោះដោយអគ្គសញ្ញាជ្រមុជទឹកដ៏វិសុទ្ធ គេបានទទួលព្រះហឫទ័យសន្តោសប្រណីរបស់ព្រះជាម្ចាស់ ដែលប្រោសឲ្យគេចូលរួមចំណែក ក្នុងភាពដ៏វិសុទ្ធរបស់ព្រះអង្គ (២ ស ១,៤)។
- ១ ជនដ៏វិសុទ្ធ ពីព្រោះដោយសារអគ្គសញ្ញាជ្រមុជទឹក គេជាសមាជិកមេដឹកនាំម្នាក់ ដែលជាជនដ៏វិសុទ្ធបំផុត ក្នុងចំណោមជនដ៏វិសុទ្ធទាំងឡាយ ហើយជាអវយវៈរបស់ព្រះកាយដ៏វិសុទ្ធនៃព្រះយេស៊ូគ្រីស្ត គឺព្រះសហគមន៍ដ៏វិសុទ្ធ។
- ១ ជនដ៏វិសុទ្ធ ពីព្រោះព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកណែនាំគេ។ ហេតុនេះហើយ សន្តៈប៉ូល ស្រែកថា៖ អ្នកដែលគ្មានព្រះវិញ្ញាណរបស់ព្រះយេស៊ូគ្រីស្តទេ អ្នកនោះមិនមែនជាកម្មសិទ្ធិរបស់ព្រះអង្គឡើយ (រម ៩, ៨)។
- ១ ជនដ៏វិសុទ្ធ ពីព្រោះគេបានទទួលព្រះយេស៊ូគ្រីស្ត៖ បងប្អូនទាំងអស់គ្នាបានទទួលពិធីជ្រមុជទឹក ដើម្បីឲ្យបានរួមជាមួយព្រះគ្រីស្ត បងប្អូនក៏មានព្រះគ្រីស្តនៅជាប់ជាមួយដែរ (កាឡ ៣,២៧)។
- ១ ជនដ៏វិសុទ្ធ ពីព្រោះគេត្រូវតែបានថែបំប៉នចំណី ដែលវិសុទ្ធណាស់ និងដែលមកពីព្រះជាម្ចាស់ គឺជាព្រះកាយ និងព្រះលោហិតដ៏ថ្លៃថ្លារបស់ព្រះបុត្រាព្រះអង្គ។
- ១ ជនដ៏វិសុទ្ធ ពីព្រោះគេជាបុត្រធីតានៃព្រះរាជនីរបស់ជនដ៏វិសុទ្ធទាំងអស់។
- ១ ជនដ៏វិសុទ្ធ ពីព្រោះគេក៏ជាបុត្រធីតារបស់សន្តបុគ្គលទាំងឡាយ គឺជាបុព្វបុរស ព្យាការី គ្រីស្តទូត និងសន្តបុគ្គលឯទៀត ដែលបានជួយឲ្យគេកើតក្នុងអង្គព្រះវិញ្ញាណ។ យើងទាំងអស់ជាបុត្រធីតារបស់សន្តបុគ្គលទាំងឡាយ។
- ១ ជនដ៏វិសុទ្ធ ពីព្រោះគេរៀនសូត្រក្នុងសាលាដ៏វិសុទ្ធមួយ ហើយគេសន្យាថា នឹងប្រតិបត្តិតាមវិន័យដ៏វិសុទ្ធ។
- ១ ជនដ៏វិសុទ្ធ ពីព្រោះព្រះជាម្ចាស់បានជ្រើសតាំងយើងនៅក្នុងអង្គព្រះបុត្រាព្រះអង្គ ដើម្បីឲ្យទៅជាសន្តបុគ្គលចំពោះព្រះភ័ក្ត្រព្រះអង្គ តាំងពីមុនពេលបង្កើតពិភពលោកមកម្ល៉េះ (អភ ១,៤)។
- ១ ជនដ៏វិសុទ្ធ ពីព្រោះព្រះបុត្រារបស់ព្រះជាម្ចាស់បានលោះយើង ដើម្បីឲ្យយើងបម្រើព្រះជាម្ចាស់ដោយទៅជាជនដ៏វិសុទ្ធ និងសុចរិតរាល់ថ្ងៃនៃជីវិតរបស់យើង (លក ១,៦៨.៧៤.៧៥)។

ប្រហែលជាអ្នករាល់គ្នានឹងសួរខ្ញុំថា ហេតុដូចម្តេចបានជាសត្វលោកទន់ខ្សោយដូចមនុស្ស អាចទៅជាជនដ៏វិសុទ្ធដូចព្រះជាម្ចាស់ដែរ។ ប៉ុន្តែ ខ្ញុំនឹងឆ្លើយទៅវិញថា រឿងនោះ នៅតែអាចទៅរួច ហើយងាយផង ដោយសារសេចក្តីសន្តោសប្រណីនៃព្រះជាម្ចាស់ ព្រះអង្គមិនដែលបដិសេធចំពោះអ្នកណាទេ កាលណាគេសុំសេចក្តីសន្តោសប្រណីនោះដោយចិត្តស្មោះ។

ដូច្នោះត្រូវធ្វើដូចម្តេច ដើម្បីទទួលបានសេចក្តីប្រណីនោះ? មានតែម៉្យាងគត់ គឺស្រឡាញ់ព្រះជាម្ចាស់។ តើមានអ្វី ទន់ភ្លន់ ស្លូតបូត ហើយងាយស្រួលដូចសេចក្តីស្រឡាញ់? តើមានអ្វីដែលផ្តល់អំណរសប្បាយ និងនាំឲ្យស្រួលក្នុងចិត្តជាងស្រឡាញ់ អ្នកដែលសប្បុរសជាអនេក ស្រស់ស្អាតជាអនេក គ្រប់លក្ខណៈជាអនេក គួរឲ្យស្រឡាញ់ជាអនេក អ្នកដែលមានសប្បុរសធម៌ មានសោភណភាពគ្រប់លក្ខណៈ អ្នកដែលមិនដែលប្រព្រឹត្ត

អំពើអាក្រក់ អ្នកដែលធ្វើអំពើល្អឥតគណនា ហើយអ្នកដែលមានចិត្តថ្លើម និងស្រឡាញ់អ្នករាល់គ្នាគ្រប់ពេលវេលាទៀតនោះ? ចូរអ្នកស្រឡាញ់ព្រះជាម្ចាស់ដែលសប្បុរស និងគួរឲ្យស្រឡាញ់យ៉ាងខ្លាំងនេះ ហើយអ្នករាល់គ្នានឹងទៅជាសន្តបុគ្គល(ជនដ៏វិសុទ្ធ)។

អ្នកមិនដឹងទេថា សេចក្តីស្រឡាញ់ផ្លាស់ប្តូរអ្នកដែលស្រឡាញ់ ឲ្យទៅជាអ្នកដែលគេស្រឡាញ់? សន្តៈអូគូស្ទីនមានប្រសាសន៍ថា៖ បើសិនជាអ្នកស្រឡាញ់រឿងលោកីយ៍ អ្នកនឹងក្លាយជាដូចរឿងលោកីយ៍។ បើអ្នករាល់គ្នាស្រឡាញ់ព្រះជាម្ចាស់ អ្នករាល់គ្នា នឹងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ ចូរអ្នករាល់គ្នាស្រឡាញ់ព្រះដ៏វិសុទ្ធបំផុត នោះអ្នករាល់គ្នានឹងទៅជាជនដ៏វិសុទ្ធ។ ចូរអ្នករាល់គ្នាស្រឡាញ់ព្រះជាម្ចាស់ នោះអ្នករាល់គ្នានឹងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយរួមជាមួយព្រះអង្គ និងដោយទៅជារូបតំណាងរបស់ព្រះអង្គ។

ប៉ុន្តែបើអ្នករាល់គ្នាស្រឡាញ់ព្រះជាម្ចាស់ ចូរអ្នករាល់គ្នាស្អប់នូវអ្វីៗដែលព្រះអង្គស្អប់។ អ្នកណាប្រកាសថា ខ្លួនស្រឡាញ់ព្រះអម្ចាស់ ចូរស្អប់អំពើអាក្រក់ (ទន ៩៦,១០)។ គឺត្រូវស្អប់អំពើអាក្រក់ដែលព្រះអង្គស្អប់ដែរ។ បើអ្នករាល់គ្នាស្រឡាញ់ព្រះអម្ចាស់ ចូរអ្នករាល់គ្នាស្រឡាញ់អ្វីៗ ដែលព្រះអង្គស្រឡាញ់ គឺគុណធម៌ទាំងអស់ ជាពិសេសការបន្ទាបខ្លួន សប្បុរសធម៌ ភាពបរិសុទ្ធនៃវិញ្ញាណ និងរាងកាយ។ បើអ្នករាល់គ្នាស្រឡាញ់ព្រះជាម្ចាស់ ចូរអ្នកផ្តាច់ចិត្តនឹងរឿងលោកីយ៍ ដើម្បីថ្វាយអ្វីៗទាំងអស់នោះ ទៅឲ្យអ្នកដែលបានប្រគល់ខ្លួនទាំងស្រុងដល់អ្នករាល់គ្នា។ បើអ្នករាល់គ្នាស្រឡាញ់ព្រះជាម្ចាស់ ចូរធ្វើអ្វីៗដែលព្រះអង្គគាប់ព្រះហឫទ័យ គឺធ្វើតាមព្រះបំណងដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ ដែលទ្រង់សម្តែងឲ្យអ្នករាល់គ្នាស្គាល់ ដោយវិន័យដ៏វិសុទ្ធ និងបទបញ្ជារបស់អ្នកគ្រប់គ្រងអ្នក៖ អ្នកណាមានវិន័យរបស់ខ្ញុំ និងប្រតិបត្តិតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ (យហ ១៤,២១)។

ខ្ញុំក្រាបថ្វាយបង្គំ និងស្រឡាញ់ព្រះរបស់ខ្ញុំ ដែលមានព្រះហឫទ័យឲ្យបុត្រធីតាទាំងអស់របស់ព្រះអង្គបានសុភមង្គល។ ខ្ញុំស្ញឹងស្ញាធ៏ទៅដល់សុភមង្គលពេញលក្ខណៈ ដោយអរព្រះគុណព្រះអង្គអស់ពីចិត្តខ្ញុំ។

## ទុកពេល សម្រាប់ការលើកលែងទោស

**១**- ចូរប្រៀបធៀបសុភមង្គល ដែលយើងបានសរសេរនៅខាងដើមជំណាក់កាល និងសុភមង្គលដែលយើងស្គាល់ ក្រោយពីបានរៀនអំពីព្រះយេស៊ូ។

**២**- ចូរអាន (ទក ៣០,១៥-២០) និងដំណឹងល្អតាមសន្តៈម៉ាថាយ (មថ៦,១៩-២៤)។ អស់អ្នកដែលចង់បានសុភមង្គលតាមព្រះយេស៊ូត្រូវតែធ្វើការជ្រើសរើសជាច្រើន។ សូមសួរខ្លួនឯងថា ថ្ងៃនេះតើខ្ញុំត្រូវលះបង់អ្វីខ្លះ?

**៣**- ព្រះយេស៊ូបើកផ្លូវនៃជីវិត ជាផ្លូវដែលត្រូវរងទុក្ខលំបាករហូតដល់ស្លាប់ ដើម្បីបានជីវិតថ្មី។ ដោយយើងស្គាល់កំណត់ និងស្នាមរបួសនៃចិត្តយើង យើងត្រូវយល់ថាត្រូវតែខិតខំ ដើម្បីបានសុភមង្គល។

ខ្ញុំជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ ហើយព្រះបិតាខ្ញុំជាម្ចាស់ចំការ។ មែកណា ដែលគ្មានផ្លែព្រះអង្គកាត់ចោល ហើយមែកណាមានផ្លែព្រះអង្គលោះមែកនេះ ដើម្បីបានផ្លែកាន់តែច្រើន (យហ ១៥,១-២)។ ក្នុងសុភមង្គលរបស់យើង តើយើងគិតយ៉ាងណាអំពីទុក្ខលំបាក និងការខិតខំប្រឹងប្រែង?

ខ្ញុំរំពឹងគិតទៅដល់ព្រះយេស៊ូ ដែលបានទទួលសុភមង្គលពិតប្រាកដ។ ខ្ញុំសូមព្រះអង្គលើកលែងទោស

ឲ្យខ្ញុំដែលបានរកសុភមង្គលក្លែងក្លាយ និងងាយស្រួល។ ខ្ញុំសូមអង្វរព្រះវិញ្ញាណព្រះយេស៊ូឲ្យព្រះអង្គជួយណែនាំខ្ញុំនៅតាមផ្លូវនៃសុភមង្គលពិតប្រាកដ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ...ដើម្បី...

**១**-ក្នុងលិខិតរបស់សន្តៈប៉ូលផ្ញើទៅគ្រីស្តបរិស័ទជាតិរ៉ូម៉ាំង លោកពន្យល់ថា ព្រះជាម្ចាស់ធ្វើអ្វីៗទាំងអស់ ដើម្បីឲ្យអស់អ្នកដែលព្រះអង្គបានត្រាស់ហៅមានសុភមង្គល (រម ៨,២៨-២៩)។ តើយើងមានបទពិសោធន៍នេះមែនឬ? តើថ្ងៃនេះ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យធ្វើអ្វីខ្លះ ដើម្បីទទួលសុភមង្គលនេះ?

**២**- តើមានសន្តៈ ឬសន្តីម្នាក់ ដែលជាគំរូសម្រាប់យើង? តើយើងនឹងចែករំលែកសុភមង្គលរបស់យើងយ៉ាងដូចម្ដេចជាមួយអ្នកដទៃ?

នៅក្នុងពិភពយើងនេះ មនុស្សជាច្រើនលក់សុភមង្គលក្លែងក្លាយ...ខ្ញុំអាចយល់ថា សុភមង្គលរបស់ព្រះគ្រីស្តជាសុភមង្គលពិតប្រាកដ។ ខ្ញុំមានបំណងចង់ចែកសុភមង្គលនេះដល់អ្នកដទៃ។

# សម្តែងធម៌មេត្តាករុណា

ព្រះយេស៊ូគ្រីស្តពោរពេញទៅដោយធម៌មេត្តាករុណា ដោយព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ បំពោះទុក្ខវេទនាគ្រប់យ៉ាងរបស់អស់អ្នកដែលរងទុក្ខលំបាក!

## ដំណាក់កាលទី ២០

យើងបានឃើញទុក្ខវេទនារបស់ប្រជារាស្រ្ត (សរ ៣,៧)

**ក្នុងដំណាក់កាលនេះមាន៖** ព្រះជាម្ចាស់ ដែលប្រទានសុភមង្គល ដោយឥតគិតថ្លៃ ទៅឲ្យអស់អ្នកដែលមានចិត្តជាអ្នកក្រខ្សត់ ជាព្រះបិតាពោរពេញទៅដោយធម៌មេត្តាករុណា៖ ប្រវត្តិរបស់ប្រជារាស្រ្តព្រះអង្គ ជាប្រវត្តិនៃធម៌មេត្តាករុណារបស់ព្រះអង្គ។ នៅក្នុងអង្គព្រះយេស៊ូ ព្រះជាម្ចាស់សម្តែងឲ្យយើងស្គាល់ព្រះហឫទ័យអាណិតអាសូរ និងសេចក្តីសង្ឃឹមរបស់ព្រះអង្គចំពោះអស់អ្នកដែលរងរបួស។ ព្រះហឫទ័យព្រះយេស៊ូតែងតែអាណិតអាសូរ ព្រះអង្គបានសម្តែងឲ្យយើងស្គាល់ថា ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ជាសប្បុរសធម៌ តែងតែលើកលែងទោស អត់ធ្មត់ និងសង្ឃឹមជានិច្ច...មនុស្សកាន់តែក្រីក្ររងរបួស ព្រះអង្គកាន់តែស្រឡាញ់គេ។
ដល់វេនយើងទទួលយកមនុស្សរងទុក្ខវេទនាមកទុកក្នុងចិត្តយើងយ៉ាងពិតប្រាកដ...យើងត្រូវបើកចិត្តស៊ីជម្រៅ ទើបអាចទទួលយកទុក្ខវេទនារបស់អ្នកក្រតោកយ៉ាក។ យើងសន្យាថា នឹងបម្រើគេ។

**គោលដៅនៃដំណាក់កាលនេះ៖** ទទួលធម៌មេត្តាករុណារបស់ព្រះយេស៊ូ និងអនុវត្តតាម៖...រកក្នុងព្រះគម្ពីរនូវអ្វីៗ ដែលទាក់ទងនឹងព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ... ទទួលព្រះជាម្ចាស់ ដែលមានព្រះហឫទ័យមេត្តាករុណាចំពោះយើង ជាអ្នករងរបួស...ទន់ខ្សោយ...ជាអ្នកបាប...
...រិះគិតឡើងវិញ អំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ក្នុងជីវិតយើង ដើម្បីអរព្រះគុណព្រះអង្គ។
...ថ្វាយខ្លួនចំពោះព្រះហឫទ័យអាណិតអាសូររបស់ព្រះជាម្ចាស់ ដោយបើកចិត្តឲ្យទូលាយចំពោះទុក្ខវេទនារបស់អ្នកដទៃ និងជួយបម្រើគេយ៉ាងពិតប្រាកដ។ ទីបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចនិយាយប្រាប់អ្វី ដែលខ្ញុំបានយល់ឃើញអំពីធម៌មេត្តាករុណា ដែលខ្លួនខ្ញុំត្រូវការ ហើយរបៀបអនុវត្តធម៌មេត្តាករុណារបស់ខ្ញុំនេះជាមួយអ្នកដទៃ។

## ទុកពេលសម្រាប់ បើកចិត្ត និងទទួល

១- ទទួលយកមកក្នុងខ្លួន ពាក្យ "មេត្តាករុណា"។ តើយើងយល់ពាក្យនេះយ៉ាងដូចម្ដេច? តើពាក្យនេះធ្វើឲ្យយើងនឹកឃើញអ្វី? តើពាក្យណាខ្លះទៀត ដែលពាក្យនេះធ្វើឲ្យយើងគិត? តើយើងធ្លាប់ពិសោធន៍អំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះយើងឬទេ?

២- តើយើងធ្លាប់ពិសោធន៍ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះខ្លួនយើង តាមរយៈអ្នកដទៃឬទេ?

៣- តើយើងធ្លាប់រំជួលចិត្ត ដោយទុក្ខវេទនារបស់អ្នកដទៃឬទេ? ប្រសិនបើមែន តើនៅក្នុងស្ថានភាពណា នៅក្នុងកាលៈទេសៈណា? តើយើងបានធ្វើអ្វីខ្លះ នៅពេលនោះ?

ខ្ញុំទទួលយកពាក្យមេត្តាករុណានេះ មកទុកក្នុងចិត្តខ្ញុំ, ខ្ញុំបណ្ដោយខ្លួនឲ្យរំជួលចិត្ត ពីព្រោះពាក្យនេះធ្វើឲ្យខ្ញុំនឹកឃើញអំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់...អំពីទុក្ខវេទនារបស់អ្នកដទៃ... ។ ខ្ញុំថ្វាយបង្គំព្រះយេស៊ូដែលគង់នៅជាមួយអស់អ្នកដែលរងទុក្ខលំបាកជាងគេ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យយល់ថា ព្រះអង្គជាព្រះមួយអង្គដែល «ឈឺឆ្អាល» ចំពោះអស់អ្នកដែលរងទុក្ខវេទនា (សរ ៣៤,៦-៧) ដែលមិនខឹងនឹងការបដិសេធរបស់យើង (ហស ១១,៨-៩) ដែលមិនប្រព្រឹត្តទៅតាមទោសកំហុសរបស់យើង (ទន ៥១)។

២- ក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី កិច្ចការ និងព្រះបន្ទូលរបស់ព្រះយេស៊ូសម្ដែងឲ្យយើងដឹងថា ព្រះអង្គផ្ទាល់ជាអ្នកដែលមានព្រះហឫទ័យមេត្តាករុណា...ព្រះយេស៊ូរំជួលព្រះហឫទ័យ ដោយសារព្រះអង្គអាណិតអាសូរ (លក ៧...) សូមអានម្ដងទៀត ដំណឹងល្អតាមសន្តៈលូកា ជាពិសេសជំពូកទី១៥... ដើម្បីយល់ឃើញថាព្រះយេស៊ូមានព្រះហឫទ័យមេត្តាករុណា។ សូមរិះគិតអំពីទុក្ខវេទនា ដែលមាននៅក្នុងព្រះហឫទ័យព្រះអង្គ។

៣-ចំពោះសន្តៈយ៉ូហាន អើដ អ្នកដែលមានចិត្តមេត្តាករុណា គឺជាអ្នកដែលយកទុក្ខវេទនារបស់អស់អ្នកកម្សត់ទុកនៅក្នុងចិត្តខ្លួន។

**អ្នកណាមានចិត្តមេត្តា ករុណា មានលក្ខណៈបី ៖ ទីមួយ** គេអាណិតអាសូរចំពោះទុក្ខវេទនារបស់អ្នកដទៃ គឺគេយកទុក្ខវេទនារបស់អ្នកកម្សត់ទុកនៅក្នុងចិត្ត។ **ទីពីរ** អ្នកនោះមានបំណងយ៉ាងធំធេងចង់ជួយសង្គ្រោះទុគ៌តជនឲ្យរួចផុតពីទុក្ខវេទនា។ **ទីបី** អ្នកនោះមានបំណង ហើយអនុវត្តតាមបំណងនេះ ដោយប្រព្រឹត្តកិច្ចការជួយសង្គ្រោះអ្នកកម្សត់មែន។ រីឯព្រះសង្គ្រោះរបស់យើងវិញ ព្រះអង្គចាប់កំណើតជាមនុស្សដើម្បីអនុវត្តធម៌មេត្តាករុណាដ៏ធំធេងរបស់ព្រះអង្គចំពោះយើង។ ជាដំបូងដោយហេតុថា ព្រះអង្គចាប់កំណើតជាមនុស្សហើយមានព្រះកាយ និងព្រះហឫទ័យ ដែលអាចរងទុក្ខលំបាក និងអាចឈឺចាប់ដូចរាងកាយយើង ព្រះអង្គពោរពេញទៅដោយព្រះហឫទ័យអាណិតអាសូរ ចំពោះទុក្ខវេទនារបស់យើង ហើយទទួលយកទុក្ខវេទនានោះដាក់ក្នុងព្រះហឫទ័យព្រះអង្គដោយឈឺចាប់ក្រៃលែង។ ដោយព្រះអង្គមានសេចក្ដីស្រឡាញ់ជាអនេកចំពោះយើងរាល់គ្នា ដូចជាឪពុកដ៏ល្អម្នាក់ស្រឡាញ់កូនៗរបស់ខ្លួន ហើយដោយព្រះអង្គទតឃើញជានិច្ចនូវការឈឺចាប់នៃរាងកាយ និងវិញ្ញាណ ការព្រួយបារម្ភ ទុក្ខវេទនា ទាំងកាយទាំងចិត្ត ការរងទុក្ខធំៗទាំងអស់ដែលបុត្រ

ធីតារបស់ព្រះអង្គត្រូវទទួលរងរហូតដល់អវសានកាលនៃពិភពលោក ព្រះហឫទ័យសន្តោស ប្រោសប្រណី របស់ព្រះអង្គរងទុក្ខយ៉ាងខ្លាំង ដោយឈឺចាប់ក្រៃលែង។ ការឈឺចាប់ទាំងអស់នោះ នឹងធ្វើឲ្យព្រះអង្គសុគត រាប់ពាន់ដង បើសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដែលខ្លាំងជាងសេចក្ដីស្លាប់មិនបានថែរក្សាព្រះជន្មព្រះអង្គ ដើម្បីឲ្យព្រះអង្គលះបង់ព្រះជន្មនេះនៅលើឈើឆ្កាង ដើម្បីសង្គ្រោះយើង។

៤- សូមរិះគិតអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះយើង។

«អស់អ្នកដែលមានចិត្តមេត្តាករុណា មានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងមានធម៌មេត្តាករុណាចំពោះគេ »

បើតាមឫសគល់នៃពាក្យធម៌មេត្តាករុណា អ្នកមានធម៌មេត្តាករុណា គឺជាអ្នកដែលមានទុក្ខព្រួយនៅក្នុងចិត្ត គឺជាអ្នកដែលកើតទុក្ខអំពីទុក្ខវេទនារបស់អ្នកដទៃ។ អ្នកដែលមិនចេះ «កើតទុក្ខជាមួយគេ» មិនអាចទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ទេ ដ្បិតព្រះជាម្ចាស់ជាព្រះមួយអង្គ ដែលកើតទុក្ខជាមួយមនុស្ស។ ព្រះគ្រីស្តកើតទុក្ខ រងទុក្ខលំបាក និងសោយទិវង្គតលើឈើឆ្កាង បង្ហាញអំពីសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅរបស់ព្រះជាម្ចាស់ដែលយើងអាចហៅថា ទុក្ខជាអ្វីមួយដ៏អាថ៌កំបាំងខ្លាំងណាស់ ដ្បិតបើគ្មានទុក្ខទេ សេចក្ដីស្រឡាញ់ មិនមែនជាសេចក្ដីស្រឡាញ់ឡើយ។ មានតែទុក្ខលំបាករបស់ព្រះគ្រីស្តនេះទេ ដែលអាចសម្ដែងឲ្យយើងដឹងអំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ អ្នកមានចិត្តមេត្តាករុណាចូលចិត្តអ្នកទន់ទាប អ្នកទន់ខ្សោយ អ្នកទុគ៌ត អ្នកជំងឺ អ្នកឯកា (គឺជាទុក្ខមួយដ៏ធំធេងជាងគេក្នុងចំណោមទុក្ខរបស់មនុស្ស!) អ្នកដែលគេធ្វើឲ្យអាម៉ាស់ ដែលគេរំលោភបំពាន អ្នករងអំពើអយុត្តិធម៌ អ្នកដែលរងទុក្ខទាំងកាយទាំងចិត្ត អ្នកដែលព្រួយបារម្ភ។ ព្រះយេស៊ូបានបំពេញកិច្ចការ ដើម្បីរំដោះអ្នកដែលជាខ្ញុំបម្រើគេ ព្រះអង្គបង្ហាញថា មនុស្សមានសេរីភាព លុះត្រាតែគេធ្វើការដើម្បីរំដោះបងប្អូនរបស់ខ្លួន។ យើងមានសេរីភាព លុះត្រាតែយើងចេះស្រឡាញ់។ គ្មានសេរីភាពក្រៅពីសេចក្ដីស្រឡាញ់ឡើយ។ អ្នកមានសេរីភាព និងអ្នកមានចិត្តស្រឡាញ់ គឺជាមនុស្សតែមួយដដែល។

ខ្ញុំទទួលយកព្រះជាម្ចាស់ ដែលមានព្រះហឫទ័យមេត្តាករុណាចំពោះទុក្ខវេទនានៃប្រជាជនព្រះអង្គ។ ខ្ញុំអរព្រះគុណព្រះអង្គចំពោះអ្វីៗ ដែលខ្ញុំយល់ឃើញអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ខ្ញុំបណ្ដោយចិត្តឲ្យជ្រួតជ្រាបទៅដោយធម៌មេត្តាករុណា សប្បុរសធម៌ ការអត់ធ្មត់ ដើម្បីអស់អ្នកដែលរងទុក្ខ។

## ទុកពេល សម្រាប់ការលើកលែងទោស

១- យើងសញ្ជឹងគិតទៅដល់ព្រះជាម្ចាស់ ដែលរំជួលព្រះហឫទ័យ ដោយសារទុក្ខវេទនានៃប្រជាជនរបស់ព្រះអង្គ (សរ ៣,៤)។ បន្ទាប់មកយើងសញ្ជឹងគិតទៅដល់ព្រះយេស៊ូ ដែលរំជួលព្រះហឫទ័យ ដោយសារសេចក្ដីអាណិតអាសូរចំពោះហ្វូងចៀមដែលគ្មានគង្វាល (លក ៧)។ តើមានអ្វីផុសចេញអំពីចិត្តយើង?

២- តើចិត្តអាណិតអាសូរនោះ នាំយើងទៅរកអ្វី? តើមានការប្រែប្រួលក្នុងជីវិតយើងឬទេ? ក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់? ក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ?

៣- តើអ្វីដែលជាឧបសគ្គក្នុងចិត្ត ដែលរាំងមិនឲ្យយើងរំជួលចិត្ត ដោយសារគ្រោះភ័យរបស់អ្នកដទៃ? ខ្ញុំទុកឲ្យសេចក្ដីស្រឡាញ់ដ៏ប្រសើរអស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះខ្ញុំចូលជ្រាបក្នុងចិត្តខ្ញុំ។ ខ្ញុំទុកឲ្យព្រះអង្គយាង

មករកខ្ញុំ ដើម្បីបំភ្លឺចិត្តខ្ញុំ។ ខ្ញុំសូមព្រះអង្គលើកលែងទោសឲ្យខ្ញុំ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ...ដើម្បី...

១- យកទុក្ខវេទនារបស់ទុគ៌តជន មកទុកនៅក្នុងចិត្ត ដោយសារសេចក្តីអាណិតអាសូរ។ តើយើងទទួលយកប្រសាសន៍ នៃសន្តៈយ៉ូហាន អើដ នេះយ៉ាងដូចម្តេច? ហើយយើងយកប្រសាសន៍នេះ មកធ្វើជារបស់យើងយ៉ាងដូចម្តេច?

២- តើធ្វើដូចម្តេច ដើម្បីប្រមូលជាមួយអស់អ្នកដែលមានគ្រោះភ័យ ដែលគេបោះបង់បោល ប្រមាថមើលងាយ?

៣- តើយើងគួរធ្វើអ្វីខ្លះ?

៤- តើធ្វើដូចម្តេច ដើម្បីឲ្យបេះអត់ធ្មត់... ឲ្យចាប់ផ្តើមជាថ្មីម្តងហើយម្តងទៀត ជាមួយនឹងអ្នកណាម្នាក់... ដូចព្រះជាម្ចាស់ចាប់ផ្តើមជាថ្មីជាមួយយើងជានិច្ច?

៥- សូមអធិដ្ឋានលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដែលមានព្រះហឫទ័យមេត្តាករុណា។ សូមទុកនៅក្នុងចិត្តនូវទុក្ខវេទនារបស់អ្នកដទៃ។ សូមឲ្យព្រះអង្គយកទុក្ខវេទនារបស់យើង និងរបស់អ្នកឯទៀតទៅក្នុងព្រះហឫទ័យព្រះអង្គ។ សូមថ្វាយខ្លួនចំពោះព្រះអង្គ ដោយមានបំណងចង់រស់នៅពោរពេញទៅដោយសេចក្តីស្រឡាញ់ មេត្តាករុណារបស់ព្រះអង្គ។

ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យថ្វាយខ្លួនចំពោះព្រះយេស៊ូ ដើម្បីជួយរំដោះអស់អ្នកដែលត្រូវគេជិះជាន់សង្កត់សង្កិន...ដើម្បីប្រាប់គេថា ព្រះជាម្ចាស់ស្រឡាញ់គេ ទោះជាគេត្រូវគេជិះជាន់សង្កត់សង្កិនយ៉ាងណាក៏ដោយ។ ខ្ញុំក៏ទទួលធម៌មេត្តាករុណាពីពួកគេដែរ។

# តើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើអ្វីខ្លះ?

ខ្ញុំចាត់អ្នករាល់គ្នា ដើម្បីបន្តនៅលើផែនដី នូវកិច្ចការដែលខ្ញុំបានប្រព្រឹត្ត !

**ដំណាក់កាលទី ២១**

ខ្ញុំនេះហើយ សូមព្រះអង្គចាត់ឲ្យខ្ញុំទៅ...

**ក្នុងដំណាក់កាលនេះមាន ៖** អ្នកណាដែលបើកចិត្តទទួលទុក្ខវេទនានៃទុគ៌តជន គឺជាម្នាក់ដែលសុខចិត្តទទួលការត្រាស់ហៅ ដែលពួកសាវ័កផ្ទាល់បានឮ៖ "សូមអញ្ជើញមកទុកសំណាញ់នោះចោល ហើយដើរតាមខ្ញុំ"។

ព្រះជាម្ចាស់ត្រាស់ហៅយើងរៀងៗខ្លួន ចំៗឈ្មោះ។ ព្រះអង្គត្រាស់ហៅយើងនៅពេលកំពុងធ្វើការ ដោយសារហេតុការណ៍ និងសញ្ញាសម្គាល់ផ្សេងៗ។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សជានិច្ច ដូចព្រះអង្គស្រឡាញ់គេជានិច្ចដែរ។

**គ្រីស្តទូតទាំងអស់នឹងមិនខ្វះសំណួរដេញដោលទេ ៖** គេភ័យខ្លាចអ្វីៗ គេមិនយល់អ្វីៗទាំងអស់គេធ្លាក់ទឹកចិត្ត...ទោះជាយ៉ាងណាព្រះគ្រីស្តនៅតែទទួលពួកលោកជាមួយនឹងគុណវិបត្តិ និងគុណសម្បត្តិរបស់ពួកលោក...ព្រះអង្គទុកព្រះហឫទ័យពួកលោក ដ្បិតពួកលោកនឹងទៅជាសាក្សី នៅពេលព្រះវិញ្ញាណយាងមក។ "អ្នករាល់គ្នាមិនបានជ្រើសរើសខ្ញុំទេ គឺខ្ញុំនេះហើយដែលបានជ្រើសរើសអ្នករាល់គ្នា"។ សូមព្រះអង្គចាត់ឲ្យខ្ញុំទៅ!

**គោលដៅនៃដំណាក់កាលនេះ ៖** ត្រៀមខ្លួន ដើម្បីទទួលការត្រាស់ហៅរបស់ព្រះជាម្ចាស់។

- ស្ទឹងស្មាធ៏អំពីការត្រាស់ហៅនៅក្នុងព្រះគម្ពីរ
- យល់ឃើញថា យើងរស់នៅជាគ្រីស្តបរិស័ទ នៅពេលដែលយើងឆ្លើយតបនឹងព្រះជាម្ចាស់ដែលចាត់ឲ្យយើងទៅ។
- យល់អំពីការត្រាស់ហៅ ដែលខ្ញុំបានឮ ហើយចម្លើយដែលខ្ញុំផ្តល់ឲ្យ។
- យល់ឲ្យច្បាស់អំពី តើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើអ្វីខ្លះក្នុងជីវិតខ្ញុំ។

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចយល់ឃើញថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើអ្វីខ្លះ ហើយខ្ញុំចង់ឆ្លើយតបវិញយ៉ាងដូចម្តេច។

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- តើអ្វីខ្លះជាតម្រូវការ ជាការរង់ចាំ ជាសំណួរ ជាសេចក្តីសង្ឃឹម របស់អស់អ្នក ដែលរស់នៅជាមួយយើង? នៅកន្លែងដែលយើងរស់នៅ នៅកន្លែងដែលយើងធ្វើការ? តើអ្វីទៅដែលនាំឲ្យយើងគិតថា ការត្រាស់

ហៅរបស់អ្នកដទៃ ជាការត្រាស់ហៅរបស់ព្រះជាម្ចាស់ដែរ?

**២-** ថ្ងៃនេះក៏ដូចជាម្សិលមិញ មានអ្នកស្រេកឃ្លាន មានជនបរទេស មានអ្នកដែលគ្មានអ្វីទាល់តែសោះ មានអ្នកជំងឺ មានអ្នកជាប់ទោស... មនុស្សដែលយើងជួបនៅតាមផ្លូវនៅផ្ទះ នៅកន្លែងធ្វើការ នៅមហាវិទ្យាល័យ អ្នកក្រីក្រអ្នក ទន់ខ្សោយ...ចំពោះយើង តើអ្នកទាំងនោះជាអ្នកណា? បើយើងស្គាល់អ្នកទាំងនោះ តើយើងអាចបម្រើគេបានដែរឬទេ ?

មានពេលវេលាសម្រាប់អ្វីៗទាំងអស់។ នេះជាពេលដែលខ្ញុំត្រូវឈប់។ ខ្ញុំចូលទៅជួបព្រះជាម្ចាស់។ ខ្ញុំទទួលយកការត្រាស់ហៅរបស់ព្រះអង្គក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ដោយសារអ្នកណាម្នាក់ សម្ដីមួយ ហេតុការណ៍មួយណានោះ...។

ខ្ញុំទទួលយកបំណងចង់ឲ្យមានប្រយោជន៍ ចង់ឲ្យបានជោគជ័យក្នុងជីវិត ចង់ធ្វើអ្វីដែលខ្ញុំចូលចិត្តចង់ធ្វើអ្វីៗ ដែលមាននៅក្នុងចិត្តខ្ញុំក្នុងពេលនេះ។ ខ្ញុំទទួលការត្រាស់ហៅរបស់ព្រះអម្ចាស់នេះ។ ថ្ងៃនេះ ព្រះអង្គត្រាស់ហៅខ្ញុំថា៖ “សូមអញ្ជើញមកដើរតាមខ្ញុំ”។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

**១-** ការត្រាស់ហៅនៅក្នុងព្រះគម្ពីរ៖

| | |
|---|---|
| លោក អាប្រាហាំ | (កណ១២,២-៤) |
| លោកម៉ូសេ | (សរ ៣,១-១៥) |
| លោកអេសាយ | (អស ៦,១-១៣) |
| លោកសាមូអែល | (១សម ៣,៣-១៩) |
| ព្រះនាងម៉ារី | (លក ១,២៦-៣៨) |
| លោកសីលា | (លក ៥,១-១១ មថ ១៦,១៨-២១ យហ ២១,១៥-១៩) |
| លោកយ៉ូហាន និងសាវ័កដំបូង | (យហ ១,៣៥-៥១) |
| លោកម៉ាថាយ | (មថ ៩,៩) |
| អ្នកមានវ័យក្មេង | (មក ១០,១៧-២៧) |
| លោកប៉ូល | (កក ៩,១-២២) |

ខ្ញុំអានការត្រាស់ហៅប្លែកៗពីគ្នាតាមសម្រួល។ ខ្ញុំជ្រើសរើសយកមួយ។ ខ្ញុំសម្លឹងមើលទៅព្រះអម្ចាស់យ៉ាងយូរដែលត្រាស់ហៅខ្ញុំ...របៀបដែលអ្នកទទួលការត្រាស់ហៅឆ្លើយតប...ខ្ញុំរង់ចាំស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំនៅថ្ងៃនេះឯង។ ខ្ញុំអរព្រះគុណព្រះអង្គ ដែលយាងមករកខ្ញុំ នៅពេលដែលខ្ញុំត្រូវការព្រះអង្គ។

# សន្ត: យ៉ូហាន អើដ

## ២- យើងជាសាក្សីរបស់ដំណឹងល្អ៖

ដោយសារអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបប្រេង ព្រះជាម្ចាស់ត្រាស់ហៅយើងទាំងអស់គ្នាឲ្យបម្រើព្រះសហគមន៍...ព្រះសហគមន៍បម្រើព្រះជាម្ចាស់ ដើម្បីឲ្យសត្វលោកទាំងអស់មានជីវិត...ព្រះសហគមន៍យកចិត្តទុកដាក់អនុវត្តដំណឹងល្អ...

ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យកសាងពិភពលោកមួយ ប្រកបដោយធម៌មេត្តាករុណា ជាប្រជាជនមួយដែលចេះស្រឡាញ់គ្នាដូចបងប្អូន។ ថ្ងៃនេះ សម្ដីមួយម៉ាត់ កាយវិការ កិច្ចការរបស់យើងអាចទៅជា «ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចំពោះអ្នកដទៃ»។ យើងជាព្រះកាយព្រះគម្ពីរ ចូរយើងទៅជាព្រះបន្ទូលព្រះអង្គចំពោះគ្នាទៅវិញទៅមក។

## ខ្ញុំបំពេញមុខងារជាទូតរបស់ព្រះយេស៊ូគ្រីស្ត

ព្រះមហាក្សត្រិយ៍យាងមកដល់ ក្រោយពីខ្ញុំបានទេសនា។ ខ្ញុំបានទូលព្រះនាងអំពីអគ្គីភ័យ ដែលបានឆេះឆាប ព្រះរាជវាំងមួយផ្នែក។ កាលនោះ ខ្ញុំចាប់ផ្ដើមទូលព្រះនាងថា បពិត្រព្រះមហាក្សត្រិយ៍ ខ្ញុំម្ចាស់គ្មានពាក្យអ្វីទូលព្រះនាងទេ ក្រៅពីសុំទូលអង្វរ ដោយហេតុថាព្រះជាម្ចាស់បាននាំភ្លើងមកទីនេះ ហើយសូមកុំភ្លេចឲ្យសោះថា ព្រះជាម្ចាស់មានព្រះបន្ទូលទៅព្រះនាងតាមរយៈអគ្គីភ័យឆាបឆេះព្រះរាជវាំងមួយផ្នែកនេះ។ ដូចព្រះមហាក្សត្រិយ៍ ទ្រង់ជ្រាបស្រាប់មកហើយថា ចំពោះគ្រីស្តបរិស័ទគ្មានភាពចៃដន្យទេ ប៉ុន្តែអ្វីៗក៏មកពីឧបការគុណ និងព្រះបញ្ញារបស់ព្រះជាម្ចាស់។ អគ្គីភ័យនេះ មានអត្ថន័យដូចតទៅ៖

ព្រះជាម្ចាស់អនុញ្ញាតព្រះមហាក្សត្រឲ្យសាងសង់ព្រះរាជវាំងនេះ ប៉ុន្តែព្រះអង្គត្រាស់បង្គាប់ព្រះមហាក្សត្រនោះ ឲ្យសម្រាលទុក្ខប្រជារាស្ត្រ ដោយព្រះហឫទ័យអាណិតអាសូរទៅដល់ស្ត្រីមេម៉ាយ និងក្មេងកំព្រាជាច្រើននាក់ដែលរងទុក្ខវេទនា។ ព្រះអង្គអនុញ្ញាតឲ្យព្រះអង្គម្ចាស់ និងព្រះមហាក្សត្រទាំងឡាយកំសាន្តសប្បាយ ប៉ុន្តែបើលេងកំសាន្តរាល់ថ្ងៃ រាល់សប្ដាហ៍ រាល់ខែ រាល់ឆ្នាំ និងមួយជីវិតនោះ មិនមែនជាផ្លូវទៅស្ថានបរមសុខទេ។

ប្រសិនបើភ្លើងលោកីយ៍នេះ មិនអត់អោនឲ្យព្រះរាជវាំងទេ ភ្លើងអស់កល្បជានិច្ចនឹងមិនលើកលែងឲ្យព្រះអង្គ ឬព្រះអម្ចាស់ ក្សត្រ ព្រះរាជា ឬព្រះរាជនីទេ បើរាជវង្សទាំងនោះ មិនមែនរស់នៅដូចជាគ្រីស្តបរិស័ទ ហើយបើព្រះរាជវង្សទាំងនោះ គ្មានព្រះហឫទ័យអាណិតអាសូរដល់ប្រជារាស្ត្ររបស់ខ្លួន បើព្រះមហាក្សត្រទាំងនោះ មិនប្រើអំណាចរបស់ខ្លួន ដើម្បីបំផ្លាញអំណាចផ្ដាច់ការរបស់មារ និងអំពើបាប ហើយរៀបចំឲ្យមានព្រះរាជ្យព្រះជាម្ចាស់នៅក្នុងព្រលឹងនៃប្រជារាស្ត្ររបស់ព្រះអង្គ។

កាលនោះ ខ្ញុំបានទូលបន្ថែមទៀតថា ខ្ញុំគ្មានផលចំណេញអ្វីផ្សេងទៀតទេ ដោយនិយាយពាក្យទាំងនេះ ក្រៅពីផលប្រយោជន៍នៃព្រះរបស់ខ្ញុំ និងការសង្គ្រោះព្រះមហាក្សត្រ និងមហាក្សត្រីរបស់ខ្ញុំ ដែលខ្ញុំមានបំណងនឹងថ្វាយជីវិតមួយពាន់ដង។

គួរឲ្យអាណិតខ្លាំងណាស់ ដោយបានឃើញពួកអ្នកធំៗ នៅលើពិភពលោកនេះ ត្រូវហ៊ុមព័ទ្ធដោយពួក

អ្នកបញ្ឆោត ដែលកំហុសពួកគេ ដោយពោលពាក្យបញ្ចើចបញ្ចើធ្វើឲ្យពួកគេឈ្លក់វង្វេង ទាល់តែគ្មាននរណាពោលពាក្យពិតៗប្រាប់ពួកគេផង។ អ្នកបញ្ឆោតទាំងអស់នោះ មិនដែលនិយាយពាក្យពិតៗទេ ប្រៀបដូចជាឧក្រិដ្ឋជនចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ហើយខ្ញុំម្ចាស់នឹងត្រូវទទួលទោស បើខ្ញុំម្ចាស់មិនទូលការពិតនេះ ថ្វាយចំពោះព្រះមហាក្សត្រិយ៍ទេ។

ទីបញ្ចប់ ខ្ញុំបានទូលអង្វរសូមឲ្យព្រះនាងទទួលយកពាក្យពិតនេះ ដែលមិនមែនមកពីមនុស្សម្នាក់ទេ ប៉ុន្តែជាព្រះបន្ទូលព្រះជាម្ចាស់។ ខ្ញុំទូលទៀតថា ខ្ញុំពិតជាមនុស្សម្នាក់ទន់ខ្សោយ ហើយជាមនុស្សទុគ៌ត ប្រព្រឹត្តអំពើបាប ប៉ុន្តែខ្ញុំនិយាយបាន ព្រោះនៅទីនេះ ខ្ញុំធ្វើកិច្ចការជំនួសព្រះជាម្ចាស់។ បន្ទាប់ពីសន្តៈប៉ូល និងអស់លោកមានកិត្តិយសប្រកាសព្រះបន្ទូលដ៏វិសុទ្ធនៃព្រះជាម្ចាស់ ខ្ញុំមានមុខងារជាទូតរបស់ព្រះយេស៊ូគ្រីស្ត (២ករ ៥,២០) ដើម្បីនាំព្រះបន្ទូលព្រះរាជាខ្ពង់ខ្ពស់ជាងព្រះរាជាទាំងអស់មកទូលថ្វាយ ចំពោះមហាក្សត្រីដ៏ខ្ពង់ខ្ពស់មួយអង្គ។ ខ្ញុំក៏បានទូលអង្វរ សូមឲ្យព្រះនាងទទួលយកពាក្យពិតតាមវិធីនេះ។

សូមព្រះជាម្ចាស់ប្រទានពរសព្វប្រការ សូមព្រះអង្គប្រណីសន្តោស កុំឲ្យពួកយើងស្វែងរកអ្វីផ្សេងទៀតក្រៅពីគាប់ព្រះហឫទ័យព្រះអង្គ ហើយប្រព្រឹត្តកិច្ចការផងទាំងពួង និងនិយាយតែតាមព្រះបន្ទូលព្រះអង្គណែនាំផងចុះ។

## ៣- សាសនទូតរហូតដល់ចុងផែនដី

ក្នុងព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្ត ព្រះជាម្ចាស់ត្រាស់ហៅយើងទាំងអស់គ្នាឲ្យអនុវត្តអគ្គសញ្ញាជ្រមុជទឹក ឲ្យទៅជាព្រះភ័ក្ត្រព្រះយេស៊ូ ព្រះបន្ទូលព្រះអង្គ។ ព្រះជាម្ចាស់ប្រោសប្រទានគ្រីស្តបរិស័ទដល់ព្រះសហគមន៍ ដើម្បីជាសញ្ញាសម្គាល់ថា មនុស្សគ្រប់ជាតិសាសន៍អាចទទួលដំណឹងល្អ។ អ្នកទាំងនោះគឺជាសាសនទូត ជាសាក្សីដែលព្រះសហគមន៍សាងសង់ក្នុងកន្លែងផ្សេងៗ ជាស្នាព្រះហស្តដោយមានការណែនាំពីព្រះវិញ្ញាណរបស់ព្រះអម្ចាស់។

ជីវិតរបស់ពួកលោករំឭកឲ្យយើងដឹងថា យើងសុទ្ធតែជាអ្នកទទួលខុសត្រូវក្នុងការប្រកាសដំណឹងល្អ ហើយរស់នៅតាមដំណឹងល្អនេះ គ្រប់ទិសទី និងជារៀងរហូត។ ជីវិតរបស់ពួកលោកត្រាស់ហៅយើងឲ្យទទួល និង ប្រគល់ឥតឈប់ឈរនូវព្រះបន្ទូល ដែលយើងមិនមែនជាម្ចាស់កម្មសិទ្ធទេ។ ជីវិតរបស់ពួកលោកប្រាប់យើងម្តងទៀតថា អគ្គសញ្ញាជ្រមុជទឹកធ្វើឲ្យយើងជាអ្នកចូលរួម ជាមួយនឹងបេសកកម្មរបស់ព្រះយេស៊ូ៖ «សូមឲ្យពួកគេទាំងអស់គ្នាស្គាល់ព្រះបិតា »។

**« ក្នុងព្រះនាមព្រះត្រៃឯក ចូរអ្នករាល់គ្នាទៅ ដើម្បីឲ្យគេស្គាល់ និងស្រឡាញ់ព្រះអង្គ »**

ក្នុងព្រះនាមព្រះត្រៃឯក ចូរអ្នករាល់គ្នាទៅ ដើម្បីឲ្យគេស្គាល់ និងស្រឡាញ់ព្រះអង្គ នៅកន្លែងដែលគេមិនដែលស្គាល់ ឬស្រឡាញ់ព្រះត្រៃឯកនេះ។

ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះជាម្ចាស់ ចូរអ្នករាល់គ្នាទៅ ដើម្បីយកផលផ្លែនៃព្រះលោហិតដ៏ថ្លៃថ្លា ដែលហូរចេញមកពីព្រះអង្គ ដើម្បីសង្គ្រោះព្រលឹងទាំងអស់។

ចូរអ្នករាល់គ្នាទៅ ដើម្បីផ្តិតក្នុងចិត្តពួកគេឲ្យកោតខ្លាច និងគោរពស្រឡាញ់ព្រះសង្គ្រោះពួកគេ ដោយ

មានព្រះនាងម៉ារីជួយការពារ ក្រោមការណែនាំរបស់សន្តៈយ៉ូសែប ប្រកបដោយសុភមង្គល សន្តៈកាព្រីអែល ទេវទូតដ៏សប្បុរសរបស់អ្នករាល់គ្នា និងគ្រីស្តទូតទាំងឡាយនៅកន្លែងដែលអ្នកនឹងទៅ ដើម្បីសហការជាមួយពួកលោក ក្នុងការសង្គ្រោះព្រលឹងវង្វេង និងព្រលឹងដែលគេបោះបង់ចោល។

ចូរអ្នករាល់គ្នាទៅ ក្នុងនាមក្រុមគ្រួសារបព្វជិតដ៏តូចរបស់យើង ដើម្បីឲ្យប្រទេស ឬកន្លែងផ្សេងៗទៀតលើសកលលោក ដែលឧបការគុណនឹងណែនាំឲ្យទៅ ដោយមានព្រះលោហិតដ៏ពុះកញ្ជ្រោលរបស់ព្រះអង្គណែនាំរហូតដល់ដំណាក់ចុងក្រោយ ដើម្បីបំផ្លាញអំណាចផ្តាច់ការនៃមារសាតាំង ហើយរៀបចំព្រះរាជ្យព្រះជាម្ចាស់នៅទីនោះ។

ប៉ុន្តែចូរអ្នករាល់គ្នាចងចាំថា នេះជាកិច្ចការរបស់សាសនទូត អ្នករាល់គ្នាត្រូវមានឆន្ទៈដ៏បរិសុទ្ធ គឺស្វែងរកតែការលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។អ្នករាល់គ្នាត្រូវចេះបន្ទាបខ្លួន កុំទុកចិត្តលើខ្លួនឯងជឿទុកចិត្តយ៉ាងខ្លាំងទៅលើសប្បុរសធម៌ជាអនេករបស់ព្រះអង្គ គោរពកោតខ្លាចចំពោះព្រះហឫទ័យ គួរឲ្យគោរពស្រឡាញ់របស់ព្រះអង្គ និងបំណងនៃមន្ត្រីជាន់ខ្ពស់ នៃសាសនាដែលជឿទុកចិត្តលើអ្នករាល់គ្នា។ អ្នករាល់គ្នាត្រូវចេះអត់ធ្មត់ មិនព្រមចុះចាញ់ចំពោះការងារ ត្រូវមានចិត្តក្លាហានយ៉ាងមោះមុត ក្នុងការងារសង្គ្រោះព្រលឹង ហើយមានចិត្តស្មោះស្ម័គ្រ ដោយមានទំនាក់ទំនងល្អៗជាមួយបព្វជិតឯទៀត។

ចូរអ្នករាល់គ្នាស្មឹងស្មាធិ៍ជារឿយៗទៅលើគុណធម៌ទាំងនោះ។ ចូរអ្នករាល់គ្នាប្រញាប់សូមឲ្យព្រះជាម្ចាស់ប្រទានគុណធម៌ទាំងអស់នោះ ហើយយកមកអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ សូមឲ្យព្រះជាម្ចាស់ប្រកបដោយសប្បុរសធម៌ប្រោសប្រទានគុណធម៌ទាំងនោះ ដល់អ្នករាល់គ្នាឲ្យបានគ្រប់លក្ខណៈ ជាមួយនឹងការសន្តោសប្រណីឯទៀតៗ ដែលចាំបាច់ និងសមស្រប ដើម្បីឲ្យអ្នករាល់គ្នាបំពេញតាមព្រះបំណងដ៏វិសុទ្ធរបស់ព្រះអង្គ និងដើម្បីឲ្យអ្នករាល់គ្នាមានអាកប្បកិរិយាជាសាសនទូតពិតប្រាកដរបស់ក្រុមគ្រួសារបព្វជិត នៃព្រះយេស៊ូ និងព្រះមាតាដូចជាបុត្រពិតប្រាកដ។ សូមព្រះយេស៊ូ និងព្រះនាងម៉ារីប្រទានពរដ៏វិសុទ្ធទៅចុះ។ សូមឲ្យព្រះពរចុះស្ថិតនៅជាមួយអ្នក រាល់គ្នាទៅចុះ។ យើងពោលពាក្យជូនពរនេះដល់អ្នករាល់គ្នាក្នុងព្រះនាមព្រះយេស៊ូ និងព្រះនាងម៉ារី និងក្នុងព្រះនាមនៃសេចក្តីស្រឡាញ់របស់ព្រះបេះដូងព្រះអង្គ។

## ៤- ត្រូវមានចិត្តខ្នះខ្នែងប្រកាសដំណឹងល្អ

ដូនជីម៉ារី អឺផ្រាស៊ី ពើលើជេ បានបង្កើតគ្រួសារបព្វជិតថ្មីមួយ ដែលគេទទួលស្គាល់ក្នុងឆ្នាំ ១៨៣៥ គឺជាក្រុមគ្រួសារបងស្រី នៃអ្នកគង្វាលដ៏សប្បុរស។ ពាក្យ « ត្រូវតែ » របស់ព្រះយេស៊ូ (យហ ១០,១៦) ណែនាំគាត់។ គាត់មានចិត្តខ្នះខ្នែងប្រកាសដំណឹងល្អ ដូចអស់អ្នកដែលមានព្រះវិញ្ញាណដ៏វិសុទ្ធក្នុងខ្លួន ដូចព្រះអង្គបានដុតឡើងក្នុងចិត្តរបស់គ្រីស្តទូតទាំងដប់ពីរនាក់...

នៅក្នុងព្រះសហគមន៍នេះ ដែលជាព្រះកាយព្រះគ្រីស្ត ព្រះជាម្ចាស់ត្រាស់ហៅយើងរាល់គ្នា ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកឲ្យចូលរួមក្នុងស្នាព្រះហស្តនៃព្រះបិតា តាមព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ ក្នុងចំណោមការត្រាស់ហៅទាំងនោះ មានចម្លើយពិសេសមួយ គឺការរស់នៅដោយថ្វាយខ្លួនចំពោះព្រះជាម្ចាស់ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ចំពោះព្រះសហគមន៍ ដើម្បីបំពេញបេសកកម្មព្រះសហគមន៍នេះក្នុងពិភពលោក។ មនុស្សប្រុសស្រីជាច្រើនដែលមានបំណងខ្លាំងចង់រស់នៅតាមដំណឹងល្អ យកការរស់នៅ

របៀបនោះ មកអនុវត្តតាមព្រះបន្ទូលព្រះយេស៊ូ បន្តបេសកកម្មរបស់ព្រះអង្គដោយមិនចាំបាច់រង់ចាំ។

ដោយចាក់ឫសជ្រៅទៅក្នុងអត្តសញ្ញាជ្រមុជទឹក ជីវិតជាអ្នកបួសបង្ហាញទៅគ្រីស្តបរិស័ទថា ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យដើរតាមព្រះគ្រីស្ត។ ពួកគេរួមសាមគ្គីជាមួយមនុស្សលោក ហើយធ្វើជាសាក្សីរបស់ព្រះជាម្ចាស់។

**អ្នករាល់គ្នាត្រូវតែដឹងព្រះគុណជាអនេក, ចំពោះសប្បុរសធម៌របស់ព្រះជាម្ចាស់, ចំពោះការត្រាស់ហៅដ៏ថ្លៃថ្លានេះ!**

តើយើងធ្វើអ្វីនៅលើពិភពលោកនេះ ហើយហេតុអ្វីក៏យើងនៅទីនេះ បើមិនមែនដើម្បីចូលរួមសង្គ្រោះបងប្អូនយើងទេនោះ? ព្រះយេស៊ូស្រឡាញ់ពួកគេ ហើយព្រះអង្គតែងតែបង្ហាញស្នាមរបួសជំបៅ ដែលមានពាសពេញលើព្រះកាយព្រះអង្គ ដោយសារកិច្ចសង្គ្រោះនេះ ទៅព្រះបិតាជានិច្ច។ ព្រលឹងពួកគេស្ថិតនៅជាមួយព្រះអង្គជាកម្មសិទ្ធិរបស់ព្រះអង្គ។ ព្រះអង្គយាងមកលើផែនដីនេះ ដើម្បីរំដោះពួកគេ ដើម្បីសង្គ្រោះពួកគេ ហើយស្ថានបរមសុខរំជើបរំជួល ដោយភ្ញាក់ផ្អើលធ្ងល់ កាលដែលបានឃើញគម្រោងការដ៏អស្ចារ្យ ដែលគ្មាននរណាអាចយល់នេះបានសម្រេច។ គួរតែនិយាយថា ជាគម្រោងការដែលព្រះទាំងបីអង្គ នៃព្រះត្រៃឯកចូលរួមជាមួយគ្នា។ ព្រះបិតាអស់កល្បជានិច្ចបានប្រគល់ព្រះបុត្រា ដែលព្រះអង្គគាប់ព្រះហឫទ័យជាងគេឲ្យមកបំពេញព្រះរាជ្យកិច្ច នៃសេចក្តីស្រឡាញ់ចំពោះសត្វលោក ដែលព្រះអង្គបានបង្កើត។ ព្រះអង្គចាត់ទេវទូតកាព្រីអែលឲ្យនាំសារមកផែនដីជូនដំណឹងទៅព្រះនាងព្រហ្មចារីនីម៉ារី។ ព្រះវិញ្ញាណដ៏វិសុទ្ធរង់ចាំតែការយល់ព្រមពីព្រហ្មចារីនីដ៏បរិសុទ្ធ ក្រៃលែងនេះ ដើម្បីចុះចូលមកសណ្ឋិតជាមួយ ហើយគ្រប់ដណ្តប់ព្រះនាងដោយគុណធម៌របស់ព្រះអង្គ។ ដូច្នោះហើយ ទើបហេតុដ៏អស្ចារ្យនោះកើតឡើង ដែលប្រាជ្ញាទន់ខ្សោយរបស់យើងមិនអាចយល់បានទាល់តែសោះ។ តើព្រះជាម្ចាស់បានធ្វើហេតុការណ៍នោះ ដើម្បីអ្នកណា? ប្រហែលជាសម្រាប់ព្រលឹងល្អៗជាងគេ ជាមិត្តសម្លាញ់របស់ព្រះអង្គ? ទេ! មិនមែនទេ! កូនស្រីជាទីស្រឡាញ់! ព្រះអង្គប្រព្រឹត្តកិច្ចការនេះ គឺសម្រាប់តែសត្វលោកដែលធ្វើតែអំពើបាប ដែលវង្វេងបោះបង់ចោលផ្លូវល្អ។ អ្នកឃើញទេ? នេះហើយជាសេចក្តីស្រឡាញ់របស់ព្រះ ជាម្ចាស់! ព្រះអង្គស្រឡាញ់យើងខ្លាំងណាស់! ចុះយើងវិញ តើយើងមិនធ្វើអ្វីសោះចំពោះព្រះអង្គវិញទេឬ? តើយើងនឹងមិនសង់អ្វីខ្លះទៅព្រះអង្គវិញទេឬ? មែនហើយ! មែនហើយ! យើងនឹងទៅនាំព្រលឹងវង្វេងនោះខ្លះៗ ដែលព្រះអង្គស្រឡាញ់ឲ្យត្រឡប់មករកព្រះអង្គវិញ។

លុះត្រាតែអ្នកទាំងអស់គ្នានៅក្នុងវិទ្យាស្ថាននេះ អ្នកទាំងអស់គ្នាធ្វើការ ដើម្បីសង្គ្រោះព្រលឹង ឬយ៉ាងហោចណាស់ ក៏ព្រះជាម្ចាស់ត្រាស់ហៅអ្នកទាំងអស់គ្នាឲ្យធ្វើកិច្ចការនេះដែរ។ ទោះជាអ្នកធ្វើការនៅសួនដំណាំ នៅកន្លែងធ្វើនំប៉័ង កន្លែងបោកខោអាវ ឬធ្វើការងារអ្វីផ្សេងៗទៀត មិនថាកន្លែងណាទេ អ្នកទាំងអស់នោះធ្វើការដើម្បីសង្គ្រោះព្រលឹង។ ទោះជាអ្នកអធិដ្ឋាន ហើយនិងអ្នកមិនអធិដ្ឋានទេ ប៉ុន្តែធ្វើការដើម្បីជាតង្វាយថ្វាយព្រះជាម្ចាស់ដូចជាអ្នកខ្លះ ដែលត្រូវគេប្រើឲ្យធ្វើកិច្ចការនឿយហត់ជាងគេនៅក្នុងផ្ទះ ទោះជាអ្នកជម្ងឺដែលសម្រាកឈឺចុកចាប់នៅលើគ្រែ ក៏ធ្វើកិច្ចការសង្គ្រោះព្រលឹងច្រើនជាងអ្នកដែលទទួលបន្ទុកបង្រៀន។ ប្រហែលជាអ្នកដែលធ្វើការងារតូចតាច ដែលគេមិនសូវយកចិត្តទុកដាក់បានតាំងចិត្តខិតខំធ្វើកិច្ចការ ក្នុងបំណងជួយសង្គ្រោះព្រលឹងអ្នកនោះ ទទួលបានផលផ្លែច្រើនបំផុត ឲ្យមនុស្សជាច្រើនកែប្រែចិត្តគំនិត បែរទៅរកព្រះជា

ម្ចាស់វិញ។ ចំណែកឯអ្នកឯទៀត ដែលហាក់ដូចជាមានផលបុណ្យសព្វគ្រប់ នឹងអាចទទួលបានតែមួយចំណែកតូចប៉ុណ្ណោះ។

ចូរអ្នករាល់គ្នាស្រឡាញ់ការត្រាស់ហៅដ៏ថ្លៃថ្លានេះ ដែលអ្នករាល់គ្នាត្រូវដឹងគុណចំពោះសប្បុរសធម៌ មិនអាចថ្លែងបានរបស់ព្រះជាម្ចាស់នៃយើងនេះ។ ហើយទោះជាអ្នករាល់គ្នាធ្វើអ្វីក៏ដោយ ចូរអ្នករាល់គ្នានឹកឃើញជានិច្ចថា អ្នករាល់គ្នាត្រូវមានធន្ទះនឹងបំពេញកិច្ចការនោះដើម្បីសង្គ្រោះព្រលឹង។ អ្នករាល់គ្នាដឹងហើយថាបេសកកម្មនៃព្រះបុត្រារបស់ព្រះជាម្ចាស់នៅលើផែនដីនេះជាអ្វី។ ចូរអ្នករាល់គ្នាគិតស្រមៃថា អ្នករាល់គ្នាបានទទួលឯកសិទ្ធ ដោយបានទទួលការត្រាស់ហៅបែបនេះដែរ។ អ្នករាល់គ្នាស័ក្តិសមនឹងមានកិត្តិយសនេះណាស់។ ចូរអ្នករល់គ្នាមានមោទនភាពចំពោះកិច្ចការដ៏ខ្ពង់ខ្ពស់ ដែលព្រះអង្គប្រគល់ឲ្យនេះ។ ចូរយើងនាំយកព្រលឹងដែលព្រះអង្គបានខិតខំលះបង់ព្រះលោហិត និងព្រះជន្មនេះមកបង្ហាញព្រះអង្គ។ ចូរយើងថ្វាយពួកគេជាតង្វាយនៃសេចក្តីស្រឡាញ់របស់យើង។

## សន្តីម៉ារី អ៊ីផ្រាស៊ី ពើលើដេ

៥- ព្រះយេស៊ូចាត់យើងឲ្យធ្វើកិច្ចការ ក្នុងព្រះនាមព្រះអង្គ ក្នុងព្រះសហគន៍មួយ ដែលជាព្រះកាយព្រះគ្រីស្ត ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យអនុវត្តអគ្គសញ្ញាជ្រមុជទឹក ឲ្យទៅជាព្រះភ័ក្ត្រព្រះយេស៊ូ ព្រះបន្ទូលព្រះអង្គ។ លោកអភិបាលត្រាស់ហៅ គ្រីស្តបរិស័ទខ្លះឲ្យទៅជាបូជាចារ្យ។ ពួកលោកប្រព្រឹត្តកិច្ចការក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ដែលជាគង្វាលដ៏សប្បុរស។

- ១ ជាអ្នកដែលថែរក្សាមនុស្សទាំងអស់ ប្រមូលផ្តុំពួកគេជាធ្លុងតែមួយ
- ១ ជាអ្នកដែលស្គាល់យើង ហើយហៅយើងទាំងអស់គ្នា និងម្នាក់ៗចំឈ្មោះ។ ព្រះអង្គស្រឡាញ់យើងដូចៗគ្នាស្មើគ្នា
- ១ ជាអ្នកជូនដំណឹងល្អមកឲ្យយើងសព្វថ្ងៃនេះ។
- ១ អស់លោកបូជាចារ្យរំឭកយើងឲ្យយល់ថា ព្រះជាម្ចាស់ត្រាស់ហៅយើងទាំងអស់គ្នា នៅក្នុងព្រះសហគមន៍ឲ្យធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក។

## បូជាចារ្យម្នាក់ គឺជាព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ ហើយយាងនៅលើផែនដី

បូជាចារ្យម្នាក់ គឺជាព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅ ហើយយាងនៅលើផែនដី ដ្បិតលោកជំនួសព្រះយេស៊ូ លោកជាតំណាងព្រះយេស៊ូ លោកធ្វើកិច្ចការផងទាំងពួង ក្នុងព្រះនាមព្រះអង្គ លោកលំអដោយអំណាចរបស់ព្រះអង្គ។ ព្រះអម្ចាស់នៃយើងមានព្រះបន្ទូលថា៖ ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដូចព្រះបិតាខ្ញុំបានចាត់ខ្ញុំឲ្យយាងមកដែរ (យហ ២០,២១) បានសេចក្តីថា ខ្ញុំចាត់អ្នករាល់គ្នាទៅ ដើម្បីលុបបំបាត់ភាពងងឹតនៃស្ថាននរកដែលគ្រប់ដណ្តប់លើមុខផែនដី និងដើម្បីបំភ្លឺពិភពលោក ដោយពន្លឺនៃស្ថានបរមសុខ។ ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅដើម្បីបំផ្លិចបំផ្លាញអំពើផ្តាច់ការនៃបាបកម្ម ហើយរៀបចំសាងសង់ព្រះរាជ្យនៃព្រះជាម្ចាស់។ ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដើម្បីបន្តការរស់នៅរបស់ខ្ញុំ និងកិច្ចការផ្សេងដែលខ្ញុំបានប្រព្រឹត្តនៅលើផែនដី។ ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅដើម្បីទទួលមុខងាររបស់ខ្ញុំជាអ្នកសម្រុះសម្រួលរវាងព្រះជាម្ចាស់ និងមនុស្សទាំងឡាយ មុខងារជាចៅក្រម និង

ជាអ្នកសង្គ្រោះ។

ព្រះយេស៊ូប្រទានលក្ខណៈល្អៗបីយ៉ាងមកឲ្យលោកបូជាចារ្យ ជាពិសេសឲ្យពួកគង្វាល៖

**ទីមួយ** ពួកលោកជាអ្នកសម្រុះសម្រួលរវាងព្រះជាម្ចាស់ និងមនុស្សទាំងអស់ គឺពួកលោកប្រកាសប្រាប់ពួកគេអំពីព្រះបំណងផ្សេងៗរបស់ព្រះអង្គ ត្រាស់ហៅ និងផ្សះផ្សាពួកគេឲ្យជានានឹងព្រះជាម្ចាស់ គោរពស្រឡាញ់ព្រះអង្គ លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដែលមនុស្សផងទាំងពួង គួរតែធ្វើតបទៅព្រះអង្គវិញ។ ពួកលោកដោះស្រាយកិច្ចការធំៗសំខាន់ៗខ្លះៗ នៃស្ថានបរមសុខ និងផែនដី រវាងព្រះជាម្ចាស់ និងមនុស្សជាកិច្ចការ ដែលទាក់ទងនឹងសិរីរុងរឿងរបស់ព្រះអង្គ កិច្ចសង្គ្រោះពិភពលោក និងការបំពេញទុក្ខលំបាករបស់ព្រះបុត្រាព្រះអង្គ ដោយយកមកដាក់ភ្ជាប់ក្នុងព្រលឹងនៃមនុស្ស ។

ពួកលោកជាចៅក្រមនៃពិភពលោក ជាមួយនិងព្រះបុត្រាព្រះជាម្ចាស់ មិនមែនគ្រាន់តែជាចៅក្រមនឹងអ្វីៗដែលស្ថិតនៅលើផែនដី ក្នុងលោកីយ៍នេះប៉ុណ្ណោះទេ ប៉ុន្តែជាចៅក្រមនៃអ្វីៗនៅឯស្ថានបរមសុខ និងអស់កល្បជានិច្ចទៀតផង។ ពួកលោកជាអ្នកសង្គ្រោះពិភពលោកជាមួយព្រះយេស៊ូគ្រីស្ត។ ព្រះបុត្រាព្រះជាម្ចាស់រួបរួមជាមួយពួកលោក ដើម្បីបំពេញកិច្ចការនេះ ព្រះអង្គមានព្រះហឫទ័យឲ្យពួកលោកធ្វើកិច្ចសង្គ្រោះព្រលឹងនេះ ជាមួយព្រះអង្គ។ ហេតុនេះហើយបានជាព្រះបន្ទូលដ៏វិសុទ្ធហៅពួកលោកថា ជាសហការីនៃព្រះជាម្ចាស់ (១ករ ៣,៩)។

ព្រះអង្គមានព្រះហឫទ័យឲ្យពួកលោកទទួលមុខងារជាអ្នកសង្គ្រោះ ហើយពួកលោកត្រូវបន្តធ្វើ និងបញ្ចប់កិច្ចការដ៏ខ្ពង់ខ្ពស់បំផុត ល្អឥតខ្ចោះបំផុត ជាងកិច្ចការផ្សេងៗទៀត នៅលើផែនដី គឺជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ឲ្យលុបលាងទោសនៃពិភពលោក។ តាមពិតទៅបូជាចារ្យ និងសាសនទូតមានមុខងារជាអ្នកបង្ហើយស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមនេះ ។

ព្រះអម្ចាស់នៃយើងចំណាយពេលវេលារបស់ព្រះអង្គទាំងអស់ គំនិត ព្រះបន្ទូល សកម្មភាព ការងារទាំងអស់ព្រះលោហិត និងព្រះជន្ម ដើម្បីកសាងស្នាព្រះហស្តនេះ។ ដូចគ្នានេះដែរ អស់លោកដែលជាបូជាចារ្យ ហើយលើសពីនេះទៅទៀត អស់លោកបូជាចារ្យជាគង្វាល ត្រូវខិតខំឲ្យអស់ពីចិត្តថ្លើម អស់ពីវិញ្ញាណ អស់ពីគំនិត អស់ពីកម្លាំងកាយចិត្ត ឲ្យបានសម្រេចនូវស្នាព្រះហស្តនេះ ដើម្បីនឹងអាចនិយាយជាមួយសន្តៈប៉ូលថា៖ បំពោះខ្ញុំ ខ្ញុំពេញចិត្តនឹងចំណាយអ្វីៗដែលខ្ញុំមាន ហើយខ្ញុំក៏ចំណាយខ្លួនខ្ញុំថែមទៀត ដើម្បីជាប្រយោជន៍ដល់ជីវិតបងប្អូនដែរ (២ករ ១២,១៥)។ បើមានព្រលឹងខ្លះវង្វេង ដោយសារពួកលោកមិនយកចិត្តទុកដាក់ ធ្វេសប្រហែស ស្នាមដំបៅទាំងអស់ ដែលព្រះយេស៊ូបានរងទុក្ខ ដើម្បីសង្គ្រោះព្រលឹងនោះ ហើយព្រះលោហិតព្រះអង្គដែលហូរ ដើម្បីព្រលឹងនោះ នឹងស្រែកសងសឹកចំពោះពួកលោកនៅថ្ងៃវិនិច្ឆ័យមនុស្សលោក៖ ខ្ញុំនឹងទារពីអ្នកសងឈាមគេមកវិញ (អគ ៣,១៨)។

តាមរបៀបនេះហើយ ដែលបូជាចារ្យម្នាក់ជាព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅ ហើយយាងនៅលើផែនដី។ ដូច្នោះ ជីវិត និងទម្លាប់របស់យើងត្រូវតែជារូបតំណាង និងល្អគ្រប់លក្ខណៈ ឬក៏ជាការបន្តនៃព្រះជន្ម និងទម្លាប់របស់ព្រះយេស៊ូគ្រីស្ត។ អ្វីដែលយើងត្រូវខិតខំរៀនសូត្រដោយយកចិត្តទុកដាក់នោះ គឺថា តើព្រះអង្គមានព្រះបន្ទូលអំពីអ្វី? តើព្រះអង្គបានយកគុណធម៌ អ្វីខ្លះ មកប្រើ?? តើរបៀបរស់នៅ និងអាកប្ប

កិរិយាដូចម្ដេចរបស់ព្រះអង្គ? តើព្រះអង្គភ័យខ្លាចយ៉ាងណាចំពោះអំពើបាប? ត្រូវតែសួរសំណួរទាំងអស់នោះដើម្បីបំពេញកិច្ចការរបស់ព្រះយេស៊ូក្នុងការរស់នៅរបស់យើង។

ខ្ញុំទុកពេលដើម្បីអានអត្ថបទទាំងនេះយឺតៗទៅតាមសម្រួល។ ខ្ញុំគូសបន្ទាត់ពីក្រោមអ្វីៗដែលខ្ញុំពេញចិត្ត។ ខ្ញុំទុកពេល ដើម្បីយល់ឃើញអំពីការត្រាស់ហៅ ដែលផ្ដល់អត្ថន័យដល់ជីវិតខ្ញុំ។ ខ្ញុំអរព្រះគុណព្រះអម្ចាស់ចំពោះអ្វីៗ ដែលព្រះអង្គប្រទានមកខ្ញុំនៅកន្លែងនេះ ក្នុងពេលនេះ...អរព្រះគុណចំពោះពន្លឺ...ចំពោះជីវិត...។

## ទុកពេល សម្រាប់ការលើកលែងទោស

ទីបញ្ចប់នៃដំណាក់កាលនេះ យើងអាចចោទជាសំណួរសួរខ្លួនយើងខ្លះៗ៖

១- នៅក្នុងសកម្មភាពតូចៗប្រចាំថ្ងៃ តើគេអាចពឹងពាក់លើខ្ញុំបានឬទេ? តើគម្រោងការរបស់ខ្ញុំជាការពិត ឬគ្រាន់តែជាការស្រមៃប៉ុណ្ណោះទេ?

២- តាមរយៈការរៀនសូត្រ ការងារ គ្រួសារ មិត្តភ័ក្តិ សហជីព គណបក្សនយោបាយ... តើខ្ញុំដឹងខ្លួនថា ខ្ញុំឆ្លើយតបនឹងការត្រាស់ហៅណាមួយរបស់ព្រះអម្ចាស់ដែរឬទេ?

៣- ព្រះជាម្ចាស់មិនអាចត្រាស់ហៅខ្ញុំ បើខ្ញុំមិនអធិដ្ឋាន ឬមិនស្ដាប់ព្រះវិញ្ញាណទេ។ តើការអធិដ្ឋានជាប្រភពនៃកិច្ចការរបស់ខ្ញុំឬទេ? តើអត្តសញ្ញាអរព្រះគុណ អត្តសញ្ញាលើកលែងទោស សំខាន់យ៉ាងណាក្នុងជីវិតជាគ្រីស្ដបរិស័ទរបស់ខ្ញុំ?

៤- ពេលព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ តើខ្ញុំបដិសេធ និងភ័យខ្លាចអ្វី? «ចូរអ្នកកុំខ្លាចអី។ ចូរទុកឲ្យព្រះគ្រីស្ដទតមកអ្នក» ព្រះអង្គស្រឡាញ់អ្នក។ ព្រះអង្គត្រាស់ហៅអ្នកក្នុងពេលនេះ ទៅតាមលក្ខណៈចរិតអ្នក។

ព្រះអម្ចាស់អើយខ្ញុំម្ចាស់មកដល់ហើយ ខ្ញុំម្ចាស់ជាអ្នកតូចទន់ទាប មកនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ដើម្បីសូមព្រះអង្គយាងទតខ្ញុំម្ចាស់។ ខ្ញុំម្ចាស់ជឿថា ព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់តាមអ្វីៗដែលជាខ្លួនរបស់ខ្ញុំម្ចាស់។ ខ្ញុំម្ចាស់សូមដាក់ការភ័យខ្លាច ការបដិសេធ...ចិត្តអស់សង្ឃឹមភាពទន់ខ្សោយ...របស់ខ្ញុំម្ចាស់ទៅក្នុងព្រះហឫទ័យព្រះអង្គ។ សូមព្រះអង្គប្រទានព្រះវិញ្ញាណព្រះអង្គមកឲ្យខ្ញុំម្ចាស់ ដើម្បីស្រឡាញ់ ដើម្បីទូលប្រាប់ថា ខ្ញុំម្ចាស់យល់ព្រមចំពោះព្រះហឫទ័យរបស់ព្រះអង្គ។

## ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ...ដើម្បី...

១- ផ្លូវដែលយើងបានដើរ យើងបានយល់ឃើញសេចក្ដីជាច្រើន។ ចូរត្រឡប់មើលទៅក្រោយវិញ មួយស្របក់ចំពោះអ្វីៗ ដែលបាននាំឲ្យយើងធ្វើដំណើរទៅ...សូមអានឡើងវិញទំព័រទីមួយនៃសៀវភៅកំណត់ហេតុរបស់យើង...ចូរយើងរំឭកឡើងវិញ នូវគម្រោង បំណង សំណួរ ការភ័យខ្លាចរបស់យើង។ ឥឡូវនេះយើងនិយាយដូចម្ដេចចំពោះរឿងនោះ?

២- ចុងបញ្ចប់នៃការស្វែងរកនេះ តើខ្ញុំចង់បម្រើព្រះជាម្ចាស់យ៉ាងដូចម្ដេច? តើថ្ងៃនេះ ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យដើរតាមផ្លូវជាក់ស្ដែងអ្វីខ្លះ? តើខ្ញុំអាចឆ្លើយតបទៅព្រះអង្គវិញដូចម្ដេច? តើខ្ញុំត្រូវបោះជំហានថែមទៀតទេ? តើខ្ញុំត្រូវឈានទៅមុខទៀតទេ? តើខ្ញុំត្រូវប្រើមធ្យោបាយអ្វី ដើម្បីអនុវត្តការត្រាស់ហៅដ៏ពិសេសរបស់ខ្ញុំនេះ?

៣- នៅក្នុងអង្គព្រះវិញ្ញាណ យើងអាចថ្វាយខ្លួនចំពោះព្រះអម្ចាស់ ដើម្បីបំពេញគម្រោងការរបស់ព្រះអង្គ ចំពោះយើង។«ព្រះអម្ចាស់អើយទូលបង្គំយាងមក ដើម្បីបំពេញព្រះហឫទ័យព្រះអង្គ» (ហប ១០,៩)។

ឱព្រះយេស៊ូអើយ ខ្ញុំម្ចាស់សូមថ្វាយព្រះអង្គនូវព្រលឹង អារម្មណ៍ទាំងអស់នៃរូបរាងកាយ អវយវៈទាំងអស់ ទាំងចិត្ត និងខ្លួនប្រាណទាំងមូលរបស់ខ្ញុំម្ចាស់ ឲ្យតែខ្ញុំម្ចាស់បានគាប់ព្រះហឫទ័យព្រះអង្គ។

ដើម្បីបោះជំហានទៅមុខយ៉ាងជាក់ស្តែងដែលខ្ញុំប៉ុនប៉ងនឹងធ្វើ ខ្ញុំម្ចាស់សូមលើកតម្កើងព្រះអម្ចាស់។ សូមឲ្យព្រះវិញ្ញាណព្រះអង្គប្រគល់កម្លាំងកាយចិត្តមកខ្ញុំម្ចាស់ ដើម្បីទទួលយកគម្រោងការរបស់ព្រះអង្គ។ «ខ្ញុំនេះហើយសូមព្រះអង្គចាត់ឲ្យខ្ញុំទៅ»។

# ប្រុងប្រៀបខ្លួនឆ្លើយតបអំពីសេចក្តីសង្ឃឹម

សេចក្តីសង្ឃឹមជាកំណាប់នៃអំណរសប្បាយ... សប្បាយចិត្តម្ល៉េះទេ ដែលមានសេចក្តីសង្ឃឹម!

**ដំណាក់កាលទី ២២**

ប្រុងប្រៀបខ្លួនឆ្លើយតទល់នឹងអស់អ្នក ដែលសាកសួរអំពីសេចក្តីសង្ឃឹមរបស់បងប្អូននោះជានិច្ច (១ស ៣,១៥)

**ក្នុងដំណាក់កាលនេះមាន ៖** នៅតាមដងផ្លូវ ដែលយើងធ្វើដំណើររហូតមកដល់ថ្ងៃនេះ ថ្ងៃស្អែកនិងរហូតដល់ដង្ហើមចុងក្រោយរបស់យើង ព្រះយេស៊ូចាប់កំណើតនៅក្នុងខ្លួនយើង។ ជីវិតយើងពោរពេញទៅដោយសេចក្តីសង្ឃឹម ដែលជាអាកប្បកិរិយាសំខាន់បំផុតនៃគ្រីស្តបរិស័ទ។

«សង្ឃឹមទោះជាគ្មានទីសង្ឃឹម»...នេះហើយជាដំណើរឆ្ពោះទៅមុខរបស់យើង។ យើងត្រូវតែដឹងច្បាស់ថា ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យតែងតែបោះជំហានទៅមុខៗ។ ក្នុងដំណើរនេះ យើងមិនមែនតែម្នាក់ឯងទេ។

ចូរយើងត្រេកអរនឹងការត្រាស់ហៅនេះ ដ្បិតសេចក្តីសង្ឃឹមនេះបានចារជាប់ក្នុងចិត្តយើង។សេចក្តីសង្ឃឹមនេះគាប់ព្រះហឫទ័យព្រះជាម្ចាស់...យើងមិនរង់ចាំ «គំនិត» មួយទេ ប៉ុន្តែយើងរង់ចាំ « អ្នកណាម្នាក់ » គឺព្រះយេស៊ូដែលជាគោលដៅនៃជីវិតរបស់យើង ។

សូមយាងព្រះអម្ចាស់យេស៊ូអើយ! សូមយាងមក (វវ ២២,២០)

**គោលដៅនៃដំណាក់កាលនេះ ៖** ឲ្យយើងទៅជាសាក្សីនៃសេចក្តីសង្ឃឹម ដែលមាននៅក្នុងចិត្តយើង ៖

- សូមចាប់អារម្មណ៍នឹងពន្លកតូចៗ ដែលប្រកាសប្រាប់យើងអំពីវត្តមានរបស់ព្រះយេស៊ូនៅក្បែរយើង និងនៅក្នុងពិភពលោក (សញ្ញាសម្គាល់នៃសេចក្តីសង្ឃឹម)
- សូមរកសាក្សីនៃសេចក្តីសង្ឃឹមនៅក្នុងព្រះគម្ពីរ
- សូមរៀនហើយក្រឡេកមើលទៅមនុស្សម្នាក់ៗ ជាមួយនឹងក្រសែព្រះនេត្រនៃព្រះយេស៊ូ «ក្រសែភ្នែក នៃសេចក្តីស្រឡាញ់ពិត គឺជាក្រសែភ្នែកដែលធ្វើឲ្យយើងសង្ឃឹម»

ចុងបញ្ចប់ដំណាក់កាលនេះ ខ្ញុំគួរតែអាចនិយាយបានថា ខ្ញុំធ្វើដូចម្តេចដើម្បីរៀនផ្លាស់ប្តូរ របៀបមើលឃើញទៅមនុស្សទាំងឡាយ និងហេតុការណ៍នានា

ដោយក្រសែភ្នែកមានលក្ខណៈវិជ្ជមាន ។

## ទុកពេល សម្រាប់បើកចិត្ត និងទទួល

១- ប្រឈមមុខនឹងព្រឹត្តិការណ៍ពិភពលោក សង្គមគ្រួសារ តើយើងមានប្រតិកម្មដូចម្ដេច? តើយើងបាក់ទឹកចិត្ត ដោយសារហេតុការណ៍អាក្រក់ៗទាំងនោះឬ? តើសម្ដីយើងជាសម្ដីរបស់ពួកអ្នកមិនជឿថា បានជោគជ័យ ឬក៏ជាអ្នកទុទិដ្ឋិនិយម? តើរឿងនេះ ធ្វើឲ្យយើងក្រៀមក្រំ ឬក៏យើងទុកអ្វីៗដែលកើតមានឡើង អាចមានអត្ថន័យវិជ្ជមាន?...ជាសញ្ញាសម្គាល់ដែលត្រាស់ហៅយើងឲ្យសង្ឃឹមជានិច្ច ទោះជាមើលទៅហាក់ដូចជាអវិជ្ជមានក៏ដោយ?

២- តាមធម្មតា យើងក្រឡេកមើលទៅមនុស្សឯទៀត ដោយក្រសែភ្នែកយ៉ាងណា? តើយើងមើលឃើញលក្ខណៈអវិជ្ជមានភ្លាមៗឬទេ? ឬក៏លក្ខណៈវិជ្ជមាន?

៣- តើយើងធ្លាប់មានបទពិសោធន៍ថា យើងអស់សង្ឃឹមឬទេ?

៤- តើយើងធ្លាប់បានជួបអ្នកណា ដែលជាសាក្សីនៃសេចក្ដីសង្ឃឹមដែរឬទេ ?

ខ្ញុំយល់ឃើញអំពីគំនិតខ្ញុំ អាកប្បកិរិយាខ្ញុំ បំពោះមុខព្រឹត្តិការណ៍នានា បំពោះមនុស្សទាំងឡាយ ខ្ញុំទទួលយកអ្វីៗទាំងនោះ...ខ្ញុំស្វែងរកវត្តមានព្រះជាម្ចាស់ នៅក្នុងចិត្តមនុស្សម្នាក់ៗ...នៅក្នុងហេតុការណ៍នៃជីវិតខ្ញុំ។

## ទុកពេល សម្រាប់សញ្ជឹងគិត និងអរព្រះគុណ

១- សូមមើលទៅលោកអាប្រាហាំ។ សូមអាន (កណ ១២) យឺតៗ។ តើអ្វីដែលជំរុញឲ្យបុរសទាំងនោះ ធ្វើដូច្នោះ ?

២- សូមស្វែងរកក្នុង (រម ៨,២៤-២៥) និងក្នុង (១ករ ១៣,១២) តើអ្វីដែលជាសេចក្ដីសង្ឃឹមរបស់គ្រីស្ដបរិស័ទ?

៣- អានយ៉ាងស្ងប់ស្ងាត់លិខិតរបស់សន្តៈសិលា ហើយកត់ត្រានូវអ្វីៗ ដែលលោកនិយាយអំពីសេចក្ដីសង្ឃឹម។

៤- អានឡើងវិញការជូនដំណឹងអំពីកំណើតព្រះយេស៊ូ។ សូមយល់ឃើញអំពីសេចក្ដីសង្ឃឹមរបស់នាងម៉ារី... ហើយសញ្ជឹងគិតអំពីសេចក្ដីសង្ឃឹមនេះ។

## ៥- សូមរិះគិតអំពីសេចក្ដីសង្ឃឹមរបស់សន្តៈ យ៉ូហាន អើដះ

អ្នកណាមានសេចក្ដីសង្ឃឹម អ្នកនោះមានអំណរសប្បាយ។ សេចក្ដីសង្ឃឹមលួងលោមចិត្តយើង តាមរបៀបមិនអាចថ្លែងបាន។ នៅពេលដែលយើងសង្ឃឹម យើងរីករាយខ្លាំងណាស់។ ព្រះបន្ទូលរបស់ព្រះដែលជាសេចក្ដីពិតអស់កល្បជានិច្ច ជាគ្រឹះដ៏រឹងមាំនៃសេចក្ដីសង្ឃឹមរបស់យើង។ យើងសង្ឃឹមថា នឹងបានឃើញព្រះភ័ក្ត្រព្រះអង្គនៅថ្ងៃណាមួយ។ ព្រះជាម្ចាស់នឹងក្លាយទៅជាកម្មសិទ្ធិរបស់យើង យើងនឹងរួបរួមជាធ្លុងមួយជាមួយព្រះអង្គ យើងនឹងបរិភោគរួមតុជាមួយព្រះអង្គ យើងនឹងទៅជាព្រះរាជានៃព្រះរាជ្យអស់កល្បជានិច្ច យើងនឹងគ្រេកគ្រអាល ជាមួយនឹងព្រះរាជ្យរបស់ព្រះបិតាអស់កល្បជានិច្ច ដែលបានប្រគល់ឲ្យទៅព្រះបុត្រា

ព្រះអង្គ យើងនឹងសោយរាជ្យ ជាមួយព្រះបុត្រាព្រះអង្គ ទីបំផុតដោយសារព្រះហឫទ័យមេត្តាករុណា ហើយដោយសារយើងរួបរួមជាមួយព្រះអង្គ ព្រះអង្គមានព្រះបំណងចង់ឲ្យយើងបានសម្បត្តិដ៏ខ្ពង់ខ្ពស់នោះ។ តើជាការពិតទេ ដែលសេចក្តីសង្ឃឹមបែបនេះ នឹងធ្វើឲ្យយើងស្លាប់ក្នុងអំណរសប្បាយឬ?

### ៦- សូមទទួលយកនូវអ្វីៗ ដែលអ្នកដទៃអាចនិយាយបានអំពីសេចក្តីសង្ឃឹម

ពេលយើងប្រាប់គេថា ខ្ញុំជឿលើអ្នក ខ្ញុំស្រឡាញ់អ្នកដោយសារពាក្យទាំងនេះ យើងបើកផ្លូវឲ្យគេមានសេចក្តីសង្ឃឹម...

សេចក្តីសង្ឃឹម មិនមែនជាពាក្យតែប៉ុណ្ណោះទេ...អ្នកណាមានសេចក្តីសង្ឃឹម អ្នកនោះបញ្ចេញរស្មី ហើយមានទឹកមុខដូចជាព្រះភ័ក្ត្រព្រះយេស៊ូ។

អ្នកណាមានសេចក្តីសង្ឃឹម អ្នកនោះមានគំនិតជាច្រើន មានសេរីភាព និងចេះតស៊ូក្នុងជីវិត។

ដើម្បីជួបសេចក្តីសង្ឃឹម ត្រូវតែអស់សង្ឃឹម។ កាលណាយើងទៅរហូតដល់ចុងនៃពេលយប់ យើងជួបពន្លឺព្រះអាទិត្យថ្មី។

ខ្ញុំអរព្រះគុណព្រះជាម្ចាស់ចំពោះសេចក្តីសង្ឃឹម ដែលមានក្នុងចិត្តមនុស្សទាំងអស់។ ខ្ញុំទូលអង្វរព្រះអម្ចាស់ សូមព្រះអង្គប្រទានព្រះអំណោយទាននៃសេចក្តីសង្ឃឹម។

### ទុកពេល សម្រាប់ការលើកលែងទោស

១- យើងបានសញ្ជឹងគិតអំពីលោកអប្រាហាំ ព្រះនាងម៉ារី បទពិសោធន៍នៃសន្តះសិលា បទពិសោធន៍នៃសន្តះយ៉ូហាន អើដ។ តើប្រតិកម្មនៃអ្នកទាំងនោះ និងប្រតិកម្មរបស់យើងមានចំណុចណាខ្លះ ដែលហាក់ដូចជាខុសគ្នា?

២- តើមានអ្វីខ្លះ ក្នុងខ្លួនយើងដែលត្រូវកែ? ក្នុងគំនិតទាំងប៉ុន្មាន ដែលយើងមានអំពីព្រឹត្តិការណ៍នានា... មនុស្ស...ខ្លួនយើង?

៣- បើយើងធ្លាប់អស់សង្ឃឹម តើអ្វីទៅដែលបង្ខិតបង្ខំយើងឲ្យស្ថិតនៅក្នុងសភាពនោះ? ឬតើអ្វីទៅដែលជួយជ្រោមជ្រែងយើងឲ្យចេញផុតពីសភាពនោះ?

ខ្ញុំថ្វាយបង្គំព្រះជាម្ចាស់ ដោយសុភាពរាបសារ សូមព្រះអង្គលើកលែងទោសឲ្យខ្ញុំ ដែលមិនជឿថាព្រះអង្គជាម្ចាស់នៃហេតុការណ៍ដែលមិនអាចកើតមាន គឺមានតែព្រះអង្គទេ ដែលជឿថា ទោះជាមានពេលយប់វែងយ៉ាងណាក៏គង់តែជួបពន្លឺថ្ងៃ...ព្រះអង្គតែងតែមានព្រះវត្តមាននៅគ្រប់ហេតុការណ៍ ដែលកើតមានឡើងចំពោះខ្ញុំ។

### ទុកពេល សម្រាប់ថ្វាយខ្លួនចំពោះព្រះយេស៊ូ... ដើម្បី...

១- នៅតាមផ្លូវដែលយើងដើរ តើយើងបានឃើញព្រះអម្ចាស់យាងពីមុខយើងជានិច្ចឬទេ? តើអ្នកណាបើកផ្លូវឲ្យយើង?

២- តើយើងត្រូវចាប់អារម្មណ៍នឹងពន្លកតូចៗយ៉ាងដូចម្តេច? តើអ្នកណាប្រកាសអំពីវត្តមាននៃព្រះយេស៊ូ

នៅក្នុងពិភពលោក? ...ក្នុងខ្លួនយើង?

៣- តើយើងដែលទទួលការត្រាស់ហៅពីក្នុងបិត្តឲ្យសង្ឃឹមជានិច្ចឬទេ?

៤- តើមានអ្វីខ្លះ ដែលផ្តល់គំនិតឲ្យយើង...ប្រព្រឹត្តកិច្ចការណាមួយ ដើម្បីបានសេចក្តីសង្ឃឹម...

... ផ្លាស់ប្តូររបៀបគិតអំពីពិភពលោក? អ្នកឯទៀត? ខ្លួនយើងផ្ទាល់?

៥- តែងសេចក្តីអធិដ្ឋានមួយ ដើម្បីទូលទៅព្រះជាម្ចាស់ អំពីសេចក្តីសង្ឃឹមរបស់យើងចំពោះព្រះអង្គ?

ដោយសង្ឃឹមជានិច្ច ទោះជាគ្មានទីសង្ឃឹម...ខ្ញុំដើរទៅមុខ...

ខ្ញុំស្តាប់ព្រះបន្ទូលព្រះអម្ចាស់ ខ្ញុំជឿថា ព្រះអង្គជាអ្នកនាំផ្លូវ។